ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- បងលេខ១
- ទីបញ្ចប់នៃបដិវត្តន៍

[illegible]

លេខ១៦ ខែមេសា ឆ្នាំ២០០១

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៦ ខែមេសា ឆ្នាំ២០០១

## មាតិកា


◆ សំបុត្រ៖ វិលវល់នឹងស្រមោលអតីតកាល........................១

**ផ្នែកឯកសារ**

◆ បទសម្ភាសន៍បងលេខ១........................២

◆ យ៉ាងម៉េចហៅថាទស្សនៈមហាជននិងមាគ៌ាមហាជន........................៦

◆ រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម........................៧

◆ កំណត់ហេតុប្រចាំថ្ងៃរបស់កម្មាភិបាលខ្មែរក្រហម........................៩

◆ ឥទ្ធិពលនៃការទម្លាក់គ្រាប់បែក........................១១

◆ ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ........................១៣

◆ តួនាទីគួរឲ្យសង្ស័យរបស់ស្ថានទូតចិន........................១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សម្លេងពីមន្ទីរស-២១........................១៦

◆ ជនដៃដល់ ឬ ជនរងគ្រោះ?........................២០

◆ គិប យូណុះ........................២៨

◆ រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ........................២៩

◆ ប្រវត្តិរូបសង្ខេបរបស់ ប៉ុល ពត........................៣៤

**ផ្នែកច្បាប់**

◆ តម្លៃនៃភ័ស្តុតាង........................៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការអូតសរសើរបដិវត្តន៍........................៤០

◆ កំណត់ហេតុស្តីអំពីអង្គប្រជុំរបស់សភាជាតិ........................៤២

◆ ទីបញ្ចប់នៃបដិវត្តន៍........................៥០

**⁺ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទទួលបានប៉ុនណាបាត់ទៅវិញប៉ុណ្ណឹង........................៥៥

◆ សៀវភៅកំណត់ហេតុជីវិត........................៥៨

**សិល្បៈខ្មែរក្រហម**

◆ **កំណាព្យ៖** ប្តេជ្ញារៀនសូត្រមហាជ័យជំនះ........................ក្របក្រោយ




ប៉ុល ពត

## រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះ៖*** ដេវីត ឆេនដល័រ, អៀ សុផល, ឃិមស៊ុត វ៉ាណាជិត, ចន ឆរឆីអារី, ដេវីដ អាស្តូលី, អៀ ម៉េងទ្រី, អ៊ីសា ឧស្មាន, អ៊ូច សំអឿន ***អ្នកនិពន្ធនិងស្រាវជ្រាវ៖*** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ ***ជំនួយការនិពន្ធនាយក៖*** អែម សុខឃីម ***និពន្ធនាយករងទី១៖*** ដាត កុសល ***និពន្ធនាយករងទី២៖*** សឹម សុរិយ៉ា ***អ្នកបកប្រែ៖*** សួ ប៊ុនស៊ូ ***និពន្ធនាយកទូទៅ៖*** ឆាំង យុ ***ក្រាហ្វិកកុំព្យូទ័រ៖*** ស៊ឹម សុភ័ក្រ្ត ***គ្រប់គ្រងការចែកផ្សាយ៖*** ទ្រី សុភក្តិ

*សំបុត្រ:*

# វិលវល់នឹងស្រមោលអតីតកាល




◆ តើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យអាចចូលជាធរមានបានដែរឬទេ?

◆ តើមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យរួមមាន នួន ជា អៀង សារី ខៀវ សំផន តាម៉ុក កែ ពក ព្រមទាំង អៀង ធីរិទ្ធ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ដូចជា ឌុច ប្រធានមន្ទីរស-២១ អាចត្រូវបាននាំខ្លួនដើម្បីធ្វើការវិនិច្ឆ័យទោសដែរឬទេ?

◆ តើប្រជាជនកម្ពុជារាប់លាននាក់ដែលជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យអាចនឹងមានឱកាសត្រូវបានដឹងពុរឿងពិតទាំងស្រុងអំពីអ្វីដែលបានកើតក្នុងរបបនោះដើម្បីខ្លួនអាចនឹងចាប់ផ្តើមអភ័យទោសដល់កម្មាភិបាលថ្នាក់ក្រោមទាំងឡាយដែលបានប្រព្រឹត្តបទឧក្រិដ្ឋផ្ទាល់ដៃមកលើក្រុមគ្រួសាររបស់ខ្លួនបានដែរឬទេ?

◆ តើការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះប្រមាណពីរលាននាក់ដែលបានស្លាប់ដោយសារស្នាដៃរបបកម្ពុជាប្រជាធិបតេយ្យអាចចៀសផុតពីការជ្រៀតជ្រែកផ្នែកនយោបាយបានដែរឬទេ?

◆ តើពេលណាទៅទើបមេដឹកនាំកម្ពុជាទាំងអស់ចាប់ផ្តើមអនុវត្តជាក់ស្តែងឲ្យឃើញថា បញ្ហាយុត្តិធម៌គឺជារឿងដែលសំខាន់បំផុតនៅក្នុងសង្គម?

◆ តើពេលណាទៅទើបកម្ពុជាអាចយល់បានថាអំពើប្រល័យពូជសាសន៍គឺជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយតម្រូវឲ្យមានការចូលរួមពីមនុស្សគ្រប់ស្រទាប់ជាន់ថ្នាក់ គ្រប់រូប គ្រប់ពណ៌សម្បុរ ហើយក៏ជាកាតព្វកិច្ចរបស់មនុស្សជាតិទាំងអស់ក្នុងការចូលរួមដោះស្រាយនិងទប់ស្កាត់អំពើនេះ?

◆ តើពេលណាទើបកូនខ្មែរអាចនឹងមានឱកាសដើម្បីសិក្សាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ក្នុងថ្នាក់រៀន?

ដរាបណាមិនមានចម្លើយចំពោះសំណួរទាំងឡាយខាងលើនេះ កម្ពុជាអាចនៅតែវិលវល់នឹងស្រមោលអតីតកាលរបស់ខ្លួនជានិរន្តរ៍ ។

**ឆាំង យុ**



# បទសម្ភាសន៍បទលេខ ១

(ឯកសារ *TSL*៨៨៧៩)

*រូបថត៖ អេលីហ្សាបែត បែកឃ័រ*

*(ថ្ងៃ១២ មេសា ១៩៧៨)* សមមិត្ត ប៉ុល ពត លេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជានិងជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានអនុញ្ញាតឲ្យតំណាងទីភ្នាក់ងារសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យយើងចូលជួបធ្វើសម្ភាសន៍មួយស្តីអំពីសភាពការណ៍យួនឈ្លានពានទឹកដីកម្ពុជាយើង ។

**សំណួរៈ** ក្នុងសភាពការណ៍ដែលយួននៅតែបន្តឈ្លានពានកម្ពុជាប្រជាធិបតេយ្យយើងយ៉ាងមមាញឹក យើងខ្ញុំជាតំណាងទីភ្នាក់ងារសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ សូមស្នើសមមិត្តបញ្ជាក់ថែមអំពីសភាពការណ៍យួនឈ្លានពាននេះតើយ៉ាងណា? គោលបំណងវាយ៉ាងណា? ហើយកម្ពុជាប្រជាធិបតេយ្យមានគោលជំហរដោះស្រាយយ៉ាងណា? ដើម្បីយើងខ្ញុំយកទៅផ្សព្វផ្សាយជូនប្រជាជននិងកងទ័ពបដិវត្តកម្ពុជាយើងជ្រាបថែមទៀត ។

**ចម្លើយៈ** ចំពោះបញ្ហាយួនឈ្លានពាន វាតទីលេបទឹកដី ចង់បំបាត់ពូជសាសន៍កម្ពុជាយើង ប្រជាជនកម្ពុជានិងកងទ័ពបដិវត្តកម្ពុជាយើងទាំងអស់បានជ្រួតជ្រាបច្បាស់លាស់ណាស់ទៅហើយ ព្រោះគេទាំងឡាយធ្លាប់ទទួលរងគ្រោះដោយផ្ទាល់អំពីសំណាក់យួនឈ្លានពានវាតទីលេបទឹកដីនេះជាបន្តបន្ទាប់ដោយផ្ទាល់ខ្លួនគេតែម្តង ។ ម្យ៉ាងទៀត បក្សយើងនិងរដ្ឋាភិបាលយើង ព្រមទាំងកាសែតទស្សនាវដ្តីនិងវិទ្យុយើង បានផ្សព្វផ្សាយអំពីបញ្ហានេះជាហូរហែមកយ៉ាងច្បាស់លាស់ហើយ ។ ដូច្នេះក្នុងឱកាសនេះខ្ញុំសូមឆ្លើយនឹងសំណួរសមមិត្តតែលើចំណុចខ្លះតែប៉ុណ្ណោះ ។ មុននឹងមានមតិអំពីបញ្ហាយួនឈ្លានពានវាតទីលេបទឹកដី តាមសំណួររបស់សមមិត្តនេះ ខ្ញុំសូមតាងនាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យសម្តែងនូវការគោរពកោតសរសើរយ៉ាងស្ងប់ស្ងែងដល់វីរៈប្រជាជនកម្ពុជាយើងទាំងមូល វីរៈកងទ័ពបដិវត្តកម្ពុជាយើងទាំងមូលដែលបានសាមគ្គីគ្នាជាធ្លុងមួយយ៉ាងរឹងមាំក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាយើងប្រយុទ្ធតស៊ូប្រឆាំងកម្ទាត់កម្ចាយគ្រប់អំពើឈ្លានពាន រំលោភ បង្ករឿងហេតុ វិទ្ធង្សនា ជ្រៀតជ្រែក ចារកម្មរដ្ឋប្រហាររបស់យួនឈ្លានពានលេបទឹកដីនេះឲ្យវាបរាជ័យយ៉ាងធ្ងន់ធ្ងរនិងយ៉ាងដួរបត់ជាទីបំផុតនិងជាបន្តបន្ទាប់ ។

អំពីសំណួររបស់សមមិត្ត ខ្ញុំសូមឆ្លើយដូចតទៅៈ យួនមិនបោះបង់ចោលគោលគំនិតសហព័ន្ធឥណ្ឌូចិនរបស់វាទេ ។ វាអនុវត្តគោលគំនិតនេះជាខ្សែសង្វាក់ដោយមានផែនការនិងដំណើរការជាបន្តបន្ទាប់តាំងពីឆ្នាំ១៩៣០ជារៀងរហូតមក ។ ដំបូងវាចង់បានសហព័ន្ធឥណ្ឌូចិនជារដ្ឋតែមួយ តែម្តងគឺបក្សតែមួយ ប្រជាជនតែមួយកងទ័ពតែមួយ ប្រទេសតែមួយ នៅក្នុងឥណ្ឌូចិនរបស់យួននេះ ។ ក្រោយមកវាធ្វើជាលើកបញ្ហាតាមរូបភាពមិត្តភាពពិសេស សាមគ្គីភាពពិសេស ដោយកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាសហប្រតិបត្តិការគ្នា ពិសេសខាងនយោបាយក្នុងប្រទេសក្រៅប្រទេស ខាងយោធា ខាងសេដ្ឋកិច្ច វប្បធម៌ ដោយគ្មានព្រំដែន ។

ក្រោយពេលរំដោះឆ្នាំ១៩៧៥ហើយ ក៏យួនបានលើកបញ្ហានេះ ដោយរក្សារូបភាពនេះទៀត ។ នេះជាខ្លឹមសារបញ្ចាំងឲ្យឃើញអំពីសហព័ន្ធឥណ្ឌូចិនរបស់យួន ។ ដូច្នេះខ្លឹមសារនេះជាការរំលាយព្រំដែន ដើម្បីផ្សារភ្ជាប់កម្ពុជាឲ្យទៅជាផ្នែកមួយរបស់យួននៅក្នុងសហព័ន្ធឥណ្ឌូចិនរបស់វា ។ តាមរយៈនេះ យួនមកកាន់កាប់គ្រប់គ្រងបក្ស រដ្ឋអំណាច យោធា សេដ្ឋកិច្ចនយោបាយក្នុងប្រទេស ក្រៅប្រទេស រហូតដល់ប្រែក្លាយកម្ពុជាទៅជាផ្នែកមួយរបស់យួន ហើយប្រជាជនកម្ពុជាទៅជាជនជាតិភាគតិចរបស់យួន ។ ឯវិធីដំណើរការអនុវត្តផែនការរបស់វាគឺវាធ្វើសកម្មភាពចារកម្មគ្រប់បែបយ៉ាង វិទ្ធង្សនា ស៊ីរូងបង្កប់ផ្ទៃក្នុង បំបាក់បំបែកសាមគ្គីភាពផ្ទៃក្នុង ។ វាដំណើរការនេះជា

យូរយារមកហើយ ហើយជាបន្តបន្ទាប់ ។ ពិសេសពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៥ ពេលដែលវាមកសុំធ្វើជម្រកនៅលើទឹកដីកម្ពុជា វាឆ្លៀតឱកាសនោះកេងប្រើមិត្តភាពរបស់ប្រជាជនកម្ពុជាធ្វើវិទ្ធង្សនាបក្សជាបក្សមួយដោយឡែក រៀបចំរដ្ឋអំណាចមួយដោយឡែកបង្កើតកងទ័ពមួយ ដោយឡែកនៅលើទឹកដីកម្ពុជាដែលបដិវត្តកម្ពុជាគ្រប់គ្រងហើយ ហើយដែលកម្ពុជាមានចិត្តសន្តោសឲ្យវារស់នៅ ។ វាយកកម្លាំងទាំងនេះមកអុកឡុករដ្ឋអំណាចបដិវត្តកម្ពុជាវិញ រំលោភលើអធិបតេយ្យភាពនិងបូរណភាពទឹកដីកម្ពុជាមិនចេះចប់ ។ ប៉ុន្តែវាត្រូវបរាជ័យយ៉ាងធ្ងន់ជាបន្តបន្ទាប់ ។

ដោយឡែកតែចំពោះបក្សក្នុងរយៈកាល ១៩៧០ ដល់ ១៩៧៥ យួនបានខំប្រើគ្រប់វិធីទាំងអស់ដ៏ខ្រិជ្ឈ ប៉ុនប៉ងកម្ទេចគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាដ៏ត្រឹមត្រូវ ហើយបន្តុបពួកដៃជើងរបស់វាដែលជាសមាសភាពអាវ៉ាសែ ពុករលួយក្បត់បដិវត្ត និងមិនដឹងងោះអី ចាំតែថាបាទតាមយួន ឲ្យមកជំនួសវិញ ។

ប៉ុន្តែក្នុងសកម្មភាពដ៏ក្រខ្វក់នេះទៀត ក៏យួនត្រូវបរាជ័យយ៉ាងអាម៉ាស់ ដោយប្រជាជននិងកងទ័ពបដិវត្តកម្ពុជាសាមគ្គីគ្នាជាធ្លុងមួយក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនិស្តកម្ពុជារបស់ខ្លួន បន្តការប្រយុទ្ធយ៉ាងប្តូរផ្តាច់តាមគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ។

ដល់ឆ្នាំ១៩៧៥ ក្រោយកម្ពុជាបានរំដោះហើយ យួនបន្តធ្វើសកម្មភាពរំលោភ បង្កហេតុឈ្លានពានចូលទឹកដីកោះកម្ពុជាធ្វើវិទ្ធង្សនាជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា បង្កប់ស៊ីរូង បំបែកបំបាក់ផ្ទៃក្នុង រៀបចំធ្វើរដ្ឋប្រហារច្រើនលើកច្រើនគ្រា ដើម្បីវាយរំលំកម្ពុជាប្រជាធិបតេយ្យ ដោយរួមផ្សំកម្លាំងពួកភ្នាក់ងារចារកម្មបង្កប់ស៊ីរូងផ្ទៃក្នុងរបស់វាជាមួយនឹងកម្លាំងរបស់វាឈ្លានពាន វាយពីក្រៅមក ហើយសហការជាមួយកម្លាំងសេ.អ៊ី.អា ថែមទៀត ក្នុងគោលបំណងវាយកម្ទេចបដិវត្តកម្ពុជាហើយវាដណ្តើមគ្នាហែកហួរកម្ពុជាប្រជាធិបតេយ្យ ។ សកម្មភាពដ៏ខ្រិជ្ឈនេះវាបានធ្វើជាបន្តបន្ទាប់នៅក្នុងឆ្នាំ១៩៧៥-១៩៧៦ និង១៩៧៧ តែវាត្រូវបរាជ័យជាបន្តបន្ទាប់ទៀត ។

នៅចំពោះមុខសភាពការណ៍បរាជ័យយ៉ាងដូរចត់នេះចាប់ពីខែកញ្ញា ១៩៧៧មក យួនវាប្រជុំប្រជានធ្វើសង្គ្រាមឈ្លានពានដ៏ឃោរឃៅកាចសាហាវដោយទ្រង់ទ្រាយធំតែម្តង គឺជាសង្គ្រាមមិនប្រកាស ដោយមានកម្លាំងយោធាជាច្រើនកងពលព្រមទាំងមានទីប្រឹក្សាបច្ចេកទេសខ្លះទៀតផង មកបុកទម្លាយកម្ពុជាប្រជាធិបតេយ្យក្នុងសំណូមពរមកកាន់កាប់ទឹកដីកម្ពុជាប្រជាធិបតេយ្យផ្នែកខាងកើតទន្លេមេគង្គ និងផ្នែកខាងកើតភូមិភាគនិរតី ហើយចាត់តាំងរដ្ឋអំណាចអាយ៉ងរបស់វាតាំងពីថ្នាក់ភូមិ,ឃុំ,ស្រុកដល់ខេត្ត តាមសភាពការណ៍ដែលវាដណ្តើមទឹកដីកម្ពុជាបានដោយយកភ្នាក់ងារមួយក្តាប់តូចរបស់វាមកបន្តុបពិសេសបរិវាររបស់វាដែលវាកសាងនៅលើទឹកដីរបស់វាពីយូរឆ្នាំមកហើយ ហើយសំខាន់ណាស់ទៅទៀត គឺវាយកជនជាតិយួន យកកងទ័ពនិងកម្មាភិបាលយួនមកគ្រប់គ្រងទឹកដីទាំងអស់នេះតែម្តង ។

ហើយវាសង្ឃឹមថានឹងឈានទៅយកដែនដីកម្ពុជាទាំងមូលទៀត ។ ចំពោះវគ្គឈ្លានពានលើកទី១របស់យួននេះ កងទ័ពបដិវត្តកម្ពុជា ប្រជាជនកម្ពុជាដ៏អង់អាចក្លាហានបានវាយទប់ទល់ឲ្យវាបរាជ័យ និងបាក់ទាំងស្រុងយ៉ាងអាម៉ាស់នៅថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៨ ។ ប៉ុន្តែបរាជ័យធ្ងន់ហើយ យួនឈ្លានពាន វាតទីលេបទឹកដីវានៅតែបន្តឈ្លានពានជាបន្តបន្ទាប់តាមផែនការសហព័ន្ធឥណ្ឌូចិនរបស់វា ។ ដូច្នេះ ចាប់ពីខែកុម្ភៈ មកដល់ថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៨នេះ យួននៅតែបន្តធ្វើសកម្មភាពខ្រិជ្ឈរបស់វាតាមព្រំដែនកម្ពុជាប្រជាធិបតេយ្យ ពិសេសខាងភូមិភាគបូព៌ានិងភូមិភាគនិរតី ដោយប្រើកម្លាំងដល់ទៅ១១កងពល ។ ដើម្បីបិទបាំងមុខមាត់ឈ្លានពានរបស់វានេះ យួនបានប្រកាសចរចាស្អីវានោះ ។ អ្នកណាក៏ដឹងថា នេះគឺជាការបោកប្រាស់បោកបន្លំមតិប្រជាជនវានិងមតិសកលលោក ដើម្បីឈ្លានពាន វាយលុកយកកម្ពុជាទៀត ។ តែប្រជាជននិងកងទ័ពបដិវត្តកម្ពុជាយើង យើងស្គាល់យួនច្បាស់លាស់តាមធាតុឈ្លានពានវាតទីលេបទឹកដីរបស់វា ។ ប្រជាជននិងកងទ័ពបដិវត្តកម្ពុជាយើងលើកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច ហើយបានវាយបកទៅលើកងទ័ពយួនឈ្លានពាន ធ្វើឲ្យវាត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរនៅវគ្គទី២នេះ

ទៀត ។

តើបច្ចុប្បន្ននេះ យួនវាបោះបង់ចោលមហិច្ឆតាឈ្លានពានវាតទីលេបទឹកដីហើយឬនៅ? វាមិនបោះបង់ចោលទេ ។ កងទ័ពវាទាំងកងពល ។ កាំភ្លើងធំវា រថក្រោះវា នៅតែបន្តរំលោភឈ្លានពាន បាញ់ផ្លោង បាញ់ផ្តក់ មកលើកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែង នៅថ្ងៃ៧ មេសា ១៩៧៨ ក្នុងពេលដែលយួនស្រែកក្តែង ៗ ថា វាមិនគិតគូរដល់សហព័ន្ធឥណ្ឌូចិនទៀតទេ ថាវាចង់ដោះស្រាយបញ្ហាព្រំដែន កងទ័ពយួនជាងមួយកងពលបានវាយលុកសំដៅទម្លុះព្រំដែនតម្រង់ទៅចំណុចលក ទាន់ហាន់ និងភ្នំជាវប្តី ក្នុងខេត្តកំពត ។ ក្នុងពេលជាមួយគ្នានេះដែរនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង យួនក៏ប្រើកម្លាំងវាប្រមាណពីរកងវរ-សេនាធំ ប៉ុនប៉ងវាយលុកចូលកម្ពុជាដែរ ។ ខាងកំពង់ចាម ខាងកើតតាមព្រំដែននាស្រុកពញាក្រែក មេមត់ ត្រមូង យួនក៏ប្រើកងទ័ពជាង១កងពលវាយលុកឈ្លានពានប៉ុនប៉ងចូលមកទឹកដីកម្ពុជាដែរ ។ ហើយនៅលើផ្លូវលេខ១៣ ពី ឡុកនិញ មកស្នួលនៅតាមព្រំដែន យួនប្រើកម្លាំងវាជិតពីរកងវរសេនាធំវាយលុកប៉ុនប៉ងចូលមកទឹកដីកម្ពុជាដែរ ។ នេះមិនរាប់ពីសកម្មភាពឈ្លានពានមានទ្រង់ទ្រាយមធ្យមនិងតូចដែលវាប្រើកម្លាំងត្រឹមវរសេនាតូចនិងអនុសេនាធំ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរីទេ ។ តើនេះជាការចៃដន្យ ឬជាផែនការស៊ីខ្សែសង្វាក់គ្នា? រវាងមាត់ស្រែកនៅថ្ងៃ៧ ខែមេសា ឆ្នាំ១៩៧៨ ថាគ្មានសហព័ន្ធឥណ្ឌូចិនថាគោរពព្រំដែននេះនោះថា ចរចាស្អីវានោះ ហើយនិងការប្រើកងទ័ពដោយទ្រង់ទ្រាយធំមានទិសវាយលុកកម្ពុជាប្រជាធិបតេយ្យ ។ នេះច្បាស់ណាស់មិនមែនជាការចៃដន្យទេ តែជាផែនការគិតគូរទុកជាមុនជាខ្សែសង្វាក់ ។ មាត់ស្រែកក្តែង ៗ ដើម្បីភូតភរមតិសកលលោកតទៅទៀតថា យួនចង់ដោះស្រាយដោយចរចា ។ តែជាក់ស្តែងថ្ងៃ៧ ខែមេសា ឆ្នាំ១៩៧៨ ហើយនិងថ្ងៃបន្តបន្ទាប់មកទៀតទី៨, ទី៩, ទី១០ ។ល ។ កងទ័ពយួនបានវាយបុកដោយទ្រង់ទ្រាយធំមកលើកម្ពុជាទៀត ។ ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តកម្ពុជាដ៏អង់អាចក្លាហានធ្លាប់ស្គាល់ធាតុពិតឈ្លានពាន វាតទីលេបទឹកដី និងកលល្បិចបោកប្រាស់របស់យួនរាប់សិបឆ្នាំមកហើយ ។ បើនិយាយតែរយៈកាលបច្ចុប្បន្ននេះបានមើលឃើញធ្លុះជាងមុនគំនិតដ៏អាក្រក់បំផុតរបស់វានិងឧបាយកលដ៏ពិសពុលបំផុតរបស់វា ហើយបានវាយកម្ទាត់ការឈ្លានពានរបស់យួននៅថ្ងៃ៧, ៨, ៩, ១០ ខែមេសា ឆ្នាំ១៩៧៨នេះភ្លាមនោះដែរ ឲ្យវាបរាជ័យយ៉ាងធ្ងន់ធ្ងរនិងយ៉ាងអាម៉ាស់ម្តងទៀត ។ លើកនេះទៀត ប្រជាជននិងកងទ័ពបដិវត្តកម្ពុជាយើងដណ្តើមបានជ័យជំនះយ៉ាងធំមួយលើកទៀត ។ ជាក់ស្តែងនៅសមរភូមិកំពតនៅថ្ងៃ៧ ខែមេសា ឆ្នាំ១៩៧៨ វេលាម៉ោង៦ព្រឹក កងទ័ពយួនជាង១កងពលបើកឆាកមករំលោភទឹកដីកម្ពុជា ។ នៅម៉ោង១២ កងទ័ពបដិវត្តកម្ពុជាយើងបានវាយកងទ័ពយួនឲ្យបាក់ទ័ពងាប់រដូករណែល និងរត់ទីណាត់ទីណែងត្រឡប់ក្បាលទៅវិញ ។ នៅសមរភូមិកំពង់ត្របែកក៏វាបាក់ ។ នៅពញាក្រែក មេមត់ ត្រមូង ក៏វាបាក់ ។ នៅសមរភូមិ ព្រំដែនស្នួលក៏វាបាក់ ។ គឺគ្រាន់តែវាអើតក្បាលមកភ្លាម កងទ័ពកម្ពុជាយើងវាយវាឲ្យបរាជ័យភ្លាម ។ តាមភស្តុតាងជាក់ស្តែងនិងក៏បញ្ជាក់ឲ្យឃើញច្បាស់ថាការដែលយួនស្រែកក្តែង ៗ ថាចង់ចរចាចង់មិត្តភាពពិសេស សាមគ្គីភាពពិសេស ចង់ដោះស្រាយបញ្ហាព្រំដែនស្អីវានោះ គ្រាន់តែជាការបោកប្រាស់ជាថ្មី១លើកទៀតដើម្បីបិទបាំងនូវអំពើឈ្លានពានរបស់វា ។ គឺគ្រាន់តែសំដៅឃោសនាបោកបន្លំមតិប្រជាជនវៀតណាមនិងមតិសកលលោកតែប៉ុណ្ណោះ ។

តើគោលជំហរដោះស្រាយរបស់កម្ពុជាប្រជាធិបតេយ្យយ៉ាងដូចម្តេច ។ ខ្ញុំបានប្រកាសជាឱឡារិកនៅថ្ងៃ១៧ ខែមករា ឆ្នាំ១៩៧៨រួចមកហើយ ព្រមជាមួយនេះខ្ញុំក៏បានបញ្ជាក់ក្នុងសម្ភាសន៍ចំពោះអ្នកកាសែតយូហ្គោស្លាវីថ្ងៃ១៧ ខែមីនា ឆ្នាំ១៩៧៨រួចមកហើយដែរ ។ តែថ្ងៃនេះឈរលើខ្លឹមសារនៃសេចក្តីថ្លែងការពីមុន ៗ មកហើយ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថាៈ

១) យួនត្រូវតែគោរពដោយស្មោះត្រង់នូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីកម្ពុជា និងសិទ្ធិចាត់ចែងកិច្ចការរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ យួនមិនត្រូវជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ មិនត្រូវធ្វើវិទ្ធង្សនា ចារកម្ម រំលោភឈ្លានពាន បាញ់ផ្លោង បាញ់រះបាញ់ផ្តក់មកលើទឹកដីកម្ពុជាប្រជាធិបតេយ្យដាច់ខាត ។

(២) គោរពឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីកម្ពុជាប្រជាធិបតេយ្យក្នុងក្របខ័ណ្ឌព្រំដែនគោកនិងសមុទ្រ ដែលរដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នវៀតណាមខាងត្បូង និងរដ្ឋាភិបាលក្រុងហាណូយប្រកាសទទួលស្គាល់ជាឱឡារិកនៅឆ្នាំ ១៩៦៦-១៩៦៧ ។

សុឆន្ទៈដ៏ស្មោះសរបស់កម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជា គឺចង់តែរស់នៅដោយសុខសាន្តក្នុងព្រំដែនរបស់ខ្លួន ហើយចង់បានមិត្តភាពជាមួយប្រទេសជិតខាងទាំងអស់ ។ ដូច្នេះហើយបានជាប្រជាជនកម្ពុជាមិនសើរើសំណុំរឿងអ្វីជាថ្មីទេ ។ បើនិយាយពីសិទ្ធិទាមទារសើរើសំណុំរឿងព្រំដែន កែប្រែព្រំដែនទាំងគោក ទាំងសមុទ្រ មានតែកម្ពុជាប្រជាធិបតេយ្យទេដែលមានសិទ្ធិ មានហេតុផលត្រឹមត្រូវច្រើនលើសលប់ដូចជាលើកឲ្យដោះស្រាយបញ្ហាកម្ពុជាក្រោមឡើងវិញ ដោះស្រាយកោះកម្ពុជាឡើងវិញដែលរបបអាណានិគមនិយមបារាំងបានយកទៅខាងកូសាំងស៊ីន ហើយនិងរបបអាដៅ ឌិនយៀម និងរបបព្រៃនគរជំនាន់មុនឈ្លានពានយក ។ ដោយឡែកតែព្រំដែនសមុទ្រ បើកម្ពុជាប្រជាធិបតេយ្យចង់សើរើសំណុំរឿងឡើងវិញ ហេតុផលរបស់កម្ពុជាប្រជាធិបតេយ្យ ទាំងហេតុផលច្បាប់ ទាំងហេតុផលដែលត្រូវយកលំនាំដីគោកជាមូលដ្ឋាន ព្រំដែនសមុទ្រកម្ពុជាត្រូវពង្រីកទៅខាងត្បូងខ្សែបន្ទាត់ប្រេវីយេទៅទៀត ។ ប៉ុន្តែដោយកម្ពុជាប្រជាធិបតេយ្យចង់បានមិត្តភាព បានជាកម្ពុជាប្រជាធិបតេយ្យមិនសើរើសំណុំរឿងអ្វីទាំងអស់ ។ បញ្ហានេះកុំឲ្យភាគីយួនយល់ច្រឡំស្មានថា កម្ពុជាមិនដឹងខ្យល់អី ។ កុំចង់បោកបន្លំដើរឧបាយកលនេះ ឧបាយកលនោះ ដើម្បីវាតទីលេបទឹកដីកម្ពុជាបានតាមចិត្តនោះ ។ យួនត្រូវដឹងថាវាតទីគឺអយុត្តិធម៌ គឺអមិត្ត គឺបរាជ័យ ។ មហិច្ឆតាលោភលន់ចង់លេបទឹកដីគេ គឺព្រៃផ្សៃ វាខុសនឹងច្បាប់ទម្លាប់អន្តរជាតិទាំងអស់ ។ កម្ពុជាប្រជាធិបតេយ្យយល់ឃើញថា ដើម្បីមានមិត្តភាពរវាងកម្ពុជានិងវៀតណាមវៀតណាមត្រូវគោរព «៦» ខាងលើនេះដាច់ខាត ហើយបោះបង់ចោលជារៀងរហូតនូវគោលគំនិតនិងផែនការសហព័ន្ធឥណ្ឌូចិន ផែនការបក្សតែ១ ប្រទេសតែ១ ប្រជាជនតែ ១ កងទ័ពតែ១ បោះបង់ចោលគោលគំនិតនិងផែនការវាតទីលេបទឹកដីកម្ពុជា រំលាយពូជសាសន៍កម្ពុជា ។ ហើយបោះបង់ចោលនេះមិនមែនប្រកាសតែមាត់ទទេៗទេ គឺត្រូវឲ្យចេញជាការប្រព្រឹត្តជាក់ស្តែងជារៀងរហូត ។ ពុំនោះសោតទេ មិត្តភាព សាមគ្គីភាព មិត្តភាពពិសេសស្អីគេនោះ សាមគ្គីភាពពិសេសស្អីគេនោះ ការចរចាស្អីគេនោះ សុទ្ធតែជាការបោកបន្លំមតិប្រជាជនវៀតណាមនិងប្រជាជនសកលលោក ។

ក្នុងសភាពការណ៍ដូច្នេះ ប្រជាជនកម្ពុជានិងកងទ័ពបដិវត្តកម្ពុជាយើងលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ចការពារឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដីកិត្តិយសជាតិរបស់ខ្លួនដាច់ខាត ហើយកម្ចាត់យួនឈ្លានពានវាតទីលេបទឹកដីឲ្យវាបរាជ័យជាបន្តបន្ទាប់និងជារៀងរហូត ។ ប្រជាជន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយល់ឃើញថា បើភាគីវៀតណាម លះបង់មហិច្ឆតាលោភលន់ចង់លេបទឹកដីកម្ពុជាប្រជាធិបតេយ្យ ហើយទទួលយកមិត្តភាពនិងសុឆន្ទៈរបស់កម្ពុជានោះវាល្អជាង ។ ហើយខ្ញុំអំពាវនាវឲ្យភាគីវៀតណាមទទួលយកមិត្តភាពកម្ពុជាយើងនេះដើម្បីជាផលប្រយោជន៍របស់ប្រជាជនកម្ពុជានិងប្រជាជនវៀតណាម ដើម្បីមិត្តភាពរវាងប្រទេស និងប្រជាជនកម្ពុជានិង វៀតណាមដើម្បីប្រទេសកម្ពុជានិងប្រទេសវៀតណាមបានចម្រុងចម្រើននិងមានសុខសន្តិភាព ហើយនិងដើម្បីសុខសន្តិភាពក្នុងភូមិភាគនេះផង ។





# យ៉ាងម៉េចហៅថា ទស្សនៈមហាជននិងមាគ៌ាមហាជន?

**(សៀវភៅយុវជននិងយុវនារីបដិវត្ត លេខពិសេស ខែមេសា ឆ្នាំ១៩៧៦)**

ទស្សនៈមហាជនគឺជាការជឿជាក់លើកម្លាំងប្រជាជនមហាជន ពិសេសប្រជាជន កម្មករ កសិករ ក្រីក្រ ។ ការមើលឃើញតួនាទីសំខាន់បំផុតរបស់ប្រជាជនមហាជនក្នុងការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យកន្លងទៅក៏ដូចជាការធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមបច្ចុប្បន្ន និងការធ្វើបដិវត្តសង្គមនិយមទៅអនាគតទៀត ។ សរុបមក ទស្សនៈមហាជនគឺជាការមើលឃើញ ជឿជាក់ ហើយពឹងផ្អែកលើកម្លាំងខ្លាំងក្លាមហិមា និងលើសមត្ថភាពដ៏ធំធេងរបស់ប្រជាជនមហាជនក្នុងការធ្វើបដិវត្តន៍ កែប្រែកសាងសង្គមមនុស្ស ក៏ដូចក្នុងរាល់កិច្ចការតូចធំ លំបាក ស្រួលផ្សេងៗទៀតដែរ ។ ឧទាហរណ៍ៈ ក្នុងចលនាលើកប្រព័ន្ធភ្លឺថ្មីនិងជីកប្រឡាយថ្មីបើគ្មានទស្សនៈមហាជនទេនោះយើងនឹងឃើញតែសារសំខាន់នៃម៉ាស៊ីនចូកដី ត្រាក់ទ័រ ម៉ាស៊ីនកិនដី ។ល ។ ដូច្នេះយើងទាមទាររកតែម៉ាស៊ីនគ្រប់បែបយ៉ាង ។ ដូច្នេះយើងនឹងទាល់ច្រកធ្វើអ្វីពុំកើតឡើយ ព្រោះបដិវត្តន៍នៅក្រគ្មានលទ្ធភាពដោះស្រាយម៉ាស៊ីនសម្បូរបែបយ៉ាងនេះបានឡើយ ។ តែដោយបដិវត្តន៍យើងមានទស្សនៈមហាជនរឹងប៉ឹងយើងប្រមូលកៀងគរប្រជាជនមហាជននិងចលនាមហាជនទូទាំងប្រទេសធ្វើទាំងយប់ទាំងថ្ងៃ ដូច្នេះយើងធ្វើបាន ។ មាគ៌ាមហាជនគឺជាការប្រព្រឹត្តការអនុវត្តឬការគិតគូរអ្វីៗទាំងអស់ដែលបម្រើប្រជាជន មហាជន ពិសេសប្រជាជន កម្មករ កសិករក្រីក្រ ដែលការពារផលប្រយោជន៍ដ៏ពិសិដ្ឋរបស់ប្រជាជន មហាជន ហើយដែលសមស្របតាមសំណូមពរតាមលទ្ធភាព និងសមត្ថភាពរបស់ប្រជាជនមហាជនដ៏ច្រើនកុះករ ។ មាគ៌ាមហាជនមានន័យម្យ៉ាងទៀតគឺធ្វើអ្វីក៏ដោយក្នុងការដឹកនាំក្តី ក្នុងការឃោសនាអប់រំក្តីក្នុងការចាត់ចែងកម្លាំងប្រជាជនធ្វើកិច្ចការអ្វីៗក្តី មិនបង្ខិតបង្ខំ មិនគំហកកំហែង មិនគំរាម ឬប្រមាថកាតទានមើលងាយមើលថោកប្រជាជនមហាជនដាច់ខាត ។ តែផ្ទុយទៅវិញ គឺចេះណែនាំពន្យល់ឲ្យប្រជាជន មហាជន សុខចិត្ត សុខកាយ សោមនស្សជ្រះថ្លាពេញចិត្តពេញថ្លើម នឹងធ្វើតាមការណែនាំរបស់បដិវត្តន៍យើង ។ តែមាគ៌ាមហាជននេះមិនមែនមានន័យថាដើរតាមក្រោយមហាជនឬធ្វើតាមមហាជនដោយងងឹតងងល់ទាំងខុសទាំងត្រូវនោះទេ ។ មាគ៌ាមហាជននេះគឺគោរពតាមសំណូមពររបស់ប្រជាជនមហាជន បើសំណូមពរនោះសមស្របនឹងផលប្រយោជន៍របស់ប្រទេសជាតិរបស់ប្រជាជនច្រើនកុះករ ហើយមានលក្ខណៈចម្រើនជឿនលឿន ។ តែបើសំណូមពរនោះមានលក្ខណៈស្ងួនត្លួទៅតាមទម្លាប់ចាស់ដែលមិនបដិវត្ត មិនចម្រើនជឿនលឿននោះយើងត្រូវចេះណែនាំឬអប់រំពន្យល់ឲ្យប្រជាជនមហាជនមានការភ្ញាក់រឭកបដិវត្ត មានស្មារតីស្នេហាជាតិ ស្នេហាសមូហភាពពោលគឺចម្រើនជឿនលឿនមកតាមបដិវត្តន៍យើងវិញជាបណ្តើរៗ ។ ដាច់ខាតយើងមិនត្រូវធ្វើតាមឬគោរពតាមសំណូមពរស្ងួនត្លួងងឹតងងល់ដាច់ខាត យើងមិនត្រូវទុកឲ្យប្រជាជនមហាជនស្ថិតនៅក្នុងសភាពមិនភ្ញាក់រឭកបដិវត្តជារៀងរហូតឡើយ ។ តែយើងក៏មិនត្រូវបង្ខិតបង្ខំឲ្យប្រជាជនមហាជនធ្វើបដិវត្តន៍ **(តទៅទំព័រទី២៨)**

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម

## ស្រុកចំការលើ

ស្រុកចំការលើគឺជាស្រុកមួយក្នុងចំណោមស្រុកនានានៅក្នុងខេត្តកំពង់ចាម ដែលជាទីកន្លែងខ្មែរក្រហមបានកាប់សម្លាប់ប្រជាជនស្លូតត្រង់នៅក្នុងរយៈកាលនៃការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏បានបន្សល់ទុកនូវសាកសពជាច្រើននៅក្នុងស្រុកនេះ ។ ស្រុកចំការលើមានចម្ងាយ១៥គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម ។ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៨ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅស្រុកចំការលើ ខេត្តកំពង់ចាម ដើម្បីសាកសួរនិងថតទីតាំងប្រល័យពូជសាសន៍ទាំងនោះបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ។

**១) គុកមិត្តសោ**ៈ គឺជាទីតាំងមន្ទីរសន្តិសុខនិងគុកនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានទីតាំងស្ថិតនៅក្នុងភូមិពព្រេង ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម ហើយមានចម្ងាយ ៥៤គីឡូម៉ែត្រ ពីទីរួមខេត្ត ។ តាមប្រព័ន្ធកំណត់ទីតាំងពិភពលោកបង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប ១២° ២០' ៤៤:៨១" និងខ្សែបណ្តោយ ១០៥° ១៩' ៤៨:៨៦" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រ ត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ០៣០២០១និងលេខឯកសារ R0៧0៧0៣ A ។

លោក ប៊ុ ណាក់ ជាប្រធានភូមិពព្រេង រស់នៅភូមិពព្រេង ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម បានរៀបរាប់ប្រាប់ក្រុមស្រាវជ្រាវយើងថា នៅក្នុងភូមិរបស់គាត់មានគុកមួយកន្លែងដែលមានឈ្មោះថា គុកមិត្តសោ ។ គុកនេះគឺបានកសាងឡើងតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ ប្រភេទជនរងគ្រោះដែលមកជាប់គុកគឺប្រជាជនចាស់និងថ្មី ដោយខ្មែរក្រហមបានចោទថាខុសសីលធម៌ ឬមាននិន្នាការនយោបាយពីរបបមុន ។ បន្ទាប់ពីដាក់គុករួចហើយ ក៏សម្លាប់ចោលទាំងអស់តែម្តង ។

**២) ទីតាំងសម្លាប់គុកមិត្តសោ**ៈ ទីតាំងនេះស្ថិតនៅក្នុងភូមិពព្រេង ឃុំស្ពឺ ស្រុកកំពង់ចាម ។ ទីតាំងសម្លាប់នៅគុកមិត្តសោ ស្ថិតនៅក្នុងខ្សែស្រប១២° ២០' ៤៨:០១" និងខ្សែបណ្តោយ ១០៥° ១៩' ៥៨:០១" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រ ត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ០៣០២០២ និងលេខឯកសារ R0៧0៧0៤A ។

លោក ប៊ុ ណាក់ បានបញ្ជាក់ថានៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ទាហាន មន្ត្រីរដ្ឋការនិងប្រជាជន១៧មេសា គ្រូបង្រៀន អ្នកចេះដឹង ពាណិជ្ជករ ប៉េអឹម គិញ មកសម្លាប់នៅទីតាំងគុកមិត្តសោ ។ ឆ្នាំ១៩៧៦-១៩៧៧ ខ្មែរក្រហមបានយកទាំងប្រជាជនចាស់ ទាំងប្រជាជនថ្មី ទាហាន មន្ត្រីរដ្ឋការ ប្រជាជន១៧មេសា ទាំងអស់មកសម្លាប់នៅទីនេះដែរ ។ ចំណែកឆ្នាំ១៩៧៧-១៩៧៨ ខ្មែរក្រហមបានយកទាំងគ្រួសារៗមកសម្លាប់ចោលម្តង ។ ពេលនោះពួកខ្មែរក្រហមបានអនុវត្តទ្រឹស្តីមួយថា «ជីកស្មៅ គឺជីកទាំងឫស» ។ គាត់បានប៉ាន់ស្មានចំនួនជនរងគ្រោះដែលស្លាប់បាត់បង់ជីវិតនៅទីនេះមានចំនួនជិត១ម៉ឺននាក់ ។


លោក ប៊ុ ណាក់

**៣) វត្តពព្រេង**ៈ គឺជាកន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងខ្សែស្រប ១២° ២០' ៣៥:៨៤" និងខ្សែបណ្តោយ ១០៣° ១៩' ៤៨:១៥" ។ ចំណុចទិន្នន័យទីតាំងភូមិសាស្ត្រវត្តពព្រេងត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ០៣០២០៣ និងលេខឯកសារ R0៧0៧0៤ B ។

លោក ប៊ុ ណាក់ បានមានប្រសាសន៍បន្តថា អដ្ឋិធាតុដែលយកមកតម្កល់ទុកនៅក្នុងបរិវេណវត្តពព្រេងគឺដោយសាររដ្ឋអំណាចភូមិឃុំព្រមទាំងប្រជាជនដែលនៅក្នុងមូលដ្ឋានបាននាំគ្នាធ្វើស្តូប និងគាស់អដ្ឋិធាតុទាំងនោះបានមួយចំនួនតូចដើម្បីយក

មកតម្កល់ទុកសម្រាប់ធ្វើបុណ្យថ្ងៃ២០ឧសភា ដែលជាថ្ងៃទិវាចងកំហឹងឈឺចាប់ចំពោះបនប្រល័យពូជសាសន៍ខ្មែរក្រហម ។ បច្ចុប្បន្ននេះអដ្ឋិធាតុ ទាំងនោះត្រូវបាត់បង់អស់គ្មានសល់ឡើយ ដោយសារតែសត្វគោ ជ្រូក ឆ្កែ អូសស៊ីរប៉ាត់រប៉ាយអស់ទៅ ហើយស្តូបនោះក៏បាក់បែក ទ្រុឌទ្រោមនិងគ្មានអ្នកថែរក្សា ។

**៤) គុកសំៈ** គឺជាកន្លែងសម្លាប់មនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងខ្សែស្រប ១២° ២០' ៤៨ៈ២៥" និងខ្សែបណ្តោយ១០៥° ២០' ២៤ៈ១៧" ។ ចំណុចទិន្នន័យទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ ០៣០២០៤ និងលេខឯកសារ R០៧០៧០៥A ។

**៥) ចម្ការតាប៉ុមៈ** ចម្ការតាប៉ុមស្ថិតនៅឆ្ងាយពីផ្លូវជាតិលេខ៧១ចម្ងាយ៣គីឡូម៉ែត្រ ហើយនៅជិតចម្ការអណ្តូងដោយបត់ទៅស្តាំដៃចូលទៅប្រហែល៦០០ម៉ែត្រទើបដល់ទីតាំងនេះដែលមានដើមស្វាយនិងចម្ការទុរេនជាសម្គាល់ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក ទីតាំងចម្ការតាប៉ុមនេះស្ថិតនៅចន្លោះខ្សែស្រប ១២° ២០' ១២ៈ៧២" និងខ្សែបណ្តោយ ១០៥°១៥' ៥៦ៈ២៨" ។ ចំណុចទិន្នន័យភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិក ដោយលេខកូដ ០៣០២០៥ និងលេខឯកសារ R០៧០៧០៦A ។ ចម្ការតាប៉ុមគឺជាកន្លែងសម្លាប់ដ៏សាហាវមួយនៅស្រុកចំការលើក្នុងរបបខ្មែរក្រហម ។ ប្រជាជនស្លូតត្រង់រាប់ពាន់គ្រួសារត្រូវបានយកមកសម្លាប់នៅចម្ការតាប៉ុម ។ រហូតមកទល់សព្វថ្ងៃនេះប្រជាជននៅចម្ការតាប៉ុមក៏ដូចជាប្រជាជននៅក្នុងស្រុកចំការលើទាំងមូលនៅតែមានគំនិតដក់ជាប់ជានិច្ចនូវអំពើប្រល័យពូជសាសន៍ដ៏សាហាវយង់ឃ្នង ។



លោក ស៊ឹ សំ

លោក ស៊ឹ សំ អាយុ៤៧ឆ្នាំ ជាប្រជាជនរស់នៅភូមិតាប៉ុម ឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ។ កាលពីសម័យ ប៉ុល ពត គាត់រស់នៅក្នុងភូមិអណ្តូងពោធិ ឃុំអណ្តូងពោធិ ស្រុកចំការលើ ខេត្តកំពង់ចាម ។ គាត់បានឃើញសាកសពដែលខ្មែរក្រហមបានសម្លាប់នៅទីតាំងចម្ការតាប៉ុម នៅក្រោយឆ្នាំ១៩៧៩ គឺនៅពេលដែលគាត់ចូលមកស្រុកកំណើតវិញ ។ នៅឆ្នាំ១៩៨៤ លោកពូបានឃើញឆ្អឹងជាច្រើនដែលប្រជាជននាំគ្នាកកាយឆ្អឹងទាំងនោះដើម្បីរកមាសប្រាក់នៅជាប់និងខ្លួនសាកសព ។



លោក ឈុន អ៊ីវ

លោក ឈុន អ៊ីវ សព្វថ្ងៃរស់នៅភូមិល្វាលើ ឃុំល្វាលើ ស្រុកចំការលើ ខេត្តកំពង់ចាម ។ កាលពីសម័យ ប៉ុល ពត គាត់រស់នៅភូមិ ឃុំ ស្រុកដដែលមានដីចម្ការនៅក្បែរនឹងទីតាំងសម្លាប់នេះតែម្តង ។ ឈុន អ៊ីវ បានឃើញឆ្អឹងរបស់ជនរងគ្រោះដែលបានស្លាប់បាត់បង់ កាលពីជំនាន់ខ្មែរក្រហមដូចលោកពូ ស៊ឹ សំ ដែរ ។ គាត់បានឃើញពួកឃាតករខ្មែរក្រហមដឹកជនរងគ្រោះម្តងពី២០ឡាន ឬជាង២០ឡាន យកមកសម្លាប់ទីនោះ (គ្មានគុកទេ) ហើយការដឹកជញ្ជូននេះតាមការបំភ្លឺរបស់សាក្សីគឺថាក្នុងមួយខែដឹកម្តង ឬពីរដង ឬបីដង ។ ជនរងគ្រោះដែលស្លាប់នៅចម្ការតាប៉ុមនេះមានក្មេងចាស់ប្រុសស្រីសម្លាប់ចម្រុះតែម្តង ខ្មែរក្រហមសម្លាប់ប្រជាជននៅទីនេះចាប់ពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ។ សាក្សីទាំងពីរនាក់បានបន្តថាជនរងគ្រោះស្លាប់នៅទីនេះគឺជាប្រជាជន១៧មេសា ។ នៅឆ្នាំ១៩៧៦ ១៩៧៧ ១៩៧៨ ខ្មែរក្រហមបានសម្លាប់ទាំងប្រជាជនចាស់ ទាំងប្រជាជនថ្មីទាំងអស់សម្លាប់ខ្លាំងគឺនៅឆ្នាំ១៩៧៧ និង១៩៧៨តែម្តង ។ ទីតាំងសម្លាប់នៅចម្ការតាប៉ុមគឺជាកន្លែងសម្លាប់រួមនៅក្នុងតំបន់៤២ ។ នៅខាងស្តាំដៃនៃបរិវេណចម្ការតាប៉ុមនេះមានរណ្តៅធំចំនួន២០ ទំហំ៤ម៉ែត្រ៤ ជ្រុងជម្រៅ២ម៉ែត្រហើយក្នុងមួយរណ្តៅពី៥០ទៅ១០០នាក់ ។ រីឯរណ្តៅដែលស្ថិតនៅខាងឆ្វេងដៃមានចំនួន៣០រណ្តៅ រណ្តៅបេ៥២មាន៣រណ្តៅ មានអណ្តូងទឹកចំនួន៤កន្លែង ។ យោងតាមការប៉ាន់ស្មានរបស់សាក្សីចំនួនជនរងគ្រោះសរុបនៅក្នុងទីតាំងចម្ការតាប៉ុម គឺមានចំនួនប្រហែលពី៦២០០នាក់ឡើងទៅ ។

**អ៊ិច សំអឿន**

# កំណត់ហេតុប្រចាំថ្ងៃរបស់កម្មាភិបាលខ្មែរក្រហម

**(សៀវភៅលេខ២០៥ កណហ)**

**១)** ជ័យជម្នះដើមប្រាំង ៧៥នេះ ពិសេសចាប់ពី ១.១.៧៥ មកជាជ័យជម្នះធំណាស់នៅគ្រប់សមរភូមិទាំងបី ។

***វគ្គ:ទី១*** ១.១.៧៥-៦.១.៧៥ ជាវគ្គ:វាយសម្រុកទូទៅ ។ ចាប់ពីម៉ោង១ភ្លឺ អគ្គបញ្ជាការបក្សយើងបញ្ជាឲ្យវាយសម្រុកទូទៅទាំងអស់តាំងពីឈើគូស១ឬដុំឥដ្ឋ១ក៏ចូលវាយសម្រុកដែរ ។ សារាចរបក្សគឺគិតល្អិតសម្ងាត់ក្រោមប្រជាជន តែមិនឲ្យខាងក្រុមវិទ្យុ ទាំងក្រុមនិពន្ធ ទាំងការផ្សាយ មិនឲ្យដឹងមុន ។ វិទ្យុយើងបង្វែរដានវាជាប់ ។ ការបង្វែរដានរបស់អង្គការ ការរក្សាការសម្ងាត់របស់អង្គការ យកបានជ័យជម្នះធំណាស់ ។

មេគន្លងក្រោម: យើងដាក់ផែនការ១ខែ តែវាយតែ៣ថ្ងៃបោសសម្អាតទាំងអស់ដល់អ្នកលឿង ។ មូលហេតុយកជ័យជម្នះបាន: ១) យើងត្រៀមកម្លាំងយើងបាន ខែ១២ កម្មាភិបាលទាំងអស់ចុះអប់រំយុទ្ធជន ២) យើងប្រមូលកម្លាំង រក្សាការសម្ងាត់ ពេលនោះយើងទទួលគណ:ប្រតិភូវៀតណាមខាងត្បូង ៣) ខ្មាំងអត្តនោម័តិ ទាំងអាមេរិក ទាំងសេ.អ៊ី.អា ទាំងពួកលន់ ណុល វាមើលងាយយើង វាគិតតែពីរឿងជ័យជំនះអូនុយ (ONU) ។

***វគ្គ:ទី២:*** *Phase 2* ដោយសន្តិសម្ព័ន្ធបង្កប់ចូលក្នុងអង្គការយើង យើងមានពលីជីវិតអស់១០០ នៅខាងឧត្តរ ៣០៤ គឺព្រែកឆ្នោ ពពាលខែ អូរកុង ។ នាំឲ្យមានសភាពទ្រើង ។ ខាងមេគន្លងយើងដកទៅវាយនៅក្អមសំណ ពេលនោះវាឡើងបានពារាំងវិញដោយយកកងពល១មក(៣០០០នាក់) យើងវាយរំដោះអស់នៅសល់៥វរសេនាតូច(១០០០នាក់) ដែលសុំចុះចូលយើង ។ សមរភូមិគឺងតែងមែនទែន ក្ដៅមែនទែន តែយុទ្ធជន យុទ្ធនារីយើង ប្រជាជនយើងមានវីរភាពខ្ពស់ណាស់ គ្មានអ្នកណាគិតដល់ជីវិតខ្លួនគេទេ ទាំងកម្មាភិបាលលេខាភូមិភាគនីមួយៗ (សុទ្ធតែនៅសមរភូមិ) សរុបវគ្គ:ទី២ វាយយកបានខ្លះតែយើងត្រៀមវាយខ្លាំងទៀត ណាគ្រាប់រំសេវមានកម្រិតឧទាហរណ៍តាមរបបកាំភ្លើងធំត្រូវមានគ្រាប់៣០គ្រាប់ (យើងមាន៥ឬ១០ទេ) ។

***អាទិត្យ(វគ្គ:)ទី៣:*** យើងវាយឡើងវិញធំរំដោះក្អមសំណថ្ងៃ ២០.១.៧៥ កម្ទេចក្បាលនាវាចររបស់វា ។ នៅចុងវគ្គ:ទី៣ កប៉ាល់វានៅមានឡើងបានខ្លះ តែតិចទេ ។ យើងវាយកំពតយ៉ាងឆេះ ។ តែខ្ញុំចេញមកពីសមរភូមិថ្ងៃ ២៥.១.៧៥ ។ ២៥.១.៧៥-១៥.២.៧៥ ខ្មាំងធ្វើអីយើងអត់កើត វាចង់បើកអីក៏មិនបាន ។ យើងមិនវាយឯទៀត យើងចាប់វាយអ្នកលឿងតែម្ដង ព្រឹកមិញអាមេរិកស្រែកភ័យថាយើងរំដោះស៊ឹងស្ងួតបាញ់ផ្លោងចូលចំៗ ។ ប្រៀបធៀបកម្លាំងនឹងយើងឃើញថាខ្មាំងកាន់តែអស់កម្លាំង អស់ស្បៀង ទោះបីអាមេរិកាំងធ្វើស្ពានអាកាស ។ អង្គការថា ទោះយ៉ាងដូចម្ដេចក៏ដោយ នៅរដូវ ប្រាំងនេះ អាខ្មែរបនីយកម្មសង្គ្រាមត្រូវខ្ទេចខ្ទី ។ តែ USA និងពួកអាធីវ វាមើលទៅមិននៅស្ងៀមទេ ។

កម្រិតទី១ វាខំដឹកជញ្ជូន ទន្ទឹមនឹងវាសុំជំនួយបន្ថែមពីសភាអាមេរិក វាថាដើម្បីខបាយកលចរចា ព្រោះវាដឹងថាមិនអាចយកឈ្នះលើយើងទេ ។

កម្រិតទី២ ទម្លាក់គ្រាប់បែកទាំងយប់ថ្ងៃកាល៧៣ វាទម្លាក់ (១៩៥ថ្ងៃ ១៩៥យប់) ពិសេសជុំវិញភ.ព(ភ្នំពេញ) ។ បើវាមកទៀតក៏យើងបន្តទៀត ។ តែលទ្ធភាពនេះវាតិចណាស់ ហើយបើមានក៏អត់ដោះស្រាយអ្វីដែរ ព្រោះយើងអត់នៅទីក្រុងទេ ។

កម្រិតទី៣ ឲ្យកងទ័ពទី៧មកដឹកនាំកងទ័ពថ្មើរជើងពីកំពង់សោមមក ៣០០០នាក់-១សែននាក់ ។ តែឃើញលទ្ធភាពវាតិចណាស់ ព្រោះពិតជាមានការបះបោរខ្លាំងនៅអាមេរិក ។ ហើយវាក៏មិនមែនស្រឡាញ់អាណុលដូចកូនវាបង្កើតដែរ ។

សរុបមកអាមេរិកត្រូវបរាជ័យ វាមិនដឹងត្រូវដោះស្រាយ

បែបម្តេច ។ តែអាកប្បកិរិយាយើងមិនក្អេងក្អាងទេ ។ ឯពួកអាធិរាជ អាបាងកក បើអាមេរិកវាលំបាកយ៉ាងនេះហើយ ពួកបរិវាររបស់វាក៏រឹតតែលំបាក ។ ពួកអាធិរាជត្រូវជាប់ដៃជាមួយកងទ័ពវៀតណាមខាងត្បូង ។ ឯកម្លាំងយើងវិញកាន់តែកើនឡើងៗ (មានគ្រុនខ្លះដែរ) យើងឈ្នះដាច់ខាតខាងយោធា តែសង្គ្រាមប្រជាជនត្រូវធ្វើគ្រប់ផ្នែកទាំងអស់ ទាំងនយោបាយ សេដ្ឋកិច្ច ទូត ចលនាតស៊ូទាហានខ្លាំង ទោះនិស្សិតនៅបរទេសក៏យើងធ្វើដែរ ។ បើយើងធ្វើតែយោធាទេ គឺយើងយកជ័យជំនះមិនបាន ថ្វីដ្បិតតែយើងមានប្រៀបប៉ុណ្ណឹងហើយ ។ ខាងយោធាយើងធ្វើបានល្អហើយ ឯខាងនយោបាយ សេដ្ឋកិច្ច ទូត យើងធ្វើបានល្អដែរ តែមិនទាន់ដល់កម្រិតយើងចង់បាន ។ សភាពការណ៍រួមគឺយើងឈ្នះ ។ យើងមិនប្រានគេទេ តែបើរណសិរ្សខាងក្រៅរត់ចេញអស់ (ក៏មិនផ្លាស់ប្តូរស្ថានការណ៍ដែរ) ។

**២)** សារសំខាន់ការងារនៅខាងក្រៅ ពិសេសវិទ្យុ បើចលនានយោបាយ សេដ្ឋកិច្ច ទូត ឃោសនាមិនបានល្អ វាជះឥទ្ធិពលខាងយោធា ។ ខាងឃោសនា វាមិនមែនជាមូលដ្ឋានទេ វាគ្រាន់តែជាឧបករណ៍១បម្រើ ។ វិទ្យុភ្នំពេញរបស់យើង យើងយកកសិករក្រីក្រមកអប់រំដំណើរការបាន ។(បញ្ហាជនទៅពីក្រៅទៅ បញ្ហាធំគឺពលកម្ម៣ឆ្នាំបានឆាប់យល់មិនទាន់កែប្រែទស្សនៈទេ) ។ យើងទៅក្រៅៈ ១)សន្តិសុខ១០០% ។ ២) យើងមានសម្ភារល្អ ល្មម សមរម្យ ។ ចំណុចលំបាកៈ ១)ពិបាកក្នុងការគិតយើងអត់ចេះភាសាតែការនេះតែងឃើញជិតស្និទ្ធទៅ ២)ឆ្ងាយពីសមរភូមិ ពិបាកទាក់ទង ៣)ក្នុងក្រសួងមិនទាន់ស្នូលដើម្បីបម្រើក្រសួងមិនទាន់មាន ទេវានៅជាក្រុមជាបក្ខពួក ។ នេះជាកត្តាធំ ។ គោងលើកកម្ពស់ស្មារតីឲ្យបាន អានមិនល្អច្រៀងមិនល្អ យើងទទួលខុសត្រូវមតិខាងក្នុងមកលើអ្នកដឹកនាំក៏យើងទទួលខុសត្រូវ ។ វិទ្យុយើងនៅក្រៅដើរតួផងខាងក្នុងអូសទាញទឹកចិត្ត ឃោសនាបំផុស តស៊ូកុំភ្លេចថា (វិទ្យុរណសិរ្ស) ។

សារសំខាន់ៈ ១)សំឡេងរណសិរ្ស(សំឡេងអង្គការយើង) ស្នេហាជាតិ ២)ដោយក្នុងស្រុកអស់សិល្បៈ សិល្បៈវិទ្យុដើរតួឲ្យជាកម្សាន្តដល់ទូទាំងប្រទេស ៣)ការផ្សាយយោធា វាពុទ្ធទៅហើយជាប្រភព១ *AKI* ផ្សាយអន្តរជាតិ ។ កាលៈទេសៈសព្វថ្ងៃការរួមផ្សំជាមួយយោធា គឺសំខាន់ណាស់ ជាងពេលណាៗទាំងអស់ ។

រហូតដល់ថ្ងៃ១៥.១.៧៥ៈ មតិទោមនស្សច្រើន វាបម្រើចលនាមិនទាន់ អាចមិនសូវស្តាប់បាន ភ្លេងចម្រៀងទន់ពេកក្រុមនិពន្ធក៏នៅឃ្លោង(អត្ថបទនៅវែងៗ) ចាប់តាំងពី១៥.១.៧៥ យើងចម្រើនច្រើនហើយ ទាំងខាងអាន ខាងសិល្បៈ ធ្វើម្តេចកុំឲ្យតំអូស បំពេរ កុំយកបទបង្កងក្អែក បំពេរ កំណាព្យ ។ អាឃឹត យើងអាចលុបចោល តែស្រេចតែក្រសួងវិទ្យុ ។ ពិនិត្យឃើញសភាពដូចតទៅនេះ

សង្កេតឃើញ ១)មិនទាន់ជ្រួតជ្រាបសារសំខាន់វិទ្យុទេ អង្គការឲ្យច្រៀង អាន ចេះតែអានច្រៀងទៅ ជំហរជឿថាពាក្យមួយម៉ាត់ច្រៀង រួមវាយខ្មាំងក៏ពុំទាន់ឃើញមាននៅឡើយទេ ។ ម្នាក់ៗមិនទាន់យល់ជ្រាបដល់កំណើត ។ ២)ចលនាខាងសាមគ្គីដើម្បីបម្រើក្រសួងឲ្យក្រសួងបានល្អ ជាក្រសួង១នៅមានកម្រិតនៅឡើយ ។ នៅមានជាក្រុមៗនៅឡើយ ក្រុមអាន *Romain* អ្នកមកពីស្រុកក្រៅ អ្នកមកពីក្នុង ។ មិត្តមកពីក្រៅមិនទាន់ស្គាល់ការលំបាក ថ្វីដ្បិតតែមានសមានចិត្តចង់លត់ដំ តែនៅមិនទាន់ជ្រួតជ្រាប ។ សាមគ្គីភាពឲ្យបានល្អ លុះត្រាតែសមមិត្តមិត្តមួយចំនួនកម្ទេចបុគ្គលខ្លួន ប្តូរផ្តាច់ គិតគូរឲ្យជាក្រសួង ។ ៣)យើងមិនទាន់ដឹកនាំក្រសួង ។ លក្ខការណ៍ធ្វើការងារនៅមិនទាន់ជ្រួតជ្រាប គោងគោរពខ្សែចាត់តាំង ។ ត្រូវមានស្នូលដឹកនាំក្នុងក្រសួងស្នូល គឺសមមិត្តយើង មិត្តយើងប្តូរផ្តាច់ កម្ទេចបុគ្គលខ្លួន កសាងការដឹកនាំជាស្នូល ។ នៅឯណាក៏មានទំនាស់ដែរតែដើម្បីដោះស្រាយទំនាស់គោងគិតថាយើងជាបងប្អូន ។ ៤) ទាំងដំណើរការប្រឹងប្រែងរៀនសូត្រផ្ទាល់ខ្លួន កសាងខ្លួនដោយខ្លួនឯងនៅមិនទាន់ដល់កម្រិត អង្គការជួយហើយ ដោយវគ្គអប់រំ ។ ឃើញថា បន្ទុំមិនទាន់ដល់កម្រិតក្បៀវក្លា យើងបន្ទុំតែយើងរីករាយសប្បាយ ពិតហើយមិនដូចប្រតិកិរិយាទេ ។ រីករាយក្នុងជំហរបដិវត្ត ។ សង្កេតឃើញល្អដែរ មិត្តយើងខំពលកម្មជំនួសកីឡាកែប្រែជីវភាពរបស់យើង ។ ទោះម្តេចដំណើរការវិទ្យុបានចេះតែខំប្រឹងដែរ ។ ជាមូលដ្ឋានយើងចង់កែប្រែចង់ចម្រើនយើងនៅយុវវ័យ ។

**(នៅមានត)**

# ឥទ្ធិពលនៃការទម្លាក់គ្រាប់បែក

ខេត្តរតនគិរី ជាពិសេសស្រុកតាវែង គឺជាស្រុកមួយដែលត្រូវបានញាំញីដោយការទម្លាក់គ្រាប់បែកក្នុងអំឡុងឆ្នាំ១៩៦៥-១៩៧១ ។ ស្រុកនេះជាទីតាំងនិងជាដើមកំណើតនៃកម្លាំងយោធារបស់ចលនាតស៊ូខ្មែរក្រហម ។ ប្រជាប្រិយភាពរបស់ខ្មែរក្រហមកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដោយសារតែការទម្លាក់គ្រាប់បែកក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។

លោក ខាំ ខឿន អភិបាលខេត្តរតនគិរី ដែលមានស្រុកកំណើតនៅភូមិបានពងស ឃុំវ៉ឺនសៃ ស្រុកវ៉ឺនសៃ ខេត្តរតនគិរី បានឲ្យដឹងថាក្នុងអំឡុង៨ឆ្នាំនៃការទម្លាក់គ្រាប់បែកនោះ ប្រជាជនជាច្រើនត្រូវរងនូវផលប៉ះពាល់យ៉ាងខ្លាំងដោយសារអំបែងគ្រាប់និងជាតិថ្នាំពុលពណ៌លឿង ។ ក្នុងការហូបចុកម្តងៗអ្នកស្រុកភូមិ ទាំងអស់ត្រូវតែស្រុសចានក្បានដើម្បីចៀសវាងឬបន្ថយជាតិពុលឆ្នាំដែលមានការទម្លាក់គ្រាប់ច្រើនបំផុតគឺចាប់ពីឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៧១ ។ លោកបានបញ្ជាក់ទៀតថារណ្តៅគ្រាប់ច្រើនរាប់មិនអស់នៅតែរក្សាទ្រង់ទ្រាយរបស់វានៅឡើយទេមកដល់សព្វថ្ងៃនេះ ។

ដោយទ្រាំមិនបាននូវទិដ្ឋភាពសោកនាដកម្មបែបនេះ ប្រជាជនភាគច្រើនក៏សម្រេចចិត្តរត់ចូលព្រៃបង្កើតជាចលនាតស៊ូ ស្របពេលដែលមេដឹកនាំខ្មែរក្រហមធំៗរួមមាន ប៉ុល ពត អៀង សារី ខៀវ សំផន សុន សេន ហៅតាខៀវ ឬតាវ៉ែនតា និងអ្នកជំនិតៗជាច្រើនទៀតធ្វើការឃោសនាអូសទាញឲ្យចូលចលនាតស៊ូរបស់ខ្លួន ។ រូបលោកផ្ទាល់ក៏បានចូលរួមចលនានេះដែរគឺក្នុងឆ្នាំ១៩៧០ នៅភូមិតាវែង ឃុំតាវែង ស្រុកតាវែង ខេត្តរតនគិរី ។ នៅក្នុងពេលនោះតំបន់តាវែងទាំងមូលត្រូវបានកាត់ផ្តាច់ពីការគ្រប់គ្រងពីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ខ្ញុំបានទទួលបន្ទុកប្រមូលទិន្នន័យទាក់ទងនឹងសោកនាដកម្មដ៏ខ្លោចផ្សានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានស្វែងរកជួបជនរងគ្រោះដែលធ្លាប់ត្រូវខ្មែរក្រហមចាប់ដាក់គុកនិងធ្វើទារុណកម្ម ។ ថ្ងៃនោះ គឺជាថ្ងៃទី៦នៃការស្រាវជ្រាវនៅក្នុងខេត្តនេះ ហើយក៏ជាថ្ងៃចុងក្រោយនៃគម្រោង សម្ភាសន៍នៅស្រុកមួយក្នុងចំណោមស្រុកនានាដែលជាគោលដៅរបស់ក្រុមស្រាវជ្រាវ ពោលគឺស្រុកតាវែង ។ ខ្ញុំបានទៅដល់ទីស្នាក់ការស្រុកតាវែងនៅម៉ោង១០និង២០នាទីព្រឹក ។ នៅទីនោះ ខ្ញុំបានជួបជាមួយលោកអភិបាលស្រុក នុង ខាំសឿន អភិបាលរងទី៣ លោក យ៉េង ខួង ព្រមទាំងមន្ត្រីការិយាល័យមួយចំនួនទៀត ។ គោលបំណងចម្បងរបស់ខ្ញុំគឺធ្វើសម្ភាសន៍ ជាមួយជនជាតិភាគតិចដែលធ្លាប់បានធ្វើចលនាតស៊ូប្រឆាំងនឹងរដ្ឋាភិបាលសារធារណរដ្ឋខ្មែរ ប៉ុន្តែក្រោយមកបានបកវាយប្រឆាំងនឹងពួកខ្មែរក្រហម ។ គោលបំណងមួយផ្សេងទៀតគឺស្វែងរកទីតាំងពិឃាតរបស់ខ្មែរក្រហម ។ ខ្ញុំបានទទួលពត៌មានមួយដែលទាក់ទងនឹងជំរំរបស់វៀតណាមដែលសាងសង់ឡើងប្រហែល៣០ឆ្នាំកន្លងមកហើយ ។

នៅតាមបណ្តោយព្រំប្រទល់ខេត្តរតនគិរីដែលមានចម្ងាយ១០គីឡូម៉ែត្រខាងកើតព្រំប្រទល់ប្រទេសវៀតណាមគឺជាជំរំយោធាដ៏ធំមួយដែលជាចំណុចក្តៅនៃការទម្លាក់គ្រាប់បែក ។ តំបន់នោះស្ថិតនៅក្នុងស្រុកតាវែង ខេត្តរតនគិរី ។ លោក យ៉េង ខួង អាយុ៤៨ឆ្នាំ ជនជាតិព្រៅ ដែលបច្ចុប្បន្នជាទាហានស្រុកតាវែង ខេត្តរតនគិរី បានឲ្យដឹងថា ជំរំនេះមានឈ្មោះថា ជំរំវៀន តាំ តឿន«ជំរំ ៨៤» ដែលជាទីតាំងអគ្គសេនាធិការ និងមន្ទីរពេទ្យយោធារបស់វៀតណាម ។ ជំរំនេះមានផ្ទៃដីស្មើនឹងផ្ទៃដី ទីរួមខេត្តបានលុងនៃខេត្តរតនគិរី ។ លោក យ៉េង ខួង មានដើមកំណើតនៅភូមិបាងកើត ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ។ នៅពេលលោកពូមាន អាយុ១៣ឆ្នាំ លោកពូព្រមទាំងគ្រួសារត្រូវបង្ខំចិត្តរត់ចូលព្រៃដែលនៅក្បែរជំរំ៨៤ ។ កាលនោះលោកពូនៅក្មេងអាចដើរដោយសេរីមិនមានអ្នកណាហាមឃាត់ឡើយ ។ តែចំពោះមនុស្សវ័យចំណាស់ដែលអាច

ដឹងខុសត្រូវគឺមិនឲ្យដើរផ្តេសផ្តាសទេ ។ ប៉ុន្តែទោះជាមានបម្រាមយ៉ាងតឹងតែងយ៉ាងណាក៏ដោយ ក៏មានពេលខ្លះអ្នកស្រុកចាស់ៗដែលភៀសខ្លួនចូលទៅរស់នៅក្នុងព្រៃនោះបានឃើញកងទ័ពវៀតណាមបណ្តើរទាហានអាមេរិកាំងដែលជាប់ខ្នោះ ។

នៅឆ្នាំ១៩៩៨ មានក្រុមស្វែងរកជនជាតិអាមេរិកកាំងដែលបាត់ខ្លួនក្នុងសង្គ្រាមឥណ្ឌូចិនមួយក្រុមបានទៅធ្វើការស្រាវជ្រាវស្វែងរកអដ្ឋិធាតុទាហានដែលបាត់ខ្លួនក្នុងតំបន់នោះ ។ អ្នកដែលធ្លាប់បានឃើញកងទ័ពវៀតណាមបណ្តើរទាហានអាមេរិកក្នុងអំឡុងពេលដែលខ្លួនកំពុងរស់នៅក្នុងព្រៃនៅក្បែរដីរំត្រូវបានជួលឲ្យទៅរកទីតាំង ។ ប៉ុន្តែការងារនេះមិនបានសម្រេចឡើយដោយគាត់ភ្លេចផ្លូវទៅកាន់ទីតាំង ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ លោកពូ យ៉េង ខួង រួមដំណើរជាមួយអ្នកស្រុកចំនួន៦នាក់ផ្សេងទៀតបានធ្វើការផ្សងព្រេងស្វែងរកកំណប់អដ្ឋិធាតុដែលកប់កាលពីជាង៣០ឆ្នាំមុន ។ ជាលទ្ធផលក្រុមផ្សងព្រេងមួយនេះក៏ទទួលបានជោគជ័យបន្ទាប់ពីធ្វើដំណើរអស់រយៈពេល៣ថ្ងៃ ។ ដីរ៉ា៨៤ត្រូវបានរកឃើញដែលមានទីតាំងស្ថិតនៅចំណុចទី៤៨អន្សា ទិសខាងកើតប្រទេសវៀតណាម ។ នៅថ្ងៃទី១៧ដែលជាថ្ងៃដំបូង ក្រុមផ្សងព្រេងបានធ្វើដំណើរដល់អូរគ្រាង ក្រោយពីធ្វើដំណើរតាមកាណូតរួចមក ។ នៅថ្ងៃទី១៨ ក្រុមនេះបានទៅដល់រហាត់ទឹកដោយថ្មើរជើង ។ នៅថ្ងៃទី១៩ ក៏ធ្វើដំណើរដល់ចំណុច៤៨នៅក្នុងដែនទី ។ ពេលទៅដល់ចំណុចដីរ៉ា៨៤ លោក យ៉េង ខួង ដែលជាអ្នកផ្តើមគំនិតរុករកបានឃើញផ្នូរសាកសពដែលមានដាក់លេខរៀងពីលេខ១ដល់លេខ១០០ ។ ក្រៅពីនោះគឺជាផ្នូរដែលមានប្រវែងវែងជាងផ្នូរដែលដាក់លេខរៀង ។ លោកពូបានបញ្ជាក់ថាផ្នូរកប់ខ្មោចមានចំនួនច្រើនរាប់មិនអស់ ប៉ុន្តែគាត់មានការសង្ស័យទៅលើផ្នូរមួយចំនួនដែលមានប្រវែងវែងជាងផ្នូរធម្មតា ក្រៅពីផ្នូរខ្មោចក៏មានលេណដ្ឋានយោធា កំប៉ុង ថ្នាំពេទ្យដែលមានអក្សរចិន ចង្ក្រានដាំបាយ ក្រណាត់កៅស៊ូ កាំភ្លើងអាទៀរមួយដើមដែលប្រើការលែងកើត និងអន្ទាក់ដាក់សត្វ១ ។

គួរបញ្ជាក់ដែរថា ការសង្ស័យរបស់លោក យ៉េង ខួង នៅពេលនេះអាចស្របជាមួយទិដ្ឋភាពដែលអ្នកភូមិមួយចំនួនបានឃើញទាហានវៀតណាមបណ្តើរជនជាតិអាមេរិកកាំងក្នុងអំឡុងពេលសង្គ្រាម ។ ការពិតទាំងនេះអាចធ្វើឲ្យការស្វែងរកទាហានអាមេរិកកាំងនៅកម្ពុជាជាពិសេសក្នុងខេត្តរតនគិរីទទួលបានជោគជ័យក្នុងករណីដែលមានការប្រឹងប្រែងពុះពារ ការខិតខំខាងថវិកា សម្ភារបច្ចេកទេស អ្នកជំនាញការខាងពិនិត្យអដ្ឋិធាតុនិងការសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងរដ្ឋអំណាចមូលដ្ឋាន និងប្រជាជនក្នុងស្រុកតាវែង ។

ខ្ញុំមានសុទិដ្ឋិនិយមថា ដីរ៉ាមួយដែលត្រូវបានលាក់បាំងជាង៣០ឆ្នាំមកហើយនោះ នឹងលាតត្រដាងការពិតនិងរឿងរ៉ាវផ្សេងៗ ទាក់ទងដល់ការបាត់ខ្លួននៃទាហានអាមេរិកាំងនៅកម្ពុជា ។ ក្រុមដែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាព្រមទាំងលោក យ៉េង ខួង ដែលបានទៅរកឃើញនូវទីតាំងដីរ៉ារបស់វៀតណាមនិងជាកន្លែងលាក់ខ្លួនរបស់ជនជាតិភាគតិចដែលព្យាយាមភៀសខ្លួនចេញពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនោះមានការអន្ទះសានិងចង់ឲ្យមានការខិតខំប្រឹងប្រែងមួយដើម្បីស្រាវជ្រាវរកអដ្ឋិធាតុក្នុងគោលបំណងបន្ធូរការឈឺចាប់របស់ក្រុមគ្រួសារនិងញាតិសន្តានរបស់ទាហានទាំងនោះដែលនៅតែមានអារម្មណ៍វិលវល់គ្មានភាពប្រាកដប្រជាមិនដឹងច្បាស់ថាតើប្តីនិងកូនប្រុសរបស់ខ្លួនស្លាប់ឬក៏នៅរស់រានមានជីវិតមកដល់បច្ចុប្បន្ននេះ ។

**សូ ប៊ុនស៊ូ**

## ពាក្យស្លោកខ្មែរក្រហម

- **កម្ទាត់ជាច់ខាតភ្នាក់ងារសេ.អ៊ី.អា ឱ្យអស់ពីអង្គភាព និងពីទឹកដីកម្ពុជាជារៀងរហូត។**
- **កម្ទាត់ជាច់ខាត ខ្មាំងរណបគេ ខ្ញុំគេ សារភាពនិយម ចុះចាញ់និយម។**
- **ប្រយុទ្ធជាច់ខាត ការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដី កម្ពុជាប្រជាធិបតេយ្យ។**
- **ឈរជាច់ខាត និងគ្រប់កាលៈទេសៈ លើជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនាខ្លួន ដោយខ្លួនឯង។**

( ដកស្រង់ចេញពីសៀវភៅលេខ ០៧៦ កណហ)

# ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ
# ផ្ញើជូនចំពោះ
# ក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

កម្ពុជាប្រជាធិបតេយ្យមានបំណងចង់រស់នៅក្នុងសុខសន្តិភាព និងថែរក្សាបាននូវចំណងមិត្តភាពជាមួយនឹងប្រទេសជិតខាងជាបងប្អូន ដោយឈរលើគោលការណ៍ស្មើភាពនិងគោរពគ្នាទៅវិញទៅមក ។ ដើម្បីបង្កលក្ខណៈងាយស្រួលឈានទៅដល់ដំណោះស្រាយបញ្ហាឲ្យបានឆាប់រហ័សស្តីអំពីការរំលោភបំពាននិងការឈ្លានពានរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមមកលើប្រទេសកម្ពុជា រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យផ្ញើសំបុត្រនេះទៅកាន់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម សុំឲ្យចាត់វិធានការជាបន្ទាន់ដូចខាងក្រោមៈ

១) បញ្ឈប់ការវាយប្រហារឈ្លានពាន លុកលុយ និងកាន់កាប់ទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ ។ បញ្ឈប់រាល់សកម្មភាពបង្កការរំលោភបំពានមកលើដែនគោក ដែនទឹក និងដែនអាកាសនៃកម្ពុជាប្រជាធិបតេយ្យ ។ បញ្ឈប់ការបាញ់រះ បាញ់ផ្លោងនិងទម្លាក់គ្រាប់បែកមកលើដែនដី និងដែនទឹកនៃកម្ពុជាប្រជា-ធិបតេយ្យ ។

២) បញ្ឈប់ការបញ្ជូនគិញស៊ើបការណ៍សម្ងាត់នៅក្នុងដែនគោក ដែនទឹកនិងលើកោះនៃកម្ពុជាប្រជាធិបតេយ្យ ។ បញ្ឈប់ សកម្មភាពវិទ្ធង្សនានិងការជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់កម្ពុជាប្រជាធិបតេយ្យ ។ បញ្ឈប់ការប៉ុនប៉ងធ្វើរដ្ឋប្រហារឬក៏សកម្មភាពផ្សេងៗក្នុងគោលបំណងផ្តួលរំលំរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ។

៣) បោះបង់ចោលឲ្យអស់នូវយុទ្ធសាស្ត្រចង់ដាក់កម្ពុជាប្រជាធិបតេយ្យនៅក្រោម«សហព័ន្ធឥណ្ឌូចិន»តាមគោលការណ៍«បក្សមួយ ប្រទេសមួយ និងប្រជាជាតិមួយ» «នៅឥណ្ឌូចិន» ជារបស់វៀតណាម ។

៤) គោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ ។ គោរពសិទ្ធិរបស់ប្រជាជនកម្ពុជាដើម្បីឲ្យប្រជាជនកម្ពុជាធ្វើការសម្រេចចិត្តលើវាសនាប្រទេសខ្លួនដោយខ្លួនឯង ។ ប្រសិនបើសាធារណរដ្ឋសង្គមនិយមវៀតណាមអនុវត្តជាសកម្មភាពជាក់ស្តែងតាមកំណត់សម្គាល់ទាំងបួនចំណុចនេះក្នុងរយៈពេលប្រាំពីរខែចាប់ពីពេលនេះរហូតដល់ចុងឆ្នាំ១៩៧៨ ដោយបញ្ឈប់រាល់សកម្មភាពរំលោភបំពានឬការឈ្លានពានដែលជាការទន្ទ្រានមកលើឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យនោះនឹងនាំឲ្យមានបរិយាកាសមិត្តភាពនិងការទុកចិត្តគ្នាមិនខាន ។ នៅក្នុងបរិយាកាសបែបនេះ ភាគីកម្ពុជានិងភាគីវៀតណាមអាចជួបពិភាក្សាគ្នាដោយស្មោះស្ម័គ្រដើម្បីរកដំណោះស្រាយត្រឹមត្រូវច្បាស់លាស់ចំពោះបញ្ហានេះ ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានគំនិតនិងជឿជាក់ថានេះគឺជាដំណោះស្រាយតែមួយគត់ដែលស្របតាមផលប្រយោជន៍នៃប្រជាជនកម្ពុជានិងប្រជាជនវៀតណាមអាចជួយជំរុញចំណងមិត្តភាពរវាងប្រជាជនវៀតណាមនិងប្រជាជនកម្ពុជា ហើយធ្វើឲ្យវៀតណាមនិងកម្ពុជារស់នៅជាប្រទេសជិតខាងនៅក្នុងសុខសន្តិភាព និងសេចក្តីសម្បូររុងរឿង ។ នេះគឺជាដំណោះស្រាយតែមួយគត់ដែលអនុលោមតាមគោលការណ៍មិនចូលបក្សសម្ព័ន្ធនិងបម្រើឲ្យផលប្រយោជន៍នៃប្រជាជននៅលើពិភពលោកនិងអាចរួមចំណែកបង្កើតសន្តិភាពនៅក្នុងតំបន់ ។

ប្រសិនបើសាធារណរដ្ឋសង្គមនិយមវៀតណាមនៅតែបន្តសកម្មភាពជំរុញ រំលោភបំពាន ឈ្លានពាន និងកាន់កាប់ទឹកដីនៃកម្ពុជាប្រជាធិបតេយ្យទៀតនោះ អ្វីដែលហៅថាការចរចាដែលស្នើឡើងដោយវៀតណាមគឺគ្មានន័យអ្វីទាំងអស់ ប៉ុន្តែជាការបន្តការបោកប្រាស់ ហើយប្រជាជនដែលស្រលាញ់ឯករាជ្យភាព និងយុត្តិធម៌នៅក្នុងពិភពលោកនឹងកាន់តែស្អប់ខ្ពើមមុខមាត់ឈ្លានពានពង្រីកទឹកដីមកលើកម្ពុជាប្រជាធិបតេយ្យនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**(ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨)**

# តួនាទីគួរឱ្យសង្ស័យរបស់ស្ថានទូតចិន នៅទីក្រុងហាណូយ ១៩៧៨

***«ដំណើររឿងខាងក្រោមនេះមាននៅលើទំព័រកាសែតប្រចាំថ្ងៃ ហាណូយ ឈ្មោះ ញ៉ិន យ៉ិន ណាហាន ឌាន ចេញផ្សាយពីថ្ងៃ ១៤ ខែកក្កដា ដល់ថ្ងៃ២២ ខែកក្កដា ឆ្នាំ១៩៧៨ ។ ដំណើររឿងនេះគឺជាភ័ស្តុតាងជាក់ស្តែងបង្ហាញអំពីតួនាទីរបស់ទីក្រុងប៉េកាំងតាមរយៈស្ថានទូតចិនប្រចាំនៅទីក្រុងហាណូយ នៅក្នុងយុទ្ធនាការរបស់ខ្លួនហៅថា «អាណិកជនចិនដែលរងគ្រោះ» និងនិយាយអំពីសកម្មភាពរបស់ភ្នាក់ងារប៉េកាំងមួយចំនួនដូចជា លី ផៀបភូ ជិនហ៊ីត និងអ្នកដទៃទៀតដែលយើងបានជួបរួចមកហើយនៅក្នុងអត្ថបទមានចំណងជើងថា«គេបានបោកជនជាតិហ៊ឺរឲ្យចាកចេញពីប្រទេសវៀតណាម» ដែលចេញផ្សាយនៅក្នុងវៀតណាមគួរីយេ៉ លេខ១១៤ ខែកក្កដា ឆ្នាំ១៩៧៨» ។***

នៅពេលដែលសារពត៌មាន ញ៉ិនយ៉ិន បោះពុម្ពផ្សាយនូវអត្ថបទមួយមានចំណងជើងថា «ក្រុមប្រតិបត្តិមួយក្រុមដែលបានបង្ខិតបង្ខំឲ្យប្រជាជនចិនចាកចេញពីប្រទេសវៀតណាម» ភាគីចិនបានតវ៉ាដោយទាត់ចោលនូវការអះអាងបែបនេះ ហើយថានេះជាការបង្ខូចកេរ្តិ៍ឈ្មោះពិតប្រាកដ ។ គួររំឭកដែរថា ក្រោយពីមានយុទ្ធនាការ "អាណិកជនចិនដែលរងគ្រោះ" មក ភាគីចិនបានអះអាងថា គឺវៀតណាមខ្លួនឯងហ្នឹងដែលជាអ្នកបញ្ជាឲ្យភ្នាក់ងាររបស់ខ្លួនផ្សព្វផ្សាយដំណឹងខុសពីការពិតដើម្បីបំភិតបំភ័យ និងបណ្តេញប្រជាជនចិនឲ្យទៅកាន់ប្រទេសចិន ។ សារពត៌មាន ញ៉ិនយ៉ិន មានផ្សាយពត៌មានដូចខាងក្រោមនេះដែលបង្ហាញផ្នែកខ្លះនៃការពិតស្តីអំពីតួនាទីគួរឲ្យសង្ស័យរបស់ទីក្រុងប៉េកាំងនៅក្នុងរឿងនេះ ។ ការតវ៉ាប្រឆាំងរបស់ប្រទេសចិនដែលជាក់ស្តែងជាការប៉ុនប៉ងដែលមានលក្ខណៈឆ្គាំឆ្គងក្នុងការទុកមុខមាត់ គឺត្រូវបានបដិសេធដោយភាគីវៀតណាម ។ (ចំណងជើងនិងចំណងជើងរង ការិយាល័យនិពន្ធជាអ្នកដាក់) ។

លី ផៀបភូ កើតនៅទីក្រុងហាណូយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៣៩ ក្នុងគ្រួសារដែលមានដើមកំណើត «ក័ងទុង» ។ លី ផៀបភូ រស់នៅវៀតណាមតាំងពីតូចមក ហើយបានចូលរៀននៅសាលាបឋមសិក្សានិងមធ្យមសិក្សា បន្ទាប់មកទៅរៀននៅសាលាបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ជនជាតិចិននៅក្នុងទីក្រុងហាណូយ ។ នៅទសវត្សរ៍ឆ្នាំ១៩៦០ ផៀបភូ បានក្លាយ

រូបថតមិត្តភាពរវាងខ្មែរក្រហមនិងជនជាតិចិន នៅសៀមរាបអង្គរ



ទៅជានាយកសាលាបឋមសិក្សានៅក្នុងក្រុងហាយឌឿង ។ ចាប់ពីឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៦ ង៉ៀបភូ បង្រៀនសិស្សនៅសាលាបឋមសិក្សា គិន ហាវ នៅវិថី ឡាន អុង ស្រុក ហ៊ិន គៀម ទីក្រុងហាណូយ ។ លី ង៉ៀបភូ បាននិយាយដូចតទៅនេះ÷

## ១៩៧៥ៈ ការបង្កើតបណ្តាញ

ពេលមានមហាបដិវត្តន៍វប្បធម៌នៅប្រទេសចិន ស្ថានទូតចិនប្រចាំនៅទីក្រុងហាណូយបានរៀបចំឲ្យខ្ញុំយកគ្រួសារត្រឡប់មករស់នៅប្រទេសចិនវិញ ។ ពេលនោះខ្ញុំត្រូវបានយកដាក់នៅសណ្ឋាគារកានតុង ហើយមានក្តីអំណរចំពោះគុណសម្បត្តិនិងអភ័យឯកសិទ្ធិផ្សេងៗដែលត្រូវបានផ្តល់ឲ្យចំពោះអ្នកដែលមានបេសកកម្មពិសេសនៅឯបរទេស ។ គណៈកម្មាធិការមជ្ឈិមនៃប្រទេសចិនដែលមានបេសកកម្មនៅបរទេស បានទទួលខ្ញុំព្រមទាំងណែនាំឲ្យចុះធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ។ ក្រោមបញ្ជាមកពីទីក្រុងប៉េកាំង ខ្ញុំនិងគ្រួសារបានដើរតាមជនភៀសខ្លួននៅទីក្រុងភ្នំពេញចូលមកក្នុងទឹកដីវៀតណាមក្រោយពីមានការផ្លាស់ប្តូរអំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ។

ខ្ញុំមកដល់វៀតណាមនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៥ ហើយចំណាយពេលពីរថ្ងៃនៅក្នុងក្រុងហុងហ្គី រួចក៏ចូលមកទីក្រុងហូជីមិញ ។ នៅទីនោះខ្ញុំត្រូវបានឲ្យសម្រាកនៅផ្ទះលេខ១៨៦-បេ វិថី លឿង ញ៉ូហុក ។

ក្រោយពីខ្ញុំមានកន្លែងនៅស្រួលបួលហើយ ស្ថានទូតចិនបានបញ្ជូនឈ្មោះ ជិន ជឿងហ្វាង មកទាក់ទងខ្ញុំស្តីអំពីព្រឹត្តិការណ៍ ខែមីនា ឬមេសា ឆ្នាំ១៩៧៦ ។ ជិន ជឿងហ្វាង បាននាំមកនូវសេចក្តីណែនាំមួយចំនួនពីស្ថានទូតចិនមកឲ្យខ្ញុំឲ្យរៀបចំឲ្យបានឆាប់រហ័សបំផុត នូវបណ្តាញសកម្មជននៅក្នុងចំណោមជនជាតិចិននៅក្នុងតំបន់សៃហ្គនចឹឡឺន ដោយផ្សព្វផ្សាយនយោបាយរបស់ចិនទៅកាន់ជនជាតិចិនរស់នៅក្រៅប្រទេស និងជំរុញឲ្យប្រជាជនចិនរួមជាកម្លាំងកាយនិងសម្ភារដើម្បីកសាងប្រទេសចិន ។ ជិន បានប្រាប់ខ្ញុំថា «នេះជាឱកាសល្អបំផុតសម្រាប់ឯងក្នុងការធ្វើឲ្យលេចឈ្មោះ» ។ ជិន បន្ថែមថា «ប្រសិនបើឯងធ្វើអ្វីដែលគេចង់ឲ្យឯងធ្វើនោះ មាតុភូមិនឹងមិនបំភ្លេចឯងឡើយ! លី» ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៦ ជិន ជឿនហ្វាង, វឿង ហ័ងធៀន និងខ្ញុំ បានជួបពិភាក្សាគ្នាដើម្បីសិក្សាអំពីសេចក្តីណែនាំពីស្ថានទូតចិនស្តីអំពីការធ្វើឲ្យជនជាតិចិនចូលរួមជាកម្លាំងនិងសម្ភារដើម្បីកសាងប្រទេសចិន ។ បន្តបន្ទាប់មកទៀតយើងបានពិភាក្សាជាលម្អិតដើម្បីឈានទៅសម្រេចយកជាផែនការពិតប្រាកដ ។

នៅខែមិថុនា ឆ្នាំ១៩៧៦ វឿង ញ ដែលរស់នៅជីឡូត៍ តំបន់យ៉េនឡាង បានមកទីក្រុងហូជីមិញដោយយកលេសសុំច្បាប់មកលេងគ្រួសារនៅភាគខាងត្បូង ដោយនាំមកនូវការណែនាំថ្មីៗថែមទៀតពីស្ថានទូតចិននិងការចាត់តាំងជាលម្អិតសម្រាប់ក្រុមយើង ។ វឿង ញ និយាយថា សមាជិកក្រុមមួយចំនួនទៀត ដែលចុះធ្វើការនៅភាគខាងជើងនឹងជួយឃោសនានៅភាគខាងត្បូង ។ ក្រុមខាងជើងមានសមាជិកដូចជា ជិន ហ៊ីត, ចៀវ ជៀម ហ័រ, ប្រពន្ធរបស់ អូន ធីញណាម, លី ដោឡេ (ប្រពន្ធរបស់ធីញណាម) និងម្នាក់ទៀតជាប្អូនស្រីបង្កើតរបស់ខ្ញុំ ។ ក្រុមនេះទទួលខុសត្រូវរៀបចំផែនការឆ្លងកាត់ព្រំដែនដើម្បីប្រមូលឯកសារពីប្រទេសចិន ។ ក្រុមមួយទៀតមានឈ្មោះ វឿង ញហ្គាន់, ហ្វា ង៉ៀហ័ង, ឌឿងថាញ់ និង លាវ ខាកហ៊ាន ទទួលខុសត្រូវទទួលឯកសារ និងសារពត៌មានពីស្ថានទូតចិនប្រចាំនៅទីក្រុងហាណូយ រួចបញ្ជូនទៅតាមអាសយដ្ឋានផ្សេងៗទៅឲ្យវៀតណាមខាងត្បូង ។ ក្រុមនៅហាណូយមានឈ្មោះ ជិន ហ៊ីត និងប្រពន្ធ លី ង៉ៀបជី បងប្រុសរបស់ខ្ញុំរស់នៅផ្ទះលេខ ១០១ វិថីហាង ហៃ្គ ហ័ង, ឌឿងថាញ់ និង ឡេ ញូកន ។ លូ ថកនិញ ធ្វើការនៅ ហៃហុង ។ អុង ធិញ និង លី ង៉ៀប ថាញ់ នៅហាយហូង ។ អុង ធិញណាម និង វឿង ឈាន់ធៀន នៅឈាងនិញ ហើយអ្នកមួយចំនួនធំទៀតរស់នៅដោយក្លែងឈ្មោះនិងអាសយដ្ឋាន ។

គ្រប់សៀវភៅ សារពត៌មាន និងឯកសារផ្សេងៗទៀត រួមទាំងផែនទីនៃប្រទេសចិនយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលបោះពុម្ពនៅក្នុងទីក្រុងប៉េកាំងដែលត្រូវបានផ្ញើដោយផ្ទាល់ពីទីក្រុងប៉េកាំង ឬតាមរយៈស្ថានទូតចិនប្រចាំនៅទីក្រុងប៉េកាំង ត្រូវបានបញ្ជូនមកទីក្រុងហូជីមិញ ។

**(នៅមានត)**

**(តពីលេខមុន)** នៅចុងខែមេសា ឆ្នាំ ១៩៧៧ ស៊ាត ឆែ ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ បន្ទាប់ពី ហ៊ូ នឹម ។ ស៊ាត ឆែ បានដាក់ជំនួស ចាន់ ចក្រី ឲ្យធ្វើជាអគ្គសេនាធិការនៅក្នុងឆ្នាំ ១៩៧៦ ក្រោយពីបានធ្វើជាលេខាតំបន់២២ នៅភូមិភាគបូព៌ា ។ នៅទីនោះដោយសារ ឆែ ត្រូវបានស្គាល់ជាទូទៅថាជាមនុស្សរបស់ ប៉ុល ពត គាត់ប្រហែលជាត្រូវបានសង្ស័យថាជាអ្នកតាមដាន សោ ភឹម និងកម្មាភិបាលដទៃទៀត ។ ឆែ សិក្សាថ្នាក់ក្រោម សាឡុត ស នៅសាលាចំរើនវិជ្ជានៅទសវត្សរ៍ឆ្នាំ ១៩៥០ ។ ស៊ាត ឆែ ត្រូវបាននាំចូលក្នុងចលនាបក្សកុម្មុយនិស្តដោយ សាឡុត ស និងប្រពន្ធឈ្មោះ ខៀវ ប៉ុណ្ណារី ។ ឆែ បានអមដំណើរ សាឡុត ស ទៅកាន់មន្ទីរ១០០ កាលពីឆ្នាំ១៩៦៣ហើយជួយមើលថែជំងឺគ្រុនចាញ់និងជំងឺតម្កាត់ផ្សេងៗទៀតឲ្យ សាឡុត ស ។ ប៉ុន្តែនៅត្រឹមឆ្នាំ១៩៧៧ ប្រហែលដោយសារ ឆែ មានការពាក់ព័ន្ធជាមួយនឹងខាងភូមិភាគបូព៌ា និងអ្នកចេះដឹងកាលពីជំនាន់គាត់ដែលធ្វើការនៅក្នុងជួរបក្សដែលត្រូវបានបោសសម្អាតរួចហើយបានជាកេរ្តិ៍ឈ្មោះរបស់ ឆែ សាបសូន្យទៅវិញ ។ ដូចសម្តីរបស់ ឆែ នៅក្នុងចម្លើយសារភាពរបស់គាត់ដែរ ថាមើលទៅប្រហែលជាសមាជិកបក្សមានការច្រណែនឈ្នានីសនឹងមុខតំណែងខ្ពស់របស់គាត់បានជានាំឲ្យមានបញ្ហានេះ ។ ការចាប់ខ្លួនរបស់ ឆែ ជាការបញ្ជាក់ច្បាស់ថា ភក្តីភាពជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជាមិនអាចក្លាយជាផ្លូវមានមុខពីរដាច់ខាត ។ ហើយកាន់តែច្បាស់ជាងនេះទៀតដោយសារតែ ឆែ ត្រូវបានរំពឹងគិតថា បានក្បត់នឹងការទុកចិត្តរបស់បក្ស ឬប្រហែលដូចដែលគាត់បានអះអាងស្រាប់ថា គាត់គ្មានកំហុសនិងនៅតែសង្ឃឹមថានឹងទទួលបានការយោគយល់អត់ឱនឲ្យការសួរចម្លើយទៅលើរូប ឆែ កាន់តែមានលក្ខណៈធ្ងន់ធ្ងរ ។ ជាងនេះទៅទៀត នៅមុនពេលការចាប់ខ្លួនបន្តិចតែប៉ុណ្ណោះ ឆែ បានធ្វើការយ៉ាងជិតដិតជាមួយនឹង សុន សេន ។ ដើម្បីចៀសវាងការនិយាយពាក់ព័ន្ធដល់ខ្លួនអតីតគ្រូរបស់ ឆែ ប្រហែលជាមិនចង់ជំរុញឲ្យមានការសួរចម្លើយទេ ។

មិនខុសពី កែវ មាស ទេ ស៊ាត ឆែ បានព្យាយាមផ្ញើចំណារកំណត់សម្គាល់របស់ខ្លួនពីមន្ទីរស-២១ទៅកាន់ «បងៗថ្នាក់លើ» ។ ការពិតដែលថាឯកសារនេះនៅសល់នៅឡើយ បញ្ជាក់ថាសំបុត្រទាំងនេះមិនដែលត្រូវបានយកចេញពីគុកឡើយ ។ ប៉ុន្តែឋានៈខ្ពស់របស់ ឆែ ប្រហែលជាធ្វើឲ្យ ឌុច និងអ្នកធ្វើការជាមួយមិនហ៊ានកម្ទេចឯកសារនេះចោល ។ឯកសារទាំងនេះមានសារសំខាន់ក្នុងការទុកទាំងដុលរបៀបនេះ ។




**សម្លេងពីមន្ទីរ ស-២១**
**ភាគទី៣: ការជ្រើសរើសសត្រូវ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

នៅក្នុងសំបុត្រមួយក្នុងចំណោមសំបុត្រទាំងអស់ដែលសរសេរនៅមុនពេលចាប់ខ្លួន ឆែ បានបដិសេធចំពោះការចោទប្រកាន់មកលើខ្លួន ។ បីថ្ងៃក្រោយមក ឆែ បានសរសេរទៅកាន់ «បង៨៩» សុន សេន ថា «បងអើយខ្ញុំមានការឈឺចាប់ខ្លាំងណាស់! នៅក្នុងមួយជីវិតខ្ញុំ ខ្ញុំមិនដែលជួបប្រទះនូវការឈឺចាប់របៀបនេះឡើយ! នៅពេលដែលកូនស្រីរបស់ខ្ញុំជាប់គុករបស់ខ្មាំង (លន់ ណុល) ខ្ញុំគិតថាវាជាការធម្មតាទេចំពោះការតស៊ូរវាងខ្មាំងនឹងយើង! ប៉ុន្តែឥឡូវដល់ពេលខ្ញុំត្រូវជាប់ឃុំឃាំងនៅក្នុងគុកបដិវត្តន៍ ខ្ញុំមិនយល់ទេ ។ វាច្របូលច្របល់ពិបាកយល់ណាស់ ។ ប៉ុន្តែនៅចុងបញ្ចប់ខ្ញុំអាចមើលឃើញច្បាស់ថា គឺពួកសេ.អ៊ី.អា ពួកវៀតណាមលេបទឹកដីនិងពួកធ្វើការជាមួយកា.ហ្សេ.បេ ដែលនាំឲ្យខ្ញុំជាប់គុកបដិវត្តន៍បែបនេះ» ។

ស៊ាត ឆែ ប្រាប់ សុន សេន ថា «ពួកក្បត់បីនាក់» បានបង្ខូច

កេរ្តិ៍ឈ្មោះខ្លួន ។ ឆែ បានបញ្ជាក់ថាខ្លួនបាន «រៀបរាប់រឿងរ៉ាវលម្អិតជូនអង្គការអស់ហើយតាមរយៈមន្ទីរស-២១» ។ ដោយមានការទាក់ទងដោយផ្ទាល់ជាមួយនឹង «បងៗថ្នាក់លើ» ឆែ សង្ឃឹមថានឹងអាចសម្រួលសុំរួចខ្លួនបាន ។ ប៉ុន្តែបន្ទាប់មកនៅក្នុងកំណត់សម្គាល់មួយ ឆែ សរសេរថា «ខ្ញុំដឹងអំពីកន្លែងនេះហើយមិនប្រាប់ក៏ដឹងដែរ គឺពេលចូលមកដល់មន្ទីរស-២១ ហើយមានមនុស្សភាគតិចណាស់ដែលអាចរួចខ្លួន ពោលគឺមានតែចូលគ្មានវិលវិញដាច់ខាត ។ បងអើយ! បើសិនជាអ៊ីចឹងមែន នោះខ្ញុំគ្មានផ្លូវទេ» ។

ការអង្វរលន់តួរបស់ ឆែ សុំក្តីមេត្តា ហាក់ដូចជាការបញ្ជាក់ច្បាស់អំពីការពិតនឹងអាចកើតឡើងចំពោះខ្លួនដូចដែលយើងឃើញស្រាប់តាមរយៈការឆ្លើយតបវិញប្រកបដោយលក្ខណៈឃោរឃៅរបស់ ឌុច ។ ស៊ាត ឆែ មានការភ័យខ្លាចខ្លាំងណាស់ ។ គាត់ដឹងខ្លួនថាគាត់នឹងត្រូវរងនូវទារុណកម្មជាក់ជាមិនខានឡើយ ។ ឆែ បានសរសេរថា «នៅក្នុងមន្ទីរស-២១ មួយរយៈមកអ្នកធ្វើការនៅក្នុងគុកមិនទាន់បានប្រើមធ្យោបាយអ្វីមកលើរូបខ្ញុំទេ ។ ខ្ញុំគ្រាន់តែជាប់ខ្នោះតែប៉ុណ្ណោះ ។ អ្នកធ្វើការនៅទីនេះយកចិត្តទុកដាក់នឹងខ្ញុំណាស់ ។ តាមសម្តីរបស់អ្នកទទួលខុសត្រូវខ្ញុំប្រហែល៥ទៅ៧ថ្ងៃខាងមុខ ខ្ញុំនឹងចូលដល់ដំណាក់កាលទីពីរ ពោលគឺដំណាក់កាលរងទារុណកម្ម ។ បងជាទីស្នេហា! ខ្ញុំដឹងខ្លួនថាពេលនេះខ្ញុំចប់ហើយ ។ ទោះបីជាសមមិត្តយកខ្ញុំទៅវ៉ៃដំប្រំផាក់វាយបំបាក់ជើងដៃក៏នៅតែមិនមានចម្លើយលើសពីនេះទៀតដែរ ។ មានតែការបង្ហូរឈាមនិងលាមក ឬក៏ការស្លាប់បាត់បង់ជីវិតតែប៉ុណ្ណោះ ។ សូមបងមេត្តាជួយសង្គ្រោះខ្ញុំឲ្យទាន់ពេលវេលា ។ ទោះបីជាខ្ញុំស្លាប់ ក៏ខ្ញុំនៅតែស្មោះស្ម័គ្រចំពោះបក្សលុះដល់ចុងបញ្ចប់ ។ បើសិនជាបងមិនជួយខ្ញុំទេ ប្អូននឹងប្រាកដជាត្រូវស្លាប់មិនខាន! ហើយខ្ញុំនឹងស្លាប់ដោយដៃរបស់ខ្ញុំផ្ទាល់ មិនឲ្យសត្រូវសុខបក្សកម្ទេចខ្ញុំទេ......ដើម្បីការពារកិត្តិយសឲ្យសន្តិសុខបក្សក្នុងការកម្ទេចខ្មាំង...... ។ នេះជាពេលចុងក្រោយហើយ...សូមបងជួយប្អូនឲ្យបានទាន់ពេលផង ។ ខ្ញុំសុខចិត្តមកធ្វើស្រែជាមួយប្រពន្ធកូនខ្ញុំនៅក្នុងសហករណ៍វិញ ។ មិនចង់បានមុខតំណែងអ្វីទេ ។ បងមិនបាច់គិតពីរឿងហ្នឹងទេ...ជួយសង្គ្រោះខ្ញុំឲ្យមានជីវិតផង» ។

នៅក្នុងការឆ្លើយតបវិញតាមរយៈសំបុត្រដែលសរសេរក្រោយពីពេលដែល ឆែ ត្រូវបានធ្វើទារុណកម្ម ឌុច បានធ្វើការពិចារណាទៅលើការអះអាងរបស់អ្នកទោសម្នាក់នេះដែលថាខ្លួនត្រូវបានបក្សពួកក្បត់ឆ្លើយដាក់ ។ ឌុច សរសេរថា «ការលាបពណ៌មនុស្សឲ្យក្លាយជាពណ៌ខ្មៅ គឺជាល្បិចរបស់ខ្មាំង ។ ប៉ុន្តែបក្សកុម្មុយនិស្តកម្ពុជាដឹងច្បាស់ណាស់អំពីលទ្ធភាពក្នុងការតាមដាននិងទប់ទល់ល្បិចបែបនេះ» ។ ឌុច បន្តទៀតថា «តាមការសង្កេតតាមប្រវត្តិសាស្ត្ររបស់ខ្ញុំរហូតមក ខ្ញុំមិនដែលឃើញកម្មាភិបាលណាមួយរងគ្រោះដោយសារតែល្បិចលាបពណ៌ឲ្យខ្មៅបែបនេះទេ ។ បក្សមិនបារម្ភអំពីបញ្ហានេះសោះ ។ និយាយឲ្យស្រួលស្តាប់គឺថា មិនដែលមានកម្មាភិបាលណាម្នាក់ចូលមកសន្តិបាលដោយសារការលាបពណ៌ខ្មៅឡើយ...តើបងយល់យ៉ាងណាដែរចំពោះបញ្ហានេះ? ពិនិត្យទៅលើបញ្ហា តើបញ្ហានេះកើតឡើងដោយសារតែបក្សកុម្មុយនិស្តត្រូវបានបោកប្រាស់ដោយសារខ្មាំងឲ្យលាបពណ៌បងឯង ឬក៏ដោយសារបងមិនត្រង់នឹងបក្ស ។ តើបងយល់យ៉ាងម៉េចដែរ? សូមបងគិតនិងដោះស្រាយបញ្ហានេះ ។ នៅពេលយើងយល់ស្របគ្នាយើងនឹងធ្វើការទាំងអស់គ្នា» ។

ស៊ាត ឆែ មានការពិបាកក្នុងការដោះស្រាយបញ្ហានេះ ។ នៅក្នុងខែកក្កដា ឌុច ដឹងអំពីបញ្ហានេះ ។នៅក្នុងអ្វីដែលជាឯកសារដ៏សាហាវជាងគេបង្អស់នៅក្នុងបណ្ណសារនៅមន្ទីរស-២១នោះ អ្នកសួរចម្លើយឈ្មោះ ទុយ បានសរសេរទៅកាន់ ស៊ាត ឆែ ថា «សរសេរអំពីសកម្មភាពខុសសីលធម៌ជាមួយកូនឲ្យបានលម្អិតពីព្រោះតាមគោលជំហរមហាជនកំហុសនេះត្រូវបានមើលឃើញច្បាស់ណាស់ ។ កុំបដិសេធអី ។ កុំឲ្យឈឺខ្លួនថែមទៀតដោយសារតែបញ្ហាតូចតាចនេះ» ។ មនុស្សដែលមានការពាក់ព័ន្ធគឺកូនស្រីតែមួយរបស់ ស៊ាត ឆែ ដែលទើបតែមានអាយុ២០ឆ្នាំ ។ នាងបានក្លាយជាជនបដិវត្តរួចហើយ ។ ស៊ាត ឆែ បានបដិសេធការចោទប្រកាន់នេះ ហើយទទូចថាកូនស្រីជាទីស្រលាញ់របស់ខ្លួនគឺពិតជានៅបរិសុទ្ធល្អណាស់ ។ ការឆ្លើយបដិសេធក្តែងៗគឺមាននៅក្នុងទំព័រ «អត្ថបទបន្ថែម» នៅចុងបញ្ចប់សៀវភៅនេះ ។ មាន

របស់អ៊ីម្យ៉ាងហាក់ដូចជាបានជ្រៀតចូលទៅក្នុងខ្លួនរបស់ ផែ ក្រោយពីគាត់ត្រូវបានឃាយឃីខានផ្នែកអារម្មណ៍ ។ ចាប់ពីពេលនោះរហូតមកដល់ថ្ងៃដែល ផែ ត្រូវបានសម្លាប់ ផែ មិនបានសរសេរសំបុត្រទៀតឡើយ ។ ក៏ប៉ុន្តែចម្លើយសារភាពរបស់ ផែ ពាក់ព័ន្ធអ្នកធ្វើការជាមួយខ្លួនរាប់ សិបនាក់ ។

## ការបោសសម្អាតនៅភូមិភាគពាយ័ព្យ

នៅក្នុងអំឡុងឆ្នាំ១៩៧៧ ប្រហែលជាពេលដែលត្រូវប្រឈមមុខនឹងលទ្ធផលចម្រុះនៃការពង្រីកផ្នែកកសិកម្មដែលស្ថិតនៅក្នុងគម្រោងផែនការបួនឆ្នាំ ហើយប្រហែលដោយសារការប្រើពត៌មានដែលស្រង់ចេញមកពីចម្លើយសារភាពផ្ញើមកពីមន្ទីរស-២១ បានជាធ្វើឲ្យ ប៉ុល ពត ផ្តោតជាសំខាន់ទៅលើការតាមដានកម្ទេចខ្មាំងរបស់រដ្ឋច្រើនជាងទៅលើការអភិវឌ្ឍសេដ្ឋកិច្ច ។ ផែនការបួនឆ្នាំហាក់ដូចជាត្រូវបានបោះបង់ចោលយ៉ាងស្ងាត់ស្ងៀម ។

នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ សន្តិបាលបានងាកទៅរកភូមិភាគឧត្តរវិញ ដែលនៅទីនោះកម្មាភិបាលយោធានិងស៊ីវិលត្រូវបានចោទប្រកាន់ថាបានធ្វើអំពើវិទ្ធង្សនាទៅលើវិស័យសេដ្ឋកិច្ចរបស់បដិវត្តន៍ ដោយបង្កឲ្យមានការលំបាកទៅលើប្រជាជនដើម្បីធ្វើឲ្យសីលធម៌ធ្លាក់ចុះ និងធ្វើឲ្យគ្មានជំនឿទៅលើបដិវត្តន៍ ។ នៅក្នុងឆ្នាំ១៩៧៧ ដោយសារមានការប្រមូលផលបានតិច កម្លាំងពលកម្មមិនមានការបំពាក់សម្ភារគ្រប់គ្រាន់និងមិនមានអាហារគ្រប់គ្រាន់ ការចែកអង្ករពីភូមិភាគពាយ័ព្យមិនបានទៅដល់ទីក្រុងភ្នំពេញឡើយ ។ កម្មាភិបាលនៅក្នុងភូមិភាគត្រូវបានចោទប្រកាន់ថាបានប្រមូលផលទុក ឬបំផ្លាញភោគផលក្នុងគោលបំណងបង្អត់អាហារប្រជាជននៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយអនុញ្ញាតឲ្យប្រជាជនដទៃទៀតរត់កៀសខ្លួនទៅជនបទ ផ្តល់ទឹកដីកម្ពុជាទៅឲ្យប្រទេសថៃ មានគម្រោងការក្បត់ជាមួយនិរទេសជនជាតិខ្មែរនិងចោទថាបានលក់ស្រូវទៅឲ្យថៃ ។

នៅក្នុងសម័យបដិវត្តន៍ ភូមិភាគពាយ័ព្យគឺជាឃ្លាំងបាយរបស់ប្រជាជនកម្ពុជាទូទាំងប្រទេសដែលជាតំបន់ផលិតស្រូវសំខាន់បំផុតសម្រាប់ការនាំចេញ ។ នៅក្នុងសង្គ្រាមលោកលើកទី២ មួយភាគធំនៃភូមិភាគនេះគឺស្ថិតនៅក្នុងការគ្រប់គ្រងរបស់ប្រទេសថៃ ហើយដោយមានការលើកទឹកចិត្តពីសំណាក់ប្រទេសថៃ ។ ភូមិភាគនេះបានក្លាយទៅជាមូលដ្ឋានបង្កើតខ្មែរឥស្សរៈប្រឆាំងនឹងបារាំងនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ ។ នៅក្នុងឆ្នាំ១៩៦៧ ការបះបោរប្រឆាំងនឹងកងទ័ព សីហនុ បានកើតឡើងនៅក្នុងអតីតលេណដ្ឋានរបស់ខ្មែរឥស្សរៈនៅសំឡូត ។ ការបះបោរនេះនាំឲ្យមានការបង្ក្រាបយ៉ាងធ្ងន់ធ្ងរ និងបណ្តាលឲ្យមនុស្សរាប់ពាន់នាក់ត្រូវបាត់បង់ជីវិត ។ ការតស៊ូប្រដាប់អាវុធប្រឆាំងនឹងសម្តេច សីហនុ ចាប់ផ្តើមនៅក្នុងភូមិភាគនេះតែម្តងគឺនៅខែ



កុម្ភៈ ឆ្នាំ១៩៦៨ ។ ប៉ុន្តែនៅក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិលមួយភាគធំនៃតំបន់នេះស្ថិតនៅក្នុងដៃរបស់របបក្រុងភ្នំពេញ ។

ក្រោយឆ្នាំ១៩៧៥ ប្រជាជននៅភូមិភាគពាយ័ព្យមានថែម"ប្រជាជនថ្មី" ដែលត្រូវបានជម្លៀសមកពីក្រុងភ្នំពេញ ខេត្តបាត់ដំបង និងក្រុងនានា ។ កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជា នៅភូមិភាគពាយ័ព្យដូចជាគ្មានបទពិសោធន៍ក្នុងផ្នែករដ្ឋបាល ហើយភាគច្រើនខ្វះទំនាក់ទំនងជាមួយមូលដ្ឋាន ។ ប៉ុន្តែផ្ទុយមកវិញ ក្រុមរបស់កម្មាភិបាលទាំងនេះដែលធ្វើការនៅភូមិភាគនានាដែលមានព្រំប្រទល់ជាប់ប្រទេសវៀតណាម បានទទួលការហ្វឹកហ្វឺនបដិវត្តអស់ជាច្រើនឆ្នាំ ហើយគ្រប់គ្រងនយោបាយ

រហូតក្រោយឆ្នាំ១៩៧០ ។ កម្មាភិបាលជាច្រើននាក់ដែលទទួលខុសត្រូវភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៥ និង១៩៧៦ ជាគ្រូបង្រៀន មានជាអាទិ៍ដូចជា ខែក ប៊ុន ហៅ ស៊ូ ជាដើម ដែលធ្វើជាលេខាប្រជាជនតំបន់៤ និងត្រូវបានបោសសម្អាតនៅក្នុងឆ្នាំ១៩៧៧ ឬជាអតីតយុទ្ធជនមិនសូវចេះអក្សរមកពីភូមិភាគផ្សេង ។ ក្នុងករណីខ្លះ "ប្រជាជនថ្មី" ត្រូវបានដាក់ឲ្យទទួលខុសត្រូវ ប៉ុន្តែប្រជាជនទាំងនេះត្រូវបានចាត់ទុកថាជាអ្នកបំផ្លិចបំផ្លាញទៅវិញ ដោយសារតែធាតុវណ្ណៈនិងសកម្មភាពកាលពីមុនមករបស់ខ្លួន ។ ទស្សនាវដ្ដី "ទង់បដិវត្តន៍" បានបញ្ជាក់នៅក្នុងខែតុលា ឆ្នាំ១៩៧៧ "សហករណ៍ដែលគ្រប់គ្រងដោយវណ្ណភាពមិនល្អ គ្មានអង្ករស៊ីទេ" ។ អត្ថបទនេះសរសេរថា ត្រូវតែទម្លាក់កំហុសទៅលើ "សមាសភាពមិនល្អ" ។ ក៏ប៉ុន្តែលេខាភូមិភាគពាយ័ព្យឈ្មោះ មូល សម្បត្តិ (ហៅ ញឹម រស់) គឺជាអ្នកបដិវត្តដើងចាស់ដែលមានកំណើតកើតជានិងបានកសាងខ្លួននៅភូមិភាគនេះ ។ មិនខុសពី សោ ភឹម នៅភូមិភាគបូព៌ាទេ នៅក្នុងអំឡុងសង្គ្រាមស៊ីវិល សម្បត្តិ មិនទៅណាពីភូមិភាគនេះឡើយ ។ អ្វីដែល ប៉ុល ពត និងអ្នកធ្វើការនៅកៀកខ្លួនគាត់ មិនចូលចិត្តភូមិភាគពាយ័ព្យគឺថា មេដឹកនាំរបស់ភូមិភាគនេះមិនសូវមានឯករាជ្យពិតប្រាកដហើយមានទំនាក់ទំនងជាមួយនឹង សោ ភឹម តាមរយៈចំណងអាពាហ៍ពិពាហ៍ ។ ដោយសារ សម្បត្តិ មានប្រជាប្រិយភាពខ្លាំងពេក មជ្ឈិមបក្សក៏ផ្អាកចាប់ខ្លួនគាត់អស់រយៈពេលជាច្រើនខែ ។ នៅក្នុងភូមិភាគពាយ័ព្យតែមួយ មានទិដ្ឋភាពទូទៅផ្សេងៗពីគ្នាទៅតាមតំបន់ ។ នៅក្នុងតំបន់ផលិតស្រូវសំខាន់ដែលស្ថិតនៅតំបន់៣ ជាទូទៅប្រជាជនមានអង្ករហូបគ្រប់គ្រាន់ ហើយការសម្លាប់មនុស្សបានកើតឡើងតិចតួចតែប៉ុណ្ណោះ ។ នៅតំបន់ដែលមានរបាយប្រជាជនរស់នៅតិចពោលគឺតំបន់១ តំបន់៤ តំបន់៥ និងតំបន់៦"ប្រជាជនថ្មី"ត្រូវបានចាត់តាំងឲ្យកាប់ឆ្ការព្រៃដែលជាជម្រកជំងឺគ្រុនចាញ់ ។ ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់នេះមានលក្ខណៈធ្ងន់ធ្ងរជាងតំបន់៣ ហើយចំនួនមនុស្សស្លាប់បណ្ដាលមកពីជំងឺតម្កាត់និងកង្វះជីវជាតិអាហារមានកម្រិតខ្ពស់បំផុតក្នុងចំណោមតំបន់ផ្សេងៗទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងការបង្កើតគម្រោងផែនការបួនឆ្នាំ ប៉ុល ពត និងអ្នកធ្វើការនៅជិតខ្លួនបានផ្ដោតក្ដីសង្ឃឹមទៅលើភូមិភាគពាយ័ព្យដែលត្រូវបានសង្ឃឹមថានឹងផលិតភោគផលកសិកម្មបាន៣០ភាគរយនៃផលជាតិប្រចាំឆ្នាំ ។ មជ្ឈិមបក្សសង្ឃឹមថា "ប្រជាជនថ្មី" នៅភូមិភាគនេះដែលភាគច្រើនមិនធ្លាប់ធ្វើស្រែ នឹងអាចបំពេញកិច្ចការដែលជាក្ដីសង្ឃឹមមិនប្រាកដប្រជារបស់របបកម្ពុជាប្រជាធិបតេយ្យគឺសម្រេចឲ្យបានផលស្រូវបីតោនក្នុងមួយហិកតា ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ខៀវ ធីរិទ្ធ (អៀង ធីរិទ្ធ) ដែលជាប្រពន្ធរបស់ អៀង សារី និងជាប្អូនថ្លៃស្រីរបស់ ប៉ុល ពត បានចុះទៅភូមិភាគពាយ័ព្យ ហើយមានការព្រួយបារម្ភចំពោះអ្វីដែលខ្លួនបានឃើញផ្ទាល់នឹងភ្នែក ។ ខៀវ ធីរិទ្ធ បាននិយាយទៅកាន់អេលីហ្សាប៊ែត ប៊ែកយ័រ នៅក្នុងឆ្នាំ១៩៨០ថា "ស្ថានការណ៍ពិតជាមិនធម្មតាទេ ។ ប្រជាជនគ្មានផ្ទះសម្បែងជ្រកកោននិងសុទ្ធតែមានជំងឺតម្កាត់ទៀតផង" ។ ចំពោះស្ថានការណ៍ធ្ងន់ធ្ងរនេះ ខៀវ ធីរិទ្ធ មិនបានទម្លាក់កំហុសទៅលើខ្សែសង្វាក់បញ្ជារបស់មជ្ឈិមបក្សទេ តែបែរជាប្រាប់ ប៊ែកយ័រ ហើយប្រហែលជាបានប្រាប់ ប៉ុល ពត ដែរថា "មានពួកសមាសភាពលួចជ្រៀតចូលទៅក្នុងជួរយើង" ។ "សមាសភាព" ម្នាក់ក្នុងចំណោមសមាសភាពទាំងអស់ប្រហែលជាឈ្មោះ ភោគ ឆាយ ថ្នាក់ដឹកនាំតំបន់ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨ និងត្រូវបានទម្លាក់កំហុសអំពីបញ្ហាដែលកើតឡើងនៅក្នុងភូមិភាគនេះ: "ខ្ញុំបានណែនាំឲ្យបំផ្លាញផលស្រូវដោយឲ្យច្រូតស្រូវមិនទាន់ទុំ ។ ហើយនៅពេលបោកបែនក៏មានការណែនាំឲ្យបំផ្លាញដែរ ។ ខ្ញុំបានចាត់តាំងឈ្មោះ ឆើត ឲ្យដុតស្រូវនៅក្នុងស្រែ...ហើយផលស្រូវដែលប្រមូលបានក៏ដុតចោលមិនតិចដែរ ។ ខ្ញុំបានប្រាប់កម្លាំងនៅស្រុកទាំងអស់ថា មានចោរនិងប្រជាជនថ្មីជាអ្នកដុតស្រែស្រូវនេះ ។ គោលបំណងរបស់ខ្ញុំគឺបង្កភាពច្របូកច្របល់នៅក្នុងចំណោមប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី ។ សភាពការណ៍នេះបានបន្ទុចបង្អាក់ផែនការ(បួនឆ្នាំ)របស់បក្ស... ។ នៅពេលកំពុងបង្កបង្កើនផលគឺត្រូវបំផ្លាញសម្ភារប្រើប្រាស់សម្រាប់បង្កបង្កើនផលនិងប្រមូលផល ។ក្រៅពីនោះកម្លាំងប្រចាំលេខាស្រុកត្រូវបានណែនាំឲ្យបង្អត់បាយប្រជាជន ឲ្យប្រជាជនហូបបបរដើម្បីឲ្យប្រជាជនទៅសុំអង្គការ" ។ **(នៅមានត)**




**(តពីលេខមុន)**

អតីយុទ្ធជនវ័យក្មេងកងការពារមន្ទីរ ស-២១ ឈ្មោះ សឿ រៀបរាប់ថា ពេលដែល តាខ្មៅ លេខាស្រុកកំពង់ត្រឡាច ហៅគាត់ឲ្យចេញពីភូមិទៅធ្វើការងារនៅកន្លែងផ្សេង ដំបូងគាត់ស្ទាក់ស្ទើរមិនយល់ព្រមទេ ពេលនោះ តាខ្មៅ បានពន្យល់ប្រាប់គាត់ថា ការចេញទៅធ្វើការនេះមិនមែនទៅតែ សឿ ម្នាក់ឯងទេ គឺមានកុមារដែលជាពួកម៉ាករបស់ សឿ ជាច្រើនទៀតក៏ត្រូវចេញទៅជាមួយ សឿ ដែរ ។ ក្រោយពីឮដូច្នោះ សឿ ហាក់ដូចជាធូរចិត្ត ហើយមានអារម្មណ៍ចង់ទៅជាមួយពួកម៉ាករបស់គាត់ ។ សឿ រំឭកប្រវត្តិបន្តបន្ទាប់របស់គាត់ ដែលចុងក្រោយក្លាយជាយុទ្ធជនវ័យក្មេងការពារមន្ទីរស-២១ថា «ពេលដែលលេខាស្រុកឈ្មោះ តាខ្មៅ មកប្រាប់ខ្ញុំឲ្យចេញពីភូមិទៅធ្វើការនៅកន្លែងផ្សេង ពេលនោះខ្ញុំមិនចង់ទៅទេ ។ ភ្លាមនោះ តាខ្មៅ ប្រាប់ខ្ញុំថា ពួកម៉ាកខ្ញុំទាំងអស់ក្នុងភូមិក៏ត្រូវចេញទៅជាមួយខ្ញុំដែរ ។ ឮអីចឹងខ្ញុំហាក់ដូចជាសប្បាយ ហើយមានចិត្តចង់ចេញពីភូមិជាមួយនឹងពួកម៉ាក ។ នៅតាមផ្លូវទៅមជ្ឈិម ពួកយើងជិះឡានបណ្តើរស្រែកច្រៀងសើចលេងបណ្តើរយ៉ាងសប្បាយ ។ ពេលនោះខ្ញុំសប្បាយចិត្តព្រោះបានចេញពីភូមិជាមួយពួកម៉ាកហើយបានចូលធ្វើការនៅមជ្ឈិមដែលខ្ញុំឮថាសប្បាយ ហើយខ្ញុំមិនដែលបានស្គាល់សោះពីមុនមក» ។ កុមារដែលចង់ចូលបម្រើខ្មែរក្រហមធ្វើជាសេនាជនឈ្លបឃុំគឺក្នុងបំណងចង់ហូបឆ្អាញ់និងធ្វើការងារតិចតួចនិងធូរស្រាល ។ ប៉ុន្តែកុមារទាំងនេះពុំបានដឹងថាតើអ្វីដែលខ្លួនត្រូវប្រឈមមុខដោះស្រាយ ហើយតើខ្លួននឹងរស់នៅក្នុងស្ថានភាពបែបណាក្នុងពេលដែលខ្លួនក្លាយជាយុទ្ធជនវ័យក្មេងនៃមន្ទីរ ស-២១ ។ កុមារទាំងនោះមិនដឹងថាក្រោយការចូលរួមជាយុទ្ធជន ឬកងទ័ពខ្មែរក្រហមខ្លួនត្រូវហាមឃាត់ដាច់ខាតមិនឲ្យវិលត្រឡប់មកផ្ទះសម្បែងជួបជុំសួរសុខទុក្ខឪពុកម្តាយឬបងប្អូនឡើយ ។ ក្រោយពីឈានជើងដល់មជ្ឈិម សឿ ត្រូវខ្មែរក្រហមចាត់តាំងផ្លាស់ប្តូរការងារនិងលត់ដំចុះឡើងជាច្រើនកន្លែង ។ ឆ្លងកាត់ការងារនៅមជ្ឈិមមួយរយៈ សឿ ស្តាយក្រោយនឹកតូចចិត្តរហូតស្រក់ទឹកភ្នែកនឹកចង់វិលមកភូមិស្រុកវិញ ប៉ុន្តែវាជាការជ្រុលហួសទៅហើយ ។

ប្រធានឈ្លបឃុំ-ស្រុកក៏ដូចជាប្រធានឃុំនិងលេខាស្រុកបានប្រើល្បិចកលដើម្បីអូសទាញកុមារក្នុងភូមិរបស់ខ្លួនឲ្យចូលរួមបម្រើក្នុងចលនាបដិវត្តតាមបញ្ជាអង្គការថ្នាក់លើ ។ ប្រធានឃុំ-ស្រុក ការភូតកុហកបោកប្រាស់ទាំងនោះរួមមានដូចជាការលួងលោម ការភូតកុហក និងការចាប់បង្ខំ ។ ក្នុងសម័យសង្គ្រាមប្រឆាំង លន់ ណុល ប្រធានឈ្លបឃុំបានលួងលោម សឿ ឲ្យចូលបម្រើកងទ័ពដោយប្រាប់ សឿ ថា «បើឯងចូលបម្រើក្នុងកងទ័ពនោះ ក្រុមគ្រួសាររបស់ឯងនឹងបានរស់នៅយ៉ាងសុខសប្បាយ» ។ សឿ បញ្ជាក់បន្ថែមថា «នៅពេលដែលប្រធានឈ្លបមកហៅខ្ញុំឲ្យចូលធ្វើឈ្លបខ្ញុំមិនព្រមទៅ ដោយពេលនោះខ្ញុំប្រកែកថាខ្ញុំនៅតូចមិនចង់ទៅធ្វើទ័ពទេ ម្យ៉ាងទៀតគ្មាននរណាមើលថែម៉ែខ្ញុំ ។ ប្រធានឈ្លបនោះនិយាយថា ខ្ញុំធំល្មមចូលបម្រើទ័ពនឹងគេហើយ ។ ពេលនោះគាត់ប្រាប់ខ្ញុំទៀតថាពេលខ្ញុំចូលធ្វើកងទ័ពបម្រើបដិវត្តន៍គាត់នឹងជួយមើលថែរក្សាក្រុមគ្រួសារ ម៉ែឪខ្ញុំឲ្យបានល្អ ។ ទីបំផុតខ្ញុំក៏សម្រេចចិត្តចូលធ្វើកងទ័ពព្រោះខ្ញុំចង់ឲ្យក្រុមគ្រួសារឪពុកម្តាយខ្ញុំរស់នៅមានសេចក្តីសុខ» ។

អតីតយុទ្ធជនវ័យក្មេងការពារមន្ទីរ ស-២១ ឈ្មោះ សាត ក៏បានបញ្ជាក់ថា គាត់ត្រូវលេខាស្រុកបរិបូណ៌ ឈ្មោះ រិន បោកប្រាស់ឲ្យចូលបម្រើក្នុងចលនាបដិវត្តខ្មែរក្រហម ហើយ សមមិត្ត រិន នេះក៏ជាអ្នកបញ្ជូនគាត់ឲ្យទៅធ្វើការនៅមជ្ឈិមដែរ ។ សាត រៀបរាប់ថា «បង រិន បានមកបញ្ចុះបញ្ចូលខ្ញុំឲ្យចូលបម្រើបដិវត្តន៍ជាឈ្លបឃុំ ក្រោយពីធ្វើការបានមួយរយៈ បង រិន បាន

ចាត់តាំងខ្ញុំឲ្យចេញពីភូមិដើម្បីទៅធ្វើការ ។ ប៉ុន្តែ រិន មិនបានប្រាប់ខ្ញុំថាចេញមកខាងមជ្ឈិមទេ ។ គាត់ប្រាប់ថាចេញមកភូមិក្បែរៗហ្នឹង ។ នៅតាមផ្លូវពីស្រុកមក ពួកយើងគិតថាប្រហែលជាយើងត្រូវមកធ្វើការនៅខាងតំបន់ក្នុងទីរួមខេត្តកំពង់ឆ្នាំង ប៉ុន្តែពេលមកដល់ខេត្តឡានអត់ឈប់ ពេលនោះយើងម្នាក់ៗចាប់ផ្តើមភ័យនិងនឹកគិតថា យើងមិនដឹងត្រូវទៅដល់ទីណាហើយធ្វើការងារអ្វីទេ» ។

ការចូលរួមរបស់អតីតយុទ្ធជនវ័យក្មេងកងការពារមន្ទីរ ស-២១ ឈ្មោះ អ៊ុន ក្នុងចលនាខ្មែរក្រហមក៏មិនខុសពី សាត និង សឿ ដែរ ។ អ៊ុន បញ្ជាក់ថា គាត់ត្រូវកម្មាភិបាលខ្មែរក្រហមក្នុងភូមិស្រុកជំរុញឲ្យចូលបម្រើក្នុងជួរកងឈ្លប ហើយបញ្ជាឲ្យចេញទៅធ្វើការងារពីកន្លែងមួយទៅកន្លែងមួយ ។ ទីបំផុតគាត់ត្រូវក្លាយខ្លួនជាយុទ្ធជនការពារនៅមន្ទីរស-២១ ។ ឈ្លបឃុំនិងស្រុកតែងតែចាញ់ការបោកបញ្ឆោតរបស់ប្រធានឃុំ-ស្រុកអំពីភារកិច្ចឬទីកន្លែងដែលខ្លួនត្រូវចេញទៅ ដោយប្រធានឃុំស្រុកទាំងនោះភូតកុហកកងឈ្លបក្មេងៗថា ត្រូវចេញពីភូមិដើម្បីធ្វើស្រែចម្ការនិងចូលរួមរៀនសូត្រ ។

អតីតយុទ្ធជនខាងជាងម៉ាស៊ីនភ្លើងមន្ទីរស-២១ ឈ្មោះ ឌឿន រំឭករឿងរ៉ាវរបស់គាត់ បន្ទាប់ពីឪពុកម្តាយស្លាប់បាត់បង់ជីវិតក្នុងសង្គ្រាម គាត់ត្រូវទៅរស់នៅជាមួយពូរបស់គាត់នៅភូមិអង្គ ឃុំពពែល ស្រុកបរិបូណ៌ ។ បន្ទាប់មកគាត់ត្រូវប្រធានភូមិចាត់តាំងឲ្យចូលរួមក្នុងកងកុមារដែលមានចំនួនប្រមាណជាង១០០នាក់ ហើយធ្វើការងារលើកទំនប់នៅដំណាក់ចំបក់ស្ពានដែក ទំនប់អូររលួសនិងធ្វើស្រែជាច្រើនកន្លែងផ្សេងទៀត ។ ឌឿន រៀបរាប់រឿងរ៉ាវដែលកើតឡើងពីនោះបន្តទៀតថា «កុមារា៥នាក់ និងកុមារី៥នាក់ក្នុងក្រុមរបស់ខ្ញុំត្រូវប្រធានភូមិចាត់តាំងឲ្យទៅធ្វើខាងឈ្លបឃុំ ។ មួយឆ្នាំក្រោយមក ខ្ញុំក៏ត្រូវប្រធានឃុំចាត់តាំងឲ្យចេញពីភូមិទៅធ្វើការកន្លែងផ្សេង ។ ប្រធានឃុំមិនបានប្រាប់អំពីទីកន្លែងដែលត្រូវទៅនិងភារកិច្ចដែលត្រូវធ្វើឡើយ ។ ប្រធានភូមិកុហកខ្ញុំថាចេញទៅរៀនបន្ត ។ ក្នុងពេលចេញដំណើរនោះគ្មាននរណាម្នាក់ដែលជិះក្នុងឡានជាមួយខ្ញុំដឹងអំពីទីកន្លែងដែលយើងត្រូវទៅនិងភារកិច្ចដែលយើងត្រូវធ្វើឡើយ ។ ពួកយើងម្នាក់ៗគ្រាន់តែដឹងថាយើងកំពុងធ្វើតាមបញ្ជារបស់អង្គការថ្នាក់លើ» ។

ដៃ អតីតយុទ្ធជនវ័យក្មេងក្នុងកងចិញ្ចឹមសត្វនៅមន្ទីរ ស-២១ រៀបរាប់ថា គាត់ត្រូវប្រធានឃុំពានី ឈ្មោះ ពឿន ប្រាប់ឲ្យចេញពីភូមិដើម្បីទៅរៀនបន្ត ។ ប៉ុន្តែតាមការពិត ដៃ ត្រូវខ្មែរក្រហមបញ្ជូនឲ្យមកធ្វើការនៅក្នុងមន្ទីរស-២១ ។ ក្នុងឆ្នាំ១៩៧៣ ក្រុមគ្រួសាររបស់ ដៃ ត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិចាន់ត្រក ទៅភ្នំជីពិតក្នុងភូមិអូរឡាក្មេង ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ការជម្លៀសប្រជាជនពីក្នុងភូមិទៅកាន់ទីតាំងដែលខ្មែរក្រហមកាន់កាប់គឺក្នុងបំណងប្រមូលកម្លាំងប្រឆាំងនឹងរបប លន់ ណុល ។ ក្នុងសម័យសង្គ្រាម ដៃ ក៏បានចូលរួមក្នុងជួរកងទ័ពជាមួយកុមារដទៃទៀតវាយប្រឆាំងនឹងទាហាន លន់ ណុល ដែរ ។ ដៃ រំឭករឿងអតីតកាលរបស់គាត់ថា «ពេលដែលខ្មែរក្រហមចូលមកជម្លៀសប្រជាជនក្នុងភូមិ បើអ្នកណាមួយហ៊ានប្រឆាំងគឺត្រូវស្លាប់ខ្លួន ។ ក្រោយពេលដែលជម្លៀសប្រជាជន ហើយខ្មែរក្រហមចាប់ផ្តើមលួងលោមបញ្ចុះបញ្ចូលកុមារតូចៗឲ្យចូលរួមធ្វើជាកងទ័ពឬឈ្លបដើម្បីប្រយុទ្ធជាមួយទាហាន លន់ ណុល ។ ពេលនោះ ពឿន បានប្រាប់ខ្ញុំឲ្យចូលធ្វើកងទ័ពដោយនិយាយថា គ្មាននរណាមួយគេចផុតពីការចូលរួមក្នុងចលនាបម្រើបដិវត្តន៍ទេ ភារកិច្ចនេះជាភារកិច្ចសំខាន់បំផុត ។ ក្រោយពីទទួលបានជ័យជម្នះខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅចូលរួមរៀនសូត្រ ប៉ុន្តែតាមពិតខ្ញុំត្រូវបញ្ជូនមកឲ្យធ្វើជាយុទ្ធជនការពារនៅមន្ទីរស-២១ ។ អាសេត និងអាឌឿន ដែលចេញពីភូមិជាមួយខ្ញុំទៅធ្វើការនៅមជ្ឈិមងាប់អស់ហើយ» ។

ការចាត់តាំងឲ្យឈ្លបឃុំឬស្រុកចេញពីភូមិស្រុកផ្ទះសម្បែងទៅធ្វើការនៅមជ្ឈិមតែងតែធ្វើឡើងនៅក្នុងពេលអង្គប្រជុំឬចាត់តាំងជាបុគ្គល គ្មានពេលវេលា ទោះបីជាក្នុងពេលដែលឈ្លបទាំងនោះកំពុងដេកលក់កណ្តាលអធ្រាត្រក៏ដោយ ។ ទោះជាចាត់តាំងកើតឡើងក្នុងពេលណាក៏ដោយក៏កងឈ្លបទាំងអស់ត្រូវតែគោរពតាមការចាត់តាំងរបស់កម្មាភិបាលដឹកនាំដែរ ព្រោះកងឈ្លបទាំងនោះខ្លាចរអាប្រធានខ្លួនគ្រប់ៗគ្នា ។

ក្នុងសម័យសង្គ្រាមរវាងខ្មែរក្រហមនិងរបបសាធារណរដ្ឋ ឡា រស់នៅក្នុងភូមិត្រពាំងចាន់ក្រោមការកាន់កាប់របស់ខ្មែរក្រហម ។ ឡា ត្រូវជម្លៀសចុះឡើងជាបន្តបន្ទាប់ចេញឆ្ងាយពីភូមិនិងឪពុកម្តាយ ។ ក្នុងឆ្នាំ១៩៧៣ ឡា បានចូលរួមធ្វើទំនប់ព្រែកដីក និងស្ពានដែក ក្រោយមក ឡា ត្រូវបានចាត់តាំងឲ្យចូលធ្វើឈ្លបនៅក្បាលដំរីឃុំពពេល ។ ពេល ឡា ក្លាយជាឈ្លបឃុំ គាត់រស់នៅ និងធ្វើការក្រោមការដឹកនាំរបស់សមមិត្ត នៅ ដែលមានអាយុជាង២០ឆ្នាំ ខ្ពស់ស្រឡះ រាងស្គម ។ ឡា ត្រូវសមមិត្ត នៅ ចាត់តាំងឲ្យចេញពីភូមិដើម្បីទៅបំពេញភារកិច្ចថ្មី ។ ឡា រំឭកប្រវត្តិ ចេញដំណើររបស់គាត់ពីភូមិទៅមជ្ឈិមដូចតទៅៈ «កាលនោះនរណាក៏ខ្លាចសមមិត្ត នៅ ដែរ ជាពិសេសឈ្លបឃុំ ព្រោះគាត់ជាមនុស្សកាចនិងសាហាវបំផុត ។ នៅ បានសម្លាប់មនុស្សអស់ជាច្រើននាក់តាំងពីឆ្នាំ១៩៧៤ ។ សូម្បីតែប្អូនជីដូនមួយរបស់គាត់ឈ្មោះ ម៉ុម ក៏ត្រូវគាត់សម្លាប់ដែរ ។ ឆ្នាំ១៩៧៥ នៅ បានសម្លាប់គ្រូបង្រៀនម្នាក់នៅក្បាលដំរីចំពោះមុខកងឈ្លបកុមារតែម្តង ។ ខ្ញុំត្រូវបាន នៅ ចាត់តាំងក្នុងពេលប្រជុំឲ្យចេញពីភូមិដើម្បីទៅធ្វើការនៅកន្លែងផ្សេង ។ កាលនោះខ្ញុំចេញដំណើរពីភូមិថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៥ ។ ការដែលថ្នាក់ដឹកនាំតំបន់៣១បញ្ជូនកុមារចេញពីភូមិឲ្យចូលទៅបម្រើបដិវត្តន៍នៅមជ្ឈិម ព្រោះខាងមជ្ឈិមខ្វះខាតកម្លាំងធ្វើការ ។»

សមមិត្ត ខាន់ អតីតយុទ្ធជនវ័យក្មេងក្នុងកងចិញ្ចឹមសត្វនៃមន្ទីរ ស-២១ កើតនៅភូមិអូឡាំពិក ឃុំពពេល ស្រុកបរិបូណ៌ ។



ក្រុមកងការពារមន្ទីរ ស-២១ ហាត់ក្បាច់ប្រយុទ្ធ

ជំនួសការបានទៅរៀនសូត្រក្នុងសម័យសង្គ្រាម ខាន់ ចូលធ្វើឈ្លបឃុំនៅឆ្នាំ១៩៧៥ ។ ក្រោយពីធ្វើការបានប៉ុន្មានខែគាត់ត្រូវសមមិត្ត ធី ចាត់តាំងឲ្យចេញពីភូមិដើម្បីទៅធ្វើការនៅមជ្ឈិម ។ ខាន់ រៀបរាប់ដំណើររឿងរបស់គាត់ដូចតទៅៈ «យប់មួយក្នុងឆ្នាំ១៩៧៥ ធី បានមកដាស់ខ្ញុំដែលកំពុងតែដេកលក់ឲ្យក្រោកទាំងកណ្តាលអធ្រាត្រ ។ គាត់បានប្រាប់ខ្ញុំឲ្យរៀបចំបង្វេចខោអាវដើម្បីទៅសាលាស្រុក ។ រៀបចំបង្វេចខោអាវបណ្តើរ ខ្ញុំគិតបណ្តើរថា ខ្ញុំមានធ្វើអ្វីខុសបានជា ធី មកនាំខ្ញុំយកទៅសម្លាប់យ៉ាងនេះ ព្រោះកាលនោះគ្មានការងារអ្វីសំខាន់ទាំងកណ្តាលអធ្រាត្រក្រៅពីសម្លាប់ទេ ។ ពេលមកដល់សាលាស្រុកខ្ញុំត្រូវលេខាស្រុកហៅឡើងឡានដោយមិនទាំងបានសួរនាំថាត្រូវទៅណានិងទៅធ្វើអ្វីឡើយ ។»

ក្នុងឆ្នាំ១៩៧៤ ភាព ត្រូវបានបង្ខំឲ្យចូលបម្រើក្នុងចលនាបដិវត្តខ្មែរក្រហមដើម្បីប្រយុទ្ធប្រឆាំងនឹងទាហាន លន់ ណុល ។ ភាព រំឭកព្រឹត្តិការណ៍អតីតកាលរបស់គាត់ថា «កាលនោះប្រធានភូមិមកហៅខ្ញុំចូលបម្រើកងទ័ព ខ្ញុំមិនចង់ចូលធ្វើកងទ័ពយុទ្ធយោធាស្អីទេ ។ ខ្ញុំព្យាយាមគេចជាញឹកញាប់ ប៉ុន្តែខ្ញុំមិនអាចគេចរួច ។ ខ្ញុំខំធ្វើពុតជាឈឺពេលដែលប្រធានភូមិមកហៅខ្ញុំទៅប្រជុំនៅសាលាស្រុក ។ ក្រោយមកខ្ញុំចូលធ្វើឈ្លបស្រុក ។ លេខាស្រុកបានប្រាប់ខ្ញុំថានេះជាភារកិច្ចដ៏សំខាន់ដែលត្រូវតែធ្វើគ្មានឈឺ គ្មានរួញរាទេ ។ ប៉ុន្មានខែក្រោយមក ខ្ញុំត្រូវចាត់តាំងឲ្យចេញពីភូមិពេលដែលត្រូវឡើងឡានចេញពីសាលាស្រុកដើម្បីទៅធ្វើការនៅមជ្ឈិម ខ្ញុំបានគេចទៅផ្ទះបាត់ទៀតដោយប្រាប់គេថាខ្ញុំឈឺ ។ មួយខែក្រោយមកខ្ញុំត្រូវហៅឲ្យចេញពីភូមិម្តងទៀត ។ ម្តងនេះខ្ញុំត្រូវតែគោរពបញ្ជាព្រោះខ្ញុំមិនអាចគេចរួចទៀតឡើយ» ។

គ្រួសាររបស់ ធីម ដែលជាបុគ្គលិកពេទ្យមន្ទីរស-២១ រស់នៅក្នុងភូមិតាសុខ ឃុំសែប ស្រុកកំពង់ត្រឡាច ដែលជាតំបន់ស្ថិតនៅក្រោមការកាន់កាប់ដោយខ្មែរក្រហម ។ ធីម ត្រូវតាខ្មៅចាត់តាំងឲ្យចូលបម្រើកងទ័ពដើម្បីវាយប្រឆាំងនឹងទាហាន លន់ ណុល ។ ធីម និងម្តាយរបស់គាត់ សុទ្ធតែមិនចង់ចូលរួមក្នុងសង្គ្រាម ប៉ុន្តែទាំងម្តាយ និងកូននេះមិនអាចមានផ្លូវផ្សេងសម្រាប់ជ្រើសរើសបានឡើយ ។ ម្តាយរបស់ ធីម ត្រូវរស់នៅម្នាក់ឯងដោយទុក្ខព្រួយ និងអស់សង្ឃឹមដោយសារគាត់មិនអាចជួយកូនរបស់គាត់បាន ។ គាត់ខំស្កាត់ទៅជួប តាខ្មៅ តែលទ្ធផលបានត្រឹមតែអស់ទឹកភ្នែក ។ ម្តាយរបស់ ធីម រំឭកគ្រានោះថា «ខ្ញុំបានសុំតាខ្មៅថា កុំយកកូនខ្ញុំទៅ ព្រោះខ្ញុំមានកូនតែមួយ ហើយវាក៏នៅតូចដែរមិនអាចនឹងទ្រាំទ្រការលំបាកធ្វើជាកងឈ្លបបានឡើយ» ។

ក្នុងពេលធ្វើជាកងទ័ពខ្មែរក្រហម ធីម មានភារកិច្ចដឹកជញ្ជូនបាយទឹកនិងគ្រាប់រំសេវសម្រាប់ផ្គត់ផ្គង់កងទ័ព ។ ក្រោយពេលចប់សង្គ្រាម ធីម ត្រូវបានចាត់តាំងឲ្យចូលបម្រើការងារជាឈ្លបស្រុក ហើយក្រោយមកត្រូវបានចាត់តាំងឲ្យទៅបម្រើការងារបដិវត្តនៅមជ្ឈិម ។ ពេលនោះគ្មាននរណាម្នាក់អាចតវ៉ាប្រឆាំងនឹងបញ្ជារបស់លេខាស្រុកបានឡើយ ។ អតីតយុទ្ធជនពេទ្យមន្ទីរស-២១រូបនេះរៀបរាប់រឿងដើមរបស់គាត់ដូចតទៅៈ «ខ្ញុំបានចូលបម្រើជាកងទ័ពខ្មែរក្រហមខាងដឹកជញ្ជូនស្បៀងនិងគ្រាប់ក្នុងពេលសង្គ្រាម ។ ចប់សង្គ្រាមខ្ញុំត្រូវផ្លាស់ទៅធ្វើជាឈ្លបស្រុក ។ ក្រោយមកក្នុងឆ្នាំ១៩៧៥ ខ្ញុំត្រូវចាត់តាំងឲ្យចេញទៅធ្វើការនៅមជ្ឈិម ។ ម្តាយខ្ញុំមិនចង់ឲ្យខ្ញុំចេញឆ្ងាយពីភូមិស្រុកនិងផ្ទះសម្បែងទេ ដូច្នេះម្តាយខ្ញុំបានទៅសុំតាខ្មៅ ដើម្បីឲ្យខ្ញុំបានធ្វើការនៅភូមិ ប៉ុន្តែតាខ្មៅមិនព្រម ។ ពេលនោះតាខ្មៅមិនទាំងយកត្រចៀកស្តាប់ការអង្វររបស់ម្តាយខ្ញុំផង ។»

**(នៅមានត)**

**ពាក្យស្លោកខ្មែរក្រហម**

◆ **អ្វីៗដែលប៉ះពាល់ដល់ជាតិ ប្រជាជន បដិវត្តន៍ និងបក្ស មិនត្រូវគិត ឬមិនត្រូវធ្វើឱ្យសោះ។**

(ដកស្រង់ចេញពីសៀវភៅលេខ ០៧៦ កណហ)

**សេចក្តីកែតម្រូវ**

ទស្សនាវដ្តីស្វែងរកការពិត ច្បាប់ចេញផ្សាយលេខ៩ ទំព័រ៤២ កូឡោនទី២ បន្ទាត់ទី៥រាប់ពីក្រោម ដែលសរសេរថា «...វៀតណាមបាព្យាយាមទាក់ទងជាមួយខ្មែរដទៃទៀតព្រមជនជាតិខ្លួន...» សូមអានថា «...វៀតណាមបានព្យាយាមទាក់ទងជាមួយខ្មែរដទៃទៀតនៅកម្ពុជា ព្រមជនជាតិខ្លួន...» ។

សូមអរគុណ ។

# តិប យូណុះ

តិប យូណុះ ត្រូវបានខ្មែរក្រហមចាត់ទុកថាជាខ្មាំងរបស់អង្គការ ដោយសារគាត់បានរត់គេចពីរបបខ្មែរក្រហមចូលព្រៃនៅថ្ងៃទី ១៦ ខែមេសា ឆ្នាំ១៩៧៦ ។ យូណុះ ត្រូវអង្គការចាប់ខ្លួនបាន នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ និងបញ្ជូនមកឃុំឃាំង នៅមន្ទីរ ស-២១ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ រួចយកទៅសម្លាប់ចោលនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ។

ពាក់ព័ន្ធនឹងមូលហេតុដែលបណ្តាលឲ្យ យូណុះ រត់ចូលព្រៃ យូណុះ បានឆ្លើយតាមចម្លើយសារភាពថា «សេន ជាអតីតទាហានបបួលរត់ទៅចូលភ្នំវាលវេញ មានគ្នា៦នាក់ ពេលទៅដល់ភ្នំវាលវេញ រក តួនម៉ិត មិនឃើញ នៅក្នុងព្រៃមិនជួប ក៏ចាំនៅកន្លែងនោះ» ។ តាមសម្តីរបស់ យូណុះ មានន័យថា គោលបំណងនៃការរត់ចូលព្រៃនោះគឺពិតជាមានទំនាក់ទំនងទៅនឹង «តួនម៉ិត» ។ តាមការអះអាងរបស់ ឡិប ទត ជាអ្នករត់ចូលព្រៃនៅក្រុមខុសគ្នាពី យូណុះ ហើយដែលនៅរស់រហូតដល់ពេលនេះបានឲ្យដឹងថាក្រុមអ្នករត់ចូលព្រៃជាមួយគាត់មានគ្នាចំនួន៤០នាក់រត់ចេញពីភូមិជាច្រើនក្នុងស្រុកព្រៃនប់ (ក្នុងនោះមានចាម៩នាក់) ។ កាលពីនៅក្នុងភូមិ គ្រប់គ្នាទាំងអស់នៅក្នុងក្រុមនោះបានទាក់ទងខ្សែរយៈជាមួយ តួនម៉ិត អំពីផែនការរត់ចូលព្រៃ ដោយមាន តួនម៉ិត និងមនុស្សបីនាក់ទៀតឈ្មោះ តាចិន សាយ និង ឡាយ ជាមេដឹកនាំក្រុមហើយជាអ្នកដែលទៅទាក់ទងសុំជំនួយពីប្រទេសម៉ាឡេស៊ី ។ តួនម៉ិត និងតាចិន បានបំផុសប្រជាជនណាដែលមាននិន្នាការមិនពេញចិត្តនឹងខ្មែរក្រហមឲ្យរត់ចូលព្រៃ ។ ដូច្នេះមានមនុស្សចំនួន៤០នាក់ស្ម័គ្រចិត្តចូលព្រៃដើម្បីកសាងជាកម្លាំងទ័ព ។ រួចហើយ តួនម៉ិត តាចិន និងអ្នកបកប្រែពីរនាក់ សាយ និង ឡាយ បានចេញទៅប្រទេសម៉ាឡេស៊ីដើម្បីរកជំនួយ ដោយសន្យាគ្នាថានឹងជួបគ្នានៅពេលដែល តួនម៉ិត និងតាចិន ត្រឡប់មកពីប្រទេសក្រៅក្នុងរយៈពេលមួយខែកន្លះនៅក្នុងព្រៃភ្នំមួយកន្លែងហៅថា «អូរឆាំឆា» ។ ប៉ុន្តែអ្នកទាំង៤០នាក់នោះត្រូវខកបំណងយ៉ាងខ្លាំង ដោយការរង់ចាំ តួនម៉ិត និង តាចិន មិនឃើញត្រឡប់មកវិញសោះ ហើយបើវិលត្រឡប់ទៅភូមិវិញត្រូវមានទោសពៃរ៍ ព្រោះមានឈ្មោះថា «ចោរព្រៃ» ដែលពួកខ្មែរក្រហមនិយាយសំដៅទៅលើជនណាដែលបានរត់គេចពីការគ្រប់គ្រងរបស់ខ្លួនហើយទៅរស់នៅក្នុងព្រៃឬសម្ងំសុខនៅទីកន្លែងណាមួយនៅក្នុងរបបនេះ ។ «ចោរព្រៃ» មានអត្ថន័យមិនខុសពីខ្មាំងរបស់អង្គការទេ ប្រសិនបើចាប់ខ្លួនបានហើយ គឺត្រូវយកទៅសម្លាប់តែម្តង ។ ក្នុងករណីដែល ឡិប ទត បានរៀបរាប់ទាំងប៉ុន្មានយកមកប្រៀបធៀបជាមួយចម្លើយរបស់ យូណុះ «រក តួនម៉ិត មិនឃើញ» ដូចជាបញ្ជាក់នូវហេតុផលតែមួយ គឺ «ចូលព្រៃចាំ តួនម៉ិត ត្រឡប់មកពីរកជំនួយនៅប្រទេសម៉ាឡេស៊ី» ។

ហេតុផលនេះ តាមរយៈការសម្ភាសន៍ជាមួយ ម៉ាន វី (ជាម្តាយ) និង តិប ម៉ាត់ (ជាប្អូនប្រុស) ពុំបានដឹងថា យូណុះ មានទំនាក់ទំនងរឿងរត់ចូលព្រៃនេះជាមួយ តួនម៉ិត ឡើយ ។ គាត់ទាំងពីរនាក់ស្គាល់តួនម៉ិត ។ ម៉ាន វី បានប្រាប់ខ្ញុំថា «តួនម៉ិតជាតួន(គ្រូបង្រៀនសាសនា)របស់ យូណុះ ។ តួនម៉ិត ក៏បានរត់ចូលព្រៃដែរ តែក្រុមផ្សេងពី យូណុះ» ។ តាមការរៀបរាប់របស់ម្តាយនិងប្អូនប្រុសរបស់ យូណុះ មុនពេលរត់ចូលព្រៃមួយអាទិត្យ យូណុះ ក៏បានមកប្រាប់ដំណឹងដល់ក្រុមគ្រួសារជាមុនដែរ ។ ពេលនោះ យូណុះ នៅកងចល័តបោះទីតាំងឆ្ងាយពីភូមិ ចំណែកឪពុកម្តាយនិងប្អូនតូចៗនៅភូមិភ្នំតូច ឃុំស្រែចាម ស្រុកព្រៃនប់ ។ ម៉ាន វី និយាយថា «គេចេះតែចោទថាវា(យូណុះ)ស័ក្តិ១ ប្រជុំថ្ងៃណាក៏ស័ក្តិ១ ប្រជុំថ្ងៃណាក៏ស័ក្តិ១ វាប្រាប់ខ្ញុំថា ម៉ាក់អើយ ខ្ញុំដូចជានៅមិនបានទេ ខ្ញុំទៅហើយ ។ ខ្ញុំសួរវាថា កូនឯងទៅណា វាឆ្លើយថា ខ្ញុំទៅណាក៏ទៅដែរ ។ ខ្ញុំប្រាប់វាថា បើកូនឯងទៅខ្មែរក្រហម ឃើញគេចាប់យកទៅសម្លាប់ហើយ វាថាឥឡូវវាទៅ វាសុំពី អល់ឡោះ វាថា អ៊ិនសារអល់ឡោះ ម្ចិញកាន់អល់ឡោះ ម្ចាស់យើងតែមួយ វាថាបើអល់ឡោះពង្រួចវា វាទៅរៀនទៀត ។ វាផ្តាំដែរថា កីតាបនោះម៉ាក់កុំយកទៅឲ្យគេ បើខ្ញុំទៅ ម៉ាក់ឯងដុតចោលឲ្យអស់ទៅ កុំឲ្យគេយកទៅហែកជក់ថ្នាំ» ។ រួចគាត់បន្តទៀតថា «វា(យូណុះ) ធ្វើទាហាន លន់ ណុល មែន បានប្រហែលមួយឆ្នាំ នៅពេលវា

ត្រឡប់មកពីរៀន ប៉ុន្តែគ្មានស័ក្តិអីទេ» ។ ចំណែក តិប ម៉ាត់ ជាប្អូនប្រុសរបស់ យូណុះ ក៏បានឲ្យហេតុផលនៃការរត់ចូលព្រៃរបស់បងប្រុសបន្ថែមលើម្តាយទៀតថា «បងប្រុសខ្ញុំនៅមិនបានទេ គាត់នៅមិនបានពីរឿងសាសនាយើង (ព្រោះគាត់ជាអ្នករៀនសាសនាឥស្លាមខាង អ៊ូគើម៉ា (សាសនា) គាត់លួចសំបះយ៉ាង (ថ្វាយបង្គំព្រះ) និងដល់ពេលណាសម្រាកគាត់លួចមើលគីតាបគូរ៉អានទៅដល់គាត់ នៅមិនបាន ខ្មែរក្រហមបង្ខំឲ្យគាត់ស៊ីសាច់ជ្រូក អត់ឲ្យមើលអី (អានគីតាបគូរ៉អាន) មិនឲ្យសំបះយ៉ាង ហើយគាត់នៅមិនបាន គាត់ទៅតស៊ូធ្វើចោរព្រៃទៅ» ។ អ្វីដែល ម៉ាន រី និង តិប ម៉ាត់ កំពុងនិយាយពុំមានសរសេរនៅក្នុងចម្លើយសារភាពរបស់ តិប យូណុះ ទេ ។

មុនបែកទៅ ម្តាយបានសួរបញ្ជាក់ យូណុះ ថា «ឯងទៅជាមួយអ្នកណា? ឯងដឹងផ្លូវទេ?» ។ យូណុះ បានឆ្លើយថា «ខ្ញុំទៅមានគ្នា៥នាក់ទៀត ហើយមានគេដឹងផ្លូវ» ។ ពេលនោះម្តាយពុំបានឃាត់កូនទេ «ខ្ញុំមិនដឹងថាឃាត់វាយ៉ាងម៉េចទេ បើវាទៅ ទៅបានរួចផុតក៏ល្អដែរ ពីព្រោះបើនៅគេចោទថា ទាហានបើនៅក៏មិនរស់ដែរ អីចឹងហើយបើទៅក៏ស្លាប់ បើនៅក៏ស្លាប់» ។ តាមចម្លើយសារភាព យូណុះ បានបញ្ជាក់ច្បាស់អំពីឈ្មោះមនុស្សដែលទៅជាមួយគ្នាមាន៥នាក់នោះគឺ «សេន រី អេល មានពីរនាក់(ឈ្មោះអេលដូចគ្នា) និងហាំ» ។ ប៉ុន្មានថ្ងៃក្រោយពីជម្រាបឪពុកម្តាយរួច គឺនៅចំថ្ងៃបុណ្យចូលឆ្នាំខ្មែរ កម្លាំងនៅកងចល័តទាំងអស់ត្រូវបានឲ្យសម្រាកពីការងារនិងចូលរួមពិធីបុណ្យតាមការរៀបចំរបស់ខ្មែរក្រហមដែលមិនមែនតាមប្រពៃណីរបស់ខ្មែរទេ ។ ឆ្លៀតឱកាសនោះ យូណុះ និងបក្ខពួក៥នាក់ទៀតរត់ចូលព្រៃតែម្តង ។ ពេលដឹងថាបាត់ យូណុះ ពីកងចល័ត មេកងបានចាត់មនុស្សឲ្យមកសួរឪពុកម្តាយនៅឯផ្ទះ ។ នៅពេលដែលឪពុកម្តាយនិយាយថាមិនដឹងអំពីការបាត់កូនត្រូវពួកខ្មែរក្រហមព្រមានថា «បើឪពុកម្តាយ យូណុះ មានគំនិតលាក់ខ្ទាំងអង្គការត្រូវសម្លាប់ចោលមួយពូជ» ម៉ាន រី និយាយប្រាប់ ហើយគាត់បញ្ជាក់ទៀតថា «គេនិយាយអីចឹងច្រើនលើកណាស់» ។ ទោះជាយ៉ាងនេះក្តីក៏ក្រុមគ្រួសារនេះហាក់ដូចជានឹកអរទាំងអស់គ្នាទៅវិញ ។ ម៉ាន រី បាននិយាយថា «សំណាងដែរដែលកូនទៅនោះគេគ្រាន់តែមកសួរ គេអត់ចាប់ទោសយើងដែរ» ។

ក្នុងចំណោមមនុស្ស៦នាក់ដែលបានរត់ចូលព្រៃជាមួយ យូណុះ ត្រូវយោធាខ្មែរក្រហមបាញ់និងដាន់មីនស្លាប់អស់៥នាក់ នៅរស់តែ យូណុះ ម្នាក់ឯងប៉ុណ្ណោះ ។ ការបាត់បង់ជីវិតចំពោះ យូណុះ គឺមកពីម្នាក់ៗអត់ឃ្លាន គ្មានស្បៀង ហើយពេលយប់លួចចេញពីក្នុងព្រៃមកដកដំឡូងនៅតាមចម្ការ ។ «នៅជើងភ្នំអន្លង់ធំ ចម្ងាយប្រហែល៣ទៅ៤គីឡូម៉ែត្រពីថ្នល់ជាតិ មានចម្ការដំឡូង ហើយគាត់ (យូណុះ) និងគ្នីគ្នាអត់បាយ មកដកដំឡូងហូបដល់មកយោធាខ្មែរក្រហមឃើញ បានបាញ់ស្លាប់ខ្លះ... គាត់ (យូណុះ) ប្រាប់ទៀតថា ដំឡូងនោះស៊ីឆៅ ជួនកាលស៊ីទាំងសំបកព្រោះគ្មានកាំបិត គ្មានភ្លើងអីទេ» ។ ខាងលើគឺ តិប ម៉ាត់ និយាយតាមដំណើររឿងដែល យូណុះ បាននិយាយប្រាប់គាត់ នៅពេលដែល យូណុះ បានត្រឡប់មកជួបឪពុកម្តាយនិងបងប្អូនរយៈពេលមួយថ្ងៃមុនពេលដែលគាត់រត់ទៅមួយសាទៀត ។ សម្តីរបស់ យូណុះ និយាយប្រាប់ប្អូនប្រុសនោះគឺដូចគ្នាទៅនឹងផ្នែកមួយក្នុងចម្លើយសារភាព «កងទ័ពបដិវត្តន៍បាញ់ស្លាប់អស់៥នាក់ នៅរស់តែ យូណុះ ម្នាក់ឯង... ។ ខ្ញុំបានលួចដំឡូង អំពៅ ផ្សៀវ ខ្នុរ ម្នាស់ ស្វាយ...» ។ ប៉ុន្តែ យូណុះ ពុំបាននិយាយក្នុងចម្លើយសារភាពថា គាត់ធ្លាប់បានរត់មកជួបក្រុមគ្រួសារម្តងណាទេ ។

«វាមកនោះយប់ វាហៅម៉ែៗ វាថាវាមកឲ្យម៉ែគាត់សក់ឲ្យ សក់វាវែងពេកគាត់សក់ឲ្យខ្លីបន្តិច វាថាងាប់អស់ហើយម៉ាក់អើយ នៅសល់តែខ្ញុំម្នាក់ហ្នឹង ដល់វាមកផ្ទះមករៀបខោអាវទៅវិញទៀត» ម៉ាន រី រំឭកពីសម្តីរបស់កូនគាត់ ។ និយាយមកដល់ត្រឹមនេះ គាត់ឈប់មួយសន្ទុះ ដកដង្ហើមធំទឹកមុខស្លុតបញ្ជាក់នូវទុក្ខព្រួយរបស់គាត់ រួចបានបន្តទាំងអួលដើមកលាយឡំនឹងទឹកភ្នែកថា «ពេលវាមកឃើញខ្លួនប្រាណវាស្គម ស្គមមែនទែន វាប្រាប់ថាហូបដំឡូងឆៅទៅអត់មានអីដុតទេ... ពេលវាមកមានអីដៃទទេ ហើយដេកផ្ទះបានពីរយប់ក៏ទៅទៀត» ។ ចំណែក តិប ម៉ាត់ វិញក៏បាននឹកឃើញដែរថា «គាត់(យូណុះ) រត់ចូលព្រៃបានប្រហែលកន្លះខែ គាត់រត់មកវិញដេកផ្ទះបានពីរយប់ ស្គមនៅសល់តែឆ្អឹងនឹងស្បែកទេ ហើយប្រាប់ថានៅសល់ តែគាត់ទេ គេបាញ់ងាប់អស់ហើយ...គាត់មកប្រហែលម៉ោង៩យប់ គាត់

លួចមកនោះហៅសើៗ ខ្ញុំមិនទាំងហ៊ានឆ្លើយផង ម៉េចហ៊ានឆ្លើយ ខ្លាចអាពតយកយើងទៅទៀត ។ ពេលមកខ្ញុំនិង ឪពុកម្ដាយ នៅក្នុងផ្ទះទាំងអស់ គាត់មកអត់មានស្អីទេមិនមានអ្វីជាប់ខ្លួន» គិប ម៉ាត់ និយាយ ។

ក្នុងរយៈពេល១ថ្ងៃដែល យូណុះ មកពួននៅឯផ្ទះបាន ជួបនូវការលំបាកវេទនាយ៉ាងខ្លាំង ។ គិប ម៉ាត់ នៅតែពោលដដែលៗថា «ថ្ងៃនោះ បើហ៊ានគេឃើញត្រូវគេយកទៅសម្លាប់ចោលមួយពូជ» ។ រួចគាត់ក៏បានឲ្យដឹងអំពីសកម្មភាពខ្លះៗដែលគាត់នៅចាំបាន «គាត់(យូណុះ) ពួននៅក្នុងព្រៃអាចម៍ ។ ក្នុងគុម្ពោតព្រៃនោះមានកន្ទុកមួយ គាត់ដេកផ្ទាល់ដីក្នុងកន្ទុកនោះ អត់មានកន្ទេលអីក្រាលទេ ហើយខ្ញុំចេះតែយកមែកឈើ ស្លឹកឈើ កាច់គ្រប អីចឹងទៅ គាត់នៅអីចឹងទៅ ថ្ងៃនោះក្ដៅខ្លាំងណាស់ ។ ធ្វើម៉េចឲ្យបានរស់ម្ញ៉ៃ ដើមទន្ទ្រានខែត្រនិងធាងដូងអី ខ្ញុំចេះតែយកបោះចោលគរលើគាត់ ជិតឈឹងមើលមិនឃើញទេ ហើយពេលមានមនុស្សដើរមក ខ្ញុំធ្វើជាទៅបត់ជើងកន្លែងនោះ កាលណាគេដឹងថាយើងនៅបត់ជើង គេអត់ហ៊ានមកក្បែរទេ» ។ គិប ម៉ាត់ ក៏បានឲ្យដឹងទៀតថា «បងខ្ញុំរត់ចូលធ្វើចោរព្រៃនោះ មានអ្នកណាថាមិនដឹង ពួកប្រជាជនដឹងទាំងអស់គ្នា បើគេឃើញ (ឃើញយូណុះ) គេចាប់ភ្លាមហ្នឹង» ។ ចំណែក ម៉ាន វី ជាម្ដាយ បានរៀបរាប់ថា «ពេលចង់ជួបកូននៅក្នុងគុម្ពោតព្រៃនោះ ឪពុកម្ដាយធ្វើជាទៅបត់ជើងមួយភ្លែតទៅ អត់ហ៊ាននិយាយអីយូរទេ ខ្លាចគេដឹង» ម៉ាន វី ក៏បានបញ្ជាក់អំពីការភិតភ័យដូចគ្នានឹង គិប ម៉ាត់ ដែរ «បើគេដឹងគេចាប់យកទៅសម្លាប់ចោលមួយពូជ» ។ ម៉ាន វី បានរៀបរាប់ទៀតថា «ពេលថ្ងៃកូនអត់មានបាយហូបទេ ហូបតែល្ងាចមួយពេល បាយនោះមានរបបគេឲ្យយើងមួយចាន ប៉ុនៗណឹង» គាត់លើកដៃធ្វើសញ្ញា រួចបន្តទៀតថា «បាយនោះវិលែកធ្វើម៉េចទុកឲ្យកូនបានហូបខ្លះ ម្ដាយវិលែកបន្តិចទៅ ឪពុកបន្តិចទៅ លួចដាក់ហោប៉ៅអាវយកមកផ្ដុំគ្នា អត់មានម្ហូបអីទេ ហើយយកទៅឲ្យវា» ។ និយាយមកដល់ត្រឹមនេះ គាត់និយាយអ្វីលែងកើតតទៅទៀត គាត់ទាញក្រមាចាស់មួយដែលគាត់កំពុងទទូតាមទម្លាប់សាសនាមកជូតទឹកភ្នែកគាត់ ហើយគាត់ចាប់ខ្ញុំឱបយ៉ាងស្និទ្ធដូចជាឱបកូនរបស់គាត់ រួចលាន់មាត់ថា «កូនខ្ញុំមានសាច់ឈាមដូចក្មួយឯងហ្នឹង» ។ ក្នុងករណីដូច គិប ម៉ាត់ និង ម៉ាន វី កំពុងរៀបរាប់នេះគឺគូសបញ្ជាក់ឲ្យឃើញនូវការតស៊ូផ្សារភ្ជាប់មនោសញ្ចេតនាក្នុងស្ថាប័នគ្រួសារមួយ ដែលស្ថាប័ននេះ ខ្មែរក្រហមចាត់វិធានការកម្ទេចចោលដើម្បីឲ្យបាត់បង់អស់ភាពជាគ្រួសារឯកជនរួចឲ្យមានលក្ខណៈជាគ្រួសារសមូហភាពបានស្គាល់និងស្ដាប់តាម«អង្គការ» តែមួយប៉ុណ្ណោះ ។


គិប ម៉ាត់ ប្អូនប្រុសរបស់ គិប យូណុះ

យូណុះ បានពួនពេញមួយថ្ងៃក្នុងគុម្ពោតព្រៃនោះ ។ លុះដល់យប់ម៉ោងប្រហែល៩ យូណុះ បានចេញដំណើរតទៅទៀត ។ «មុនទៅ ឪពុកខ្ញុំនិយាយថា ធ្វើម៉េចកូនអើយ បើនៅក៏ស្លាប់ដែរ ពុកមិនឃាត់ទេ ទៅបើរួចក៏បានល្អហើយ» គិប ម៉ាត់ និយាយ ។ គិប ម៉ាត់ ក៏បានរំឭកពីសម្ដីផ្ដាំផ្ញើរបស់បងប្រុសមុននឹងបែកគ្នារហូតថា «ប្អូនអើយ អញចេញទៅទៀតហើយ បើស្លាប់រស់ក៏ប្រការអល់ឡោះដែរ បើរស់គង់ជួបគ្នាទៀត» ។ តាមការរៀបរាប់របស់ គិប ម៉ាត់ គឺនៅពេល យូណុះ ចេញដំណើរទៅមានឪពុកជូនទៅដល់ជើងព្រៃមួយកន្លែងហៅថា «បឹងតាឡោះ» ចម្ងាយប្រហែលមួយគីឡូម៉ែត្រពីភូមិភ្នំតូច ។ យូណុះ យក កីតាបគួរអាន កន្ទីប និងសារុង រេចជាបង្វេចមួយស្ពាយទៅជាមួយ ។ «ក្រោយពីនោះប្រហែលកន្លះខែឮថា គេចាប់បញ្ជូនទៅកោះខ្យងក្នុងឃុំ អូរជ្រៅ ស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្នខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ) ឮថាមានគេឃើញ

បណ្តើរទៅ គ្រាន់តែពុអត់ហ៊ានសួរគេទេ» តិប ម៉ាត់ និយាយ ។ គ្មានអ្នកណាម្នាក់បានដឹងច្បាស់ពីពេលវេលានៃការចាប់ខ្លួនរបស់ យូណុះទេ ។ តាមចម្លើយសារភាព យូណុះ ចាប់ខ្លួនបាន នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ ។ បន្ទាប់ពីបានឮដំណឹងនោះ មកប្រហែល៥ខែ ឪពុករបស់ យូណុះ បានធ្លាក់ខ្លួនឈឺ រួច បញ្ជូនទៅមន្ទីរពេទ្យ «បឹងតាស្រី» ជាពេទ្យឃុំនៅទីនោះ គាត់បាន ស្លាប់នៅទីនោះ ។ ការស្លាប់របស់ឪពុក យូណុះ បង្ហាញឲ្យឃើញ ពីលក្ខណៈវិស័យសុខាភិបាលក្នុងរបបខ្មែរក្រហមដែលមានគំនិត បោះបង់ចោលបច្ចេកទេសសុខាភិបាលដូចជាមន្ទីរពេទ្យគ្រឿង បរិក្ខារពេទ្យនិងថ្នាំពេទ្យដែលបណ្ឌិតទាំងឡាយរកឃើញ ។ សូម្បីតែសៀវភៅ«រៀនអក្សរ» សម្រាប់សិស្សថ្នាក់ទី២នៅក្នុង របបនោះក៏មានមេរៀនសម្រាប់អប់រំក្មេងៗឲ្យដើរតាមមាគ៌ានេះ ដែរ« ពូមីងផ្សំថ្នាំស្ពុង ថ្នាំដុស ថ្នាំលាប ថ្នាំសូនជាគ្រាប់បានច្រើន មុខ...ពូមីងធ្វើសេរ៉ូម ថ្នាំរីត ថ្នាំចាក់ ប្រេកដប ប្រេកអំពូល និងថ្នាំគ្រាប់...ឯវត្ថុធាតុដើមសម្រាប់ផ្សំ ពូមីងយកឫសឫស្សី វល្លិនិងសត្វផ្សេងៗ...» ។ «នៅគ្រប់ការដ្ឋានទូទាំងប្រទេសសុទ្ធតែ មានពូមីងពេទ្យបដិវត្តយើងនៅប្រចាំការជានិច្ច ។ ពូមីងចុះរួម ប្រឡូកធ្វើពលកម្មបង្កបង្កើនផលជាមួយពុកម៉ែផងនិងជួយ ព្យាបាលជំងឺនៅនឹងកន្លែងផង» ។ សាកសពឪពុករបស់យូណុះ ត្រូវយោធាខ្មែរក្រហមបដិសេធមិនព្រមឲ្យក្រុមគ្រួសារយក មកផ្ទះដើម្បីធ្វើបុណ្យតាមប្រពៃណីសាសនាទេ ។

ចម្លើយសារភាពរបស់ យូណុះ មាន១៣ទំព័រ ។ នៅលើ ទំព័រដំបូងនៃឯកសារនេះសរសេរថា «តិប យូណុះ ចោរព្រៃចាប់ មកពីភ្នំវាលរេញ កំពត» ។ នៅទំព័រទី៤សរសេរអំពីប្រវត្តិផ្ទាល់ របស់យូណុះ ដែលខ្ញុំសូមដកស្រង់ខ្លះៗៈ «ខែមករាដល់ខែធ្នូ ឆ្នាំ១៩៧២ ចូលធ្វើទាហានសេ.អ៊ី.អា នៅកំពង់សោម ឋានៈ ពលទោ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជម្លៀសទៅភ្នំតូច ឃុំស្រែចាម ស្រុកព្រៃនប់ ខេត្តកំពត ជម្លៀសចេញពីភូមិទួល ទទឹង ឃុំសំរុង ស្រុកព្រៃនប់(ជាឃុំដែលនៅជិតខាងគ្នា) ។ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ១៩៧៦ សេន បបួលចូលព្រៃ (ម្តាយយូណុះ និយាយថា យូណុះ រត់ចូលព្រៃនៅថ្ងៃចូលឆ្នាំរោង) ។ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ អង្គការចាប់បាន» ។ តាមបញ្ជីកម្មុចអ្នក ទោសមន្ទីរ ស-២១សរសេរថា «តិប យូណុះ ថ្ងៃចូលទី២០ ខែឧសភា ឆ្នាំ១៩៧៦ ថ្ងៃកម្ទេចទី១០ ខែមិថុនា ឆ្នាំ១៩៧៦» ។

ក្នុងចម្លើយសារភាពពីទំព័រទី៥-៧ ផ្នែក«ឪពុកម្តាយនិង បងប្អូនបង្កើត» យូណុះ ឆ្លើយដូចគ្នាតាមចម្លើយសាក្សី ។ ផ្នែក «លំនាំខ្សែចាត់តាំង» សរសេរថា «តួនម៉ិត ជាមេធំជាងគេ កសាងកម្លាំងក្បត់ពីរនាក់ ឈ្មោះ សេន និង ឡេះ ។ ឡេះ កសាង កម្លាំងនៅក្នុងភូមិបានបួននាក់...សេន កសាងកម្លាំងចោរព្រៃ បាន៥នាក់...ក្នុងចំណោមនោះក៏មានឈ្មោះ តិប យូណុះ ដែរ» ។ តាមការសាកសួរពត៌មានដើម្បីរកជួបមនុស្សដែលមានឈ្មោះ ទាំងអស់នេះនៅតាមភូមិចាមក្នុងខ័ណ្ឌព្រៃនប់ ហើយត្រូវបានអ្នក ភូមិប្រាប់ខ្ញុំថា ក្រោយឆ្នាំ១៩៧៩ មានតែ តួនម៉ិត ម្នាក់ទេដែល នៅរស់ ក្រៅពីនោះបាត់ខ្លួនទាំងអស់ក្នុងរបបខ្មែរក្រហម ។

មិនមែនត្រឹមតែ យូណុះ ម្នាក់ទេដែលបានរត់ចូលព្រៃ ហើយត្រូវខ្មែរក្រហមសម្លាប់ ។ យោងតាម ឡិប ទត ក្រៅពី ក្រុមគាត់មានគ្នា៤០នាក់ គាត់បានឃើញពួកអ្នកចូលព្រៃមួយ ក្រុមទៀតមានគ្នា១៩នាក់ ភាគច្រើនជាជនជាតិចាម ប៉ុន្តែក្រុម ទាំងពីរនេះមិនបានបញ្ចូលកម្លាំងគ្នាទេ គឺនៅតាមទីកន្លែងរៀងៗ ខ្លួន ហើយក៏គ្មានការទាក់ទងគ្នាដែរ ។ ឡិប ទត ពុំបានជួបគ្នាជា មួយក្រុម៦នាក់ឡើយ(ក្រុមយូណុះ) ។ ដើមហេតុដំបូង ឡិប ទត បាននិយាយថា «តាចិន ជាគណៈស្រុកព្រៃនប់របស់ខ្មែរក្រហម បានមកប្រជុំ ។ ប្រជុំនោះរើសក្រុមពិសេស អ្នកដែលធ្លាប់ស្គាល់ ចិត្តគ្នាហើយ ហើយទៅប្រជុំនៅក្បែរជ្រលងជិតមាត់ទឹកក្នុង ភូមិទួលទទឹង ឃុំសំរុង ស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្នខណ្ឌ ព្រៃនប់ ក្រុងព្រះសីហនុ) ប្រហែលជា៣០នាក់សុទ្ធតែចាមទាំង អស់ ។ តាចិននិយាយថា ឥឡូវជីវិតបងផ្ញើលើប្អូនៗទាំងអស់ ហើយ... ឥឡូវគេចាប់ផ្តើមបំបិទសាសនា គេចាប់ផ្តើមបាយរួម ហើយឥឡូវបើបងប្អូនណាមានលទ្ធភាពចេញកសាងជាកម្លាំងទ័ព គឺបបួលគ្នាចូលព្រៃទៅ» ។ ប្រជុំរួចនៅព្រឹកថ្ងៃបន្ទាប់ តាចិន តួនម៉ិត និងអ្នកបកប្រែភាសាពីរនាក់ឈ្មោះ សាយ និង ឡាយ បានឡើងរថយន្តមួយបើកសំដៅឆ្ពោះទៅខាងកំពង់សោម (ក្រុង ព្រះសីហនុ) ។ តាមសម្តីរបស់ ឡិប ទត ថា តាចិននោះប្រាប់ គាត់ថា គាត់ (តាចិន) តួនម៉ិត និងអ្នកបកប្រែភាសា ធ្វើដំណើរ

ទៅប្រទេសម៉ាឡេស៊ីតាមទូកផ្ទាល់ខ្លួនដើម្បីទាក់ទងកម្លាំងជំនួយពីខាងក្រៅ និងយកមាសដែលគាត់ប្រមូលបានពីប្រជាជនទៅដូរយកអាវុធ ។ ឡិប ទត បានបន្ថែមទៀតថា «តាចិន សន្យានឹងពួកខ្ញុំថា មួយខែកន្លះទៀតជួបគ្នានៅមាត់ពាមកំពង់ស្នាញ់ (ព្រៃភ្នំមួយកន្លែងនៅខាងលិចវ័ណ្ឌព្រៃនប់) ។ ប៉ុន្តែអត់ដឹងទាល់តែសោះថាអ្នកដែលទៅនោះអត់មានត្រឡប់មកវិញទេ ព្រោះទូកនោះទៅបុកថ្មនៅក្បែរម៉ាឡេស៊ីងាប់អស់ រស់តែ តួនម៉ិត មួយទេ» ។ តួនម៉ិត ទៅទាក់ទងជាមួយម៉ាឡេស៊ីអត់បានលទ្ធផលអ្វីទេ ព្រោះមាសក៏បាត់ គ្នាក៏ស្លាប់អស់ ហើយរកវិធីវិលត្រឡប់មកជួបកម្លាំងដែលនៅរង់ចាំក្នុងប្រទេសនេះក៏មិនបាន ។ ចំណែកអ្នកនៅក្នុងប្រទេសវិញមានសង្ឃឹមថា នឹងមានអ្នកជំនួយពីខាងក្រៅនឹងមានអាវុធកាន់គ្រប់ដៃ ដូច្នេះក៏នាំគ្នារត់ចូលព្រៃយ៉ាងច្រើន ។ នៅពេលដែលក្ដីសង្ឃឹមនោះមិនបានសម្រេចក៏ខកខ្លួនហើយដឹងថា ប្រសិនបើវិលមកភូមិវិញត្រូវខ្មែរក្រហមសម្លាប់ចោល ម្ល៉ោះហើយក៏ទ្រាំរស់ពួននៅក្នុងព្រៃរហូតដល់ឆ្នាំ១៩៧៧ ទើបមានការវាយប្រហារពីយោធាខ្មែរក្រហមដែលបណ្ដាលឲ្យស្លាប់ស្ទើរតែទាំងអស់ ។ នៅសល់ចំនួន១៥នាក់ ក្នុងចំណោមក្រុម៤០នាក់នោះ បានរត់ទៅប្រទេសវៀតណាម ហើយធ្វើកងទ័ពក្នុងរណសិរ្សសាមគ្គីសង្គ្រោះជាតិមាតុភូមិកម្ពុជាសហការជាមួយវៀតណាម វាយខ្មែរក្រហមរហូតបានទទួលជ័យជម្នះ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ចំពោះក្រុម១៩នាក់និងក្រុម៦នាក់ទៀតនោះ ពុំមានអ្នកណាម្នាក់នៅរស់ឡើយ ។ ចំពោះ តួនម៉ិត បានត្រឡប់មកភូមិកំណើតនៅក្រោយឆ្នាំ១៩៧៩ ហើយបានជំណាលប្រាប់អំពីដំណើររឿងរបស់គាត់ដូច ឡិប ទត និយាយខាងលើនេះដែរ ។ តួនម៉ិតទើបតែស្លាប់ក្នុងឆ្នាំ១៩៩៩ នៅព្រៃថ្នង ខេត្តកំពត ។ អ្នកដែលរត់ចូលព្រៃទាំងអស់ក្នុងស្រុកព្រៃនប់ មានចំនួន៦៨នាក់(រាប់បញ្ចូលទាំងអ្នកទៅប្រទេសម៉ាឡេស៊ី) ។ មកដល់ឆ្នាំ១៩៧៩ អ្នកទាំងនោះនៅរស់តែ១៦នាក់ ។ ប្រជាជនភាគច្រើននៅក្នុងវ័ណ្ឌព្រៃនប់ បច្ចុប្បន្នបានសន្និដ្ឋានថា គាត់ត្រូវបានជម្លៀសមកខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង នៅឆ្នាំ១៩៧៧ គឺបណ្ដាលមកពីមានអ្នកភូមិខ្លះរត់ចូលព្រៃធ្វើជា «ចោរព្រៃ» នេះឯង ។

**អ៊ីសា ឧស្មាន**

**(តមកពីទំព័រទី៦)** ដោយមិនទាន់យល់ មិនជ្រះស្រឡះ ឬស្អុកស្អាញទោមនស្សក្នុងចិត្តគំនិតក្នុងសតិអារម្មណ៍ជាដាច់ខាត ។ឧទាហរណ៍ៈ ក្នុងការដឹកនាំប្រជាជនមហាជនលើកប្រព័ន្ធភ្លឺស្រែថ្មី បើប្រជាជនមហាជនមិនទាន់យល់ពីសារសំខាន់នៃប្រព័ន្ធភ្លឺថ្មី មិនទាន់ឃើញផលប្រយោជន៍របស់ខ្លួនក្នុងការលើកប្រព័ន្ធភ្លឺថ្មី ឬមិនទាន់មានជំនឿលើប្រព័ន្ធភ្លឺថ្មីថាអាចដោះស្រាយបញ្ហាទឹក បើយើងមានមាគ៌ាមហាជនត្រឹមត្រូវ យើងមិនបង្ខិតបង្ខំប្រជាជន មហាជនឲ្យលើកភ្លឺថ្មី ជីកប្រឡាយថ្មីតាមផែនការរបស់បក្សដែលបានដាក់ចុះដោយប្រើអាជ្ញាសម្ភុតគំរាមកំហែងថាបើអ្នកណាមិនធ្វើបដិវត្តន៍អ្នកនោះជាជនក្បត់នោះឡើយ ។ តែយើងក៏មិនបណ្ដែតបណ្ដោយទុកឲ្យប្រជាជននៅតែរក្សាប្រពៃណីនិងទម្លាប់ធ្វើភ្លឺតូចៗក្រងិកក្រងក់ដូចមុនទៀតដែរ ។ បើមានមាគ៌ាមហាជនត្រឹមត្រូវនោះយើងត្រូវធ្វើការឃោសនាអប់រំពន្យល់ណែនាំប្រជាជនមហាជនជាមុនសិន ឲ្យគេយល់ ឲ្យគេឃើញនូវសារសំខាន់នៃប្រព័ន្ធភ្លឺថ្មីនិងប្រឡាយថ្មី ឲ្យគេឃើញនូវផលប្រយោជន៍គ្រប់យ៉ាងរបស់គេក្នុងការលើកប្រព័ន្ធភ្លឺថ្មីនិងប្រឡាយថ្មីនេះ ។ ឲ្យគេជឿជាក់ហើយជ្រះស្រឡះក្នុងសតិអារម្មណ៍ឃើញថាគេចំណាយកម្លាំងលើកប្រព័ន្ធភ្លឺថ្មីនិងប្រឡាយថ្មីនេះគឺដើម្បីដោះស្រាយបញ្ហាទឹកបង្កបង្កើនផលគឺជាការរួមចំណែកការពារនិងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យយ៉ាងសកម្មស័ក្ដិសិទ្ធនិងដោយផ្ទាល់ដៃគេតែម្ដង ។ រួចហើយទើបយើងបំផុសនិងជំរុញចលនាលើកប្រព័ន្ធភ្លឺថ្មីជីកប្រឡាយថ្មីនេះ ហើយដឹកនាំនិងចាត់តាំងប្រជាជនមហាជនធ្វើការងារជាក់ស្ដែងនៅលើការដ្ឋានតែម្ដង ។ ធ្វើយ៉ាងនេះទើបចលនាមហាជនផុសផុលស្រាក់ស្រាំទាំងយប់ទាំងថ្ងៃជាប់ជានិច្ចពុំមានពេលណាចុះទ្រោមឡើយ ។ ការងារក៏លឿនប្រជាជនក៏សប្បាយរីករាយសោមនស្សជ្រះថ្លាទាំងអស់គ្នា ។ នេះហើយជាអត្ថន័យពិតប្រាកដនៃទស្សនៈមហាជននិងមាគ៌ាមហាជន ។ ក្នុងគ្រប់កិច្ចការតូចធំធ្ងន់ស្រាលលំបាកស្រួលទាំងអស់ឲ្យតែយើងមានទស្សនៈមហាជនរឹងប៉ឹងនិងមានមាគ៌ាមហាជនត្រឹមត្រូវយើងប្រាកដជាសម្រេចបានទិសដៅដោយជោគជ័យពុំខានឡើយ ។

# វង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា

**(តពីលេខមុន)** *រណ្តៅសាកសពធំដែលមានមកដល់បច្ចុប្បន្ននេះត្រូវបានជឿថាមានផ្ទុកជនរងគ្រោះក្នុងមួយរណ្តៅចំនួន៧ពាន់នាក់ ។*

*នៅក្នុងស្រុកមួយចំនួនដែលក្រុមដែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅដល់មានការជឿជាក់ថា មានទីតាំងមួយចំនួនផ្សេងទៀតដែលសេសសល់ ហើយរណ្តៅនីមួយៗមានទំហំធំ ប៉ុន្តែក្រុមដែនទីមិនអាចទៅដល់ដោយសារសភាពការណ៍មិនអំណោយផលដូចជាមានបញ្ហាសន្តិសុខ (ចម្ការមីន) អំពើឃោរឃៅ ឬបញ្ហាផ្សេងៗ ។ ដូច្នេះនៅសេសសល់ទីតាំងមួយចំនួនទៀតដែលច្រើនជាងទិន្នន័យដំបូងប្រមូលបានពីស្រុកផ្សេងៗដែលក្រុមដែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការផែនរកន្លងមក ។ លើសពីនេះទៅទៀត ភាគច្រើនចំពោះទីតាំងដែលត្រូវបានចុះទៅធ្វើការស្រាវជ្រាវរួចហើយ មានហេតុផលជាច្រើនដែលក្រុមធ្វើដែនទីគ្មានបំណងធ្វើការប៉ាន់ស្មានចំនួនពិតនៃរណ្តៅសាកសព ។ ដូច្នេះទីតាំងទាំងនោះត្រូវបានចាត់ទុកថាគ្មានរណ្តៅសាកសពនិងជនរងគ្រោះ ។ (យើងនឹងត្រឡប់មកបញ្ហាដែលនៅខាងក្រោមនេះវិញក្រោមប្រធានបទដែលមានការកំណត់ទិន្នន័យ) ។ ដូចនេះរណ្តៅសាកសពចំនួន២ម៉ឺនដែលបានមកពីទិន្នន័យដើមនៅតែជាការប៉ាន់ស្មានមិនទាន់មានលក្ខណៈច្បាស់លាស់ដាច់ស្រេចនៅឡើយទេ សូម្បីតែទីតាំងក្នុងស្រុកចំនួន១៥០ដែលត្រូវបានចុះធ្វើដែនទីរួចមកហើយក៏ដូច្នេះដែរ ។*

## ការបែងចែកទិន្នន័យ

*តារាងទី១និងទី២ (តារាងមានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) បង្ហាញថា មកដល់សព្វថ្ងៃនេះក្រុមចុះធ្វើដែនទីរណ្តៅសាកសពបានរកឃើញគុករបស់ខ្មែរក្រហមចំនួន១២៥ ដែលស្ទើរតែមានន័យថាក្នុងស្រុកមួយមានគុកមួយទៅហើយ ។ ចំនួននេះពិតជាខ្ពស់ណាស់ចំពោះប្រទេសមួយដែលមន្ត្រីដឹកនាំរបស់ខ្លួនបានបដិសេធថាមិនមានគុកទាល់តែសោះ ។ ទិន្នន័យបង្ហាញថា គិតជាមធ្យមក្នុងគុកនីមួយៗមានអ្នកទោសចំនួនមួយម៉ឺននាក់ត្រូវបាន «ដាក់ឲ្យដំណើរការ» ក្រោមប្រព័ន្ធគុកទាំងនេះ ហើយជាលទ្ធផល អ្នកទោសត្រូវស្លាប់បាត់បង់ជីវិតទាំងអស់ ។ ប៉ុន្តែដូចដែលបានបង្ហាញនៅក្នុងតារាងទី២ដូច្នេះដែរ មធ្យមភាគនេះមានភាពខុសប្លែកគ្នាច្រើនពីខេត្តមួយទៅខេត្តមួយ ។ នៅក្នុងខេត្តមួយចំនួនដូចជាក្រុងព្រះសីហនុ និងខេត្តស្វាយរៀង ចំនួនមធ្យមភាគមានកម្រិតទាបជាងច្រើន គឺប្រហាក់ប្រហែល៥០០នាក់ក្នុងគុកមួយ ហើយខេត្តផ្សេងៗទៀតដូចជាខេត្តកំពង់ឆ្នាំងនិងខេត្តកំពង់ធំ ចំនួនមធ្យមភាគគឺមានកម្រិតខ្ពស់រហូតដល់ ៤ម៉ឺននាក់ ។ ចំនួនជាមធ្យមនៃរណ្តៅសាកសពនៅក្នុងបរិវេណគុក ។ គឺ១៥០រណ្តៅ ហើយចំពោះតួលេខរណ្តៅនៅតាមខេត្តនានាគឺខ្ពស់ជាង ។ ក្នុងគុកមួយមានចាប់ពី១រណ្តៅនៅខេត្តរតនៈគិរីរហូតដល់៨រណ្តៅនៅខេត្តក្រចេះ និង៥២៤រណ្តៅក្នុងគុកមួយនៅខេត្តកំពង់ឆ្នាំង ។*

*តារាងទី២បង្ហាញចំនួនគិតជាមធ្យមគឺ៤២រណ្តៅដែលមានជនរងគ្រោះស្លាប់ប្រមាណ៣០០០នាក់ ក្នុងមួយទីតាំងដែលជាការបញ្ជាក់អំពីការរកឃើញរួចមក ហើយដែលថាមានរណ្តៅពី៣ទៅ៤ក្នុងគុកនីមួយៗ ។*

*តារាងទី៣ ទិន្នន័យរបាយប្រជាជននៅក្នុងប្រទេសកម្ពុជា ។ ដោយប្រើប្រាស់នូវការប៉ាន់ស្មានជាលក្ខណៈភូមិសាស្ត្រនៃរបាយប្រជាជនតាមខេត្តគិតចាប់ពីឆ្នាំ១៩៧៥ក្រោយពីការជម្លៀសប្រជាជនដំបូងដោយខ្មែរក្រហម យើងឃើញថារបាយប្រជាជនមានលក្ខណៈខុសៗគ្នាច្រើននៅតាមតំបន់ផ្សេងៗ ។ នៅតំបន់ភ្នំ ភូមិភាគព្រៃស្រោងដូចជាខេត្តរតនៈគិរី មណ្ឌលគិរី និងខេត្តស្ទឹងត្រែង ចំនួនប្រជាជនក្នុងខេត្តនីមួយៗមានតិចជាង១ភាគរយនៃប្រជាជនសរុបក្នុងប្រទេសទាំងមូល ។ ចំណែកឯនៅតាមខេត្តនៅតំបន់ទំនាបដែលមានប្រជាជនរស់នៅច្រើនដូចជាខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ និងខេត្តកណ្តាលគឺចំនួនប្រជាជនសរុបនៃខេត្តទាំងអស់នេះស្ទើរនឹងពាក់កណ្តាលនៃចំនួនប្រជាជនទាំងអស់ ។*

*ដោយប្រៀបធៀបចំនួនជនរងគ្រោះដែលត្រូវបានរក*

ឃើញនៅតាមខេត្តនីមួយៗជាមួយនឹងចំនួនប្រជាជននៅក្នុងខេត្តនោះអាចជួយឲ្យយើងមានអារម្មណ៍កាន់តែធូរស្បើយចំពោះទម្រង់នៃអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម ។ ខេត្តកំពង់ឆ្នាំងជាករណីពិសេសប្លែកពីខេត្តផ្សេងៗដែលមានចំនួនប្រជាជនសរុបតែ៤ភាគរយប៉ុណ្ណោះ ប៉ុន្តែជនរងគ្រោះមានរហូតទៅដល់ ២០ភាគរយ ។ នេះបណ្តាលមកពីមានប្រជាជនជាច្រើនត្រូវបានបញ្ជូនមកពីភូមិភាគបូព៌ារបស់កម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលមួយដែលហៅថា «ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា» យកទៅសម្លាប់នៅខេត្តកំពង់ឆ្នាំង នាពាក់កណ្តាលឆ្នាំ១៩៧៨ ។ កត្តាមួយទៀតដែលបណ្តាលឲ្យមានអត្រាអសមាមាត្រនៃការសម្លាប់នៅក្នុងខេត្តកំពង់ឆ្នាំងគឺថា ដោយមានជំនួយឧបត្ថម្ភផ្នែកបច្ចេកទេសពីប្រទេសចិន ខ្មែរក្រហមស្ថិតក្នុងដំណើរការសាងសង់បរិវេណព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំងដោយប្រើពលកម្មក្នុងលក្ខណៈទាសភាព ។ យោងតាមពត៌មានផ្សេងៗមួយចំនួនទៀតបានបង្ហាញថា ក្រុមពលកម្មក្នុងលក្ខណៈទាសភាពដែលត្រូវបានបង្ខំឲ្យធ្វើការសាងសង់ក្នុងទ្រង់ទ្រាយធំបែបនេះ ត្រូវបានសម្លាប់ទាំងហ្វូងៗពេលដែលខ្លួនចុះខ្សោយកម្លាំងមិនអាចបំពេញកិច្ចការបានល្អ ។ ខេត្តកំពង់ឆ្នាំងមានតួលេខអំពើឃោរឃៅខ្ពស់ជាងគេដែលបានមកពីការយកភាគរយសរុបនៃជនរងគ្រោះចែកជាមួយនឹងភាគរយប្រជាជនសរុប ។

ជាទូទៅ តួលេខបញ្ជាក់ពីអំពើឃោរឃៅតាមខេត្តមានចំនួនប្រមាណ១ ហើយភាគច្រើនស្ទើរតែទាំងអស់នៃខេត្តផ្សេងៗមានតួលេខចាប់ពី០,៥ដល់១,៥ ដែលជាការបញ្ជាក់ពីលក្ខណៈដូចគ្នាទូទៅនៃអត្រាការកាប់សម្លាប់នៅគ្រប់កន្លែងទូទាំងប្រទេសកម្ពុជា ។ នៅចុងតារាងចាប់ពីខេត្តកំពង់ឆ្នាំងមក មានខេត្តមួយទៀតគឺខេត្តស្វាយរៀងដែលមានចំណាត់ថ្នាក់អំពើឃោរឃៅ ០,១៧ ។ នេះប្រហែលមកពីជនរងគ្រោះក្នុងចំនួនច្រើននៅខេត្តស្វាយរៀងដែលមានព្រំប្រទល់បីជ្រុងជាប់នឹងប្រទេសវៀតណាមត្រូវបានបញ្ជូនមកខេត្តដែលនៅជិតៗនឹងខេត្ត ហើយនិងមានភាពងាយស្រួលក្នុងការសម្លាប់ ។ ករណីពិសេសរបៀបនេះក៏ឃើញមានដែរនៅតាមខេត្តនានានៅភាគឦសានដែលក្នុងនោះខេត្តក្រចេះមានអត្រា០,២៧ និងរតនៈគិរី០,៣១ ។ លទ្ធផលនេះមានលក្ខណៈស្របគ្នាទៅនឹងការពិតដែលមានការដឹងឮជាទូទៅថាមេដឹកនាំខ្មែរក្រហម ប៉ុល ពត បានបង្កើតនូវទ្រឹស្តីនរវិទ្យាថាជនជាតិភាគតិចរស់នៅភាគឦសាននៃប្រទេសកម្ពុជាគឺជាជនជាតិកម្ពុជាសុទ្ធសាធដែលស្អាតបរិសុទ្ធគ្មានទទួលនូវការបំពុលដោយព្រះពុទ្ធសាសនា ប្រពៃណីផ្សេងៗរបស់ខ្មែរនិង «ជំងឺ» ទីក្រុងដូចជាការធ្វើជំនួញសោះឡើយ ។ ដូច្នេះការទាមទារពីមជ្ឈិមបក្សដើម្បីបោសសម្អាតក្រុមជនជាតិទាំងអស់នេះមានតិច បើប្រៀបធៀបទៅនឹងប្រជាជននៅទំនាប ។ គួរបញ្ជាក់ដែរថា ទិន្នន័យទទួលបាននៅខេត្តបាត់ដំបងនៅមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ។ មកដល់សព្វថ្ងៃនេះមានតែឃុំមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានប្រមូលយកទិន្នន័យដោយពេញលេញត្រឹមត្រូវ ។ ដូចនេះប្រសិនបើទិន្នន័យត្រូវបានប្រមូលបានច្រើនជាងនេះតួលេខតារាងកំណត់អំពើឃោរឃៅនៅក្នុងខេត្តបាត់ដំបងនឹងកើនឡើងខ្ពស់ ។

## ការប៉ាន់ស្មានចំនួនមនុស្សស្លាប់

ក្រៅពីការសម្លាប់នៅមានមូលហេតុផ្សេងទៀតដែលនាំឲ្យមានការបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដូចជា ការបង្អត់អាហារ ជំងឺ និងការធ្វើការបាក់កម្លាំង ។ ភស្តុតាងច្បាស់លាស់ចេញពីអ្នកដែលមានវាសនារស់រានមានជីវិតបង្ហាញយ៉ាងប្រត្យក្សថាចំនួនមនុស្សស្លាប់បណ្តាលមកពីករណីដូចបានរៀបរាប់នេះក៏មានកម្រិតខ្ពស់ណាស់ដែរ ។ តើខ្ពស់ដល់កម្រិតណាទៅ? ។

យោងតាមលោក ប៊ែន គៀនិន បានឲ្យដឹងថា ទិន្នន័យដែលប្រមូលបានដោយ មីលតុន អូសបូន បញ្ជាក់ថា ចំនួនមនុស្សដែលត្រូវបានសម្លាប់នៅក្នុងជំនាន់ខ្មែរក្រហមមានតែ៣១ភាគរយតែប៉ុណ្ណោះ ។ អ្នកថតរូបឈ្មោះ ម៉ារ៉េក ស្លីវិនស្គី ធ្វើការប៉ាន់ស្មានថា មានមនុស្សចំនួន៤០ភាគរយស្លាប់ដោយការកាប់សម្លាប់ ៣៦ភាគរយដោយសារការបង្អត់អាហារ ១៣ភាគរយដោយសារជំងឺ ហើយនៅសល់ពីនោះស្លាប់នៅសមរភូមិឬស្លាប់តាមលក្ខណៈធម្មជាតិ ។ ស្នាដៃសំណេររបស់អ្នកវិទ្យាសាស្ត្រផ្នែកនយោបាយ ស៊ីវ ហេដឌ័រ បង្ហាញថាចំនួនប្រជាជនថ្មីស្លាប់មាន៣៣ភាគរយ ហើយប្រជាជនមូលដ្ឋានមាន៥០ភាគរយ ។ ដូច្នេះ តាមរយៈការប៉ាន់ស្មានដែលមានសមាមាត្រផ្សេងៗពីគ្នាចំនួនមនុស្សស្លាប់បាត់បង់ជីវិតដោយការកាប់សម្លាប់មានចាប់

ពី៣០ភាគរយដល់៥០ភាគរយចំពោះប្រជាជនមូលដ្ឋាន ។

តួលេខនេះមានកម្រិតខ្ពស់ណាស់ ។ ប្រសិនបើការគណនាសមាមាត្រចំនួនមនុស្សស្លាប់ដោយមូលហេតុផ្សេងៗមានលក្ខណៈពិតនោះ យើងអាចចាប់ផ្តើមទាញសេចក្តីសន្និដ្ឋានច្បាស់លាស់បានហើយ ។ វាអាចមានលក្ខណៈប្រាកដប្រជាក្នុងការសន្និដ្ឋានថាការប៉ាន់ស្មានតាំងពីដើមដំបូងរបស់ប្រទេសកម្ពុជាដែលថាមានមនុស្សស្លាប់ចំនួន៣លាន៣សែននាក់នៅក្នុងជំនាន់ខ្មែរក្រហមអាចដល់កម្រិតមួយដែលជិតត្រូវមែនទែនហើយ ។

ប្រសិនបើមានការស្លាប់ដោយការកាប់សម្លាប់មានចំនួន៣១ភាគរយ ដូច្នេះចំនួនមនុស្សស្លាប់ទាំងអស់ដែលមាន៣លាន៣សែននាក់នឹងមានចំនួនជាង១លាន ដែលស្លាប់ដោយការកាប់សម្លាប់ ហើយទិន្នន័យនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថាមានជនរងគ្រោះស្លាប់ដោយការកាប់សម្លាប់ច្រើនជាងចំនួនដែលបានបញ្ជាក់ខាងលើទៅទៀត ។ ប្រសិនបើផ្អែកទៅលើការប៉ាន់ស្មានរបស់ ស៊ីវ ហេឌ័រ ដែលថាមានមនុស្សស្លាប់ចំនួន៥០ភាគរយប្រៀបធៀបទៅនឹងចំនួនប្រជាជនសរុបនិងផ្អែកទៅលើការសិក្សាស្រាវជ្រាវរណ្តៅសាកសពដែលបង្ហាញថាមានជនរងគ្រោះបាត់បង់ជីវិតដោយសារការកាប់សម្លាប់ដល់ទៅ១លាន៥សែននាក់ នោះយើងអាចទាញបានថាចំនួនមនុស្សស្លាប់ទាំងអស់នៅក្នុងរបបខ្មែរក្រហមមានទៅដល់ជិត៣លាននាក់ ។ នៅក្នុងករណីទាំងពីរនេះយើងអាចទាញសេចក្តីសន្និដ្ឋានថាប្រជាជនកម្ពុជាដែលស្លាប់មុនអាយុនៅក្នុងរបបខ្មែរក្រហមមិនមែនមានតែ១លានឬ២លានទេ ប៉ុន្តែមានរហូតដល់៣លានឯណោះ ។

## បញ្ហា និង ការកំណត់ទិន្នន័យ

គួរកត់សម្គាល់ថា តួលេខដែលបានបង្ហាញមកខាងលើគឺជាការរកឃើញដំបូង ។ តាមពិតនៅមានទិន្នន័យជាច្រើនទៀតដែលត្រូវប្រមូល ។ មានភាពមិនប្រាកដប្រជាច្រើនណាស់ចំពោះទិន្នន័យដែលស្រង់បានមកពីទីតាំងរណ្តៅសាកសព ។ ដើម្បីដោះស្រាយបញ្ហាមិនប្រាកដប្រជានេះវាត្រូវការការសិក្សាស្រាវជ្រាវថែមទៀត ហើយការសិក្សាស្រាវជ្រាវកំពុងតែដំណើរការទៅមុខដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទន្ទឹមពេលគ្នានេះដែរលទ្ធផលនៃគម្រោងសិក្សាស្រាវជ្រាវផ្តល់ឱកាសក្នុងការវាយតម្លៃទៅលើចំណុចខ្លាំងចំណុចខ្សោយរបស់ទិន្នន័យដែលមានស្រាប់និងកត់សម្គាល់បញ្ហាដែលកើតមានឡើងកន្លងមក ព្រមទាំងការកម្រិតវិធីសាស្ត្រដើម្បីបន្តកិច្ចប្រឹងប្រែងនៅពេលខាងមុខទៀត ។

អ្នកសិក្សាជាន់ខ្ពស់ម្នាក់គឺលោក ម៉ៃឃើល វីកឃ័រី បានរិះគន់ចំពោះការប្រើទិន្នន័យដែលស្រង់បានមកពីទីតាំងរណ្តៅសាកសពដើម្បីចេញជាការប៉ាន់ស្មានចំនួនមនុស្សស្លាប់នៅក្នុងរបប ប៉ុល ពត ។ ទោះជាយ៉ាងណាក៏ដោយក៏មានចំណុចខ្លះដែលលោក វីកឃ័រី និយាយត្រូវដែរ ។ ទាក់ទងទៅនឹងការប៉ាន់ស្មានចំពោះចំនួនមនុស្សស្លាប់ដោយខ្មែរក្រហមគិតចាប់ពីឆ្នាំ១៩៨៤ លោក វីកឃ័រី បានទាញហេតុផលថា ដោយសារខ្វះភាពជាក់លាក់នៅក្នុងទិន្នន័យនិងការប៉ាន់ស្មានមិនអាចមានចំនួនសរុបត្រឹមត្រូវពិតប្រាកដឬការថយចុះនៃចំនួនប្រជាជនកម្ពុជាដោយសារការសម្លាប់ចោល ការឈឺស្លាប់ និងដោយសារគ្រោះទុរ្ភិក្ស ឬការខកខានមិនបានបង្កើនចំនួនប្រជាជនដោយសារការប្រែប្រួលផ្នែកជីវភាពរស់នៅ ។ រណ្តៅសាកសពខ្លះដែលត្រូវបានជីករកឃើញផ្តល់នូវភស្តុតាងបង្ហាញថាមានការសម្លាប់មនុស្សទាំងហ្វូងៗប៉ុន្តែគ្មានមធ្យោបាយក្នុងការដឹងថាមានចំនួនប៉ុន្មានស្លាប់ដោយការកាប់សម្លាប់និងស្លាប់ដោយមូលហេតុផ្សេងៗឡើយ ។ ពិន យ៉ាថៃ បញ្ជាក់នៅក្នុងខេត្តពោធិសាត់ក្នុងឆ្នាំ១៩៧៦-១៩៧៧ ថារណ្តៅសាកសពគឺសម្រាប់តែអ្នកដែលស្លាប់ដោយការអត់អាហារនិងជំងឺ ចំណែកឯការកាប់សម្លាប់កើតឡើងដាច់ដោយឡែកនៅក្នុងព្រៃ ។ មិនតែប៉ុណ្ណោះ មានជនរងគ្រោះដោយសារសង្គ្រាមចំនួន៥សែននាក់ត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួម ហើយបើគ្មានការធ្វើកោសល្យវិច័យត្រឹមត្រូវទេ នោះនឹងមិនអាចដឹងបានថាសាកសពទាំងអស់ដែលរកឃើញស្លាប់នៅមុនឬក្រោយឆ្នាំ១៩៧៥ ។ ការធ្លាក់ចុះចំនួនប្រជាជន៤សែននាក់គឺខ្ញុំអាចនិយាយថា ជាការបង្ហាញអំពីកំហុសរបស់ប្រព័ន្ធដឹកនាំកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែការប៉ាន់ស្មានចំនួនមនុស្សស្លាប់ដោយសារការសម្លាប់និងការអត់អាហារមួយចំនួនទៀតត្រូវតែសុីគ្នាទៅនឹងតំបន់នៃយុទ្ធនាការឃោសនាដ៏ខ្មៅងងឹត ។ ជាការច្បាស់ណាស់យើងមិនអាចយកតួលេខនៅខែមេសា ឆ្នាំ១៩៧៥ ចំនួនប្រជាជនរស់នៅសព្វថ្ងៃ ស្ថិតិនៃអត្រាកំណើតប្រជាជនមកបង្ហាញថា

មានការបាត់បង់ជីវិតរហូតដល់១ឬ២លាននាក់បានឡើយ ។

មានចំណុចជាច្រើននៅក្នុងអំណះអំណាងរបស់លោក វីកឃ័រី ដែលទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវតែមានការបញ្ជាក់ឲ្យបានច្បាស់ ។ ទីមួយ អំណះអំណាងរបស់លោក វីកឃ័រី ដែលថា ស្ថិតិការស្លាប់មិនអាចមានខ្ពស់ដល់២លាននាក់ គឺមិនទទួលបាននូវការគាំទ្រពីសំណាក់អ្នកសិក្សាផ្នែកជំរឿនអត្រាប្រជាជនឡើយ ។ ការវិភាគរបស់លោក ម៉ារ៉េក ស្លីវិនស្គី បញ្ជាក់នូវការប៉ាន់ស្មានរបស់គាត់ថា ក្នុងអំឡុងឆ្នាំ១៩៧៤-៧៥ និងឆ្នាំ១៩៧៩ ចំនួនប្រជាជនកម្ពុជាសរុបថយចុះអស់ខ្ទង់ចន្លោះ ១លាន៩សែន និង២លាន៥សែន ហើយចំនួនដែលគាត់ប៉ាន់ស្មានខ្ពស់ជាងគេគឺ ២លាន១សែន៦ម៉ឺន ។ អ្នកសិក្សាផ្នែកជំរឿនអត្រាប្រជាជនឈ្មោះ ជូឌិត បានីស្ទ័រ និង ភេប ចនសុន អះអាងថា ការធ្លាក់ចុះនៃចំនួនប្រជាជនកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ និងចុងឆ្នាំ១៩៧៨ គឺ១លាន៨សែននាក់ ។

លោក វីកឃ័រី បន្តទាញហេតុផលថា មិនអាចមានការបែងចែកច្បាស់លាស់ថា រណ្តៅណាខ្លះមានផ្ទុកសាកសពជនរងគ្រោះដោយអត់អាហារឬសង្គ្រាម ហើយរណ្តៅណាផ្ទុកដោយសាកសពជនរងគ្រោះដែលបាត់បង់ជីវិតដោយការកាប់សម្លាប់ឡើយ ។ ក្រុមផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្វែងរកពត៌មានជាច្រើននៅតាមទីតាំងនានាអស់ជាច្រើនឆ្នាំ ហើយនៅកន្លែងទាំងអស់នោះ អ្នកដែលបានផ្តល់ពត៌មាននិយាយថារណ្តៅសាកសពតាមពិតមិនមែនសម្រាប់ដាក់សាកសពដែលត្រូវបានសម្លាប់ឡើយ ប៉ុន្តែសម្រាប់ដាក់មនុស្សស្លាប់បណ្តាលមកពីការទម្លាក់គ្រាប់បែកក្នុងសង្គ្រាមរវាងឆ្នាំ១៩៧០-៧៥ សាកសពដែលស្លាប់ដោយការអត់អាហារនិងការឈឺឈ្លានពានរបស់វៀតណាមក្នុងឆ្នាំ១៩៧៩ ប៉ុន្តែមានចំនួនតិចតែប៉ុណ្ណោះ ។ ប៉ុន្តែលោក វីកឃ័រី ឲ្យហេតុផលថា មានការពិបាកក្នុងការវិភាគដោយគ្មានការធ្វើកោសល្យវិច័យច្បាស់លាស់ ។ ជាងនេះទៅទៀត នៅក្នុងករណីខ្លះ ការបង្អត់អាហារហាក់ដូចជាវិធីមួយដ៏ងាយស្រួលរបស់ខ្មែរក្រហមក្នុងការសម្លាប់ប្រជាជនក្នុងទ្រង់ទ្រាយធំ ប៉ុន្តែតួលេខនេះមិនបានបញ្ចូលទៅក្នុងទិន្នន័យផែនទីរណ្តៅសាកសពឡើយ ដោយសារតែការងាររបស់គម្រោងចុះធ្វើផែនទីគឺដើម្បីស្វែងរកការសម្លាប់មនុស្សជាប់ឃុំឃាំងតែប៉ុណ្ណោះ ។

មានតែពីរករណីប៉ុណ្ណោះដែលក្រុមផែនទីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញរណ្តៅសាកសពរួមដែលមានជនរងគ្រោះដោយសារការទម្លាក់គ្រាប់បែកក្នុងអំឡុងសង្គ្រាមឆ្នាំ ១៩៧០-៧៥ ។ ភាគច្រើននៃជនរងគ្រោះដែលបាត់បង់ជីវិតដោយសារការទម្លាក់គ្រាប់បែកគឺដោយសារតែខ្សោះទឹកបណ្តាលមកពីហូរឈាម ហើយករណីនេះមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយបើយើងគិតដល់អ្វីដែលបានកើតឡើងនៅក្នុងរណ្តៅគ្រាប់បែក បេ-៥២ ។ គ្រាប់បែកដែលមិនបែកជាបំណែកតូចៗហាក់ដូចជាក្លាយជាមេរុសម្រាប់បូជាសព ។ យុទ្ធសាស្ត្រទម្លាក់គ្រាប់បែករបស់អាមេរិកាំងមកលើប្រទេសកម្ពុជាបញ្ចប់តាំងពីខែសីហា ឆ្នាំ១៩៧៣គឺនៅពេលនោះហើយដែលខ្មែរក្រហមចាប់ផ្តើមប្រើមធ្យោបាយឃោរឃៅនៅតាមតំបន់រំដោះដែលចេញបម្រាមដាច់ខាតមិនឲ្យមានការប្រារព្ធពិធីសាសនា និងបុណ្យសពឡើយ រួមទាំងការបូជាសាកសពផង ។

អ្នកធ្វើសម្ភាសន៍របស់ក្រុមផែនទីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលបាននូវបទពិសោធន៍យ៉ាងច្រើនក្រាស់ក្រែលនៅក្នុងខ្សែសង្វាក់ការងាររបស់ខ្លួន ហើយដឹងពីរបៀបជីកគាស់ក្រោមដីដើម្បីរកការអះអាងច្បាស់លាស់ និងស្រង់យកនូវពត៌មានដែលអាចឲ្យក្រុមរបស់ខ្លួនធ្វើការវាយតម្លៃអំពីភាពគួរឲ្យទុកចិត្តបានរបស់អ្នកផ្តល់ពត៌មាន ។ ដូច្នេះ ការសង្ស័យទៅលើពត៌មានដែលប្រមូលបានមកពីតាមភូមិ-ស្រុកទូទាំងប្រទេសកម្ពុជា ដែលជាកន្លែងសាក្សីមូលដ្ឋានបញ្ជាក់ថា មានមន្ទីររបស់ខ្មែរក្រហមសម្រាប់សម្លាប់មនុស្ស និងជាទីតាំងរណ្តៅសាកសពដែលអដ្ឋិធាតុរបស់ជនរងគ្រោះត្រូវបានលុបបំបាត់ចោលបន្ទាញពីការសមគំនិតនៅទូទាំងប្រទេស ។ ទោះបីវាហាក់ដូចជាថារឿងរ៉ាវនិយាយពីមាត់មួយទៅមាត់មួយដែលសង្គមទទួលយកបានអាចមានឥទ្ធិពលទៅដល់ទម្រង់ច្បាស់លាស់នៃការរៀបរាប់រឿងរ៉ាវចប់ចុងចប់ដើមដែលប្រមូលបានមកដោយក្រុមផែនទីក៏ដោយ ប៉ុន្តែវាហាក់ដូចជាថា ឥទ្ធិពលសង្គមមិនអាចពង្រីកខ្លួនដើម្បីប្រឌិតរឿងកុហកថា មានសំណង់ចាស់ៗនៃអតីតគុកខ្មែរក្រហម ឬយកភស្តុតាងរូបធាតុដូចជាឆ្អឹងជាដើមមក

ដាក់នៅក្នុងគុកទាំងអស់នោះឡើយ ។ រាល់ករណីទាំងអស់ការដែលថាកិច្ចសម្ភាសន៍ជាមួយសាក្សីឃើញហេតុការណ៍ផ្ទាល់នឹងភ្នែកជាជំហានមួយមានសារសំខាន់ចំពោះដំណើរការប្រមូលទិន្នន័យ ប៉ុន្តែកិច្ចសម្ភាសន៍នោះមិនឆ្លុះបញ្ចាំងគ្រប់ជំហាននោះឡើយ ។ តាមពិតជំហានទីមួយក្នុងការចុះធ្វើផែនទី គឺស្វែងរកទីតាំងអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលសម្បូរទៅដោយសំណង់គុកចាស់ៗដែលត្រូវបានកម្ទេចចោលដោយអ្នកស្រុកអ្នកភូមិដែលពោរពេញដោយកំហឹង ក្រោយការដួលរលំនៃរបបខ្មែរក្រហម ។ ប៉ុន្តែក្នុងករណីខ្លះអាចនិយាយឲ្យតែផុតពីមាត់ថា អតីតគុករបស់ខ្មែរក្រហមត្រូវបានថែរក្សាទុក ហើយមកដល់សព្វថ្ងៃយកធ្វើជាមន្ទីរធ្វើការ ។ ជំហានទីពីរនៅក្នុងដំណើរការចុះធ្វើផែនទីក្រោយពីរកឃើញអតីតគុករបស់ខ្មែរក្រហមរួចហើយ គឺការស្វែងរកប្រជាជនដែលបានរួចផុតពីការឃុំឃាំងរបស់របបខ្មែរក្រហម ហើយនៅរស់ដល់សព្វថ្ងៃ ឬអ្នកដែលត្រូវបាន «ប្រើ» ឲ្យធ្វើការនៅក្នុងមន្ទីរសន្តិសុខ ។ ករណីនេះប្រហែលជាមានលក្ខណៈទូទៅជាងអ្វីដែលមនុស្សម្នាក់បានគិត ។ ក្នុងករណីជាច្រើន ក្រុមស្រាវជ្រាវមានលទ្ធភាពជួបជាមួយនឹងជនដែលពោលគឺកម្មាភិបាលនៃអង្គភាពសន្តិបាលដែលជាអ្នកធ្លាប់បានធ្វើការនៅក្នុងមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ ជួនកាលអតីតអ្នកធ្វើការនៅមន្ទីរសន្តិសុខខ្មែរក្រហមទាំងនេះនិយាយសារភាពអំពីអ្វីដែលខ្លួនបានធ្វើក្នុងរបបខ្មែរក្រហម ។ នៅកន្លែងចុះស្រាវជ្រាវទាំងនោះ ក្រុមផែនទីបន្តធ្វើការងារទៀតដើម្បីបញ្ជាក់ច្បាស់អំពីកន្លែងដែលអ្នកជាប់ឃុំឃាំងមកពីមន្ទីរសន្តិសុខផ្សេងៗត្រូវបានយកមកកប់ចោល ។ ដូច្នេះដំណើរការចុះធ្វើផែនទីមិនគ្រាន់តែពឹងផ្អែកទៅលើកិច្ចសម្ភាសន៍ជាមួយនឹងប្រជាជនមូលដ្ឋានដែលបានជួបប្រទះរឿងរ៉ាវដោយចៃដន្យ ឬមួយក្តីនោះទេ ។ ដំណើរចុះធ្វើផែនទីត្រូវបានរៀបចំច្បាស់លាស់ណាស់ ។

ទីតាំងរណ្តៅច្រើនស្ថិតនៅជិតមន្ទីរសន្តិសុខខ្មែរក្រហម ឬឃ្លាតចម្ងាយប្រមាណមួយគីឡូម៉ែត្រ ។ ស្ទើរតែគ្រប់ពេលអ្នកផ្តល់ពត៌មាននៅតាមមូលដ្ឋាននិយាយអំពីឈ្មោះកម្មាភិបាលដែលទទួលខុសត្រូវគុកនិងកន្លែងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ ជាញឹកញាប់ លទ្ធផលតែងតែមានក្នុងការស្វែងរកអតីតកម្មា-ភិបាលសន្តិសុខខ្មែរក្រហមដើម្បីកិច្ចសម្ភាសន៍លើកក្រោយៗទៀត ។ មិនតែប៉ុណ្ណោះ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបណ្ណសារច្រើនក្រាស់ក្រែលទាក់ទងនឹងឯកសារផ្ទៃក្នុងរបស់នគរបាលសម្ងាត់ ហើយជួនកាលអ្នកសិក្សាស្រាវជ្រាវអាចយកឈ្មោះមនុស្សដែលទាក់ទងនឹងកន្លែងសម្លាប់ដែលផ្តល់ដោយប្រជាជនមូលដ្ឋាន ហើយផ្ទៀងផ្ទាត់ជាមួយនឹងពត៌មាននៅក្នុងឯកសារផ្ទៃក្នុងខ្មែរក្រហម ។ ប៉ុន្តែមានពេលខ្លះដំណើរការងាររបៀបនេះមានលក្ខណៈបញ្ច្រាសទៅវិញ ពោលគឺមានការប្រមូលឈ្មោះពីឯកសារសន្តិបាលដែលមាននៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចហើយ ទើបអ្នកស៊ើបសួរពត៌មានរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាចេញទៅភូមិស្រុកដើម្បីស្វែងរកបុគ្គលទាំងអស់ដែលមានឈ្មោះជាមុនស្រេច ហើយនិងទទួលពត៌មានមានអំពីមន្ទីរសន្តិសុខរបស់ខ្មែរក្រហមដោយធ្វើសម្ភាសន៍ជាមួយបុគ្គលទាំងនោះ ។

បញ្ហាចម្បងមួយនៅក្នុងការវាយតម្លៃភាពប្រាកដប្រជានៃទិន្នន័យការចុះធ្វើផែនទីរណ្តៅសាកសព គឺជាភាពគួរឲ្យទុកចិត្តនៃការប៉ាន់ស្មានចំនួនរណ្តៅសាកសពនិងជនរងគ្រោះ ។ គ្មានការងឿងឆ្ងល់ទេថា គុណភាពនៃការរាយការណ៍ដោយក្រុមធ្វើផែនទីផ្សេងៗគ្នាក្នុងបណ្តាឆ្នាំកន្លងទៅមានភាពខុសគ្នាច្រើន ។ ដោយសារមូលហេតុនេះ ការប៉ាន់ស្មានបរិមាណនៅតាមទីតាំងផ្សេងៗកសិណសាក្សីប្រមូលមកពីកន្លែងផ្សេងៗគ្នា ជាពិសេសមកពីបេសកកម្មដែលធ្វើឡើងនៅដើមឆ្នាំដំបូង អាចគួរត្រូវបានចុះទៅពិនិត្យសាជាថ្មីឡើងវិញ ។ ទោះជាយ៉ាងណាក្តី ជំនាញនិងបទពិសោធន៍របស់ក្រុមធ្វើផែនទីចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ពីមួយលើកទៅមួយលើក ហើយក្រុមផែនទីបានក្លាយទៅអ្នកអាជីពច្បាស់លាស់នៅក្នុងកិច្ចការរបស់ខ្លួន ។ ចំនួនប៉ាន់ស្មានទៅលើជនរងគ្រោះនៅក្នុងរណ្តៅសាកសពទាំងនោះជាទូទៅមិនផ្អែកទៅលើមូលដ្ឋាន ទៅលើសម្តីមាត់ទទេៗ ឬក៏ការនិទានរបស់រដ្ឋអំណាចមូលដ្ឋានឡើយ ។ ក្នុងករណីខ្លះពត៌មានតួលេខជនរងគ្រោះបានមកពីអ្នកចូលរួមគាស់រណ្តៅនោះតែម្តង ។ ***(នៅមានត)***

**របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ប្រវត្តិរូបសង្ខេបរបស់ប៉ុល ពត

រៀបរៀងដោយៈ អែម សុខឃីម, អ៊ីសា ឧស្មាន និងឡុង អូន

**អំពីផ្ទាល់ខ្លួន**

១) ឈ្មោះដើម សាឡុត ស ។ ឈ្មោះបដិវត្ត ប៉ុល ពត, ប៉ុល, សមមិត្តប៉ុល, សមមិត្តលេខា, អង្គការ, ហៃ, ៨៧០, បងធំលេខ១ បង៨៧ឬគណៈ៨៧០ ។ ឈ្មោះក្រៅ សមមិត្តពូក ។ បុគ្គលិកលក្ខណៈ ចូលចិត្តនិយាយកំប្លែងលាយឡំជាមួយសម្តីមែនទែន ។

២) កន្លែងកំណើតៈ ភូមិព្រែកស្បូវ សង្កាត់លេខ៤ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ តំបន់៤៣ ភូមិភាគឧត្តរ ។

៣) អាយុៈ កើតឆ្នាំឆ្លូវ ខែបុស្ស ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ១៩២៥ ។

**មុខងារនិងសកម្មភាពមួយចំនួនមុនឆ្នាំ១៩៧៥**

◆ នៅឆ្នាំ១៩៤៨ ប៉ុល ពត បានចូលមកទីក្រុងភ្នំពេញដើម្បីសិក្សាមុខជំនាញជាងឈើនៅសាលាបច្ចេកទេសឫស្សីកែវ ។

◆ នៅឆ្នាំ១៩៤៩ ប៉ុល ពត បានទទួលអាហាររូបករណ៍ទៅសិក្សាបច្ចេកទេសនៅទីក្រុងប៉ារីស ប៉ុន្តែប្រលងធ្លាក់នៅឆ្នាំទី៣ ហើយបានត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៣ ។

◆ នៅពាក់កណ្តាលទសវត្សន៍ឆ្នាំ១៩៥០ ប៉ុល ពត បានបង្រៀននៅសាលាឯកជន «កម្ពុជបុត្រ» នៅទីក្រុងភ្នំពេញ ដែលជាសាខានៃបក្សកុម្មុយនិស្តកម្ពុជា ។

◆ ខែសីហា ឆ្នាំ១៩៥៣ ចូលរួមជាមួយអង្គការរណសិរ្សរួបរួមជាតិឥស្សរៈ បញ្ជាការដ្ឋាននៃរណសិរ្សនេះនៅភូមិភាគបូព៌ា ។

◆ នៅឆ្នាំ១៩៥៤ ប៉ុល ពត ត្រូវបានចាប់ខ្លួនអស់រយៈពេលបួនខែ ។ គាត់គ្រាន់តែជាស្មៀនម្នាក់សម្រាប់គណៈកម្មាធិការខេត្តកំពង់ចាម ។

◆ ឆ្នាំ១៩៦០ ប៉ុល ពត មានឋានៈទី៣នៅក្នុងបក្សពលករកម្ពុជា ។

◆ឆ្នាំ១៩៦២ ប៉ុល ពត បានបង្រៀននៅសាលាបក្ស (ជិតមន្ទីរពេទ្យព្រះសង្ឃ) ក្រុងភ្នំពេញ និង ជាលេខាបក្សកុម្មុយនិស្តកម្ពុជា ។

◆ នៅឆ្នាំ១៩៦៣ ប៉ុល ពត ជាលេខាបក្សកុម្មុយនិស្តកម្ពុជាបានរត់គេចខ្លួនចូលព្រៃនៅភូមិភាគឦសាន ។

◆ នៅឆ្នាំ១៩៦៤ ប៉ុល ពត បង្រៀនលទ្ធិកុម្មុយនិស្តនៅវិទ្យាល័យចំរើនវិជ្ជា ។

◆ ឆ្នាំ១៩៦៦ ប៉ុល ពត បានផ្លាស់ប្តូរមាគ៌ា ហើយបានកែប្រែថ្ងៃបង្កើតបក្សទៅជាឆ្នាំ១៩៦០វិញ ។

◆ នៅឆ្នាំ១៩៦៧ ប៉ុល ពត បានឡើងទៅដល់មន្ទីរ១០២ ។ ក្នុងរយៈពេលនោះ ប៉ុល ពត ខស្សរាហ៍មានជំងឺគ្រុនជាញឹកញាប់ ។ (គ្រុនម្តងៗមានលក្ខណៈធ្ងន់ធ្ងរណាស់) ។

◆ ឆ្នាំ១៩៦៨ ប៉ុល ពត ជាលេខាបក្សនៅក្នុងភូមិភាគឦសាន ។

◆ នៅឆ្នាំ១៩៧០ ប៉ុល ពត បានទៅធ្វើដំណើរទីក្រុងប៉េកាំង ហើយបានត្រឡប់មកវិញ រួចបន្តដំណើរទៅភូមិភាគឦសាន ។ (ប៉ុល ពត ត្រូវបានសមាជិកបក្សពលករកម្ពុជាបោះឆ្នោតជ្រើសរើសជាលេខាបក្សរបស់បក្សពលករកម្ពុជា) ។ ពីឆ្នាំ១៩៦៨ដល់ឆ្នាំ១៩៧០ ប៉ុល ពត ជាលេខាភូមិភាគរបស់បក្សកុម្មុយនិស្តកម្ពុជាប្រចាំនៅភូមិភាគឧត្តរ ។ ប៉ុល ពត ជាមេដឹកនាំចលនាទ័ពព្រៃផ្ទៃក្នុង ។ កាលនោះ ប៉ុល ពត មានឈ្មោះថា សាឡុត ស (ក្នុងអំឡុងពេលសង្រ្គាម ប៉ុល ពត ជាប្រធានទ័ពព្រៃផ្ទៃក្នុង) ។

◆ ក្នុងឆ្នាំ១៩៧៣ សោ ភឹម បានសំណូមពរឲ្យ ម៉ែន ឆាយ ជាបក្សស្តីទីក្នុងភូមិភាគបូព៌ា ប៉ុន្តែ ប៉ុល ពត បានបដិសេធ ។

◆ នៅឆ្នាំ១៩៧៤ ប៉ុល ពត ឈឺធ្ងន់ក្រោយពីប្រជុំចប់បាន៣ថ្ងៃ ។ ប៉ុល ពត ឈឺច្រើនជាងបង១៦ទៀតទាំងអស់ ។ ឈឺរាល់ឆ្នាំ ។ យប់មួយនោះ ប៉ុល ពត ឈឺឡើងស្ពឹកអស់មួយចំហៀងខ្លួន និងមួយចំហៀងក្បាល និងត្រជាក់ខ្លួនស្រឹប ។

**(ដកស្រង់ខ្លះៗ ចេញពីប្រវត្តិរូបលម្អិតរបស់ ប៉ុល ពត)**

# តម្លៃនៃភស្តុតាង



របាយការណ៍ផ្នែកច្បាប់នេះត្រូវបានចែកជា៦ផ្នែកមានដូចតទៅ ÷

ផ្នែកទី១ ផ្តល់នូវទស្សនវិស័យទូទៅនៃប្រភេទឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយចាត់ជាចំណាត់ថ្នាក់ទៅតាមទំហំនៃការពិនិត្យរបស់ខ្ញុំទៅលើឯកសារ ។ ផ្នែកទី២ មានការសន្និដ្ឋានតាមផ្លូវច្បាប់ជាច្រើនរបស់ខ្ញុំទាក់ទងនឹងច្បាប់សារធាតុនៃឧក្រិដ្ឋកម្មដែលទទួលការចោទប្រកាន់គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា និងវិធាននៃភស្តុតាងដែលអាចយកមកអនុវត្តបាន ។ ផ្នែកទី៣ ពិភាក្សាអំពីមធ្យោបាយទូទៅដែលអាចយកឯកសារភស្តុតាងក្នុងការបង្កើតធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជា ក៏ដូចជាបទល្មើសព្រហ្មទណ្ឌផ្សេងៗដែលស្ថិតនៅក្រោមការទទួលខុសត្រូវនេះ ។ ផ្នែកទី៤ និយាយកាន់តែច្បាស់ថែមទៀតទៅលើប្រភេទឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលអាចយកមកអនុវត្តក្នុងការបង្កើតជាធាតុផ្សំសំខាន់ៗនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់រួចហើយឈានទៅដល់ការពិភាក្សាលើបញ្ហាទាក់ទងនឹងការប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ជាភស្តុតាង ។ ផ្នែកទី៥ បង្ហាញជាឧទាហរណ៍អំពីរបៀបប្រើប្រាស់ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្កើតឲ្យមានការដាក់ឲ្យទទួលខុសត្រូវរបស់បុគ្គលមួយចំនួនដែលធ្វើជាមន្ត្រីជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចុងបញ្ចប់ គឺផ្នែកទី៦ ដែលជាសេចក្តីសន្និដ្ឋានខ្លីៗមួយចំនួន ។

១) ទស្សនវិស័យទូទៅនៃប្រភេទឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

បច្ចុប្បន្ននេះមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារចំនួន៦សែនទំព័រទាក់ទងផ្នែកឯកសារនិងឯកសារផ្សេងៗទាក់ទងនឹងសម័យកាលនៃការកាន់កាប់អំណាចរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ ឯកសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជានឹងកើនឡើងនៅក្នុងអនាគតដ៏ខ្លីខាងមុខ ដោយសារតែ

នាយកនិងបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញឯកសារបន្ថែមជាច្រើនទំព័រទៀត ដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែបានទទួលឯកសារខ្មែរក្រហមជាង៧០០គីឡូក្រាម ប្រមូលមកពីបណ្ណសារផ្សេងៗនិងកន្លែងផ្សេងៗ ។ ឯកសារភាគច្រើននៃឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាចែកចេញជាផ្នែកផ្សេងៗដូចខាងក្រោម ÷

១) សំបុត្រឆ្លងឆ្លើយ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានសំបុត្រឆ្លងឆ្លើយជាច្រើនរវាងសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃបក្សកុម្មុយនិស្តកម្ពុជា ឬសមាជិកទទួលបន្ទុកផ្នែកនយោបាយតាមលំដាប់សក្តិ ។ សំបុត្រទាំងនេះជាទូទៅត្រូវបានចាត់ទុកជារបាយការណ៍ផ្ញើពីមន្ត្រីថ្នាក់ក្រោមជូនចំពោះថ្នាក់លើរបស់ខ្លួន ទោះបីសំបុត្រខ្លះជាសេចក្តីណែនាំផ្ញើពីថ្នាក់លើមកកូនចៅរបស់ខ្លួនក៏ដោយ ។ សំបុត្រទាក់ទងផ្សេងទៀតរបស់បក្សកុម្មុយនិស្តកម្ពុជារួមមានសំណើសុំជំនួយឬព័ត៌មាន ។

២) កំណត់ហេតុបានមកពីកិច្ចប្រជុំបក្សកុម្មុយនិស្តកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកំណត់ហេតុបានមកពីកិច្ចប្រជុំផ្សេងៗនៃគណៈកម្មាធិការនៃបក្សកុម្មុយនិស្តកម្ពុជា រួមទាំងគណៈកម្មាធិការមជ្ឈិមបក្ស គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណៈភូមិភាគនិងគណៈតំបន់ព្រមទាំងអង្គភាពយោធាមួយចំនួនទៀត ។

៣) សេចក្តីប្រកាសជាផ្លូវការរបស់បក្សនៃបក្សកុម្មុយនិស្តកម្ពុជា

មេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាបានចេញសេចក្តីប្រកាសជាសាធារណៈមួយចំនួនតូចតែប៉ុណ្ណោះ ។ សេចក្តីប្រកាសដែលគួរកត់សម្គាល់បំផុតគឺសេចក្តីប្រកាសដែលធ្វើឡើងនៅសមាជបក្សនៅដើមឆ្នាំ១៩៧៦ ។

៤) ចម្លើយសារភាពនិងរបាយការណ៍នៃចម្លើយសារភាព

ចម្លើយសារភាពដែលដកស្រង់មកពីអ្នកទោស នៅមន្ទីរ ស-២១(ទួលស្លែង) មានច្រើនណាស់ ។ ចម្លើយសារភាពត្រូវបានបញ្ជាក់ដោយរបាយការណ៍ធ្វើឡើងដោយអ្នកសួរចម្លើយនៅមន្ទីរស-២១ ហើយកំណត់សម្គាល់របស់អ្នកសួរចម្លើយទាំងនេះអាចត្រូវបានចាត់ទុកថាជាទម្រង់មួយទៀតនៃការទាក់ទងរបស់បក្សកុម្មុយនិស្តកម្ពុជា ។

៥) សៀវភៅសរសេរដោយដៃនិងកំណត់ហេតុផ្ទាល់ខ្លួន

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានសៀវភៅសរសេរដោយដៃផ្ទាល់ខ្លួនឬកំណត់ហេតុផ្ទាល់ខ្លួននៃយោធាឬបុគ្គលិករបស់បក្សកុម្មុយនិស្តកម្ពុជា និងសៀវភៅសរសេរដោយដៃដែលបង្ហាញពីសកម្មភាពមួយចំនួនរបស់ អៀង សារី ។

៦) ឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនិស្តកម្ពុជា

រួមមានទស្សនាវដ្តីជាច្រើនច្បាប់របស់បក្សកុម្មុយនិស្តកម្ពុជាដែលមានចំណងជើងថា«ទង់បដិវត្ត»និងទស្សនាវដ្តីយុវជនកុម្មុយនិស្តកម្ពុជាដែលរួមមាន«យុវជនបដិវត្ត»និង «ទង់ក្រហម» ។

៧) ប្រវត្តិរូបរបស់អ្នកទោស

មន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជាបានកត់ត្រាព័ត៌មានស្តីអំពីប្រវត្តិរូបរបស់អ្នកទោសដែលចូលទៅក្នុងមន្ទីរស-២១ និងគុកផ្សេងៗទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រវត្តិរូបរបស់អ្នកទោសជាច្រើនពាន់នាក់ដែលមានភ្ជាប់រូបថតផង ។

៨) ប្រវត្តិរូបរបស់បក្សកុម្មុយនិស្តកម្ពុជា

នៅពេលបុគ្គលម្នាក់ចុះឈ្មោះធ្វើការជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជា ព័ត៌មានស្តីអំពីប្រវត្តិរូបត្រូវបានកត់ត្រាទុក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រវត្តិរូបទាហាននិងមន្ត្រីរបស់បក្សកុម្មុយនិស្តកម្ពុជាជាងមួយម៉ឺនពីរពាន់នាក់ ហើយភាគច្រើននៃប្រវត្តិរូបទាំងនេះថែមទាំងមានភ្ជាប់នូវរូបថតទៀតផង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានប្រវត្តិរូបជាឯកសាររបស់ ដួន ប្រាសិទ្ធិ ដែលជាអតីតឯកអគ្គរដ្ឋទូតនៃកម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិនៅអំឡុងឆ្នាំ១៩៧៥-៩២ដែរ ។

៩) ញត្តិ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារញត្តិដែលមានបញ្ជាក់ដោយហត្ថលេខារបស់បុគ្គលជាងមួយលាននាក់ដែលរស់រានមានជីវិតផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ មានញត្តិជាច្រើននិយាយលម្អិតទៅលើអំពើឃោរឃៅនិងឈ្មោះជនរងគ្រោះរបស់ខ្មែរក្រហម សាក្សី ឬជនដៃដល់ ។ ហើយមានញត្តិ

មួយចំនួនក៏បញ្ជាក់ដែរអំពីទីតាំងគុកនិងរណ្តៅសាកសពរួមរបស់បក្សកុម្មុយនិស្តកម្ពុជា ។

១០) របាយការណ៍នៃការចុះធ្វើផែនទី

បុគ្គលិកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការចុះស្រាវជ្រាវយ៉ាងទូលំទូលាយ ទៅលើវត្ថុតាងដែលបន្សល់ទុកដោយអំពើឃោរឃៅរបស់ខ្មែរក្រហម ។ របាយការណ៍ផែនទីមិនមែនមានតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ ដូចរបាយការណ៍ផ្សេងៗដែលរៀបរាប់មកខាងលើឡើយ ។ ក៏ប៉ុន្តែរបាយការណ៍នេះផ្តល់ជាប្រភពពត៌មានដ៏សំខាន់ស្តីអំពីទីតាំងនៃរណ្តៅកប់សាកសព គុក និងវត្ថុតាង ដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។

១១) ប្រតិចារឹកនៃកិច្ចសម្ភាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រតិចារឹកដែលបានមកពីកិច្ចសម្ភាសន៍ផ្សេងៗ ធ្វើឡើងដោយនាយកនិងបុគ្គលិករបស់ខ្លួន ។ លើសពីនេះទៀតមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រតិចារឹកនៃកិច្ចសម្ភាសន៍ក្រៅផ្លូវការជាច្រើនច្បាប់បានមកពីប្រភពផ្សេងៗរួមទាំងសារពត៌មានផង ។ មានប្រតិចារឹកនៃកិច្ចសម្ភាសន៍មួយចំនួនកត់ត្រាតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ ហើយមួយចំនួនទៀតត្រូវបានកត់ត្រាក្រោយពីខែមករា ឆ្នាំ១៩៧៩ ។

១២) ពត៌មានកាត់ចេញពីសារពត៌មានផ្សេងៗ កាសែតសំឡេង និងកាសែតវីដេអូ

នៅក្នុងចំណោមឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់មានពត៌មានចំនួនមួយពាន់ច្បាប់កាត់ចេញពីសារពត៌មានផ្សេងៗដែលទាក់ទងនឹងព្រឹត្តិការណ៍កើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនិងការបញ្ជូនពត៌មាន ។ ខ្សែភាពយន្តដែលផលិតដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវបានរកឃើញពីកន្លែងផ្សេងៗដូចជាសម្លេងខ្សែអាត់ដែលថតដោយរដ្ឋាភិបាលនៃបក្សកុម្មុយនិស្តកម្ពុជាដែរ ។

១៣) ញត្តិរបស់ជនជាតិវៀតណាម

មិនតែប៉ុណ្ណោះទៀតសោត មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នៅមានញត្តិធ្វើឡើងដោយប្រជាពលរដ្ឋវៀតណាមផ្ញើមករដ្ឋាភិបាលវៀតណាមនៅទីក្រុងហាណូយ ។ ញត្តិទាំងនោះនិយាយអំពីបទល្មើសផ្សេងៗដែលត្រូវប្រព្រឹត្តឡើងដោយរបបខ្មែរក្រហមក្នុងជម្លោះព្រំដែនរវាងបក្សកុម្មុយនិស្តកម្ពុជានិងប្រទេសវៀតណាម ។

ទោះបីជាឯកសារភាគច្រើននៅមជ្ឈមណ្ឌលឯកសារកម្ពុជាសរសេរជាភាសាខ្មែរក៏ដោយ ប៉ុន្តែមានឯកសារសំខាន់ៗមួយផ្នែកត្រូវបានប្រែសម្រួលជាភាសាអង់គ្លេសដោយបុគ្គលិកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានជំនួយការពីអ្នកជំនាញការមកពីខាងក្រៅ ។ លើសពីនេះទៀត បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើជាសេចក្តីសង្ខេបជាភាសាអង់គ្លេសទៅលើឯកសារសំខាន់ៗមួយចំនួន ។

ការពិនិត្យរបស់ខ្ញុំទៅលើឯកសារដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រឹមតែទៅលើឯកសារប្រែសម្រួលជាភាសាអង់គ្លេសតែប៉ុណ្ណោះ ។ ដូច្នេះការវិភាគរបស់ខ្ញុំ អាស្រ័យសំខាន់ដែរទៅលើការសម្រេចរបស់បុគ្គលិកនិងនាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបកប្រែអ្វីដែលខ្លួនគិតថាជាឯកសារដែលមានការពាក់ព័ន្ធច្រើនជាងគេបំផុត ។ ឯកសារប្រែសម្រួលជាភាសាអង់គ្លេសរួមមានរបាយការណ៍ផែនទី សៀវភៅសរសេរដោយដៃរបស់ អៀង សារី ប្រវត្តិរូបរបស់ ដួន ប្រាសិទ្ធ និងឯកសារជម្រើសផ្សេងៗដែលជាជម្រើសឯកសារសំខាន់ៗមានរហូតទៅដល់ប្រមាណ៧០០០ទំព័រដែលមានហត្ថលេខារបស់មន្ត្រីសំខាន់ៗនៃបក្សកុម្មុយនិស្តកម្ពុជា ឬបើមិនមានហត្ថលេខាក៏មានអ្វីដែលទាក់ទងជាពិសេសដែរ ។

នៅក្នុងការវិភាគទៅលើឯកសារទាំងនេះ ទោះបីជាខ្ញុំបានយោងប្រភេទនៃប្រភពដូចបានរៀបរាប់មកខាងលើក៏ដោយ ក៏ខ្ញុំបានផ្តោតយ៉ាងពិសេសទៅលើសំបុត្រទាក់ទងគ្នារបស់បក្សកុម្មុយនិស្តកម្ពុជា កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការនៃបក្សកុម្មុយនិស្តកម្ពុជា និងឯកសារចម្លើយសារភាពដែលអាចបង្ហាញភ័ស្តុតាងដ៏មានប្រយោជន៍មួយចំនួន ។ ជាផលវិបាក ការពិនិត្យរបស់ខ្ញុំទៅលើឯកសារទាំងនេះមិនបានផ្អែកទៅលើគំរូឯកសារចាំបាច់ភាគច្រើននៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងមូលទេ ហើយសូមអានដោយមានការប្រុងប្រយ័ត្នផងចុះ ។

២) សេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់

នៅពេលដែលកំពុងសរសេរនេះនៅមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេស្តីពីការគ្រប់គ្រងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដែលនឹងអាចកើតឡើងខាងមុខ ។ ជាពិសេស រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមិនទាន់បានយល់ព្រមលើវិធាននៃភស្តុតាងនិងគោលការណ៍នៃច្បាប់សារធាតុដែលនឹងត្រូវយកមកអនុវត្តដោយតុលាការមួយដែលមានការទទួលខុសត្រូវនៅឡើយទេ ។ ដូច្នេះនៅក្នុងការធ្វើសេចក្តីព្រាងរបាយការណ៍នេះ ខ្ញុំក៏សម្រេចចិត្តធ្វើសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់ដោយយោងតាមច្បាប់សារធាតុព្រហ្មទណ្ឌ និងវិធាននៃភស្តុតាង ។ តម្លៃភស្តុតាងនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាស្រ័យយ៉ាងសំខាន់ទៅលើជម្រើសខ្ពស់បំផុតនៃវិធាននិងគោលការណ៍ក្នុងការគ្រប់គ្រងតុលាការ ។ ក្នុងការបង្ហាញច្បាស់អំពីមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់ខ្ញុំនិងដើម្បីជួយឲ្យអស់លោកអ្នកវិនិច្ឆ័យទៅលើតម្លៃនៃរបាយការណ៍នេះ ខ្ញុំសូមជូននូវសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់ដ៏សំខាន់បំផុតរបស់ខ្ញុំផ្ទាល់ដូចខាងក្រោម ÷

ខ្ញុំបានទាញសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់តាមរយៈគោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិដូចដែលបានបកស្រាយដោយ «ប្រភពនានា» ដែលមានបទដ្ឋានអាចយកជាការបាននៃច្បាប់អន្តរជាតិ ។ ប្រភពទាំងនោះរួមមានៈ ១) អនុសញ្ញាអន្តរជាតិបកស្រាយដោយយោងតាមវិធីសាស្ត្រដែលបានចែងនៅក្នុងអនុសញ្ញាក្រុងវីយែន ។ ២) ច្បាប់ទម្លាប់អន្តរជាតិដែលត្រូវបានចែងយ៉ាងពិសេស ជាបទដ្ឋានដែលត្រូវបានបង្ហាញចេញតាមរយៈការអនុវត្តរបស់រដ្ឋមានលក្ខណៈដូចៗគ្នានិងត្រូវបានអនុវត្តដោយប្រាសចាកពីកាតព្វកិច្ចច្បាប់ ។ ៣) «គោលការណ៍ទូទៅនៃច្បាប់» ដែលជាគំនិតមិនសូវច្បាស់លាស់ផ្អែកលើការអនុវត្តជាលក្ខណៈជាតិមួយចំនួននិងការសម្រេចទៅលើ«គំនិតដើមស្តីអំពីអ្វីដែលជាយុត្តិធម៌តាមកាលៈទេសៈ» ។ ៤) ការសម្រេចចិត្តរបស់តុលាការនិងការងារដែលមានខ្លឹមសារដែលរួមមានគំនិតដឹកនាំអ្នកជំនាញច្បាប់និងគំនិតដឹកនាំតុលាការក្នុងស្រុកនិងអន្តរជាតិ ។ ៥) សេចក្តីសម្រេចរបស់សេចក្តីសម្រេចនិងរបាយការណ៍របស់អង្គការនយោបាយអន្តរជាតិ ជាពិសេសគួរឲ្យកត់សម្គាល់គឺអង្គការពត៌មានរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ។

នៅក្នុងចំណោមប្រភពសំខាន់ៗបំផុតសម្រាប់ការទាញសេចក្តីសន្និដ្ឋានរបស់ខ្ញុំ មានការគ្រប់គ្រងលក្ខន្តិកៈនិងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលត្រូវបានបង្កើតឡើងសម្រាប់អតីតយូហ្គោស្លាវីហៅកាត់ថា ICTY និងនៅរ៉្វាន់ដាហៅកាត់ថា ICTR ។ តុលាការទាំងនេះផ្តល់នូវការបញ្ជាក់ច្បាស់អំពីគោលការណ៍បណ្តោះអាសន្ននិងការយកមកអនុវត្តនូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ក៏ប៉ុន្តែដោយសារតែមេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាមើលទៅជិតទទួលការវិនិច្ឆ័យទោសដោយតុលាការចម្រុះក្នុងស្រុកនិងអន្តរជាតិ ចំណុចខ្លះនៅក្នុងច្បាប់របស់ប្រទេសកម្ពុជាក៏នឹងត្រូវយកមកអនុវត្តដែរ ។ ចំពោះទំហំនៃការខុសប្លែកគ្នារវាងច្បាប់នៃប្រទេសកម្ពុជានិងច្បាប់អន្តរជាតិ ការវាយតម្លៃនិងសេចក្តីសន្និដ្ឋានរបស់ខ្ញុំតម្រូវឲ្យមានការការពិនិត្យដោយហ្មត់ចត់សាឡើងវិញ ហើយចងចាំក្នុងគំនិតនូវការបែងចែកដាច់ពីគ្នានោះ ។

ក) បទល្មើសព្រហ្មទណ្ឌសារធាតុ

វគ្គជាបន្តទៅទៀតនេះបង្ហាញពីវិធានដែលទាក់ទងគ្នានៃច្បាប់ឧក្រិដ្ឋកម្មសារជាតិអន្តរជាតិដែលហាក់ដូចជាមានចាប់តាំងពីការចាប់ផ្តើមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់សារធាតុក្នុងអំឡុងឆ្នាំ១៩៧៥ - ៧៩ នឹងគ្រប់គ្រងការជម្រះក្តីអតីតមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដោយយោលតាមគោលការណ៍មួយចំនួនដូចជា nullem crimen, nullem poena sine lege ដែលត្រូវបានទទួលស្គាល់ជាសកល ។ នៅក្រោមគោលការណ៍ទាំងនេះ បុគ្គលម្នាក់មិនអាចត្រូវបានកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋដែលមិនបានកើតឡើងនៅក្នុងពេលប្រព្រឹត្តអំពើដែលនិយាយនេះឡើយ ។

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបង្កើតឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់របស់បុគ្គលដែលបានរំលោភទៅដល់ច្បាប់អន្តរជាតិធ្ងន់ធ្ងររហូតដល់អាចបង្កើតបានជាបទល្មើសប្រឆាំងនឹងសណ្តាប់ធ្នាប់អន្តរជាតិទាំងស្រុង ។ បទល្មើសមួយចំនួនដែលមានលក្ខណៈផ្សេងគ្នាអាចបណ្តាលឲ្យមានការទទួលខុសត្រូវផ្អែក

ព្រហ្មទណ្ឌអន្តរជាតិ ។ ខាងក្រោមនេះខ្ញុំបានធ្វើសេចក្តីសង្ខេបការយល់ឃើញរបស់ខ្ញុំទៅលើប្រភពផ្សេងៗនិងធាតុផ្សំជាមូលដ្ឋានមួយចំនួនទៀតនៃឧក្រិដ្ឋកម្មអន្តរជាតិដែលមានការទាក់ទងគ្នាច្រើនបំផុតទៅនឹងរបបកម្ពុជាប្រជាធិប-តេយ្យ ។ ៤) អំពើទាសភាពនិងការបង្ខំឲ្យធ្វើការងារ អំពើទាសភាពគឺជាប្រធានបទយ៉ាងជាក់ច្បាស់នៃបទដ្ឋាន *jus cogen* នៅត្រឹមឆ្នាំ១៩៧៥ ។ អនុសញ្ញាជាច្រើនត្រូវបានចុះហត្ថលេខាដោយហាមប្រាមអំពើទាសភាពដែលនៅក្នុងអនុសញ្ញាទាំងនោះមានភ្ជាប់ជាមួយនូវការទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះការប្រព្រឹត្តនូវអំពើនេះ ។ អនុសញ្ញាស្តីពីអំពើទាសភាព ការជួញដូរទាសករនិងការបង្កើតទាសករព្រមទាំងការអនុវត្តដែលមានលក្ខណៈប្រហាក់ប្រហែលអំពើទាសភាព (ដែលក្នុងនោះប្រទេសកម្ពុជាភាគីចុះកិច្ចសន្យាចាប់តាំងពីឆ្នាំ១៩៧៥) គឺជាអនុសញ្ញាដែលមានសារសំខាន់បំផុត ។



ការហាមប្រាមមិនឲ្យមានការបង្ខំធ្វើការងារគឺជាបទដ្ឋានទាក់ទងគ្នាមួយដែលត្រូវបានបង្កើតឡើងឲ្យទៅជាច្បាប់ទម្លាប់ដោយអនុសញ្ញាឆ្នាំ១៩៣០ ទាក់ទងនឹងការបង្ខំឲ្យធ្វើការងារ (ដែលប្រទេសកម្ពុជាជាភាគីមួយដែរ) ក៏ហាមប្រាមការធ្វើការងារដោយបង្ខំដែរ ទោះបីជាការប្រព្រឹត្តអំពើនេះត្រូវបានចាត់ទុកថាមានលក្ខណៈខុសច្បាប់ហើយកតិកាសញ្ញានិងអនុសញ្ញាទាំងពីរនេះដែលដូចគ្នាទៅនឹងអនុសញ្ញាឆ្នាំ១៩៣០ មានការលើកលែងមួយចំនួនក៏ដោយចុះ ។ ហេតុដូចនេះវិសាលភាពនៃសកម្មភាពធ្វើការងារដោយបង្ខំដែលជាបទឧក្រិដ្ឋចាប់ពីឆ្នាំ១៩៧៥ គឺមិនមានលក្ខណៈច្បាស់លាស់ទេ ។

ចំណុចខាងក្រោមនេះគឺចូលជាបទដ្ឋាននៃអំពើទាសភាព÷ ១) ការទាញយកជាកម្មសិទ្ធិជាលក្ខណៈប្រពៃណី និងការជួញដូរទាសករឬស្រ្តីនិងកុមារ ឬ ២) ការអនុវត្តជាក់ស្តែងដែលមានលក្ខណៈប្រហាក់ប្រហែលនឹងអំពើទាសភាពរួមទាំងអំពើទាសភាពដែលកើតចេញពីបំណុល ។ តម្រូវការបទដ្ឋាន *actus reus* ចំពោះការធ្វើការងារដោយបង្ខំគឺមិនសូវមានលក្ខណៈច្បាស់លាស់ប៉ុន្មានទេ ពីព្រោះវិសាលភាពនៃឧក្រិដ្ឋភាពក្នុងការបង្ខំមនុស្សម្នាក់ឬច្រើននាក់ធ្វើពលកម្មដោយគ្មានការស្ម័គ្រចិត្ត មិនមានច្បាស់លាស់ទេ ។ ចាប់ពីឆ្នាំ១៩៧៥មក មានតែការអនុវត្តការបង្ខំឲ្យធ្វើការងារដែលមានលក្ខណៈដូចគ្នាទៅនឹងអំពើទាសភាព (ដូចជាអំពើដែលមានសញ្ញាបញ្ជាក់អំពីកម្មសិទ្ធិ ឬការផ្លាស់ប្តូរនៅក្នុងលក្ខណៈច្បាប់របស់កម្មករ) បានធ្វើឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ **(នៅមានត)**

**ចន ឆរឆីអារី**

## ពាក្យស្លោកខ្មែរក្រហម

◆ **បុគ្គលម្នាក់ៗ អង្គភាពនីមួយៗ ប្រទេសទាំងមូល ត្រូវរៀនសូត្រឱ្យបានល្អតាមគំរូវីរភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់របស់សមរភូមិមុខ។**

(ដកស្រង់ចេញពីសៀវភៅលេខ ០៧៦ កណហ)

# ការរំលោភសេរីភាពជនជាតិខ្មែរ

## តើអ្នកសិក្សាពីររូបដែលមាននយោបាយស្ពាគស្ពុំ យល់ខុសអំពីកម្ពុជាយ៉ាងដូចម្ដេចខ្លះ?

នៅគ្រប់ទីកន្លែងទាំងអស់ គ្មានសង្គ្រាមណាមួយមានភាព យោរយៅមិនគិតគូរពីជីវិតមនុស្ស ឬបំផ្លិចបំផ្លាញសង្គមជាតិ ដូចជាសង្គ្រាមនៅកម្ពុជាទេ ។ នៅក្នុងខណៈដែលរដ្ឋាភិបាល សហរដ្ឋអាមេរិកនិងបទអត្ថាធិប្បាយរបស់ប្រព័ន្ធឃោសនា ព័ត៌មានបានប្រឹងប្រែងដើម្បីចៀសវាងអំពីការស្លាប់និងការបំផ្លិច បំផ្លាញដែលបន្តឡើងដោយអន្តរាគមន៍របស់សហរដ្ឋអាមេរិកនៅ ក្នុងប្រទេសកម្ពុជា អ្នកទាំងនេះបានស៊ីជម្រៅដើម្បីគូសចេញជា រូបភាពរបស់ប្រទេសមួយដែលដឹកនាំដោយជនបដិវត្តដែលគ្មាន ហេតុផល គ្មានអារម្មណ៍ជាមនុស្ស តាំងចិត្តប្រែក្លាយប្រទេស របស់ខ្លួនឲ្យទៅជាពិភពមួយគ្មានវប្បធម៌និងយោរយៅ ។ ក្នុងការ ផ្លាស់ប្ដូរបញ្ហាពីឧក្រិដ្ឋកម្មរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេស កម្ពុជាមកជាឧក្រិដ្ឋកម្មរបស់រដ្ឋាភិបាលបដិវត្តកម្ពុជា សហរដ្ឋ អាមេរិកបានផ្ដល់នូវការបកស្រាយថ្មីរបស់ខ្លួនទៅលើការបញ្ចប់ សង្គ្រាមនៅកម្ពុជា និងការចាប់ផ្ដើមរដ្ឋាភិបាលថ្មី ។

### ផតធ័រ និង ហ៊ីលប្រែនដ៍ ១៩៧៦

បញ្ហាដែលមានសារសំខាន់ជាក់ច្បាស់ក្រៅពីមរតកសង្គ្រាម (ឧទាហរណ៍ដូចជាប្រភពនៃនយោបាយនៃរបបកម្ពុជាក្នុងសម័យ ក្រោយសង្គ្រាមនៅក្នុងបទពិសោធន៍ជាប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណីជាតិខ្មែរនិយម ឬជម្លោះសង្គមផ្ទៃក្នុង) បានកន្លងផុត ទៅដោយស្ងប់ស្ងាត់នៅពេលដែលក្បាលម៉ាស៊ីនឃោសនា ឈានទៅរកប្រព័ន្ធប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចសង្គមដ៏អាក្រក់ ដោយបង្កើតជាគោលការណ៍មូលដ្ឋានរបស់ខ្លួនដែលថា «ការ រំដោះ» ដោយ «ពួកម៉ាក្សស៊ីស» គឺជាវាសនាដ៏អាក្រក់បំផុត អាចធ្លាក់មកលើប្រជាជនគ្រប់រូបដែលស្ថិតនៅក្រោមការគ្រប ដណ្ដប់ពីលោកខាងលិច ។

### ឆមស្គី និង ហឺមែន ១៩៧៩

នៅក្នុងឆ្នាំ១៩៧៦ ហ្គារ៉េត ផតធ័រ និងហ្សច ស៊ីហ៊ីលប្រែនដ៍ ដែលជាអ្នកសិក្សាជាន់ខ្ពស់ជនជាតិអាមេរិកទាំងបានបោះពុម្ព ផ្សាយនូវសៀវភៅតូចមួយដ៏មានផលប្រយោជន៍មានចំណង ជើងថា «កម្ពុជាៈ ការអត់អាហារនិងការធ្វើបដិវត្តន៍» ។ វាមាន សារសំខាន់ដោយសារមូលហេតុពីរយ៉ាង ។ ទី១ វាជាសៀវភៅ បោះពុម្ពផ្សាយជាភាសាអង់គ្លេសមុនដំបូងបង្អស់សម្រាប់ ពិពណ៌នាព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ។ ទី២ វាធ្វើឲ្យអ្វីៗគ្រប់យ៉ាង ដែលខ្មែរក្រហមបាននិងកំពុងធ្វើឲ្យមានលក្ខណៈសមហេតុផលៈ ចាប់ពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងអ្នកជំងឺនៅតាម មន្ទីរពេទ្យនានារហូតដល់ការផ្សឹកព្រះសង្ឃឲ្យធ្វើការជាទម្ងន់ ។ នៅក្នុងសៀវភៅនេះ ផតធ័រ និង ហ៊ីលប្រែនដ៍ បានផ្ដល់នូវអ្វី ដែលជាភ័ស្ដុតាងមិនអាចទៅរួច ហើយជុយគ្នាទៅនឹងរបាយ ការណ៍ស្ដីពីអំពីយោរយៅដែលកំពុងកើតឡើងនៅក្នុងប្រទេស កម្ពុជាដែលរបបនោះឲ្យឈ្មោះថា «កម្ពុជាប្រជាធិបតេយ្យ» ។

ការប្រើប្រាស់នូវឯកសារ«សម្ងាត់» និងទិន្នន័យវត្ថុ «ផ្លូវការ» របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ (ពោលគឺ ខ្មែរក្រហមខ្លួនឯងផ្ទាល់) អ្នកទាំងពីរបានទាញហេតុផលថា ការ ជម្លៀសប្រជាជនចេញពីទីក្រុងនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គឺដោយសារតែមានសង្គ្រាមអាមេរិកប្រឆាំងនឹងប្រជាជនកម្ពុជា បណ្ដាលឲ្យប្រជាជននៅទីក្រុងភ្នំពេញឡើងលើសចំនួន(ពី៦សែន នាក់ទៅ២-៣លាននាក់ រវាងឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥) ។ ជាងនេះទៅទៀត អ្នកទាំងពីរអះអាងថា ការផ្ទុះចេញនូវអំពើពុក រលួយនៅក្រោមរបប លន់ ណុល គឺដោយសារតែមានជំនួយ របស់អាមេរិក ហើយថា ការណ៍នេះបានធ្វើឲ្យមានការស្លាប់កាន់ តែច្រើនទៅៗ ខូះជីវជាតិទ្រទ្រង់រាងកាយនិងជំងឺតម្កាត់នៅ ទីក្រុងភ្នំពេញ ធ្វើឲ្យទីក្រុងនេះមិនអាចរស់នៅបាន ។ ផតធ័រ និង ហ៊ីល ប្រែនដ៍ និយាយយោងដល់ខ្មែរក្រហមត្រឹមតែពាក្យល្អ ស្ដាប់ថារណសិរ្សរួបរួមជាតិកម្ពុជា (FUNK) ដែលជាអក្សរកាត់ ក្នុងភាសាបារាំងតែប៉ុណ្ណោះ ហើយត្រូវបានប្រើនៅពេញ សំណេរនេះ ។ ផតធ័រ និង ហ៊ីលប្រែនដ៍ យករូបថតឃោសនា

មួយចំនួនពីរបបនោះមកប្រើជាល្បោយសម្រាប់សៀវភៅរបស់ខ្លួន ។

នៅជំពូកទីពីរដែលមានចំណងជើងថា «នយោបាយនៃភាពអត់ឃ្លាននៅទីក្រុងភ្នំពេញ» នៃសៀវភៅ «កម្ពុជាៈ ភាពអត់ឃ្លាន និងការធ្វើបដិវត្តន៍» ដគធ័រ និង ហ៊ីលប្រែនដ៍ វាយប្រហារទៅលើរបាយការណ៍របស់ប្រព័ន្ធឃោសនាស្តីពីអំពើឃោរឃៅដែលអ្នកកាសែតម្នាក់ឈ្មោះ ស៊ីដនី សេនប៊ឺក ធ្វើការឲ្យកាសែតញូវយ៉កថែម បានសរសេរដោយផ្អែកការណ៍នេះទៅលើពត៌មានដែលខ្លួនទទួលបានបីសប្តាហ៍បន្ទាប់ពីការជម្លៀសក្នុងខណៈដែលខ្លួនកំពុងស្ថិតនៅក្នុងស្ថានទូតបារាំងនោះ ។ ដគធ័រ និង ហ៊ីលប្រែនដ៍ សរសេរថា «អត្ថបទនេះមានមូលដ្ឋានខ្សោយណាស់សម្រាប់ការវិនិច្ឆ័យទូទៅជាលក្ខណៈប្រវត្តិសាស្ត្ររបស់ប្រព័ន្ធឃោសនា ។ វាគ្មាននិយាយអំពីរបាយការណ៍ពីសាក្សីដែលឃើញហេតុការណ៍ផ្ទាល់ភ្នែកស្តីអំពីបញ្ហាថាតើការជម្លៀសត្រូវបានដំណើរការយ៉ាងដូចម្តេច ដូចជាការហូបចុក ការថែទាំសុខភាព ការដឹកជញ្ជូន ឬការប្រព្រឹត្តទូទៅមកលើអ្នកដែលត្រូវជម្លៀស» ។ ថ្វីដ្បិតតែលោក សេនប៊ឺក មិនបានដើរចេញក្រៅស្ថានទូតនោះក៏ពិតមែន ប៉ុន្តែ សេនប៊ឺក ក៏ប្រហែលជាមើលឃើញព្រឹត្តិការណ៍ដែលកើតឡើងនោះបានច្រើនជាងលោក ដគធ័រ និង ហ៊ីលប្រែនដ៍ ដែលមិនឃើញមានមុខនៅក្នុងប្រទេសកម្ពុជា ។ ដគធ័រ និង ហ៊ីលប្រែនដ៍ បន្តរិះគន់ប្រព័ន្ធផ្សព្វផ្សាយនេះទៀតថា «ហើយក៏គ្មានការវិភាគឲ្យបានទូលំទូលាយទៅលើមូលហេតុដែល សេនប៊ឺក អះអាងថា ថ្នាក់ដឹកនាំបដិវត្តបានធ្វើការឲ្យជម្លៀសនេះ» ។ នៅទីនេះ ដគធ័រ និង ហ៊ីលប្រែនដ៍ និយាយយោងដល់ស្ថានការណ៍កម្ពុជាក្រោយពេលសង្គ្រាមផុតរលត់ អ្នកទាំងពីរនិយាយថា ជាការគួរឲ្យស្តាយចំពោះសកម្មភាពរបស់អាមេរិកដែលនាំដល់ការជម្លៀសនេះ ។

ដគធ័រ និង ហ៊ីលប្រែនដ៍ ឲ្យតម្លៃទាបចំពោះរឿងដែលមានលក្ខណៈប្រហាក់ប្រហែលនឹងរឿងសរសេរដោយ សេនប៊ឺក ថាជាការបំផ្លើសឲ្យមានការចាប់អារម្មណ៍(តាមរយៈចំណងជើង) ហើយបានសរសេរថា «អ្នកធ្វើអត្ថាធិប្បាយ និងអ្នកសរសេរបទវិចារណកថានានាបានរំពឹងថា ជនបដិវត្តមានចរិត«មិនអាចបត់បែនបាន» ហើយមិនគោរពជីវិតមនុស្ស ដោយសារតែអ្នកទាំងនេះមិនបានត្រៀមរៀបចំពិនិត្យទៅលើលទ្ធភាពដែលអាចឲ្យមានតម្រូវការផ្លាស់ប្តូរយ៉ាងច្រើននៅក្នុងសភាពការណ៍ពេលនោះ» ។ គ្មានកន្លែងណាមួយដែលអ្នកសិក្សាមានមនោសញ្ចេតនានយោបាយស្អាតស្អំចំពោះបដិវត្តន៍ច្បាស់ជាងនៅទីនេះទេ ។ (ខ្ញុំប្រើពាក្យ «នយោបាយស្អាតស្អំ» ទាំងការមិនប្រាកដក្នុងចិត្ត ហើយមិនមានន័យត្រង់ថាខុសនិងត្រូវទេ ។ ខ្ញុំប្រើពាក្យនេះនៅក្នុងសំណេរគឺចង់មានន័យថា អ្វីៗជាគំនិតដែលត្រូវបានទទួលយកកាលសម័យនោះដែលប្រើដោយក្រុមឬវណ្ណៈអភិជនហើយក្នុងករណីនេះគឺប្រើដោយអ្នកសិក្សាជាន់ខ្ពស់ ។ គំនិតនេះត្រូវបានអភិវឌ្ឍថែមទៀតនៅក្នុងគោលការណ៍ខ្មែរក្រហមជាទស្សនវិស័យជាបទដ្ឋានសម្រាប់ការសិក្សាទៅលើបញ្ហាកម្ពុជាដែលជាគំនិតស្រង់យកដោយផ្ទាល់ចេញពីទស្សនវិស័យជាបទដ្ឋានរបស់លោក ម៉ៃឃើល វីកឃ័រី បង្កើតឡើងនៅក្នុងសៀវភៅបោះពុម្ពក្នុងឆ្នាំ១៩៨៤ មានចំណងជើងថា «កម្ពុជាៈ ១៩៧៥-១៩៨២») ។ ដគធ័រ និង ហ៊ីលប្រែនដ៍ គិតថា ជនបដិវត្តមានលក្ខណៈអាចបត់បែនបាន ហើយមានមនុស្សធម៌ ពីព្រោះបើនិយាយឲ្យស្រួលស្តាប់ទៅ ជនបដិវត្តជាជនល្អ ហើយបដិវត្តន៍របស់គេក៏ល្អដែរ ។ ដគធ័រ និង ហ៊ីលប្រែនដ៍ បានទាញហេតុផលថាទីក្រុងភ្នំពេញហៀបតែនឹងអត់អាហារទៅហើយ នៅពេលដែលខ្មែរក្រហម «រំដោះ» បានហើយគ្មានផ្លូវណាជ្រើសរើសក្រៅពីជម្លៀសប្រជាជន ដូចដែលបានកើតឡើងរួចហើយនោះទេ ។ ដគធ័រ និង ហ៊ីលប្រែនដ៍ បានប្រវេប្រវារកការពន្យល់ជាផ្លូវការ និងប្រភពពត៌មានផ្សេងៗ ដើម្បីយកមកការពារនយោបាយរបស់ខ្មែរក្រហម និងជាពិសេសគឺដើម្បីការពារខ្មែរក្រហមតែម្តង ។ ថ្វីដ្បិតតែមានការលើកឡើងអំពីបដិវត្តន៍ក៏ពិតមែន តែមិនបាននិយាយអំពីឧក្រិដ្ឋកម្មណាមួយដែលត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហមនៅក្នុងពេលជម្លៀសទេ ។ ផ្ទុយមកវិញ អ្នកទាំងពីរបានលើកយកឧទាហរណ៍សមហេតុផលជាច្រើននិយាយពីអំពើខ្មែរក្រហម ទោះជាមិនមានមនុស្សធម៌ក្តីដែលផ្ទុយនឹងការលើកហេតុផលនេះត្រូវបានបរិយាយយ៉ាងល្អិតល្អន់ ។ **(នៅមានត)** **អៀ សុផល**

# កំណត់ហេតុស្តីអំពីអង្គប្រជុំរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជា លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

***(តពីលេខមុន)* សម្តេច ហេង សំរិន:** *បន្ទាប់ពីការអនុម័តលើជំពូកទី៦ សូមអញ្ជើញប្រធានគណៈកម្មការអាននៅជំពូកទី៧បាទ ។*

**ឯកឧត្តម ម៉ោញ សាផាន:** *ជំពូកទី៧: អំពីការស៊ើបអង្កេត មាត្រា២៣: រាល់ការស៊ើបអង្កេតគឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រម២នាក់ ម្នាក់ជាកម្ពុជានិងម្នាក់ទៀតជាបរទេស ដោយហៅថាសហចៅក្រមស៊ើបអង្កេតដែលអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើចាំបាច់ ហើយនីតិវិធីនៅជាធរមាននោះមានការខ្វះចន្លោះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រមត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម: ការស៊ើអង្កេតត្រូវធ្វើបន្តដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរឬមួយរូបក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេល៣០ថ្ងៃ ថាភាពខ្វែងយោបល់គ្នាក្នុងដោះស្រាយដោយអនុវត្តតាមបទបញ្ញតិដូចខាងក្រោម: សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដែលអង្គបុរេជំនុំជម្រះដូចជាចែងក្នុងមាត្រា២០នៃច្បាប់នេះ ។ បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៣រួចមក ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រម៤រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដោយសហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឲ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៅទៀត ។ សហចៅក្រមស៊ើបអង្កេត ដោយផ្អែកទៅលើមូលដ្ឋាននៃពត៌មានដែលទទួលបានពីស្ថាប័ននានារួមមាន រដ្ឋាភិបាល ស្ថាប័ននានា របស់អង្គការសហប្រជាជាតិឬអង្គការក្រៅរដ្ឋាភិបាលជាដើម ។ សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភ័ស្តុតាង ដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ខានមិនបាន សហចៅក្រមស៊ើបអង្កេតអាចចេញជាដីកាសុំឲ្យសហព្រះរាជអាជ្ញាធ្វើការសាកសួរសាក្សីបន្ថែមបាន ។ ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថា សមស្របនិងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧត្ថម្ភនេះត្រូវតែផ្តល់ជូន ។ មាត្រា២៤: ក្នុងដំណាក់កាលស៊ើបអង្កេតជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដោយខានមិនបាន ហើយដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន ។ មាត្រា២៥: សហចៅក្រមស៊ើបអង្កេតត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាននេះ ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ សុចរិត មានបទពិសោធន៍ក្នុងការងារទាំងនេះ សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយឬពីប្រភពមួយផ្សេងទៀតបានឡើយ ។ មាត្រា២៦: សហចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុងខ្មែរត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរ ។ ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិនៅពេលណាដែលចៅក្រមនេះអវត្តមានឬមានធុរៈ ។ ចៅក្រមស៊ើបអង្កេតទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។ ចៅក្រមស៊ើបអង្កេតបរទេសត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់រយៈពេលនៃការស៊ើបអង្កេតបន្ទាប់ពីការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិច២រូបជាចៅក្រមស៊ើបអង្កេតបរទេសជូនរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជាហើយបានក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិ១រូបនិង*

បម្រុង១រូបពីបញ្ជីបេក្ខជននេះ ។
មាត្រា២៧ៈ ចៅក្រមស៊ើបអង្កេតទាំងអស់ដែលឋិតក្រោមច្បាប់នេះ មានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នា ចៅក្រមស៊ើបអង្កេតមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេតក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមានឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុង ។ មាត្រា ២៨ៈ សហចៅក្រមស៊ើបអង្កេតមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការនៅការិយាល័យរបស់ខ្លួន ។ ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាមស្មារតីនៃបទបញ្ញត្តិដូចមានចែងនៅក្នុងមាត្រា៨នៃច្បាប់នេះ ។ ទូលបង្គំខ្ញុំបាទសូមដាក់ជូនជំពូកទី៧ជូនថ្វាយជូនអង្គសភាដើម្បីពិភាក្សា និងអនុម័តតាមការគួរ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងសូមអង្គប្រជុំទាំងមូលពិភាក្សានៅជំពូកទី៧ បាទ... ខ្ញុំសូមអញ្ជើញឯកឧត្តម សមរង្ស៊ី ។

**ឯកឧត្តម សម រង្ស៊ី:** សូមថ្លែងអំណរគុណចំពោះសម្តេចប្រធាន សូមគោរពអង្គសភាទាំងមូល ហើយសូមគោរពតំណាងរាជរដ្ឋាភិបាល ។ ខ្ញុំមានបំណងចង់សួរទៅតំណាងរាជរដ្ឋាភិបាលថាតើក្នុងមាត្រា២៣ដែលថាសហចៅក្រមស៊ើបអង្កេត ស៊ើបអង្កេតទទួលនូវការឧបត្ថម្ភពីរាជរដ្ឋាភិបាលនេះថាការឧបត្ថម្ភនេះ យើងអាចយល់ក្នុងន័យថាសហការបានឬបានពីព្រោះឧបត្ថម្ភដូចជាបារាំង Suspension ដូចថាផ្តល់អ្វីមកឲ្យ បើថាក្នុងការនិយាយថាធ្វើការជាមួយគ្នាយើងប្រើពាក្យសហការ Coopération ជាមួយ Collaboration ដើម្បីបញ្ជាក់ពាក្យនេះ មិនមែនគ្រាន់តែថាឧបត្ថម្ភទេ គឺថាមានពាក្យធ្វើការឬមួយដូចថា គឺថាត្រូវតែកោះហៅ គឺតម្រូវឲ្យជនសង្ស័យឆ្លងឆ្លើយ ហើយបាទជនសង្ស័យមិនព្រមមកដោយចិត្តឯង ពេលនោះគឺត្រូវសហការជាមួយនឹងរាជរដ្ឋាភិបាល ពាក្យសហការហើយនិងពាក្យឧបត្ថម្ភវាអាចមិនទៅទន្ទឹមគ្នាបានទេ នេះសំណួរទី១ ។ សំណួរទី២ទាក់ទងទៅនឹងមាត្រា២៤ ខ្ញុំចង់សួររាជរដ្ឋាភិបាលថាតើមានការបញ្ជាក់ឲ្យបានច្បាស់ជាងនេះបានទេថា ជនសង្ស័យមានសិទ្ធិជ្រើសរើសមេធាវីរបស់ខ្លួន គឺថា មានសិទ្ធិទទួល ហើយនៅក្នុងច្បាប់មានចែងមានសិទ្ធិទទួល ប៉ុន្តែចង់បញ្ជាក់ថាមានសិទ្ធិជ្រើសរើសទេ? សូមកុំឲ្យគេបង្ខំជនសង្ស័យឲ្យទទួលយក មេធាវីដែលជនសង្ស័យមិនពេញចិត្តឲ្យជនសង្ស័យមានជម្រើសក្នុងការជ្រើសរើសមេធាវី មានជម្រើសឲ្យបានច្បាស់ថាទោះជាមានបញ្ហាយ៉ាងណាជនសង្ស័យអាចជ្រើសរើសខ្លួនឯង ហើយអាចបដិសេធមេធាវីដែលគេស្នើមកឲ្យ ហើយក្នុងចំណោមមេធាវីនោះសូមតំណាងរាជរដ្ឋាភិបាលមេត្តាបញ្ជាក់ថាតើត្រូវជ្រើសរើសមេធាវីក្នុងចំណោមសមាជិកគណៈមេធាវីឬមួយអាចយកមេធាវីដែលមានមជ្ឈដ្ឋានដែលចេញមកពីមជ្ឈដ្ឋានផ្សេងៗទៀតបាន? សូមអរគុណ បាទ ។

**សម្តេច ហេង សំរិន:** សូមអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រីតំណាងរាជរដ្ឋាភិបាលសូមអញ្ជើញអានសំណួរ ។

**ឯកឧត្តម សុខ អាន:** សូមគោរពសម្តេចប្រធានជាថ្មីម្តងទៀតនិងសូមគោរពឯកឧត្តមអនុប្រធានទីពីរ ថ្វាយបង្គំគោរពអង្គសភាទាំងមូល ។ ទូលបង្គំខ្ញុំបាទសូមបញ្ជាក់លើសំណួរទាំងពីរដែលបានលើកឡើងនេះ សំណួរទីមួយអំពីពាក្យថាការជួយឧបត្ថម្ភ តើយើងគួរបន្ថែមពាក្យសហការឬទេ ឬក៏ប្រតិបត្តិការនោះទេនៅក្នុងមាត្រា២៣ ។ នៅក្នុងមាត្រា២៣នេះបានចែងពីការស៊ើអង្កេត ជាពិសេសគឺថានៅក្នុងជំពូកទី៧នេះតែម្តងដែលមានខ្លឹមសារស្នូលជាសំខាន់គឺថា ការដែលយើងសរសេរអំពីគោលការណ៍សហចៅក្រមស៊ើបអង្កេត ។ អ៊ីចឹងនៅក្នុងដំណើរការជាធម្មតាដែលយើងលើកឡើងអំពីគោលការណ៍បែងចែកអំណាចនេះជាអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការនេះ គឺអំណាចនីមួយៗនៅដាច់ពីគ្នា ប៉ុន្តែនៅក្នុងមាត្រា២៣ យើងបានលើកឡើងអំពីលទ្ធភាពជួយឧបត្ថម្ភ បាទវាត្រូវនឹងពាក្យថា Assistance ដូច្នេះបើយើងសរសេរសង្កត់ថែមអំពីសហការ សហប្រតិបត្តិការទៀតឃើញថា ហាក់បីដាយើងដៅឆ្ងាយពេកអំពីគោលការណ៍នៃការបែងចែកអំណាច ។ ហេតុដូច្នេះហើយនៅក្នុងការសរសេរនេះគឺយើងបានថ្លឹងថ្លែងយើងគិតគូថានៅពេលដែលចៅក្រមស៊ើបអង្កេតត្រូវការការជួយឧបត្ថម្ភនោះ គឺរាជរដ្ឋាភិបាលត្រៀមនឹងផ្តល់ជូននូវការជួយឧបត្ថម្ភ ក៏ប៉ុន្តែទូលបង្គំខ្ញុំបាទយល់ឃើញថា ដូចជាមិនបាច់មិនគួរសរសេរដល់សហការ ឬសហប្រតិបត្តិការទេ គឺថាវាយើងក៏ត្រូវមានសរសេរ យើងត្រូវគិតអំពីគោលការណ៍រួម ដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើង ។ ចំណុចជាសំណួរទីពីរអំពីមាត្រា២៤ បាទដែលចែងអំពីមេធាវី មាត្រា២៤បានសរសេរថាក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដោយខានមិនបានហើយដោយ នៅក្នុងករណី...បាទ ដោយឥតគិតថ្លៃទៀតប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីនឹងចេញថ្លៃមេធាវី ។ ដូច្នេះដោយស្មារតីនៃមាត្រាទី២៤នេះ គឺបើកទូលាយណាស់ បាទមិនមានការហាមឃាត់មិនឲ្យជនសង្ស័យទៅជ្រើសរើសមេធាវីទេ ទូលបង្គំខ្ញុំបាទបានយល់ថា មានន័យមាត្រា២៤នេះមានន័យគ្រប់គ្រាន់ បាទនៅក្នុងការសរសេរនេះ ហើយគឺវាបើកទូលាយបញ្ជាក់អំពីសិទ្ធិរបស់ជនសង្ស័យគឺគេចង់បានមេធាវីខ្លួនគេក៏បាន ប៉ុន្តែក្នុងករណីដែលគេរកមិនបាន ពីព្រោះពេលខ្លះពិបាករកដែរ អ្នកខ្លះមេធាវីខ្លះគាត់មិនចង់ទៅជំពាក់ជំពាន់និងការងារដ៏ស្មុគស្មាញនេះអ៊ីចឹងគឺ

លទ្ធភាពរកនេះមិនច្បាស់ជាបានពេលខ្លះបានហើយ ពេលខ្លះក៏មិនបានដែរ អ៊ីចឹងបានយើងសរសេរដោយបើកសិទ្ធិទូលាយថាបើគេរកមិនបានទេគឺត្រូវតែជួយរកបាទ ជួយរកបាទ យើងប្រព្រឹត្តពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវីគឺថា អ្នកគឺៗអាជ្ញាធរដែលរៀបចំបានន័យថាដែលទទួលខុសត្រូវហ្នឹងគឺត្រូវតែជួយរក ប៉ុន្តែមាត្រា២៨មិនមានហាមឃាត់ មិនមានបិទសិទ្ធិមិនឲ្យគេរកទេ បាទខ្ញុំបាទសូមឆ្លើយប៉ុណ្ណឹង ។

**សម្តេច ហេង សំរិន:** បាទសូមអញ្ជើញ ។

**ឯកឧត្តម ម៉ៅញ សាផាន:** ទូលបង្គំខ្ញុំបាទសូមបន្ថែមបន្តិចនែ៎ គឺថាឯកឧត្តមបានសួរថាមេធាវីយកពីណាមៅ៉ គឺមេធាវីវានៅឋិតនៅក្នុងក្របខ័ណ្ឌមេធាវីដែលមានច្បាប់ចែង ហើយមិនថាបរទេសថាខ្មែរទេអាចយកបាន ប៉ុន្តែគ្រាន់តែបរទេសមេធាវីបរទេសមិនអាចឡើងការពារនៅក្នុងតុលាការបានទេ គ្រាន់តែគេអមមេធាវីខ្មែរ អ៊ីចឹងតាមច្បាប់លក្ខន្តិកៈមេធាវីដែលបានចែង ចំណែកឯនៅក្នុងនេះអត់មានបញ្ជាក់ទេគឺ អត់មានថាហេស៎ បរទេស នែ៎ យកមិនបាន នែ៎ ខ្មែរបានយកបានមិនមែនទេ ប៉ុន្តែគ្រាន់តែមានថា ល័ក្ខខ័ណ្ឌបរទេសមិនអាចឡើងការពារក្តីនៅចំពោះមុខតុលាការខ្មែរបានទេតាមច្បាប់នៃលក្ខន្តិកៈមេធាវីដែលបានចែង ហើយមេធាវីហ្នឹង គឺយកមកយកពីក្នុងក្របខ័ណ្ឌរបស់មេធាវីហ្នឹងហើយ អត់មានយកពីណាមកក្រៅទេ ហើយបើបរទេស ក៏មានចុះបញ្ជីនៅក្នុង នែ៎លក្ខន្តិកៈមានចុះបញ្ជីនៅក្នុងនែ៎ គណៈមេធាវី អាហ្នឹងគឺអាចមកការពារបានហើយអត់មានបញ្ហាអីទេ អ៊ីចឹងគឺត្រូវយកនៅក្នុងក្របខ័ណ្ឌគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមអរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងអង្គសភាមិនមានមតិអីទេ សូមធ្វើការអនុម័តនៅជំពូកទី៧ បាទ ។

**អគ្គលេខាធិការរងប្រចាំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី៧លើសេចក្តីព្រាងនៃច្បាប់នេះមាន៩៤លើ៩៤សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងសម្រាកភេសជ្ជៈសិន ។...(បន្ទាប់ពីម៉ោងសម្រាក) អ៊ីចឹងយើងនឹងបន្តពិភាក្សាទៅទៀត អញ្ជើញប្រធានគណៈកម្មការអាននៅជំពូកទី៨ ។

**ឯកឧត្តម ម៉ៅញ សាផាន:** ទូលបង្គំខ្ញុំបាទសូមអានបន្តជំពូកទី៨ៈ ការទទួលខុសត្រូវជាបុគ្គល មាត្រា២៩ៈ ជនសង្ស័យណាមួយដែលមានផែនការញុះញង់ បញ្ជាប្រព្រឹត្ត ឬជួយ និងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តខុក្រិដ្ឋកម្មក្នុងមាត្រា៣,៤,៥,៦,៧និងមាត្រា៨នៃច្បាប់នេះត្រូវទទួលខុសត្រូវជាបុគ្គលចំពោះខុក្រិដ្ឋកម្មនេះ ។ តួនាទីឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ ។ ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងនៅក្នុងមាត្រា៣-៤-៥-៦-៧ និងមាត្រា៨នៃច្បាប់នេះត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះខុក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជានិងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ឬមានអំណាចនិងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹងនិងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ ។ ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ ទូលបង្គំខ្ញុំបាទសូមថ្វាយនិងដាក់ជូនអង្គសភាទាំងមូលនូវជំពូកទី៨ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេងសំរិន:** សូមអង្គសភាទាំងមូលពិភាក្សានៅជំពូកទី៨ !

**ឯកឧត្តម ប៉ែន បញ្ញា:** និយាយរួមខ្ញុំបាទគាំទ្រជំពូកទី៨ ស្តីពីការទទួលខុសត្រូវជាបុគ្គល ប៉ុន្តែសូមស្នើអង្គសភាជួយពិនិត្យនូវពាក្យ“និង” និង “ឬ”នេះគួរតែដាក់ឲ្យបានច្បាស់លាស់ក្នុងមាត្រា៣,៤,៥,៦,៧ ឬមាត្រា៨នៃច្បាប់នេះខាងក្រោមក៏អ៊ីចឹងដែរឬមួយខ្ញុំបាទយល់ច្រឡំយ៉ាងណា ពីព្រោះថាខុសនៅក្នុងមាត្រាណាមួយក៏ត្រូវតែទទួលខុសត្រូវពាក់ព័ន្ធនិងចំណុចនេះដែរ មាត្រា៣,៤,៥,៦,៧ ឬមាត្រា៨នៃច្បាប់នេះ ហើយវាក្យខ័ណ្ឌទី៣ក៏អ៊ីចឹងដែរ ៣,៤,៥,៦,៧ ឬមាត្រា៨នៃច្បាប់នេះ សូមអរគុណ ។

**សម្តេច ហេង សំរិន:** តំណាងឲ្យរាជរដ្ឋាភិបាល

**ឯកឧត្តម សុខ អាន:** ខ្ញុំបាទសូមគោរពសម្តេចប្រធាន សូមគោរពអង្គសភា អំពីពាក្យ “ឬ” និងពាក្យ “និង”នេះនៅក្នុងកថាខ័ណ្ឌទីមួយ កថាខ័ណ្ឌទីមួយនោះគឺយើងប្រើពាក្យ “ឬ” ចង់បញ្ជាក់ថា ករណីណាមួយនៅលើហ្នឹង គឺសុទ្ធតែជាកម្មវត្ថុនៃការចោទប្រកាន់ទាំងអស់ ហើយជនសង្ស័យណាដែលមានផែនការញុះញង់ បញ្ជាប្រព្រឹត្តអាហ្នឹងមួយផ្នែក ឬជួយជំរុញ បានន័យថា អាមុខនេះក៏បាន ឬជួយជំរុញនេះក៏បាន ឬក៏ការ

*ប្រព្រឹត្តក្នុងមាត្រានេះក៏បាន ។ បាទអ៊ីចឹងហើយពាក្យ "ឬ"នេះ ខ្ញុំបាទយល់ឃើញថា គឺជាពាក្យសមស្របហើយ គឺមិនមែនថាចាំតែធ្វើអាទី១ បូកអាទី២ បូកអាទី៣បានក្លាយជាកម្មវត្ថុនៃការចោទប្រកាន់ទេ ប៉ុន្តែធ្វើចំណុចណាមួយក្នុងចំណុចឬៗពីរជង វាចែកជា៣ផ្នែក អ៊ីចឹងដូចអាម្តុំទីមួយនេះក៏ជាប់ ហើយអាទី២នេះក៏ជាប់ បានន័យថាជួយជំរុញក្នុងរឿងនេះ ការរៀបចំផែនការ ឬប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា៣,៤,៥,៦ និងអ៊ីមាត្រា៨នេះ នេះចំពោះពាក្យ "ឬ" ។ ចំពោះពាក្យ "និង" ខ្ញុំបាទយល់ឃើញថា ពាក្យ"និង"នេះ អានេះគ្រាន់ថា យើងនឹងអាចនិយាយបានថា បើយើងនិយាយតាមវេយ្យាករណ៍ គឺថាគ្រាន់តែបន្ត្រប់កិច្ច ឆាប់ អាហ្នឹងវាចុងក្រោយបានន័យថា វាអស់ត្រឹម៨ហ្នឹង ឧបមាថា យើងថាយើងមានមនុស្ស៣នាក់ ថាមនុស្ស "ក" មនុស្ស "ខ" និងមនុស្ស "គ" គេថាលោក "ក" លោក "ខ" លោក "គ"បានដែរ ក៏ប៉ុន្តែបើយើងនិយាយឲ្យសមស្របតាមអាដែងសរសេរក្នុងប្រទេសរបស់យើងដែលយើងធ្លាប់និយាយពីដើមមក គឺយើងថា លោក "ក" លោក "ខ" និងលោក "គ" បានន័យថា វាអស់ត្រឹមលោក "គ" ហ្នឹង អ៊ីចឹង "និង" និងមានន័យតែប៉ុណ្ណឹងទេ បើបានមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨ បានន័យថាវាចប់តែត្រឹមមាត្រាប៉ុន្មានទេពី៣, ៤, ៥, ៦, ៧ និង៨តែប៉ុណ្ណឹងទេ បាទខ្ញុំបាទសូមមានយោបល់តែប៉ុណ្ណឹង ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹង បើអង្គសភាឯកភាពលើជំពូកទី៨នេះ មិនមានបញ្ហាមិនមានមតិអីទេសុំធ្វើការអនុម័ត*

**អគ្គលេខាធិការអង្គប្រជុំ:** *សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន និងសូមគោរពអង្គសភាទាំងមូលជាទីគោរពសំឡេងគាំទ្រលើជំពូកទី៨ លើសេចក្តីព្រាងលើច្បាប់នេះមានចំនួន៩១ លើ៩១ ។*

**សម្តេច ហេងសំរិន:** *អ៊ីចឹងបន្ទាប់ពីអង្គសភាបានអនុមត្តិនៅជំពូកទី៨ សូមអញ្ជើញប្រធានគណៈកម្មការអាននៅជំពូកទី៩ ។*

**ឯកឧត្តម ម៉ោញ សាផាន:** *ជំពូកទី៩ ការិយាល័យរដ្ឋបាល មាត្រា៣០ៈ បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ ។ ការិយាល័យនេះមានប្រធានខ្មែរ១រូប អនុប្រធានបរទេស១រូប និងបុគ្គលិកមួយចំនួនតាមតម្រូវការជាក់ស្តែង ។ មាត្រា៣១ៈ ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់រយៈពេល២ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាល មានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល ។ ប្រធានការិយាល័យរដ្ឋបាលត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាលតុលាការមានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈ និងស្មារតីខ្ពស់ និងសុចរិត ។ អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាលត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ដូចដែលបានតម្រូវឲ្យមានដែនសមាសភាពបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេតការិយាល័យនៃសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវគ្រប់គ្រងប្រាក់ធនធានដែលផ្តល់ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។ ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការតាមតម្រូវការជាក់ស្តែង បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាតាមសំណើរបស់ប្រធានការិយាល័យ បុគ្គលិកបរទេសត្រូវតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល ។ បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀតដែលមានសមាសភាពក្នុងករណីចាំបាច់ ។ មាត្រា៣២ៈ បុគ្គលិកទាំងអស់ដែលមានភារកិច្ចជួយជាជំនួយការដល់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ទទួលបានល័ក្ខខ័ណ្ឌការងារដូចៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ទូលបង្គំខ្ញុំបាទសូមថ្វាយ និងជាក់ជូនអង្គសភាទាំងមូលនូវជំពូកទី៩ដើម្បីពិភាក្សា និងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។*

**សម្តេច ហេង សំរិន:** *សូមអង្គសភាទាំងមូលពិភាក្សានៅជំពូកទី៩បាទ...។ អ៊ីចឹងសូមអញ្ជើញឯកឧត្តម អ៊ុន នឹង ។*

**ឯកឧត្តម អ៊ុន នឹង:** *ខ្ញុំបាទសូមគោរពសម្តេចប្រធានអង្គប្រជុំ សូមគោរពឯកឧត្តមអនុប្រធាន ខ្ញុំបាទគ្រាន់តែសុំការបំភ្លឺតែបន្តិចទេពីតំណាងរាជរដ្ឋាភិបាលនៅក្នុងមាត្រា៣១ វាក្យខ័ណ្ឌទី២ ត្រង់ឃ្លាថា ប្រធានការិយាល័យរដ្ឋបាលត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាល តុលាការ ក្នុងចំណុចរដ្ឋបាលតុលាការ ។ បាទចង់សួរបញ្ជាក់ថា មានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាល ដកឃ្លាទៅតុលាការដាច់ពីគ្នា ឬក៏រដ្ឋបាលតុលាការ? ចង់សួរបញ្ជាក់កន្លែងហ្នឹង បើកាលណាដាច់ពីគ្នាបានសេចក្តីថា ជ្រើសរើសអ្នកដែលមានបទពិសោធន៍ក្នុងការងាររដ្ឋបាលក៏បាន អ្នកមានបទពិសោធន៍ក្នុងការងារតុលាការក៏បាន បើកាលណាជាប់គ្នាបានសេចក្តីថា អ្នកនឹងទាល់តែមានបទពិសោធន៍ការងាររដ្ឋបាលដែរ ក៏ប៉ុន្តែការងាររដ្ឋបាលតុលាការបាទ យើងចង់សុំសួរបញ្ជាក់ត្រង់ហ្នឹងពីព្រោះមានចំណុចមួយចំនួនដែលបានលើកឡើង*

*នៅក្នុងអី...ជំពូកទី៧ មាត្រា២៣ នៅវាក្យខ័ណ្ឌទី៣ មានសរសេរថា សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល កន្លែងនេះទាំងចៅក្រមស៊ើបអង្កេតទាំងសហព្រះរាជអាជ្ញា បើកាលណាមានយោបល់ខ្វែងគ្នា គឺត្រូវដាក់ពាក្យបណ្ដឹងនោះទៅការិយាល័យរដ្ឋបាល គឺទៅប្រធានការិយាល័យរដ្ឋបាល បើប្រធានការិយាល័យរដ្ឋបាលនោះមិនមែនជាអ្នកច្បាប់ មិនមែនជាចៅក្រម តើប្រធានការិយាល័យរដ្ឋបាលនោះចាត់ការយ៉ាងម៉េច បើជាអ្នករដ្ឋបាលសុទ្ធសាធនេះជាបញ្ហាមួយដែលយើងត្រូវពិចារណា ហើយខ្ញុំក៏សូមការបំភ្លឺកន្លែងហ្នឹងឲ្យបានច្បាស់លាស់ សូមអរគុណ ។*

**សម្ដេច ហេង សំរិន:** *សូមអញ្ជើញតំណាងរាជរដ្ឋាភិបាលបាទ ។*

**ឯកឧត្ដម សុខ អាន:** *ខ្ញុំបាទសូមគោរពសម្ដេចប្រធានជាថ្មីម្ដងទៀត ។ ចំណុចដែលឯកឧត្ដម អ៊ុន នឹង លោកបានលើកឡើងនេះ ខ្ញុំបាទចង់គូសបញ្ជាក់បន្ថែមបន្តិចអំពីស្មារតីនៃការរៀបចំការិយាល័យរដ្ឋបាលនេះ ។ ការិយាល័យរដ្ឋបាលអាចនិយាយបានថាជាក្បាលម៉ាស៊ីនមួយសំខាន់សម្រាប់រៀបចំធ្វើឲ្យអង្គជំនុំជម្រះនេះដំណើរការ ដូច្នេះលេចចេញអំពីគោលការណ៍ដែលយើងទទួលឲ្យមានសមាសភាពចម្រុះ បានន័យថាបរទេសផងកម្ពុជាផង ដូច្នេះការិយាល័យរដ្ឋបាលបាទត្រូវទទួលបន្ទុករៀបចំការងារជាទូទៅរបស់អង្គជំនុំជម្រះ បានន័យថាការងារសម្រាប់មន្ត្រីបុគ្គលិកឬចៅក្រមកម្ពុជាផង និងការងារសម្រាប់ចៅក្រមសម្រាប់មន្ត្រីឬបុគ្គលិកបរទេសផង បាទដូច្នេះហើយបានជាយើងចែងថា មានអ្នកធ្វើការនៅទីនេះគឺ កម្ពុជាផង បរទេសផង ។ បាទដូច្នេះមានប្រធានជាមន្ត្រីកម្ពុជា ហើយដែលឯកឧត្ដម អ៊ុន នឹង គាត់បានលើកឡើងនៅចំណុចសំខាន់មួយដែលគួរបញ្ជាក់ឲ្យហើយ គឺថាដែលយើងប្រើពាក្យថារើសហ្នឹងគឺរើសយកតែមន្ត្រីដែលមានបទពិសោធន៍ខាងរដ្ឋបាល ឬមួយក៏ខាងរដ្ឋបាលតុលាការតែម្ដង ខ្ញុំបាទសូមបញ្ជាក់ជូនដែរថា អ្វីដែលយើងចង់បានសរសេរឲ្យបាននៅក្នុងអត្ថបទ យើងសរសេរដល់កន្លែងហ្នឹង គឺវាត្រូវចុះបន្ទាត់អីចឹងហើយមិនដឹងថាជាប់គ្នា ឬក៏មិនជាប់គ្នាបាទ ហើយខ្ញុំបាទក៏សូមបញ្ជាក់ថាវាជាប់គ្នា បើយើងចង់បានអ្នកដែលមានបទពិសោធន៍ខាងរដ្ឋបាលខាងពាក់ព័ន្ធនឹងតុលាការនោះតែម្ដងដើម្បីស្រួលរៀបចំឲ្យអង្គជំនុំជម្រះនេះ គឺដំណើរការបានល្អ ហើយគឺមានភារកិច្ចគ្រប់គ្រងហិរញ្ញវត្ថុផងហើយខាងបរទេសគឺគេនឹងបើតាមស្មារតីនេះ គឺគេនឹងបង្កើតអ្វីដែលហៅថា* trust fund *គឺថាមូលនិធិមួយដោយឡែកបាទ អីចឹងមន្ត្រីបរទេសរបស់គេ គេនិងគ្រប់គ្រងមូលនិធិនេះបាទ រៀបចំឲ្យសម្រួលការងាររបស់មន្ត្រីបរទេសដែលធ្វើការនៅក្នុងអង្គជំនុំជម្រះនេះ ។ បាទចំណែកមន្ត្រីយើងគឺគាត់មានភារកិច្ចលើការងារច្រើនដែរបាទ ដោយសម្រួល សម្របសម្រួល សម្រុះសម្រួលការងារនៅក្នុងដែលពាក់ព័ន្ធមន្ត្រី និងចៅក្រមនិងបុគ្គលិកខ្មែរយើង ហើយនិងហិរញ្ញវត្ថុដែលត្រូវដំណើរការដែលយើងបានចែងថាមន្ត្រីកម្ពុជាចៅក្រមកម្ពុជា គឺទទួលបៀវត្សរ៍ពីរាជរដ្ឋាភិបាលកម្ពុជា ។ អីចឹងគឺនៅមានបន្ទុកហិរញ្ញវត្ថុហ្នឹងក៏២ចំណែកអីចឹងដែរ បាទខាងមន្ត្រីយើង យើងរៀបចំរបស់យើងបាទ ហើយខាងមន្ត្រីបរទេសគេរៀបចំតាមរយៈ* trust fund *នេះបាទ ។ ដូច្នេះខ្ញុំបាទសូមបញ្ជាក់ម្ដងទៀតដែរគឺថា ពាក្យពីរម៉ាត់គួរនឹងសរសេរ អាដែងគំនិតដើមគឺសរសេរឲ្យជាប់គ្នា បានន័យថាបើនិយាយជាអង់គ្លេសគឺថា អ្នកដែលមានបទពិសោធន៍ បើខ្មែរថារដ្ឋបាលតុលាការអីចឹង បើនិយាយជាអង់គ្លេសគឺថា ខាងដែលគេហៅថា* court administration *បានន័យថាគ្រប់គ្រងការងាររដ្ឋបាលនៅក្នុងតុលាការ បាទសូមមានយោបល់តែប៉ុណ្ណឹង ។*

**សម្ដេច ហេង សំរិន:** *អីចឹងបើអង្គសភាមិនមានមតិអីថែមទៀតទេ សូមធ្វើការអនុម័តនៅជំពូកទី៩ ។*

**អគ្គលេខាធិការរងប្រចាំ:** *សូមគោរពទូលថ្វាយសម្ដេចប្រធាន ឯកឧត្ដមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី៩លើសេចក្ដីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។*

**សម្ដេច ហេង សំរិន:** *អីចឹងបន្ទាប់ពីការអនុម័តនៅជំពូកទី៩ សូមអញ្ជើញប្រធានគណៈកម្មការអាននៅជំពូកទី១០ ។*

**ឯកឧត្ដម ម៉ោញ សាផាន:** *ជំពូកទី១០ កិច្ចដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ មាត្រា៣៣ៈ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ ឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ បើជាការចាំបាច់ ហើយនីតិវិធីដែលនៅជាធរមាននោះ មានការខ្វះចន្លោះគេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ ហើយត្រូវបានចាប់ខ្លួនត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួនដោយស្ម័គ្រចិត្តនៅក្នុងការចាត់ការឲ្យចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថមដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗទៀតរបស់រដ្ឋាភិបាលដែលរួមមានកងកម្លាំងប្រដាប់អាវុធ ដើម្បីធានាឲ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ ។ ល័ក្ខខ័ណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន ។ តុលាការត្រូវផ្ដល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការ*

ការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់លើការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ។ មាត្រា៣៤ៈ អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈ លើកលែងតែក្នុងកាលៈទេសៈពិសេសអង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ ដោយមានមូលហេតុត្រឹមត្រូវដោយយោងតាមនីតិវិធីជាធរមាន ។ មាត្រា៣៥ៈ ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឲ្យឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បរមានិងស្មើៗគ្នាដូចខាងក្រោមៈ ក) ទទួលពត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់អំពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ។ ខ) រៀបពេលវេលាដើម្បីរៀបចំខ្លួនដើម្បីទាក់ទងជាមួយមេធាវីរបស់ខ្លួន ។ គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ ។ ឃ) ត្រូវបានការការពារដោយខ្លួនឯងឬតាមរយៈមេធាវីរបស់ខ្លួន ។ ង) ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួមនិងការពិនិត្យភស្តុតាងដាក់បន្ទុកក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងភស្តុតាងដាក់បន្ទុកដែរ ។ ច) មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ឬមិនអាចនិយាយបាននូវភាសាដែលប្រើក្នុងនៅក្នុងតុលាការ ។ ឆ) មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯងឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស ។ មាត្រា៣៦ៈ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ ជំនុំជម្រះលើបណ្តឹងឧទ្ធរបស់ជនជាប់ចោទរបស់ជនរងគ្រោះឬរបស់សហព្រះរាជអាជ្ញាក្នុងលក្ខខណ្ឌដូចខាងក្រោមៈ ការភ័ន្តច្រឡំទៅលើអង្គហេតុ ការភ័ន្តច្រឡំទៅលើអង្គច្បាប់ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ពិនិត្យឡើងវិញនៅការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ។ អង្គជំនុំជម្រះវិសាមញ្ញនេះអាចសម្រេចសេចក្តីស្របឬផ្ទុយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងឬកែប្រែសេចក្តីសម្រេចនេះបាន ។ ក្នុងករណីនេះ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ត្រូវអនុវត្តតាមនីតិវិធីជាធរមាន ។ ប្រសិនបើជាការចាំបាច់ ហើយបើនីតិវិធីដែលនៅជាធរមាននោះមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ មាត្រា៣៧ៈ អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ជំនុំជម្រះលើបណ្តឹងសារទុក្ខរបស់ជនជាប់ចោទរបស់ជនរងគ្រោះ និងរបស់សហព្រះរាជអាជ្ញា សាលដីកានៃការរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ ក្នុងករណីនេះតុលាការកំពូលពិនិត្យសម្រេចជាចុងក្រោយទាំងអង្គហេតុទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍វិញទេ ។ ទូលបង្គំខ្ញុំបាទសូមដាក់ថ្វាយ និងជូនអង្គសភានូវជំពូកទី១០ ដើម្បីពិភាក្សា និងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** សូមអង្គសភាពិភាក្សានូវជំពូកទី១០ បាទ ។ បាទៗសូមអញ្ជើញឯកឧត្តម សម រង្ស៊ី ។

**ឯកឧត្តម សម រង្ស៊ី:** សូមអរគុណសម្តេចប្រធាន សូមគោរពអង្គសភា ហើយសូមគោរពតំណាងរាជរដ្ឋាភិបាលម្តងទៀត ខ្ញុំមានសេចក្តីរីករាយណាស់ដោយឃើញថា នៅក្នុងមាត្រា៣៣វាក្យខ័ណ្ឌចុងក្រោយនៃឃ្លាមួយដែលចែងថា តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ សំខាន់ណាស់មិនមែន តែជនជាប់ចោទមិនមែនតែជនសង្ស័យទេដែលយើងត្រូវតែគិតដល់សុវត្ថិភាព និងផលប្រយោជន៍និងសិទ្ធិរបស់គេ ។ ហើយជនរងគ្រោះ និងសាក្សីក៏យើងត្រូវគិតដល់សុវត្ថិភាពរបស់គេដែរ ពីព្រោះជនរងគ្រោះ ហើយសាក្សីដើម្បីមានភាពក្លាហានហ៊ានស្ម័គ្រចិត្តឡើងមកធ្វើជាសាក្សីរៀបរាប់អំពីអ្វីដែលខ្លួនបានរងគ្រោះពីមុន ឬអ្វីដែលខ្លួនបានឃើញដល់ឡើងមកខ្លាចខ្ញុំបារម្ភ ហើយខ្ញុំជឿថាប្រជារាស្ត្រខ្មែរទាំងមូលបារម្ភដែរថា ពេលជំនុំជម្រះចប់ខ្លាចមានការទៅគាបសង្កត់ទៅធ្វើបាបដល់ជនរងគ្រោះ ឬមួយសាក្សីដែលហ៊ានឡើងមកថ្លែងការពិតចំពោះមុខតុលាការ ។ អ៊ីចឹងខ្ញុំសូមតំណាងរាជរដ្ឋាភិបាលមេត្តាអត្ថាធិប្បាយបន្តិច តើមានវិធានការអ្វីខ្លះទៅដែលធានាការការពារដល់ជនរងគ្រោះនិងសាក្សី បន្ទាប់ពីជនរងគ្រោះនិងសាក្សីនោះបានមកថ្លែងលើសេចក្តីថ្លែងហេតុនេះជូនចំពោះមុខតុលាការបាទ សូមអរគុណ ។

**សម្តេច ហេង សំរិន:** សូមអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រី ។

**ឯកឧត្តម សុខ អាន:** ខ្ញុំបាទសូមគោរពសម្តេចប្រធានជាថ្មីម្តងទៀត អំពីមាត្រាទី៣៣បាទ ដែលចែងអំពីដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញនេះ ហើយស្មារតីធំនៅក្នុងមាត្រាទី៣៣ គឺនៅការអនុវត្តនីតិវិធីជាធរមានដោយយើងយកគោលការណ៍ថា វចនាសម្ព័ន្ធនៅនឹងកន្លែង បាទដូច្នេះគឺនីតិវិធី ដូចជានីតិវិធីដែលមានជាធរមានបាទនៅនឹងកន្លែង ។ នៅក្នុងកថាខ័ណ្ឌចុងក្រោយក៏បានគូសបញ្ជាក់អំពីចំណុច អំពីជនដែលជាអ្នករងគ្រោះនិងសាក្សីបានន័យថាវាមានជនសង្ស័យ ហើយមានជនរងគ្រោះនិងសាក្សី ។ ដូច្នេះ ជាការសំខាន់ណាស់ដែលជនរងគ្រោះ និងសាក្សីអាចផ្តល់ពត៌មានយ៉ាងច្រើនដល់អង្គជំនុំជម្រះដើម្បីអង្គជំនុំជម្រះ លោកមានមូលដ្ឋានច្បាប់មានទឡ្ហីករណ៍ច្បាប់កាន់តែគ្រប់គ្រាន់ដើម្បីធ្វើការឲ្យបានប្រសិទ្ធិភាព ។ ដូច្នេះការលើកទឹកចិត្តការធ្វើឲ្យជនរងគ្រោះនិងមុខសញ្ញាដែលអាចធ្វើជាសាក្សី បើគេហ៊ាននិយាយ គេហ៊ានស្តី គឺជាការសំខាន់បាទការលើកទឹកចិត្តឲ្យគេហ៊ាននេះជាការសំខាន់ដើម្បីរួមចំណែកនៅក្នុងតម្លៃការងារនេះ ។ នៅក្នុងកថាខ័ណ្ឌចុងក្រោយគឺចែងខ្លីទេ ប៉ុន្តែចែងច្បាស់ថាចំណុចដែលការពារជាដំបូង គឺថាការពារនៅក្នុងការដែលអាចនឹងជំនុំជម្រះជាសម្ងាត់មិនចេញឈ្មោះៗគឺថា គោលការណ៍ជារួមគឺថា ត្រូវធ្វើជា

ចំហដោយមានការផ្សព្វផ្សាយទូលំទូលាយផង ប៉ុន្តែក្នុងចំណុចក្នុងការងារដែលចៅក្រមដែលអង្គជំនុំជម្រះយល់ថា ត្រូវការពារជនរងគ្រោះឬត្រូវការពារសាក្សី គឺគេអាចធ្វើដោយមិនចំហបាទ មិនចំហ ហើយមិនមែនតែវិធានការហ្នឹងមួយទេ គឺអាចនឹងមានវិធានការលើសពីនេះ បាទ ស្មារតីនៃកថាខ័ណ្ឌចុងក្រោយ អ៊ីចឹងគឺលើសពីនេះៗយើងក៏មិនអាចគិតមុនថា ទាំងអស់សព្វគ្រប់ថា ត្រូវការពាររបៀបណាខ្លះដែរ បាទគឺថាករណីដែលផ្សេងៗគ្នាច្រើន ប៉ុន្តែអ្វីដែលយើងមើលឃើញមុនគឺថាអាចតុលាការក៏នឹងគិតគូរ អាចចៅក្រមក៏គិតគូរ បាទថាមានវិធានការយ៉ាងណាដើម្បីរក្សាសន្តិសុខ ធានាសុវត្ថិភាពឲ្យជនរងគ្រោះ និងសាក្សីដែលហ៊ានទៅរួមចំណែក ដែលហ៊ានទៅផ្តល់ព័ត៌មានដល់អង្គជំនុំជម្រះ ដល់ចៅក្រម ហើយចំណុចនេះទៀតដែលយើងលើកឡើងអំពីការការពារអត្តសញ្ញាណនេះ ការពារអត្តសញ្ញាណគឺមកដល់ទំព័រហ្នឹងហើយ គឺលើកពីការការពារអត្តសញ្ញាណលើកពីការជំនុំជម្រះដោយសម្ងាត់ គឺអាចមានវិធានការផ្សេងទៀតដែលអាចអង្គជំនុំជម្រះលោកពិចារណា លោកសម្រេចជាវិធានការសមស្របតាមករណីនីមួយៗ ដូច្នេះយើងមិនអាចគិតមុនទាំងអស់ថា វិធានការអីខ្លះដែលសមស្របដើម្បីនិងស្ថានភាពទៅនឹងសភាពការណ៍នីមួយៗនោះគឺទាល់តែករណីនោះវាលេចឡើង ហើយត្រូវផ្អែកលើច្បាប់នេះ ផ្អែកលើស្មារតីនៃមាត្រា៣៣ ជាពិសេសកថាខ័ណ្ឌចុងក្រោយនៃមាត្រា៣៣ គឺអង្គជំនុំជម្រះវិសាមញ្ញ លោកសម្រេចយកវិធានការនោះ ។ បាទសូមមានយោបល់ប៉ុណ្ណឹង ។

**សម្តេច ហេង សំរិន:** *អ៊ីចឹងបើអង្គសភាមិនមានមតិអីថែមទៀតទេ សូមធ្វើការអនុម័តនៅជំពូកទី១០ ។*

**អគ្គលេខាធិការនៃអង្គប្រជុំ:** *សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរពសំឡេងគាំទ្រលើជំពូកទី១០លើសេចក្តីព្រាងច្បាប់នេះគឺមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹងបន្ទាប់ពីការអនុម័តនៅជំពូកទី១០សូមអញ្ជើញប្រធាគណៈកម្មការអាននូវជំពូកទី១១ បាទ ។*

**ឯកឧត្តម ម៉ោញ សាផាន:** *ទូលបង្គំខ្ញុំបាទសូមអាននៅជំពូកទី១១ ទោសបញ្ញត្តិ មាត្រា៣៨ៈ ទណ្ឌកម្ម ទាំងអស់ដែលត្រូវយកមកដាក់ត្រូវកំណត់ត្រឹមទោសដាក់ពន្ធនាគារ ។ មាត្រា៣៩ៈ ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា៣,៤,៥,៦,៧ និងមាត្រា៨នៃច្បាប់នេះត្រូវផ្តន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារពី៥ឆ្នាំរហូតដល់មួយជីវិត ។ ក្រោយពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងអាចសម្រេចរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ ។ ទូលបង្គំខ្ញុំបាទសូមដាក់ថ្វាយនិងជូនអង្គសភានៅជំពូកទី១១ ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណនិងអរគុណ ។*

**សម្តេច ហេង សំរិន:** *សូមអង្គសភាពិភាក្សានៅជំពូកទី១១ បើអង្គសភាឯកភាពនៅជំពូកទី១១នេះ សូមធ្វើការអនុម័តដោយលើកដៃ ។*

**អគ្គលេខាធិការនៃអង្គប្រជុំ:** *សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១១លើសេចក្តីព្រាងនៃច្បាប់នេះមាន៩១លើ៩២ សូមអរព្រះគុណ អរគុណ ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹងបន្ទាប់ពីការអនុមត្តិនៅជំពូកទី១១ ហើយសូមអញ្ជើញប្រធានគណៈកម្មការ អាននូវជំពូកទី១២ ។*

**ឯកឧត្តម ម៉ោញ សាផាន:** *ជំពូកទី១២ ការលើកលែងទោស និងការអនុគ្រោះទោស មាត្រា៤០ៈ រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោសឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា៣,៤,៥,៦,៧ និងមាត្រា៨នៃច្បាប់នេះបានឡើយ ។ ទូលបង្គំខ្ញុំបាទសូមដាក់ថ្វាយ និងជូនអង្គសភាទាំងមូលនូវជំពូកទី១២ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹងសូមអញ្ជើញឯកឧត្តម ជាម យៀប ។*

**ឯកឧត្តម ជាម យៀប:** *ខ្ញុំបាទសូមអរគុណសម្តេចប្រធានអង្គប្រជុំនៃរដ្ឋសភា សូមគោរពអង្គសភា ។ ដោយយល់ឃើញថាខ្លឹមសារនៃសេចក្តីព្រាងជំពូកទី១២នេះ ស្តីពីការលើកលែងទោសនិងការអនុគ្រោះទោសមានសារសំខាន់ ទូលបង្គំសូមស្នើ ខ្ញុំសូមស្នើសួរឯកឧត្តមតំណាងរាជរដ្ឋាភិបាលអំពីមូលហេតុដែលរាជរដ្ឋាភិបាលដាក់ខ្លឹមសារនៃពង្រាងមាត្រា៤០នេះឡើង ។ ហេតុយ៉ាងម៉េចបានដាក់មាត្រានេះ ដោយយល់ឃើញនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៣និងវិសោធនកម្មឆ្នាំ៩៩កន្លងមកយើងឃើញថានៅមាត្រា អ៊ុំនៅជំពូកទី២ មាត្រា២៧ បាន...។ គឺបន្ថយនិងលើកលែងទោសហ្នឹងទី១ ទី២ហ្នឹងជំពូកទី៧ មាត្រា៩០ថ្មីនៃរដ្ឋធម្មនុញ្ញដែលបានចែងថានៅក្នុងកឋាខ័ណ្ឌទី៤នៃមាត្រានេះបានលើកឡើងថារដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។ អ៊ីចឹងរដ្ឋធម្មនុញ្ញមានតែពីរហ្នឹងទេ មានតែព្រះមហាក្សត្រនិងរដ្ឋសភា ។ អ៊ីចឹងទេគឺថាក្នុងមាត្រានេះបានលើកឡើងដល់រាជរដ្ឋាភិបាលមិនអាចស្នើសុំ ខ្ញុំបាទគ្រាន់តែឆ្ងល់ទេ ឆ្ងល់ថា ចាំបាច់ដាក់មាត្រាហ្នឹងមកធ្វើអី? ។ មូលហេតុ*

នៃការដាក់នេះពីព្រោះអីចេះ បើតាមខ្ញុំបាទស្រាវជ្រាវខ្លះមើលឃើញថា ព្រះមហាក្សត្រ ព្រះអង្គមានព្រះរាជសិទ្ធិដើម្បីលើកលែងទោស ភាសាបារាំងហៅ grâce. grâce មានន័យអីចេះ grâce មានន័យថាព្រះអង្គលើកលែងទោសឲ្យរូបខ្លួន ក៏ប៉ុន្តែបើសិនសាលក្រមនៃតុលាការបានកាត់ត្រូវសងជំងឺចិត្តឬបង់ការខូចខាតឬក៏រឹបអូសទ្រព្យសម្បត្តិឬអ្នកដែលត្រូវរួចទោសនោះត្រូវតែធ្វើទៅតាមសាលក្រមតុលាការបន្ថែមទៀត ។ អាហ្នឹងអត់មានអីទេ អត់មានអត់ទាំងអស់ទេ ប៉ុន្តែបើសិនជារដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ មានន័យអត់ទោស អត់សាលក្រមនឹងលែងថ្កោលទោសគេទៅទៀត ។ មានន័យថាអត់មានត្រូវការសងអីទេ គឺថាឲ្យទៅសភាអនុម័តថាលែងហើយ គឺលែងតែម្តង អត់មានសងជំងឺចិត្តសងអីទាំងអស់ ។ អីចឹងគឺថា Amnesty ភាសាបារាំង Amnesty ។ អីចឹងបានជាអាដែងនែ៎ ខ្ញុំសុំឯកឧត្តមតំណាងរាជរដ្ឋាភិបាលសូមមេត្តាបញ្ជាក់ពីមូលហេតុ ។ ខ្ញុំឯកភាពគឺឯកភាពហើយ ប៉ុន្តែគ្រាន់តែថា មានការឆ្លល់រដ្ឋធម្មនុញ្ញមានចែងដល់តែពីរមាត្រាឯណោះ ជំពូក២ មាត្រា២៧ និងជំពូក៧ មាត្រា៩០ មួយព្រះមហាក្សត្រ មួយរដ្ឋសភា ។ អីចឹងទេបានជាហេតុដូចម្តេចបានជារាជរដ្ឋាភិបាលលោកលើកមាត្រានេះឡើង? មូលហេតុម្តេច? ខ្ញុំបាទគ្រាន់តែសូមបញ្ជាក់ប៉ុណ្ណឹងទេ សូមអស់យោបល់ ។ សូមអរគុណ ។

**សម្តេច ហេង សំរិន:** អីចឹងសូមអញ្ជើញតំណាងរាជរដ្ឋាភិបាល ។

**ឯកឧត្តម សុខ អាន:** ខ្ញុំបាទសូមគោរពសម្តេចប្រធានជាថ្មីម្តងទៀត នេះជាចំណុចសំខាន់ដែលឯកឧត្តម ជាម យៀប លោកចាប់អារម្មណ៍ ហើយបានលើកឡើងនេះ ។ ខ្ញុំបាទបានលើកពីខាងដើមអំពីជំហានទាំងបួននៃការសម្របសម្រួល និងសម្រុះសម្រួលគ្នារវាងរាជរដ្ឋាភិបាលនិងឯកឧត្តមអគ្គលេខាអង្គការសហប្រជាជាតិ ។ នេះមាត្រា៤០ នេះជាជំហានមួយទៀតដែលទូលបង្គំខ្ញុំបាទមិនបានលើកឡើងនៅក្នុងជំហានទាំងបួននោះ ដោយចាត់ទុកថាចំណុចនេះវាមានអាចថាវិសាលភាពនោះ វាតូចជាងជំហានទាំងបួន ។ ចំណុចទាំងបួនដែលបានកំណត់នៅក្នុងជំហានទាំងបួនដែលទូលថ្វាយ និងជម្រាបជូនអង្គសភាពីថ្ងៃមុន ។ ប៉ុន្តែតាមពិតនេះក៏ជាចំណុចមួយដែលជាកម្មវត្ថុនៃការពិភាក្សាគ្នាយ៉ាងយូរយ៉ាងស៊ីជម្រៅដែរ ខាងឯកឧត្តមអគ្គលេខាអង្គការសហប្រជាជាតិស្នើថា នៅក្នុងមាត្រា៤០ នេះដែលចែងពីការលើកលែងទោសនេះ គឺសុំសរសេររបៀបម៉េចមិនឲ្យមានការលើកលែងទោសតែម្តង មិនឲ្យមានការលើកលែងទោសតែម្តង គឺការកាត់ហើយ ការកាត់ដោយអង្គជំនុំជម្រះគឺកាត់ហើយ គឺអនុវត្តទោសនោះដោយមិនមានការលើកលែង ។ ចំពោះរាជរដ្ឋាភិបាលយើងបញ្ជាក់ជម្រាបគេវិញថាមិនអាចសរសេរអីចឹងបានទេ ក៏ព្រោះវាផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់ព្រះរាជាណាចក្រកម្ពុជាដែលចែងអំពីព្រះរាជសិទ្ធិរបស់ព្រះករុណាព្រះមហាក្សត្រក្នុងការលើកលែងទោសក៏ដូចដែលឯកឧត្តម ជាម យៀប លោកឡើងថា Grâce ហើយនិងសិទ្ធិរបស់រដ្ឋសភាដែរដែលលើកលែងអំពីការលើកលែងទោសនេះដែរដែលឯកឧត្តម ជាម យៀប លោកឆ្លើយថា Amnesty ។ ដូច្នេះបើសរសេរតាមគំនិតដើម តាមសំណើរបស់ឯកឧត្តមអគ្គលេខាអង្គការសហប្រជាជាតិគឺយើងមិនអាចសរសេរបាន ។ ដូច្នេះត្រូវតែរើសរូបមន្តសម្របសម្រួលមួយ ។ អីចឹងរាជរដ្ឋាភិបាលបានគិតថា អ៊ីដែលសន្យាជាមួយគេបានច្បាស់លាស់គឺការដែលរាជរដ្ឋាភិបាលមិនស្នើសុំបាទ ផ្តើមគំនិតសុំឲ្យមានការលើកលែងទោស ហើយចំណុចនេះក៏បានជជែកពិភាក្សាគ្នាយូរដែរ ។ ទូលបង្គំខ្ញុំបាទនៅចាំថាគេឯកភាពចំណុចនេះជាមួយយើង ប៉ុន្តែគេឯកភាពការពន្យល់របស់យើងថា រាល់ការលើកលែងទោសសំខាន់ៗកន្លងមកគឺព្រះមហាក្សត្រ ព្រះករុណា ព្រះមហាក្សត្រលោកបានពិនិត្យសំណើរបស់រាជរដ្ឋាភិបាលនិងសំណើរបស់សមាជិកសភាដែរ ។ ដូច្នេះដោយផ្អែកលើការពិចារណាចំណុចនេះ គឺចុងក្រោយយើងបានឈានមកដល់រូមមន្តសម្របសម្រួលនេះបានដែលយើងត្រឹមតែថា រាជរដ្ឋាភិបាលមិនស្នើសុំ ដូច្នេះទូលបង្គំខ្ញុំបាទយល់ថា មាត្រា៤០គឺអាចសមស្របទៅនឹងស្មារតីនៃរដ្ឋធម្មនុញ្ញរបស់យើង ហើយក៏ជាចំណុចដែលគេពិចារណាច្រើនជាងគំនិតការងារដែលធ្វើមកហើយនោះគឺគេបានឯកភាពដោយគេបានស្នើឲ្យទូលបង្គំខ្ញុំបាទធ្វើលិខិតមួយប្រាប់គេជូនដំណឹងគេជាលាយលក្ខណ៍អក្សរអំពីដំណើរការដែលមានកន្លងមក ។ ក្នុងលិខិតនោះគឺយើងមិនមានលើកគោលការណ៍អីថ្មីទេ មិនមាននិយាយគំនិតអីដែលខុសពីមាត្រាដែលយើងសរសេរនៅក្នុងមាត្រា៤០ នោះទេ គ្រាន់តែយើងជូនពត៌មានគេថា ករណីពីមុនយើងបានធ្វើអីចេះៗ ។ ដូច្នេះគេបានឆ្លើយមកយើងវិញថា អីចឹងគេឃើញថាដំណើរការយើងគឺដូចដែលយើងបានពន្យល់គេនៅលើតុចរចាដែរមែន ហើយគេឯកភាពតាមយើង នេះជាចំណុចដែលជាមូលហេតុសំខាន់នៅពេលឯកឧត្តម ជាម យៀប លោកស្វែងយល់ថា ហេតុដូចម្តេចបានជាមានមាត្រា៤០ នេះដែលបានចែងអំពីការមិនលើកលែងទោស ខ្ញុំបាទសុំមានយោបល់ប៉ុណ្ណឹង ។

**សម្តេច ហេង សំរិន:** ខ្ញុំសូមឲ្យអង្គសភាធ្វើការអនុម័តនូវជំពូកទី១២

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន និងអង្គសភាទាំងមូលជាទីគោរព ។ សំឡេងគាំទ្រលើជំពូកទី១២ លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ ។ សូមអរព្រះគុណ អរគុណ ។ ***(នៅមានត)***

# ទីបញ្ចប់នៃបដិវត្តន៍

នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ ប៉ុល ពត បានប្រកាសថា «អ្វីដែលត្រូវការជាមុនគឺត្រូវវិនិច្ឆ័យថាអ្វីត្រូវអ្វីខុស ។ ចម្លើយគឺៈ កម្លាំង!កម្លាំង!...បើអ្នកឯងមានកម្លាំងអ្នកឯងពិតជាត្រូវ ហើយប្រសិនបើអ្នកឯងខ្វះកម្លាំងអ្នកឯងពិតជាខុស» ។

ប្រសិនបើ ប៉ុល ពត ជឿយ៉ាងដូច្នេះ នោះ ប៉ុល ពត អាចមានការភ័ន្តគំនិតខ្លះអំពីរបៀបដែលប្រវត្តិសាស្ត្រនឹងវិនិច្ឆ័យរូបគាត់ផ្ទាល់និងចលនារបស់បដិវត្តខ្មែរក្រហម ។ អាចនិយាយបានថា ប៉ុល ពត ស្លាប់នៅពេលដែលគាត់ត្រូវរត់គេចខ្លួនពីសំណាញ់យុត្តិធម៌អន្តរជាតិ ប៉ុន្តែ ប៉ុល ពត បានរស់នៅក្នុងរយៈពេលមួយគ្រប់គ្រាន់រហូតដល់បានឃើញការស្រមើស្រមៃរបស់ខ្លួននៅទីបញ្ចប់រលំរលាយដោយជាក់ច្បាស់ ។ ប៉ុល ពត ស្លាប់ទៅក្នុងខណៈដែលចលនាកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួនស្ថិតនៅក្នុងភាពខ្សោយបំផុតក្នុងរយៈពេល៣០ឆ្នាំនេះ ដោយមានទាហានពីរឬបីនាក់ និងទឹកដីកាន់កាប់តែមួយក្រវេចតូចតែប៉ុណ្ណោះ ។ ប៉ុល ពត ស្លាប់នៅចំពោះមុខសត្រូវរបស់ខ្លួនដែលគាំទ្រដោយវៀតណាមពោលគឺគណបក្សប្រជាជនដែលមានកម្លាំងខ្លាំងជាងពេលណាៗទាំងអស់ ។ ប៉ុល ពត ស្លាប់ ទៅ ដោយមានអ្នកក្បត់ស្ទើរតែទាំងអស់រួមទាំងអ្នកដែលខ្លួនមានការសង្ស័យជាយូរមកហើយ និងអ្នកដែលខ្លួនទុកចិត្តបំផុតទៀតផង ។ ជាងនេះទៀតនៅប៉ុន្មានខែចុងក្រោយ ប៉ុល ពត មិនបានលាក់ខ្លួនដោយសុខស្រួលនៅក្នុងរបាំងសម្ងាត់របស់ខ្លួនឡើយ ។ ទោះជាមានល្បិចផ្ទាល់ខ្លួនខ្លាំងប៉ុនណាក៏ដោយ ក៏ ប៉ុល ពត ត្រូវស្លាប់ដោយនាំយកទាំងការដឹងឮថាការតស៊ូដែលខ្លួនខំធ្វើមួយជីវិតបែរជាត្រូវបញ្ចប់ដោយបរាជ័យយ៉ាងអាម៉ាស់ជាទីបំផុត ។


ប៉ុល ពត

ហេតុដូចម្តេចបានជារឿងកើតឡើងដល់ថ្នាក់នេះ? តើ ប៉ុល ពត ធ្វើដូចម្តេចខ្លះទើបអាចដឹកនាំចលនាឈ្លបដែលគួរឲ្យភ័យខ្លាចបំផុតនៅលើពិភពលោកបានក្រោយពីការតស៊ូអស់រយៈពេលជិត៥០ឆ្នាំនេះ ហើយចុងក្រោយបែរជាត្រូវបញ្ចប់ដោយអាណោចអធ័មយ៉ាងនេះទៅវិញ? អត្ថបទនេះនឹងធ្វើការពិពណ៌នា និងពន្យល់អំពីឆ្នាំចុងក្រោយរបស់ខ្មែរក្រហម ដោយទាញយកតាមរយៈឯកសារផ្ទៃក្នុងនិងខាងក្រៅរបស់ខ្មែរក្រហម និងកិច្ចសម្ភាសន៍ជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហម ។

## ការដួលរលំច្បាស់ក្រឡែត

តាមពិតមានភាពប្រត្យក្សនៃប្រវត្តិសាស្ត្រស្តីអំពីការធ្លាក់ចុះនិងការរលំរលាយរបស់ខ្មែរក្រហមដែលជាចលនាកុប្បកម្មមានចរិតម៉ៅនិយមចុងក្រោយគេបង្អស់នៅភូមិភាគអាស៊ីអគ្នេយ៍ និងចលនាកុប្បកម្មមួយក្នុងចំណោមចលនាកុប្បកម្មនានានៅលើពិភពលោក ។ ប៉ុល ពត មិនខុសពីជនកុម្មុយនិស្តនៅគ្រប់ទីស្ថានទាំងអស់ដែលទទួលបានជោគជ័យ ទេគឺតែងតែជឿជាក់ថាជោគជ័យបានមកដោយសារកម្លាំងប្រជាជននិងការគាំទ្រពីសំណាក់មាគ៌ាបក្សនិងការដឹកនាំដ៏ត្រឹមត្រូវ ។ ប៉ុន្តែតាមការពិតមិនដូច្នេះឡើយ ។មហាជនមិនដែលត្រូវបានឲ្យដឹងអំពីមាគ៌ានិងការដឹកនាំពិតប្រាកដ

របស់បក្សដែលមហាជនត្រូវរំពឹងឲ្យគាំទ្រនោះទេ ។ ការគាបសង្កត់ត្រូវតែមានក្នុងការបំពេញចន្លោះរវាងវោហាសាស្ត្រនិងការជាក់ស្ដែង រវាងគំនិតអ្នករដ្ឋការនិងការគិតរបស់ប្រជាជនទូទៅទៅលើអ្វីដែល «ប្រជាជនចង់បាន» ។ ប៉ុន្ដែតាមការពិតខ្មែរក្រហមទទួលបានជោគជ័យដោយសារតែខ្លួនចងសម្ព័ន្ធភាពជាមួយនឹងជាតិនិយមដែលមានជាប្រពៃណីយូរណាស់មកហើយ ជាមួយរណសិរ្សរួបរួមជាតិដឹកនាំដោយសម្ដេចសីហនុ និងជំនួយយោធាមកពីខាងក្រៅ ។ ខ្មែរក្រហមបានទទួលអំណោយផលផ្នែកសង្គ្រាមពីសំណាក់វៀតណាមខាងជើងនិងប្រទេសចិន ហើយអាចរួចជីវិតសាជាថ្មីក្រោយពីបរាជ័យក្នុងឆ្នាំ១៩៧៩ ដោយសារការជ្រោមជ្រែងពីប្រទេសថៃ និងប្រទេសចិនដែរ ។ នៅពេលដែលចលនាខ្មែរក្រហមត្រូវបានដាត់ចោលតាមក្រុមរបស់ខ្លួនដូចជានៅក្រោយកិច្ចព្រមព្រៀងនៅទីក្រុងហ្សឺណែវឆ្នាំ ១៩៥៤និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ ចលនានេះមិនបានសម្រេចជោគជ័យឡើយទាំងផ្នែកនយោបាយនិងផ្នែកយោធា ។ ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យដែលចងក្រងឡើងនៅក្នុងអំឡុងនៃការកាន់អំណាចរបស់ខ្លួនបានបង្ហាញថាថ្នាក់ដឹកនាំមិនត្រឹមតែសាហាវឃោរឃៅប៉ុណ្ណោះទេ តែថែមទាំងគួរឲ្យរំខានមិនប្រាកដប្រជាហើយនិងអសមត្ថភាពទៀតផង ។

ទោះបីជាមានឯកសារបញ្ជាក់យ៉ាងនេះក៏ដោយក៏ ប៉ុល ពត នៅតែរក្សាការដឹកនាំចលនាខ្មែរក្រហមរហូតដល់ទសវត្សរ៍ឆ្នាំ ១៩៩០ ដោយសារនៅក្នុងចំណោមសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ប៉ុល ពត ជាអ្នកយុទ្ធសាស្ត្រខ្លាំងជាងគេ និងជាដែលអ្នករក្សាភក្ដីភាពបានយូរបង្អស់ ។ មិនតែប៉ុណ្ណោះ ការរស់នៅបានយូរ បានផ្ដល់ភាពស្របច្បាប់ទាំងចំពោះការដឹកនាំ និងគំនិតព្រមទាំងយុទ្ធវិធីរបស់ខ្លួន ។ ក៏ប៉ុន្ដែ បរាជ័យដ៏យូរអង្វែងទៅមុខទៀតនៃការផ្ដើមគំនិតរបស់ ប៉ុល ពត ទោះបីជាមានតក្កភាពនិងជោគជ័យនៅពីដំបូងដែយ៉ាងណាក៏ដោយ ប៉ុន្ដែចុងបញ្ចប់វាបានធ្វើឲ្យការដឹកនាំរបស់ខ្លួនចុះអន់ថយ ។ មហាឃាតកម្មអាចអត់ឱនទោសឲ្យបាន តែការបរាជ័យមិនអាចទៅរួចតាមផ្លូវនេះទេ ។ ការដឹងខ្លួនថា បរាជ័យនៃអ្នកដែលជឿតាម ប៉ុល ពត ត្រូវបានពិពណ៌នាដោយអតីត «អ្នកចេះដឹង» របស់របបកម្ពុជាប្រជាធិបតេយ្យថា «ក្នុងចំណោមអ្នកដឹកនាំទាំងអស់មានតែ ប៉ុល ពត ទេដែលពូកែខាងគំនិតនិងវិភាគ ។ ពេលនិយាយអំពីបញ្ហាអ្វីមួយ ប៉ុល ពត ប្រសប់ពន្យល់ណាស់ ពន្យល់ទាល់តែអ្នកឯងជឿថា គាត់ពិតជារកឃើញដំណោះស្រាយចំពោះបញ្ហានេះហើយ ។ ប៉ុន្ដែពេលមកអនុវត្តផ្ទាល់វិញដំណោះស្រាយរបស់ ប៉ុល ពត ខុសទទេ ។ បន្ទាប់មកទៀតគាត់បានដាក់គំនិតមួយទៀតដែលអាចទាញការជឿជាក់បាន ប៉ុន្ដែក្រោយមកបរាជ័យម្ដងទៀត ។ ដល់អីចឹងក្រោយមកខ្ញុំលែងជឿគាត់រហូត» ។

## ១៩៧៩-៩០: ការកសាងចលនាសាជាថ្មី

នៅចុងឆ្នាំ១៩៧៨ ប៉ុល ពត ទទួលស្គាល់ដោយស្ទាក់ស្ទើរថាការគំរាមកំហែងរបស់វៀតណាមនឹងបង្អាក់ដំណើរការ «មហាលោតផ្លោះ»របស់ខ្លួនដែលជាការប៉ុនប៉ងដើរតាមផ្លូវកាត់ឆ្ពោះទៅរកលទ្ធិកុម្មុយនិស្ត និងដើម្បីឲ្យខ្លួនវិលត្រឡប់មកប្រើល្បិចចូលរួមជាមួយនឹង«រណសិរ្សរួបរួមជាតិ»ដែលបក្សបានប្រើយ៉ាងជោគជ័យនៅមុនឆ្នាំ១៩៧៥ ។ ប៉ុន្ដែល្បិចកលរបស់ «រណសិរ្សរួបរួមជាតិ»ដែលពាក់ព័ន្ធក្នុងការបំភ្លៃគោលដៅពិតប្រាកដរបស់បដិវត្តន៍ដើម្បីទទួលបាននូវការគាំទ្ររយៈពេលខ្លីពីសំណាក់សត្រូវយូរអង្វែងគឺអាចប្រើបានតែម្ដងតែប៉ុណ្ណោះ ។ ដូច្នេះក្រោយពីការចូលលុកលុយរបស់វៀតណាមពេលដែលកម្ពុជាប្រជាធិបតេយ្យបង្ហាញជាលើកដំបូងនូវនិន្នាការរបស់ខ្លួនដែលឈានជិតដល់ការដួលរលំ ការប៉ុនប៉ងប្រមូលផ្ដុំកម្លាំងរណសិរ្សរួបរួមជាតិ (ដែលជារណសិរ្សស្នេហាជាតិ និងរួបរួមជាតិប្រជាធិបតេយ្យដើម្បីមហាសាមគ្គីកម្ពុជាដឹកនាំដោយ ខៀវ សំផន) បានចេញមុខច្បាស់ក្រឡែត ហើយទទួលបរាជ័យយ៉ាងដំណំដូចជាការប៉ុនប៉ងក្នុងការវាយលុកផ្នែកយោធាទូទាំងប្រទេសដែរ ។

ដោយដឹងថាកម្លាំងកងទ័ពរបស់ខ្លួនចុះខ្សោយហើយ ប៉ុល ពត បែរមកធ្វើការតស៊ូ«ជាលក្ខណៈយូរអង្វែង» ដោយប្រើ «សង្គ្រាមឈ្លបនិងសង្គ្រាមប្រជាជន» ។ ដើម្បីទទួលមនុស្សចូលថ្មីនិងធានាសម្ព័ន្ធភាពជាមួយនឹងពិភពមូលធននិងសមភាពក្នុងស្រុក ប៉ុល ពត បានធ្វើការផ្លាស់ប្ដូរចំណុចសំខាន់ៗនៅក្នុងអង្គការនិងនយោបាយរបស់ខ្លួនៈ បក្សកុម្មុយនិស្តកម្ពុជាត្រូវបាន

រំលាយ ហើយគ្រប់ការឃោសនាទាំងអស់ផ្តោតលើគោលការណ៍ជាតិនិយមប្រឆាំងនឹងវៀតណាមហើយចលនាកងទ័ពត្រូវប្រកាន់ខ្ជាប់បទដ្ឋានសេដ្ឋកិច្ចនិងនយោបាយសេរី ។ ការផ្លាស់ប្តូរនេះភាគច្រើនកើតឡើងមែន ប៉ុន្តែក៏វាក្លាយជាគំនិតដែលគិតតែពីលទ្ធផលពេក ពីព្រោះស្ថានភាពអន្តរជាតិនិងមតិសាធារណៈត្រូវការរបៀបនេះ ។ ប៉ុល ពត និងថ្នាក់ដឹកនាំជាន់ខ្ពស់នានាដែលស្ថិតនៅក្នុងអំណាចនៅឡើយ ទោះបីជាមានការរំពឹងថានឹងលាលែងនិងចូលនិវត្តន៍ក៏ដោយនោះ បានអត្តនោម័តិបន្តលាក់បាំងនូវភាពរកាំរកូសជាមួយនឹងមូលធននិយមនិងជនមូលធន ។ មិនតែប៉ុណ្ណោះថែមទាំងបានបន្តជឿថាការអនុញ្ញាតឲ្យមានសេរីភាវូបនីយកម្មនៅក្នុងតំបន់រំដោះមួយក្តាប់តូចនេះនិងពាណិជ្ជកម្មនិងការទាក់ទងសេរីជាមួយនឹងលោកខាងក្រៅអាចធ្វើឲ្យគ្រោះថ្នាក់ដល់ភាពប្រកាន់ខ្ជាប់ខ្ជួនស្អិតល្មួតនឹងវិន័យរបស់ចលនានេះ ។ ហេតុដូចនេះបានជា ប៉ុល ពត និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្លួនយកលេសនិយាយថាមានសង្គ្រាមដើម្បីដាក់កម្រិតលើសេរីភាពដែលខ្លួនទទួលយកជាសាធារណៈ ។

នៅពេលដែលល្បិចកលរបស់រណសិរ្សរួបរួមជាតិបានសម្រេចគោលបំណងរយៈពេលខ្លីដោយនាំមកនូវការកើនឡើងនូវកម្លាំងទ័ពកម្លាំងការទូត និងនយោបាយពេញទសវត្សរ៍ឆ្នាំ ១៩៨០ ប៉ុល ពត និងថ្នាក់ដឹកនាំបានបង្កុកជាការលំបាករយៈពេលយូរអង្វែង ។ ដោយឡែកការអូសបន្លាយល្បិចកលរបៀបនេះមានន័យថានៅក្នុងឆ្នាំ១៩៩០ ដូចនៅឆ្នាំ១៩៧៥ដែរ ប៉ុល ពត មិនដឹងថាអ្នកណាមានភក្តីភាពជាមួយនឹងបក្សនិងឧត្តមគតិបដិវត្តពិតៗឡើយ ហើយក៏មិនដឹងថាអ្នកណាខ្លះពេញចិត្តចំពោះការដកចេញរបស់បរទេសនិងរដ្ឋាភិបាលកាន់លទ្ធិប្រជាធិបតេយ្យដែលដឹកនាំដោយសម្តេច ព្រះនរោត្តម សីហនុ ។

## ១៩៩០-១៩៩៤ ការលេងសើចជាមួយសន្តិភាព

នៅក្នុងឆ្នាំ១៩៩០ បន្ទាប់ពីកងទ័ពវៀតណាមបានដកចេញពីកម្ពុជានិងមានសម្ពាធអ្នកគាំទ្រនៅបរទេសកាន់តែកើនឡើងជំរុញឲ្យមានដំណោះស្រាយមួយ ខ្មែរក្រហមនៅតែមិនស្ថិតនៅក្នុងជំហរយោធានិងនយោបាយក្នុងការឆក់យកអំណាចសាជាថ្មីឡើយ ។ តាម៉ុក ចង់បន្តការវាយប្រហារតទៅទៀតទោះបីជាគ្មានជំនួយក៏ដោយ ប៉ុន្តែ ប៉ុល ពត វិញសន្និដ្ឋានថាដំណោះស្រាយបញ្ហាសន្តិភាពអាចរារាំងដល់ការវាយប្រហារនេះ ហើយបានលើកឡើងលក្ខខណ្ឌពីរចំណុច ។

លក្ខខណ្ឌទីមួយគឺថា ដំណោះស្រាយបញ្ហាសន្តិភាពធ្វើឲ្យខ្លាំងរបស់ខ្លួនចុះថមថយកម្លាំងតាមរយៈការបំបាក់ក្បាលម៉ាស៊ីនរដ្ឋរបស់គណបក្សប្រជាជននិងការដកកងទ័ពវៀតណាម ។ ក្នុងគំនិត ប៉ុល ពត ការដកកងទ័ពវៀតណាមទាំងអស់ចេញពីប្រទេសកម្ពុជាអាចនាំដល់ការបញ្ចប់របបដែលដឹកនាំដោយគណបក្សប្រជាជន ពីព្រោះក្នុងចំណោមក្រុមប្រឆាំងទាំងអស់គណបក្សប្រជាជនគ្មានមូលដ្ឋានសង្គមនៅក្នុងសង្គមកម្ពុជាទេ ។ ប៉ុន្តែការព្រួយបារម្ភចម្បងរបស់ ប៉ុល ពត គឺការរំលាយរដ្ឋកម្ពុជាដែលខ្លួនយល់ថាជាមធ្យោបាយសំខាន់បំផុតដើម្បីធានាដល់ការដកទ័ពឲ្យអស់ពីប្រទេសកម្ពុជា ។

លក្ខខណ្ឌទីពីររបស់ប៉ុល ពត គឺថាដំណោះស្រាយអ្វីក៏ដោយមុននិងក្រោយការបោះឆ្នោតនឹងនាំដល់ការបង្កើតរដ្ឋាភិបាលចតុភាគី ។ ដោយមានតួនាទីឯករាជ្យនៅក្នុងរដ្ឋាភិបាល និងកងទ័ព និងដោយរក្សាទុក «តំបន់រំដោះ» របស់ខ្លួនកម្ពុជាប្រជាធិបតេយ្យអាចនឹងទទួលបាននូវភាពស្របច្បាប់ផ្នែកនយោបាយនិងមូលដ្ឋានសេដ្ឋកិច្ចដែលជាតម្រូវការដ៏ចាំបាច់ ។ កម្ពុជាប្រជាធិបតេយ្យអាចមានសមត្ថភាពក្នុងការការពារទឹកដីរបស់ខ្លួន កងកម្លាំងប្រដាប់អាវុធ និងថ្នាក់ដឹកនាំមិនឲ្យមានគ្រោះថ្នាក់ដែល ប៉ុល ពត យល់ថាជាបញ្ហានៅពេលទទួលយកមូលធននិយម និងការបែងចែកអំណាច ។ ដោយសារមានការកសាងមូលដ្ឋានសេដ្ឋកិច្ចនយោបាយ និងយោធានៅក្នុងប្រទេសខ្មែរក្រហមអាចបាត់បង់ជំនួយពីប្រទេសចិននិងជំរំសម្រាប់ជ្រកកោននៅក្នុងប្រទេសថៃ ។

ប៉ុល ពត មិនដែលពន្យល់អំពីអ្វីដែលនឹងត្រូវកើតឡើងក្រោយពីការបង្កើតរដ្ឋាភិបាលចតុភាគីនេះឡើយ ។ ប៉ុន្តែហាក់ដូចជាថា ប៉ុល ពត យល់ឃើញថា កម្ពុជាប្រជាធិបតេយ្យកំពុងតែទទួលបាននូវការគាំទ្រនៅពេលដែលក្រុមបដិបក្ខដទៃទៀតដួលរលំដោយសារទំនាស់ផ្ទៃក្នុងនិងការចុះខ្សោយកម្លាំង ។ មិនយូរមិនឆាប់នៅពេលខាងមុខ នៅពេលមានអំណោយផលពីក្នុងស្រុក និងអន្តរជាតិ ខ្មែរក្រហមអាចឡើងមកកាន់អំណាចតាម

មធ្យោបាយនយោបាយនិងយោធាដូចជាករណីប្រទេសឡាវនិងជនកុម្មុយនិស្តវៀតណាមខាងត្បូងកាលពី២ឆ្នាំមុន ក្រោយពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសកាលពីឆ្នាំ១៩៧៣ ។

ប៉ុល ពត ជឿថាកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដោយមានវត្តមានដ៏សន្ធឹកសន្ធាប់របស់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលចតុភាគីដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ (ក្រុមប្រឹក្សាជាន់ខ្ពស់ជាតិកម្ពុជា) នឹងសម្រេចលក្ខខណ្ឌទាំងពីររបស់ខ្លួនមិនខាន ។ ក៏ប៉ុន្តែក្នុងអំឡុង២សប្តាហ៍ ក្រោយពីការចុះហត្ថលេខានៅខែតុលា ឆ្នាំ១៩៩១ ប៉ុល ពត បានរំពឹកឡើងវិញនូវការវិភាគរបស់ខ្លួន ហើយសម្រេចចិត្តថាវត្តមានរបស់អង្គការសហប្រជាជាតិនិងការវិលត្រឡប់របស់សម្តេច សីហនុ មកទីក្រុងភ្នំពេញ កំពុងតែជំរុញជាជាងធ្វើឲ្យខ្សោយដល់រចនាសម្ព័ន្ធរបស់រដ្ឋកម្ពុជា ។ ការផ្លាស់ប្តូរដែលជាការយល់ឃើញគឺការធ្វើអន្តរាគមន៍របស់«សត្រូវថ្មី»ដែលជា«ប្លុកមហាអំណាចលោកខាងលិច» បន្ថែមទៅលើ «សត្រូវចាស់» គឺវៀតណាម ។ ប៉ុល ពត យល់ថា ការចងសម្ព័ន្ធភាពរវាងគណបក្សប្រជាជនរបស់សម្តេច ហ៊ុន សែន និងគណបក្សហ៊្វុនស៊ិនប៉ិចរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ កាលពីខែកញ្ញាឆ្នាំ១៩៩១ថា ជាការរៀបចំរបស់សហរដ្ឋអាមេរិកក្នុងគោលបំណងធ្វើឲ្យខ្មែរក្រហមឯកោ និងទប់ស្កាត់មិនឲ្យមានការដួលរលំនៃគណបក្សប្រជាជន ។ ប៉ុល ពត ជឿជាក់ថា «សម្ព័ន្ធភាព» នេះត្រូវបានធ្វើឡើងក្នុងគោលបំណងបំផ្លាញកិច្ចព្រមព្រៀងទីក្រុងប៉ារីសនិងជំនួសវិញដោយដំណោះស្រាយ «ទ្វេភាគី» ដែលលោកខាងលិច «បានព្យាយាមគ្របដណ្តប់លើសម្តេចព្រះ នរោត្តម សីហនុ និងក្រុមផ្សេងៗទៀតឲ្យចូលរួមជាមួយគ្នាជាមួយនឹង «អាយ៉ង» ដែលទទួលបាននូវជំនួយនិងការទទួលស្គាល់ពីអន្តរជាតិ ។ ក្នុងខណៈដែល ប៉ុល ពត ជឿជាក់ថា សត្រូវចាស់និងសត្រូវថ្មីមាន «ទំនាស់គ្នាចង់គ្រប់គ្រងទឹកដីកម្ពុជាដោយខ្លួនឯង» ប៉ុល ពត យល់ថាអ្នកទាំងនេះរួបរួមគ្នាដើម្បីលុបបំបាត់កម្ពុជាប្រជាធិបតេយ្យដែលជាឧបសគ្គដ៏ធំរារាំងដល់មហិច្ឆតារបស់ខ្លួន ។

ព្រឹត្តិការណ៍ឆ្នាំ១៩៩២និង១៩៩៣គ្រាន់តែបញ្ជាក់ជំនឿរបស់ ប៉ុល ពត ទៅលើការវិភាគរបស់ខ្លួនតែប៉ុណ្ណោះ ។ ប៉ុល ពត យល់ឃើញថា ការខកខានរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជាក្នុងការរំលាយក្បាលម៉ាស៊ីនដឹកនាំរបស់រដ្ឋកម្ពុជា និងការបង្កើតបន្តបន្ទាប់នូវរដ្ឋាភិបាលក្បាលពីរ គឺជាការប៉ុនប៉ងរបស់លោកខាងលិចធ្វើឲ្យរបប «អាយ៉ងយួន» មានភាពស្របច្បាប់ពេញមុខពេញមាត់ ។ ប៉ុល ពត ជឿជាក់ថាការទទួលយក«សន្តិភាព»និងប្រជុំយជាក់ទឹកដីកម្ពុជាប្រជាធិបតេយ្យអង្គការចាត់តាំងនយោបាយនិងយោធាទៅក្នុងការគ្រប់គ្រងរបស់គណបក្សប្រជាជន វាមិនខុសពីការធ្វើអត្តឃាតទេ ។ នៅដើមឆ្នាំ១៩៩២ ប៉ុល ពត ងាកមករកការតស៊ូខាងយោធាដើម្បីបង្ខំ«អ៊ុនតាក់» ហើយក្រោយមកទៀត រដ្ឋាភិបាលចម្រុះថាខ្មែរក្រហមមិនចូលរួមទេ ។ ប៉ុល ពត ហាក់ដូចជាមិនសូវជឿជាក់លើខ្លួនឯងឡើយក្នុងខណៈដែលកម្ពុជាប្រជាធិបតេយ្យបង្កើតនិងពង្រឹងកម្លាំងថាតុល្យភាពអំណាចមានទំនោរតាមទិសដៅរបស់ខ្លួន ហើយថាអតីតសម្ព័ន្ធមិត្តរបស់ខ្លួននឹងផ្លាស់ប្តូរជំហរវិញ ។

ក៏ប៉ុន្តែយុទ្ធសាស្ត្ររបស់ ប៉ុល ពត ពឹងផ្អែកទាំងស្រុងលើគំនិតសុទិដ្ឋិនិយមហួសហេតុនៃកម្លាំងនយោបាយនិងយោធារបស់ចលនាខ្មែរក្រហម ។ ការជឿជាក់របស់ ប៉ុល ពត ដែលថាការវាយប្រហាររបស់កម្ពុជាប្រជាធិបតេយ្យអាចរារាំងមិនឲ្យមានការបោះឆ្នោតក្នុងឆ្នាំ១៩៩៣ដែលកំពុងតែដំណើរការនិងការគិតថាពហិការមិនចូលរួមក្នុងដំណើរការបោះឆ្នោតអាចធ្វើទទួលបានការគាំទ្រលើសលប់នោះគឺខុសពីការពិតទាំងស្រុង ។ ការសង្ឃឹមទុកថា ការសម្លាប់រង្គាលជនស៊ីវិលវៀតណាមអាចបង្កឲ្យមានការកាប់សម្លាប់ក្នុងទម្រង់រាលដាលនោះ គឺមិនទាន់មានចម្លើយនៅឡើយទេ ។ កន្លងមក នៅពេលណាដែល ប៉ុល ពត ចង់ឲ្យ «ប្រជាជន» ងើបឈរឡើងធ្វើការងារ ប៉ុល ពត ត្រូវតែបញ្ជាឲ្យទាហានរបស់ខ្លួនធ្វើជំនួស ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៩៣ ប៉ុល ពត ទទួលស្គាល់ថា ចលនាខ្មែរក្រហម ឥឡូវនេះឯកោទាំងក្នុងប្រទេសនិងលើឆាកអន្តរជាតិ ហើយថា«មនុស្សទូទៅឬមនុស្សភ្លីភ្លើ» អាចគិតថា«ឥឡូវនេះត្រូវបរាជ័យហើយ» ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ប៉ុល ពត បានបន្តទាំងភ័ន្តច្រឡំថា កម្ពុជាប្រជាធិបតេយ្យមានកម្លាំងមហាជនច្រើនលើសលប់ ហើយ

ការវាយរុញផ្នែកយោធាអាចធ្វើឲ្យគណបក្សប្រជាជនចុះខ្សោយនិងបញ្ចុះបញ្ចូលសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងសម្តេចព្រះនរោត្តម សីហនុ បែរមកជ្រើសរើសរដ្ឋាភិបាលចតុភាគីវិញ។ ប៉ុន្តែមិនខុសពីអ្នកដទៃទៀតឡើយ ប៉ុល ពត ត្រូវបានសម្តេចក្រុមព្រះក្បត់ និងដើរល្បិចខ្សែលើដោយសម្តេច ហ៊ុន សែន។ ផុយទៅវិញរដ្ឋាភិបាលទេដែលជាអ្នកវាយលុកដ៏គួរឲ្យភ្ញាក់ផ្អើល នៅខែសីហា ឆ្នាំ១៩៩៣នោះ។ ទោះបីជាមានការព្រមានជាមុនក៏ដោយ ក៏ ប៉ុល ពត មិនជឿថាអតីតសម្ព័ន្ធមិត្តរបស់ខ្លួនហ៊ានបើកយុទ្ធនាការមកលើមូលដ្ឋានថ្មីរបស់ខ្លួននៅភ្នំយ៉ាត ដែលស្ថិតនៅប៉ុន្មានគីឡូម៉ែត្រពីមូលដ្ឋានសឹករបស់គណបក្សហ៊ុនស៊ិនប៉ិចដែរ។ ក្រោយពីផ្លាស់មូលដ្ឋានថ្មីបានប៉ុន្មានខែពីភូមិភាគនិរតីដែលជាកន្លែងខ្មែរក្រហមលែងមានទំនុកចិត្តផ្នែកនយោបាយនោះ ប៉ុល ពត បានផ្លាស់មួយជំហានចុងក្រោយទៀតទៅកាន់អន្លង់វែង គ្រប់គ្រងដោយតាម៉ុក ដែលជាជំហានចុងក្រោយរបស់ ប៉ុល ពត។

## ១៩៩៤: ឫសគល់នៃការខ្វែងយោបល់គ្នា

រាល់ក្តីសង្ឃឹមកាលពីដើមដំបូងថាមានដំណោះស្រាយចុងបញ្ចប់ត្រូវរលាយអស់នៅឆ្នាំ១៩៩៤ ក្នុងពេលដែលរដ្ឋាភិបាលបញ្ចប់កិច្ចចរចា ហើយដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ជាផ្លូវការ។ ប៉ុល ពត ពីមុនបានទទូចថា «បើនិយាយឲ្យខ្លីទៅ យើងត្រូវការមិត្តលុះដល់ថ្ងៃស្លាប់»។ ប៉ុន្តែនៅពេលនេះ ប៉ុល ពត បែរជាប្រកាសថា ខ្មែរក្រហមដែលគ្មានសល់មិត្តម្នាក់សោះ គ្មានផ្លូវជ្រើសរើសក្រៅពីបន្តការតស៊ូប្រដាប់អាវុធគ្មានទីបញ្ចប់ប្រឆាំងនឹងកងកម្លាំងចម្រុះរបស់ «សត្រូវចាស់» និង «សត្រូវថ្មី»។ ប៉ុល ពត ជឿជាក់ថា ដោយការខិតខំប្រយុទ្ធទោះជាមានការលំបាកយ៉ាងណាក៏ដោយ កម្ពុជាប្រជាធិបតេយ្យនឹងស្ថិតនៅក្នុងជំហរមួយមាំជាងមុនដូចកាលពីឆ្នាំ១៩៧០ ក្នុងការទាញយកផលប្រយោជន៍ពីសភាពការណ៍នៅពេលមាន«ទំនាស់សង្គមនិងទំនាស់ជាតិ»នៅក្នុងទីក្រុងភ្នំពេញផ្ទុះឡើង។ ប៉ុល ពត គិតត្រូវដែលថា រដ្ឋាភិបាលចម្រុះនឹងមិនស្ថិតស្ថេរយូរអង្វែង។ ប៉ុន្តែនៅពេលរដ្ឋាភិបាលក៏បែកខ្វែកគ្នា ខ្មែរក្រហមក៏បែកបាក់គ្នាដែរ។ វិធីសាស្ត្ររបស់ ប៉ុល ពត ត្រូវទទួលបរាជ័យដោយមូលហេតុបីយ៉ាង÷

ទី១៖ ការបាត់បង់ការគាំទ្រផ្នែកសម្ភារនិងភ័ស្តុភារមានផលប៉ះពាល់យ៉ាងខ្លាំងដល់កម្លាំងយោធារបស់កម្ពុជាប្រជាធិបតេយ្យ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសនិងសម្ពាធជាបន្តបន្ទាប់របស់សហរដ្ឋអាមេរិកមកលើប្រទេសថៃឲ្យផ្តាច់ខ្សែរយៈជាមួយខ្មែរក្រហម ធ្វើឲ្យខ្មែរក្រហមឯកោពីសម្ព័ន្ធមិត្តជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ដោយគ្មានសង្ឃឹមថានឹងបានជោគជ័យក្នុងរយៈពេលខ្លីទៅលើមហាសត្រូវ និងដោយជួបការលំបាកក្នុងការទិញគ្រាប់រំសេវឲ្យបានគ្រប់គ្រាន់កាត់តាមព្រំដែនថៃ មេដឹកនាំខ្មែរក្រហមក៏សម្រេចចិត្តបន្តចលនា «តស៊ូមួយរយៈទៀត» ហើយងាកមកធ្វើ «សង្គ្រាមស៊ិតស្មាញនិងអូសបន្លាយ» ទៅវិញ។ ល្បិចថ្មីនេះមិនខុសពីយុទ្ធសាស្ត្ររបស់ចលនារបស់ខ្លួនដែលកំពុងតែធ្វើទេ គឺត្រឡប់ទៅដើរតាមចលនាតស៊ូប្រដាប់អាវុធប្រឆាំងនឹង សីហនុ កាលពីអំឡុងឆ្នាំ១៩៦៨-៦៩។ ខ្មែរក្រហមមិនត្រូវការសម្ភារយោធានិងកម្លាំងយោធាច្រើនឡើយ គឺគ្រាន់តែបង្កើត «អាវុធធម្មតាតាមប្រពៃណី» ដូចជាចម្រួងពិស និងមីនថ្នៃ។ «អាវុធប្រពៃណី» នេះត្រូវធ្វើឡើងដោយ «ប្រជាកសិករក្រីក្រ» ដែលជាទ្រឹស្តីកើតចេញពី «កំហឹងវណ្ណៈ» ប៉ុន្តែតាមការពិតជាក់ស្តែងកើតចេញពីការបង្ខិតបង្ខំតែប៉ុណ្ណោះ។

វិទ្យុផ្សាយសម្លេងចេះតែអួតក្អេងៗអំពីប្រសិទ្ធិភាពនៃការវាយប្រហាររបស់ខ្លួនតាមពិតអាវុធធុននេះថោកជាងគេបំផុតហើយងាយរកបំផុតក្នុងការការពារមូលដ្ឋានរបស់កម្ពុជាប្រជាធិបតេយ្យ។

**(នៅមានត)**

**ដេវីដ អាស្លី**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី "ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
ឬ Email: dccam@bigpond.com.kh

# ទទួលបានប៉ុនណាបាត់នៅវិញប៉ុណ្ណឹង

**(តពីលេខមុន)** មុនពេលជម្លៀស សេរី បងប្រុសខ្ញុំត្រូវបានអនុញ្ញាតឲ្យមកផ្ទះ ពីព្រោះប្រពន្ធគាត់ឈ្មោះ សាអ៊ុម មានផ្ទៃពោះជិតឆ្លងទន្លេកូនដំបូង ។ ម្នាក់ៗបារម្ភខ្លាចក្រែង សាអ៊ុម ឆ្លងទន្លេនៅតាមផ្លូវ ។ ប៉ុន្តែយើងមានមធ្យោបាយជួយយ៉ាងម៉េចទៅ បើស្ថិតនៅក្នុងកាលៈទេសៈបែបនេះ? នាងចេះតែដើរតាមយើងប៉ុណ្ណោះ ។ នៅពេលមានមនុស្សម្នាច្រើនកកកុញដើរចេញពីទីក្រុង មានសមាជិកគ្រួសារជាច្រើនបានបែកឃ្លាតពីគ្រួសាររបស់ខ្លួន ។ កម្មាភិបាលខ្មែរក្រហមបានប្រាប់យើងថា អ្នករាល់គ្នានឹងបានជួបជុំគ្រួសារវិញនៅពេលដល់គោលដៅកំណត់ ។ នៅព្រឹកថ្ងៃជម្លៀសនោះ មុនពេលចេញដំណើរ ម្នាក់ៗត្រូវបានបញ្ជាឲ្យប្រមូលផ្តុំនៅតាមដងផ្លូវធំនៅឃ្លាតពីទីក្រុង ។ គ្មានអ្នកណាដឹងថាទិសដៅត្រូវទៅណាទេ មានតែទាហានមើលការខុសត្រូវតែប៉ុណ្ណោះ ។ ប្រជាជនវ័យចំណាស់មានការព្រួយបារម្ភថាខ្លួននឹងត្រូវសម្លាប់នៅកន្លែងមួយដែលហៅថាវត្តយៀងដែលជាអតីតវត្តមានចម្ងាយប្រហែលជា២០គីឡូខាងត្បូងតាប៉ាង ។ វត្តយៀង គឺជាកន្លែងសួរចម្លើយនិងដំណើរការរបស់ខ្មែរក្រហមនិងជាកន្លែងដែលមានមនុស្សជាច្រើននាក់បានបាត់បង់ជីវិត ។

ខ្ញុំបានឮអ្នកជិតខាងខ្ញុំនិយាយទាំងស្ងៀមស្ងាត់និងទាំងក្តីសង្ឃឹមថា «ដើរកាត់វត្តយៀងមានទៅសួគ៌» ។ អ្នកផ្សេងទៀតអង្គុយនៅក្រោមម្លប់ឈើនិងបួងសួងយ៉ាងទទូច ។ ម្នាក់ៗចង់ឃើញថ្ងៃរះម្តងទៀត ។ ចេញពីវត្តយៀងកាន់តែឆាប់កាន់តែល្អ ។ ខ្ញុំបន្តបន់ស្រន់ទៅទៀត ។ ការធ្វើដំណើរដោយមាន សាអ៊ុម ទៅជាមួយផងមានការពិបាកណាស់ព្រោះនាងមានផ្ទៃពោះ ។ នាងធ្លាប់មានទម្ងន់ ហើយរលូតកូនម្តងហើយ ពេលនេះនាងគិតថាអ៊ីៗនឹងស្ថិតក្នុងផ្លូវតែមួយដូចពីមុនអ៊ីចឹង ។ ឪពុករបស់ សាអ៊ុម មានវ័យកាន់តែចាស់ជរាណាស់ទៅហើយ ។ គាត់មិនអាចដើរទៅណាមកណាឆ្ងាយពីផ្ទះឡើយដោយសារគាត់ហើមសន្លាក់ជង្គង់ ។ សេរី បានព្យាយាមឲ្យប្រពន្ធដែលកំពុងតែពពោះខំដើរ រីឯខ្ញុំវិញជួយគ្រាឪពុកក្មេករបស់ សេរី ។ គ្មានកន្លែងច្រើនសម្រាប់ដាក់កន្ទេលមុងភួយសម្រាប់ដេកទេ ។ ខ្ញុំបានកាន់កន្ទេលស្ទើរតែទាំងអស់សម្រាប់គ្រួសារទាំងមូលនិងភួយព្រមទាំងក្រណាត់វែងសម្រាប់រុំខ្លួននិងក្រមា ។ គ្រួសារខ្លះមានកូនតូចតាចដឹកដៃតាមផ្លូវ ។ នេះគឺជា «មហាលោតផ្លោះមហាអស្ចារ្យ» ក្រោមអំណាចរបស់អង្គការដែលយើងបានឃើញនិងបានភ្លក្សរសជាតិ ។

នៅពេលដែលយើងមកដល់វត្តយៀង យើងហាក់ដូចជាអស់កម្លាំងល្ហិតល្ហៃ ។ មានអ្នកស្លុតម្នាក់ក្នុងចំណោមគ្នាវាបួននាក់ដែលជាមេ បានបញ្ជាយើងឈប់នៅតាមផ្លូវ ហើយរង់ចាំ ។ ពេលនោះមេម្នាក់នោះ បានទៅជួបកម្មាភិបាលអង្គការលើដែលទទួលខុសត្រូវកន្លែងនោះ ។ នៅពេលកំពុងរង់ចាំ យើងបានបន់ស្រន់បួងសួងម្តងហើយម្តងទៀត ។ ពេលនោះ ខ្ញុំចាំពាក្យរបស់អ្នកជិតខាងខ្ញុំដែលនិយាយថា «ដើរកាត់វត្តយៀងមានទៅសួគ៌» ។ ខ្ញុំមិនដែលបន់ស្រន់ដល់ថ្នាក់ហ្នឹងពេកទេ តាំងពីដើមមក ទើបតែពេលនេះទេ ។ ខ្ញុំសង្ឃឹមថាយើងនឹងឆ្លងកាត់ដំណាក់កាលនេះមិនខាន ។ ប្រហែលជា២០នាទីក្រោយមក អ្នកស្លុតដំណើរបានត្រឡប់ថយក្រោយវិញជាមួយនឹងកម្មាភិបាលមួយចំនួនដែលទទួលខុសត្រូវនិងគ្រួសារជាច្រើន ។ មានគ្រួសារថ្មីរហូតដល់១៥គ្រួសារ ឬក៏ប្រហាក់ប្រហែលនេះ ។ ខ្ញុំមើលក្រុមនេះពីចម្ងាយប្រហែល២០ម៉ែត្រដែលអាចមើលមុខមនុស្សច្បាស់ ។

ខ្ញុំសម្លឹងមើលមុខគ្រួសារខ្លះនៅក្នុងចំណោមគ្រួសារថ្មីទាំងអស់ ។ បេះដូងខ្ញុំគ្មុកគ្មាក់ៗ ។ ខ្ញុំស្គាល់មនុស្សទាំងអស់នេះ! ខ្ញុំស្គាល់មនុស្សទាំងនេះ! ។ រំពេចនោះខ្ញុំចង់តែស្ទុះទៅជួបគាត់ទាំងអស់តែម្តង ។ ខ្ញុំក្រោយឈរឡើងបម្រុងនឹងរត់ទៅហើយ ប៉ុន្តែតក្កភាពនិងសុភវិនិច្ឆ័យបានឃាត់ខ្ញុំឲ្យថយក្រោយវិញ ។ ខ្ញុំមិនចង់ធ្វើឲ្យមានគ្រោះថ្នាក់ទេជាពិសេសនៅកន្លែងដ៏ល្បីអសោចនេះ ។ បេះដូងខ្ញុំនៅតែលោតហើយមានក្តីរន្ធត់យ៉ាងខ្លាំង ។ គ្មានពាក្យអ្វីអាចរៀបរាប់ពីទឹកភ្នែករបស់ខ្ញុំដែលកើតឡើងដោយការអរជ្រុលនេះឡើយ ។ ទឹកភ្នែកខ្ញុំហូរចុះមកដូចជាទឹកធ្លាក់ពីលើផ្ទៃមុខអ៊ីចឹង ។ ឪពុករបស់ខ្ញុំមើលទៅចាស់ណាស់ចំណាស់ប្រហែល

ម្តាយខ្ញុំដែរ ។ ឪពុកម្តាយខ្ញុំមានការផ្លាស់ប្តូរច្រើនណាស់ ប៉ុន្តែខ្ញុំដឹងពីចម្ងាយថា នោះពិតជាឪពុកម្តាយខ្ញុំហើយ ។ គាត់រុំកន្សែងជាប់ខ្លួនដូចជាពួកយើងទាំងអស់គ្នានេះដែរ ។ គាត់បានដាក់បងប្អូនបង្កើតរបស់ខ្ញុំនៅពីក្រោយខ្នង ។ ខ្ញុំសប្បាយចិត្តណាស់ដោយឃើញគ្រួសារខ្ញុំជិតបានជួបជុំគ្នាវិញបន្ទាប់ពីការបែកគ្នាប៉ុន្មានឆ្នាំនេះ ។ សមាជិកគ្រួសាររបស់ខ្ញុំនៅទីនោះទាំងអស់ បាត់តែពីរនាក់ប៉ុណ្ណោះ ។ ខ្ញុំព្យាយាមរាប់ម្តងហើយម្តងទៀត ។ បងប្រុសខ្ញុំឡារ៉ូនី និងបងស្រី ម៉ាលីនី មិនឃើញមុខសោះ ។ តាមពិតអ្នកទាំងអស់នៅកៀកខ្លួនខ្ញុំសោះ ប៉ុន្តែធ្វើស្មាក់ស្មើរមិនច្បាស់ក្នុងចិត្ត ។ រាងកាយបងប្អូនរបស់ខ្ញុំ មើលទៅគួរឲ្យរន្ធត់មែនទែនមានតែស្បែកដណ្តប់ឆ្អឹង ។ ប្អូនប្រុសរបស់ខ្ញុំដែលមិនមានស្លៀកពាក់អ្វីសោះនោះខ្ញុំមើលសឹងតែមិនស្គាល់ប្អូនប្រុសខ្ញុំខ្ពស់ជាងមុន ។ ក្រោយពីការបែកគ្នាអស់រយៈពេលជាងបីឆ្នាំសមាជិកគ្រួសារខ្ញុំភាគច្រើននៅទីនោះទាំងអស់ ។ មុនដំបូងខ្ញុំស្មាក់ស្មើរមើលមិនសូវស្គាល់ដែរ ។ ខ្ញុំបានសុបិននិងរង់ចាំថ្ងៃនេះជាច្រើនឆ្នាំមកហើយ ។ ភ្នែករបស់វាជាសាច់ញាតិរបស់ខ្ញុំដែលពោរពេញទៅដោយភាពអស់សង្ឃឹម បានសម្លឹងមើលទៅដី ហើយមើលជុំវិញខ្លួន ។ អ្នកទាំងអស់មិនស្គាល់ សេរី ដែលជាបងប្រុសខ្ញុំ និងខ្ញុំដែលកំពុងតែស្ថិតនៅក្នុងហ្វូងមនុស្សឡើយ ។ បងប្អូនខ្ញុំទាំងអស់ហាក់ដូចជាគ្មានព្រលឹងនិងក្តីសង្ឃឹមនៅក្នុងខ្លួនសោះ ។ មើលទៅដូចជាមិនមែនមនុស្សដែលខ្ញុំធ្លាប់ស្គាល់ ។ សេរី ក៏ដើរមកជិតហើយចាប់ដៃឆ្វេងរបស់ខ្ញុំ ។ គាត់បានដកដង្ហើមដាក់មុខខ្ញុំហើយនិយាយថា «កុំសម្លឹងអី អាក្អាក់!» ។ សេរី និយាយដាក់ត្រចៀកខាងឆ្វេងខ្ញុំខ្លាំងៗ ដោយប្រើឈ្មោះហៅក្រៅក្នុងគោលបំណងសង្កត់ន័យនិងឲ្យខ្ញុំជឿតាម ។ ខ្ញុំក៏ខ្សឹបដាក់ សេរី វិញដោយក្តីរំភើបថា «នោះម៉ែ នោះពុក! ហើយនោះ បងប្អូនយើងហ្នុំ!» ។ ហើយ សេរី និយាយតបវិញថា «អញដឹងហើយ ចាំបន្តិច!» ។ ពេលនោះខ្ញុំឃើញដំណក់ទឹកភ្នែកហូរធ្លាក់នៅលើថ្ពាល់ សេរី ។ ខ្ញុំដឹងថាគាត់ច្បាស់ជាចង់រត់សម្តៅទៅបងប្អូនឪពុកម្តាយដូចដែលខ្ញុំចង់កាលពីដំបូងដែរ ប៉ុន្តែនៅក្នុងកាលៈទេសៈនេះ យើងត្រូវតែមានវិន័យខ្លះ ហើយប្រុងប្រយ័ត្នឲ្យមែនទែន ។ យើងមិនដឹងពីជោគវាសនារបស់យើង និងឪពុកម្តាយបងប្អូនយើងទេ ។

ខ្ញុំបានសម្លឹងភ្នែកប្អូនប្រុសខ្ញុំឈ្មោះ អាឡុង ។ ខ្ញុំបានញញឹមដាក់ប្អូនប្រុសវិញដោយសង្ឃឹមថាវានឹងស្គាល់ខ្ញុំមិនខាន ។ ខ្ញុំមានការខកចិត្តយ៉ាងខ្លាំងមិនបានទទួលចម្លើយតប ។ ប្អូនខ្ញុំបានមើលទៅលើមេឃ ។ ខ្ញុំដឹងថាអ្នកទាំងអស់នោះហើយជាសាច់ញាតិរបស់ខ្ញុំ ។ តើខ្ញុំខុសពីមុនដល់ថ្នាក់ណាទៅបានជាគ្មានអ្នកណាម្នាក់ស្គាល់ខ្ញុំសោះអ៊ីចឹង ។ តើអ្នកទាំងអស់មានការប្រុងប្រយ័ត្នដូចដែល សេរី បានប្រាប់ខ្ញុំ? ។ ខ្ញុំចង់តែប្រថុយរត់ទៅឱបរឹតឲ្យអស់ចិត្ត ហើយខ្ញុំចង់និយាយប្រាប់ថាខ្ញុំនឹកអ្នកទាំងអស់គ្នាណាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ខ្ញុំតឹងចិត្តឥតឧបមា ដ្បិតមិនអាចធ្វើតាមបំណងដែលកំពុងតែអន្ទះសា ។

ប្រមាណមួយម៉ោងក្រោយពីអង្គុយនៅតាមដងផ្លូវ យើងទាំងអស់ត្រូវបានបញ្ជាឲ្យបន្តដំណើរទៅមុខទៀត ។ ទាហានបានរាប់ចំនួនមនុស្សម្តងមួយៗ នៅពេលដែលប្រជាជនទាំងអស់ដើរកាត់មុខខ្លួន ។ ខ្ញុំនៅតែងាកក្រោយរកមើលក្រុមគ្រួសាររបស់ខ្ញុំដែលបានព្រាត់ប្រាសគ្នាអស់រយៈពេលជាយូរណាស់មកហើយ ។ ខ្ញុំសប្បាយចិត្តណាស់ដែលអាចបំភ្លេចការគំរាមកំហែងកាត់ផ្តាច់ជីវិតរបស់អង្គការលើដោយសារយើងអាចឆ្លងផុតពីកន្លែងពិឃាតនេះ ។ ខ្ញុំលែងគិតអ្វីទៀតហើយ ។ ខ្ញុំរំភើបចិត្តក្រៃលែងដោយមានឱកាសបានជួបមនុស្សដែលជាទីស្រឡាញ់និងបាត់បង់ជាយូរណាស់មកហើយ ។ គ្មានអ្វីគួរឲ្យព្រួយបារម្ភទៀតទេនៅពេលនេះ ។ នៅទីបញ្ចប់ខ្ញុំបានជួបគ្រួសារខ្ញុំវិញហើយ ។

ក្រុមយើងនេះបានធ្វើដំណើរតាមដានដែលខ្ញុំបានដើរមកពីក្រុងតាប៉ាង ។ ប្រជាជនមានការធូរស្រាលក្នុងចិត្តបន្តិចដោយបានឆ្លងកាត់វត្តយៀងដឹគួរឲ្យគ្រោះថ្នាក់នេះ ។ យើងបានឆ្លងកាត់ប្រកទីមួយ ។ ប៉ុន្តែម្នាក់ៗមិនប្រាកដក្នុងចិត្តថាអ្វីនឹងកើតឡើងបន្ទាប់ទៀតឡើយឬមានអ្វីនៅខាងមុខយើងទេ ។ ខ្ញុំមានការសប្បាយចិត្តដោយសារមានក្រុមគ្រួសារនៅជិត ទោះបីជាខ្ញុំមិនទាន់បានទាក់ទងនិយាយជាមួយដោយផ្ទាល់ក៏ដោយចុះ ។ ខ្ញុំសង្ឃឹមក្នុងចិត្តថាខ្ញុំនឹងបាននិយាយជាមួយឆាប់ៗនេះ ។ ខ្ញុំតែងរំឭកពាក្យរបស់ សេរី ថា «ទ្រាំបន្តិចទៅ អាក្អាក់!» ។

ការធ្វើដំណើរចេះតែបន្តទៅរហូតដល់ផ្លូវជាតិលេខ៦ ដែលស្ថិតនៅខាងលិចខេត្តបាត់ដំបងនិងខាងកើតខេត្តសៀមរាប ។

ទាហានបានបញ្ជាឲ្យយើងបោះជំរំស្នាក់នៅមួយយប់សិន ចំណែកឯទាហានទាំងអស់រកកន្លែងដើម្បីចងអង្រឹងដេក ។ នៅទីនោះគ្មានអាហារពីអង្គការលើសម្រាប់ហូបចុកទេ ។ យើងត្រូវតែមើលការខុសត្រូវចំពោះខ្លួនឯង ។ ប្រជាជនទាំងអស់ក៏ប្រាសខ្លួនលង់លក់ក្រោយពីធ្វើដំណើរយ៉ាងនឿយហត់កន្លងមក ។ ទន្ទឹមពេលនោះមានអ្នកខ្លះស្រមុកឮសូរក្រកៗលាយឡំនឹងសម្រែករបស់ក្មេងៗ ។ វាមិនជាថ្មីទេពីព្រោះខ្ញុំធ្លាប់ជួបប្រទះសភាពបែបនេះពីមុនរួចមកហើយ ។ ខ្ញុំយកថង់ដាក់បាយហាលស្ងួតមកហូបគ្រាន់តែកំដរក្រពះ ហើយដើរសំដៅទៅឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំ ។ ប្រហែលជាអ្នកទាំងអស់នេះសម្លឹងមើលអ្វីដែលខ្ញុំកំពុងតែហូបជាជាងសម្លឹងមុខខ្ញុំ ។ ពេលខ្ញុំបែរខ្លួនវិញ ឪពុកម្តាយបងប្អូនខ្ញុំនៅតែមិនទាន់ដាក់ភ្នែកមើលមកខ្ញុំនៅឡើយទេ ។ «ម៉ែពុកនិងអ្នកទាំងអស់គ្នា ខ្ញុំនេះហើយណាជិត» ។ ខ្ញុំបានព្យាយាមគ្រវាសសក់ទៅក្រោយ ហើយបង្ហាញមុខខ្ញុំឲ្យកាន់តែច្បាស់ ។ អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលគឺហេតុការណ៍ដែលកើតឡើងក្រោយមកទៀត ។ អ្នកទាំងអស់គ្នាសម្លឹងមើលមុខខ្ញុំទាំងមិនដឹងថាជាអ្នកណាហើយគ្មាននិយាយអ្វីទាំងអស់ ។ គ្មានអ្នកណាម្នាក់ស្គាល់ខ្ញុំឡើយបន្ទាប់ពីបែកគ្នាអស់រយៈពេលបីឆ្នាំមក ។ ឪពុកខ្ញុំក៏មិនស្គាល់ដែរ ។ គ្មានអ្វីត្រូវនិយាយទេគ្រាន់តែទឹកភ្នែកហូរមកហ្នឹងវាគ្រប់គ្រាន់ទៅហើយ ។ បន្តិចក្រោយមកម្នាក់ៗមករោមខ្ញុំជិតមិនឲ្យខ្ញុំទៅណាខ្លាចខ្ញុំទៅបាត់ទៀត ។ ប្អូនតូចៗរបស់ខ្ញុំឈ្មោះ ម៉ូនីកា និង សីលា បានភ្លេចខ្ញុំអស់ទៅហើយ ។ មានតែប្អូនប្រុសពីរនាក់គឺឡុង និង ណូសាយ ដែលនៅស្គាល់ខ្ញុំនិង សេរី ទាំងស្រពេចស្រពិល ។ អ្នកទាំងប្អូននាក់បានទទួល «បាយសង្គ្រោះ» របស់ខ្ញុំ ។ ខ្ញុំសឹងតែឲ្យដៃស្តាំរបស់ខ្ញុំ បើដៃនេះអាចជួយសម្រន់ក្តីស្រេកឃ្លាននិងទុក្ខវេទនា ។ ម្តាយខ្ញុំសួរទាំងរវើរវាយនិងយំខ្សឹកខ្សួលថា «ឯណាទៅ សេរី និង សាអ៊ុម?» ។ «ចាំខ្ញុំទៅយកគាត់មកនៅហ្នឹងហើយ» ។ ខ្ញុំឆ្លើយ ហើយដើរយ៉ាងលឿនត្រឡប់ទៅកន្លែងជំរំវិញ ។ ប្អូនប្រុសខ្ញុំដើរតាមក្រោយខ្ញុំរកបាយហូបទៀតជាជាងចង់ដឹងរឿងហេតុ ។ ខ្ញុំបានឱបក្បាលប្អូនទាំងពីរកុំឲ្យដើរតាម ។ នៅពាក់កណ្តាលផ្លូវយើងបានជួប សេរី ។ សេរី ក៏មានការរំភើបចិត្តណាស់ដែរដែលបានជួបជុំគ្រួសារជាថ្មីឡើងវិញ ។ ពេលបាត់ខ្ញុំ សេរី ដឹងថាខ្ញុំទៅទីណា ។ ដូច្នេះគាត់ត្រូវតែដើរតាមក្រែងខ្ញុំបន្តជាបញ្ហាដល់យើងទាំងអស់គ្នា ។ យើងត្រឡប់មកវិញដោយស្ងាត់ៗនិងនាំ សាអ៊ុម មកជាមួយមកជួបជុំគ្រួសារវិញ ។ ការរួបរួមសន្តមគ្រួសារនេះគឺជាបន្ថែមយ៉ាងពិសេសសម្រាប់យើងទាំងអស់គ្នា ។ នៅយប់នោះយើងពុំសូវបានសម្រាកប៉ុន្មានទេ ប៉ុន្តែរវល់តែជជែកគ្នាសួរដំណើរដើមទងនិងការលំបាកជូរចត់កន្លងមក ។ ការបងចាំត្រូវបានគាស់សាជាថ្មី ហើយម្នាក់ៗបានបង្ហូរទឹកភ្នែកស្ទើរតែពេញអំឡុងពេលនៃការជជែកគ្នានេះ ។ យើងសំណាងល្អណាស់ដែលបានរួចពីសេចក្តីស្លាប់អាចរស់នៅមកដល់ពេលនេះ ហើយមានឱកាសបានជួបគ្នាជាថ្មីម្តងទៀត ។ ការបាត់បង់មិត្តសម្លាញ់របស់ខ្ញុំឈ្មោះ ឡៃ ថ្មីៗនេះអាចនាំឲ្យខ្ញុំបានជួបគ្រួសារសាជាថ្មី ។ ខ្ញុំនៅតែនឹក ឡៃ ប៉ុន្តែឥឡូវការជួបជុំគ្រួសារ ខ្ញុំបានធ្វើឲ្យខ្ញុំកាត់ចិត្តបានខ្លះហើយ ។ ប៉ុន្តែការក្រោមអំណាចរបស់របបអង្គការលើប្រល័យពូជសាសន៍នេះការជួបជុំកើតមានឡើងបានតែមួយរយៈពេលខ្លីតែប៉ុណ្ណោះ ។

**យិមស៊ុត រ៉ាណាឋិត**

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០១

ខ្ញុំ **ម៉ាត់ លី** ជាតំណាងរាស្ត្រមណ្ឌលកំពង់ចាម និងឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ផ្ញើជូនៈ លោក **ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកនាយកដែលបានផ្តល់ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «ស្វែងរកការពិត» មកឲ្យខ្ញុំជារៀងរាល់ខែ ។

ខ្ញុំសូមកោតសរសើរដោយស្មោះត្រង់បំផុតចំពោះស្នាដៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានតស៊ូព្យាយាមចងក្រងបាននូវឯកសារប្រវត្តិសាស្ត្រស្តីពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ ជាពិសេសមជ្ឈមណ្ឌលឯកសារកម្ពុជាបានបំពេញការងារស្រាវជ្រាវមួយទៅលើបទឧក្រិដ្ឋប្រល័យពូជសាសន៍របស់ខ្មែរក្រហមទៅលើបងប្អូនជនជាតិចាមដោយបញ្ជូនក្មួយស៊ុម សុរិយ៉ា និងក្មួយ អ៊ីសា ឧស្មាន ទៅជួបជនរងគ្រោះផ្ទាល់ហើយជាឱកាសផ្តល់ឲ្យជនរងគ្រោះបានរ៉ាយរ៉ាប់ប្រាប់ពីពិសោធន៍ដ៏ជូរចត់និងឈឺចាប់នៃការនិរាសព្រាត់ប្រាសសមាជិកគ្រួសារនិងការបាត់បង់ប្រពៃណីសាសនាឥស្លាម ។ ខ្ញុំសូមជូនពរដល់លោកនាយកនិងសហការីទាំងអស់ឲ្យបានទទួលជោគជ័យជាបន្តទៀតក្នុងដំណើរការ «ស្វែងរកការពិត» ជូនប្រជាជនកម្ពុជា ។

**ម៉ាត់ លី**

# សៀវភៅកំណត់ហេតុជីវិត

**(តពីលេខមុន) រូអ៊ី ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៦**

កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំបានទៅជួយជ្រោមជ្រែងក្នុងពិធីបុណ្យរដ្ឋធម្មនុញ្ញ ខ្ញុំបានឡើងធ្វើអន្តរាគមន៍នៅចំពោះមុខមនុស្សជាងមួយពាន់នាក់ នេះជាលើកទីមួយហើយដែលខ្ញុំបាននិយាយនៅចំពោះមុខទីប្រជុំធំដូច្នេះ ។ ខ្ញុំហាក់ដូចជាភ័យដែរកាលពីដំបូងធ្វើឲ្យសំឡេងញ័រ លុះដល់យូរបន្តិចទៅជាការធម្មតាឡើងវិញ ។ ខ្ញុំទៅធ្វើនេះគ្មានបំណងចង់ធំមុខមាត់អ្វីទេ គឺធ្វើដើម្បីជាតិ ខ្ញុំជួយឧបត្ថម្ភអង្គការតាមសមត្ថភាពដែលខ្ញុំមាន ។

**រូអ៊ី ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៦**

កាលពីថ្ងៃម្សិលមិញខ្ញុំបានស្គាល់និងដើរជាមួយមិត្តបុរសម្នាក់នៅពេលដែលខ្ញុំជូនដំណើរបង ដានី ត្រឡប់ទៅអាល្លឺម៉ង់វិញ ។ គ្រាន់តែក្នុងការស្គាល់គ្នាដ៏ខ្លីនេះ ខ្ញុំអាចស្គាល់ចិត្តនៃមិត្តនេះបានមួយភាគយ៉ាងធំ ។ យើងស្គាល់គ្នាមិនទាំងបានយូរប៉ុន្មានផង តែគេហាក់ដូចជាត្រឡប់មិត្តភាពនេះឲ្យទៅជាស្នេហាវិញ ។ ឱ!នេះ ហើយឬមិត្តភាពរវាងនារីនិងបុរស ។ ចំពោះខ្ញុំវិញនេះខ្ញុំគ្មានគំនិតគិតដូច្នេះឡើយ គឺខ្ញុំចាត់ទុកថាជាមិត្តធម្មតាឥតមានក្លែងក្លាយទេ ។ ខ្ញុំគ្មានចិត្តស្រឡាញ់អ្វីគេដល់បន្តិចបន្តួចសោះឡើយ ។ សេចក្តីស្នេហារបស់ខ្ញុំ គឺចប់ហើយនៅក្នុងជាតិនេះព្រោះខ្ញុំបាននិយាយប្រាប់គេរួចទៅហើយថាខ្ញុំស្រឡាញ់រួចទៅហើយ គឺមានតែបុរសម្នាក់គត់ដែលខ្ញុំស្រឡាញ់នៅក្នុងជាតិនេះ ។ ខ្ញុំបានសម្រេចចិត្តថាស្រឡាញ់ហួសទៅហើយ ទោះបីខ្ញុំមិនបានជួបក៏ដោយនៅក្នុងជាតិនេះគឺចប់ហើយសេចក្តីស្នេហា ។ ខ្ញុំសច្ចាថាស្រឡាញ់តែម្នាក់គត់ ហើយខ្ញុំក៏បានឆ្លើយប្រាប់ទៅរួចហើយថាខ្ញុំស្រឡាញ់គេ ។ គឺជាបុរសទីមួយនិងចុងក្រោយបង្អស់ដែលខ្ញុំសម្រេចចិត្តថាស្រឡាញ់ ។ ទោះបីអ្នកឯទៀតមានគុណសម្បត្តិនិងរូបសម្បត្តិល្អជាងយ៉ាងណាក៏ដោយក៏ខ្ញុំមិនត្រូវការដែរ ។ ព្រោះស្នេហាខ្ញុំសម្រេចហួសទៅហើយ ។ ខ្ញុំនឹងរៀបរាប់ប្រាប់មិត្តឲ្យដឹងនូវរឿងនេះដើម្បីកុំឲ្យអ្នកខូចចិត្តដោយសារខ្ញុំ ។ ខ្ញុំមិនចូលចិត្តឲ្យអ្នកណាម្នាក់កើតទុក្ខព្រួយដោយសារខ្ញុំទេ ។ ខ្ញុំត្រូវតែកាន់ពាក្យសច្ចៈ ចិត្តគំនិត ឥតត្រូវប្រែប្រួលទេចំពោះសេចក្តីស្នេហាពីព្រោះមុននឹងសម្រេចចិត្តនេះខ្ញុំបានគិតជាយូររួចមកហើយ ។ បើគំនិតនេះខុស វាជាកំហុសខ្ញុំ ខ្ញុំសុខចិត្តទទួលទាំងអស់នូវផលវិបាកទាំងឡាយដែលកើតឡើងពីការសម្រេចនេះ ។ ហេតុនេះខ្ញុំសូមបួងសួងដល់អស់ទេវតាទាំងឡាយឲ្យជួយបង្វែរចិត្តមិត្តទាំងឡាយកុំឲ្យមានចិត្តស្នេហាលើខ្ញុំឲ្យសោះ ព្រោះមានម្ចាស់រួចទៅហើយ ។

**រូអ៊ី ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៦**

ឱ! ធម្មជាតិស្ងាត់ស្ងូន្យពេលរាត្រីនៃរដូវរងាធ្វើឲ្យចិត្តខ្ញុំវិលវល់ពេកកន្លង រិះគិតនិងពិចារណាជានិច្ចនូវពាក្យពេចន៍ទាំងឡាយដែលបានដាក់កំហុសឲ្យខ្ញុំថាបានបកស្រាយប្រាប់គេឯងឲ្យដឹងពីគុណវិបត្តិរបស់គាត់ ។ ឱលោកអើយ! ជាការពិតណាស់មនុស្សម្នាក់ៗមិនចង់ឲ្យគេបកស្រាយកំហុសរបស់ខ្លួនប្រាប់អ្នកឯទៀតទេ គឺបារម្ភណាស់ ព្រួយណាស់ ខឹងណាស់ តែគេភ្លេចបានគិតថាកាយវិការដែលខ្លួនធ្វើទាំងប៉ុន្មានអាចចាត់ទុកថាជាកត្តាមួយឲ្យគេវិនិច្ឆ័យខ្លួនរួចទៅហើយ ការនិយាយទៅនេះប្អូនគ្មានបំណងដើម្បីឲ្យគេស្អប់បងឬដើម្បីឲ្យគេមើលងាយបងទេ តែតាមការពិតការនិយាយនេះគឺក្នុងបំណងឲ្យអ្នកនោះដែលជាមិត្តជិតស្និទ្ធរបស់បងជួយប្រាប់និងជួយកែកំហុសរបស់បងឲ្យផុតពីគុណវិបត្តិទាំងនោះ ។ ហើយមនុស្សដែលប្អូននិយាយប្រាប់នោះគឺសុទ្ធតែមនុស្សដែលប្អូនយល់ថាជាមិត្តយ៉ាងជិតស្និទ្ធដែលប្រៀបដូចជាបងប្អូនទៅហើយ ។ តើការនេះជាកំហុសធំណាស់ទៅឬចំពោះប្អូន តើប្អូនជាអ្នកសម្លាប់កិត្តិយសបងឬ? ប្អូនហាក់ដូចជាឆ្អែតអស់ហើយចំពោះបង ទោះជាបងស្រឡាញ់ប្អូនយ៉ាងណាក៏ដោយ ប្អូនគ្មានបំណងឲ្យបងសរសើរពីគុណសម្បត្តិរបស់ប្អូនទេ តែផ្ទុយទៅវិញបើសិនជាបងនិយាយរៀបរាប់ប្រាប់គុណវិបត្តិរបស់ប្អូនដល់មិត្តភក្តិដែលបងយល់ថាជាអ្នកស្រឡាញ់និងជិតស្និទ្ធជាងគេនោះ ក៏ប្អូនឥតមានខឹងឬតូចចិត្តអ្វីដែរគឺមិនដូចអាកប្បកិរិយារបស់បងមកលើរូបប្អូនទេ ។

បងអើយ រូបបងធ្វើឲ្យប្អូនព្រួយច្រើនណាស់ ធ្វើបាបប្អូនណាស់ ថ្វីត្បិតតែបងធ្វើដោយអចេតនាក៏ដោយ ប្អូនឈឺចិត្តណាស់ លើកយករឿងរ៉ាវទាំងនោះមកគិតពិចារណាមិនចេះចប់ តែបងនៅតែមិនយល់ចិត្តប្អូនទៀត ធ្វើឲ្យប្អូនមានការតូចចិត្តនិងវាសនាប្អូនអស់កម្លាំងចិត្តរលីងដើម្បីខំរៀន ។ ប្អូនមិននឹកស្មានសោះថា ចិត្តប្អូនជ្រាយដល់ម្លឹង មិនអាចទប់ទល់នឹងកំហឹងរបស់បង តែមិនមែនមានតែម្តងទេគឺជាច្រើនលើកមកហើយ ធ្វើឲ្យប្អូនអស់ជំនឿថានឹងអាចតស៊ូយកជ័យជំនះលើចិត្តខ្លួនឯងបានក្នុងការតស៊ូដើម្បីរៀនសូត្រតទៅទៀតនៅចំពោះមុខបង ពីព្រោះក្នុងតែប្អូនខំតាំងចិត្តឲ្យស្ងប់មិនបានប៉ុន្មានក៏កើតមានរឿងរ៉ាវអ្វីផ្សេងមួយមកទៀតដែលជាហេតុធ្វើឲ្យប្អូនអស់ជំនឿខ្លួនឯងថានឹងអាចយកជោគជ័យបានលើអាកប្បកិរិយារបស់បង ។ ប្អូនក៏សម្រេចចិត្តថាត្រូវតែត្រឡប់ទៅស្រុកវិញឲ្យឆាប់ទោះលំបាកម្តេចម្តាតែម្នាក់ឲ្យឆ្ងាយ ឲ្យដាច់ស្រឡះពីបង ហើយនិងតាំងចិត្តគិតថាខ្លួនគ្មានបងគ្មានប្អូនអ្វីទាំងអស់ គឺមានតែលោកម្តាយនិងលោកឪពុកតែប៉ុណ្ណោះ ។ ហើយនិងប្តេជ្ញាលះបង់អ្វីៗទាំងអស់ដើម្បីធ្វើការបម្រើជាតិតាមសមត្ថភាពដែលខ្លួនមានដ៏តិចតួច ហើយនិងខំចិញ្ចឹមរៀនសូត្រតទៅទៀត បើសិនជាអាចធ្វើទៅបានដោយនៅឲ្យដាច់ស្រឡះពីបងប្អូន គឺខ្ញុំគិតថាខ្ញុំនឹងតាំងចិត្តគិតថាខ្ញុំមានតែម្នាក់ឯងជានិច្ច... ។ ក្រៅពីឪពុកម្តាយចេញគឺសុទ្ធតែមិត្តដែលមានល្អនិងអាក្រក់ ។ ឱ!នេះហើយឬបងសម្លាញ់ខ្ញុំ នេះគឺមកពីការស្រឡាញ់ពេក គឺប្រណែនណាស់មិនចង់ឲ្យប្អូនត្រូវអ្នកឯទៀតស្រឡាញ់ផងទេ ។ នេះហើយ គឺបងខ្ញុំ ។ ឱ! ជីវិតដ៏កម្មក្រាស់អើយ តើថ្ងៃណាទើបចប់ ជីវិតខ្ញុំអ៊ីក៏មានលំនាំដូចជាជីវិតលោកម៉ែម៉្លេះ?

## រូអី ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៦

ឱ! ថ្ងៃនេះជាថ្ងៃដែលមិត្ត កាណុល បានសារភាពប្រាប់ខ្ញុំថាគេស្រឡាញ់ហើយអាណិតខ្ញុំ ហើយសូមអង្វរខ្ញុំឲ្យមានការអាណិតដល់រូបគេវិញផងលាយឡំនឹងទឹកភ្នែកគួរឲ្យអាណិតដែរ តែអនិច្ចាអើយ ចិត្តខ្ញុំបានសម្រេចយ៉ាងមុតមាំរួចទៅហើយថាខ្ញុំស្រឡាញ់តែបុរសម្នាក់ទេ ពាក្យស្រឡាញ់ខ្ញុំនិយាយតែម្តងទេ ហើយជាមួយមនុស្សតែម្នាក់ទេ ហេតុនេះហើយបានជាខ្ញុំបដិសេធជាដាច់ខាតចំពោះសេចក្តីស្នើរបស់មិត្ត ។ ខ្ញុំគ្មានចិត្តរំភើបញាប់ញ័រ ឬទោរទន់អ្វីដល់តិចតួចឡើយចំពោះសេចក្តីស្នើរបស់អ្នក គឺក្នុងរឿងស្នេហាខ្ញុំបានគិត... (ឯកសារបានដាច់បាត់មួយផ្នែក)

...ត្រឹមនេះឬ? ឱមិត្តអើយមិត្ត! សូមអ្នកប្រណីដល់រូបខ្ញុំផង ។ Y ជាទីនឹករឭក ជាតិនេះយើងមានកម្មពុំបានជួបគ្នាទេ ខ្ញុំការព្រោះភារកិច្ចមិនមែនព្រោះក្តីស្រឡាញ់ឬអាណិតទេ ។ Y តើសព្វថ្ងៃ Y នៅឯណា? ពេលយើងជួបមុខគ្នាជាថ្មីតើយើងស្ថិតនៅក្នុងសភាពបែបណា? ឬមួយក៏យើងគ្មានវាសនាបានឃើញមុខគ្នារហូតក្នុងមួយជីវិតនេះ ។

ឱស្នេហាខ្ញុំ! ស្នេហាបង្ខំចិត្ត ស្នេហាព្រោះភារកិច្ច ស្នេហាគ្មានទិសដោះស្រាយទទួលព្រោះភារកិច្ចតម្រូវ នេះឬជីវិតស្នេហាខ្ញុំ? ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៧ ។

...រូបខ្ញុំតើបានអ្វីសើចសប្បាយនឹងគេ មនុស្សម្នាក់ដែលខ្ញុំពុំដែលស្គាល់ចិត្តគំនិតបន្តិចសោះស្រាប់តែគេតម្រូវឲ្យចាប់ដៃគ្នាកសាងគ្រួសារ ឱលោកអើយ! ខ្ញុំតឹងទ្រូងណាស់ ចម្លើយដែលខ្ញុំធ្លាប់ដោះសាចំពោះម៉ែបានទាំងប៉ុន្មាន ខ្ញុំមិនអាចដោះសានៅចំពោះមុខអង្គការបានទេ មានតែសេចក្តីស្លាប់ទេដែលអាចដោះសាចំពោះរឿងនេះ តែស្លាប់ពីព្រោះរឿងនេះវាដូចជាកំសាកពេក តើខ្ញុំត្រូវដោះស្រាយយ៉ាងណា? បើខ្ញុំគ្មានកូនចិត្តអ្វីបន្តិចសោះនោះ ឱ! ស្នេហាដ៏សោកក្រោះអើយ រៀបការទាំងបង្ខំចិត្ត បង្ខំចិត្តខ្លួនឯងឲ្យទទួលរៀបការព្រោះភារកិច្ច រៀបការព្រោះមិនអាចឆ្លើយដោះសាបាន ឱ! វ័យយុវភាពរបស់ខ្ញុំត្រូវចប់នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ ចិត្តដែលប្រាថ្នាចង់តែនៅឲ្យក្រពុំរហូតនោះពុំបានសម្រេចទេ តើគេវិញគេរៀបការជាមួយខ្ញុំពីព្រោះភារកិច្ចដែរឬយ៉ាងណា? តើគេមានចិត្តស្រឡាញ់ខ្ញុំដែរឬទេ? បើចំពោះខ្ញុំ ខ្ញុំឥតមានចិត្តអ្វីបន្តិចសោះ ឱ! ខ្ញុំនៅសល់តែសេចក្តីអស់សង្ឃឹម អស់សង្ឃឹមៗ ពីសភាពការណ៍នេះបើអាចគេចបានម៉្លេះសមខ្ញុំគេចឲ្យផុតពីមុខគេឯងទៅហើយ ។ ឱអ្នកម៉ែជាទីស្រឡាញ់និងជាទីគោរព! ពេលកូនជួបម៉ែ តើកូនឆ្លើយប្រាប់អ្នកម៉ែថាដូចម្តេច បើពុំបានមកជាអធិបតីក្នុងពិធីរៀបការនេះទេ ។ ឱអ្នកម៉ែអើយ! កូនព្រួយសែនព្រួយចំបែងពេកណាស់ មិនដឹងដោះស្រាយយ៉ាងណា ឱ! ជីវិតខ្ញុំត្រូវចប់...(ឯកសារបានដាច់បាត់មួយផ្នែក) ...ស្នើខាងបងប្អូននារីឲ្យប្រមូលផល (កូនក្រុម ឬក្រុមសហករណ៍) ស្នើឬគួរយោបល់

គ្នា ។ សហករណ៍ធាតុ អាជ្ញា មើលទាបលើកម្លាំងខ្សោយ)...

## *ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៧ ដីក្រហមភូមិភាគឧត្តរ*

ថ្ងៃខែចេះតែកន្លងផុតទៅឆាប់រហ័សណាស់ មកទល់នឹងថ្ងៃនេះយើងបានរស់នៅទីនេះអស់ពេលជាង៧ខែហើយ ។ ៧ខែកន្លងទៅ ដីក្រហមបណ្តុះឲ្យខ្ញុំនូវអនុស្សាវរីយ៍ជាច្រើនរាប់មិនអស់នៅក្រោមដំបូលផ្ទះដ៏តូចមួយ ។ គឺនៅទីនេះហើយដែលយើងបានសាងជីវិតគ្រួសារដ៏តូចរបស់យើង ។ យើងចាប់ដៃគ្នាសាងជីវភាពគ្រួសារពិតប្រាកដនៅទីនេះឯង ។ ឱ! ជីវិតគ្រួសារបដិវត្តន៍ យើងបានជួបគ្នាព្រោះបដិវត្តន៍ យើងស្រឡាញ់គ្នាតាមរយៈអង្គការ ។ ឱដីក្រហម! អ្នកមានសម្រស់ល្អត្រកាលព្រៃព្រឹក្សាបៃតងស្រងាត់ ជ្រោះជ្រលងដងអូរមានទឹកហូរមិនដាច់លម្ហដោយសំឡេងសត្វបក្សីបក្សាគ្រប់ប្រភេទគួរឲ្យសប្បាយរីករាយណាស់ ។ មើលទៅឯនាយឃើញវាលស្រែប្រជាជនផ្លាស់ប្តូរពណ៌ជាប្រចាំ សោតឯចម្ការយើងក៏មានសភាពប្រែប្រួលជាលំដាប់ដែរ ផ្លូវកាត់ខ្វាត់ខ្វែងចម្ការជាក្រឡាឈើត្រង់គួរឲ្យគយគន់និងពេញចិត្តណាស់ដែរ ។ ខ្ពង់រាបខ្ពស់ទាបនៅដីក្រហមនេះបញ្ចេញសម្រស់ស្រស់ឆើតឆាយណាស់ ពិសេសពេលថ្ងៃរះនិងថ្ងៃលិច នៅទីនេះរឹតតែបណ្តុះមនោសញ្ចេតនាយើងឲ្យជាប់នឹងទីនេះមួយកម្រិតថែមទៀត ។ ដោយសារធម្មជាតិទាំងនេះ ជីវភាពយើងហាក់ដូចជាសប្បាយរីករាយណាស់ ដូចជាគ្មានអ្វីគួរឲ្យខ្វល់ខ្វាយឡើយ ។ សុភមង្គលមួយដែលមិនស្មានថាអាចកើតមានឡើង ឥឡូវអាចមានរូបរាងគួរជាទីពេញចិត្ត ។ ថ្វីត្បិតតែយើងគ្មានមនោសញ្ចេតនារកគ្នាកាលពីមុន តែដោយសារការខិតខំបណ្តុះបន្តិចម្តងៗនិងការយល់ចិត្តគ្នាទៅវិញទៅមក យើងក៏អាចរកសុភមង្គលនៅក្នុងសង្គមថ្មីនេះឃើញ ។ ចំណងគ្រួសារនេះក៏រឹតភ្ជាប់យើងទាំងពីរនាក់បានមួយកម្រិតថែមទៀត ។ ទោះបីខ្ញុំមិនបានសម្រេចនូវគោលបំណងខ្ញុំពីមុនមកក៏ដោយ ក៏ឥឡូវខ្ញុំមានការជ្រះស្រឡះហើយសប្បាយរីករាយច្រើនចំពោះជីវភាពនៃយើងសព្វថ្ងៃនេះ ។ នៅទីនេះថ្វីត្បិតតែមានការនឿយហត់ផ្នែកកម្លាំងកាយខ្លះ តែចិត្តគំនិតគ្មាននឿយអំពល់ឬពិបាកអ្វីទេមានតែការសប្បាយរីករាយជានិច្ច ។ ការស្រឡាញ់ដែលពីដើមគ្មានសោះ ឥឡូវក៏មានការរីកចម្រើនជាលំដាប់បង្កើតបានជាកម្មសិទ្ធិផ្នែកមនោសញ្ចេតនាយ៉ាងក្រាស់ក្រែល តែទោះជាយ៉ាងណាក៏ដោយ ក៏យើងមានលក្ខណៈមួយត្រៀមនូវការបែកគ្នាទៅតាមការកិច្ចផ្សេងគ្នាដោយជ្រះស្រឡះ ។ ឱ! ខ្ញុំទើបតែស្គាល់អ្វីដែលហៅថាជីវិតគ្រួសារ អ្វីហៅថាស្នេហ? ដីក្រហមបានចងដៃឲ្យយើងនូវសុភមង្គលត្រជាក់ត្រជុំសុខដុមរមនាប្រៀបបីដូចជាធាតុអាកាសនៅទីនេះដែរ ។ ទំព័រគ្រួសារដ៏ថ្មីសន្ធាននិងក្មេងខ្ចីរបស់យើងបានត្រូវចារដោយធម្មជាតិនៅដីក្រហមនូវសុភមង្គមួយថ្មី ។ មិនតែប៉ុណ្ណោះ ដីក្រហមបានផ្តល់ឲ្យខ្ញុំនូវការដកពិសោធន៍ជាច្រើនទៀតទៅលើធម្មជាតិនិងទៅលើមនុស្សដែលរស់នៅជុំវិញខ្ញុំនៅក្នុងជួរបដិវត្តន៍ ។ ឱ! ដីក្រហមទ្រនំជីវិតនៃយើង ។ សូមឲ្យជីវិតគ្រួសារយើងមានពណ៌ក្រហមឆ្អិនឆ្អៅដូចពណ៌ដីក្រហមនេះ ។

## ដីក្រហម ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨

កន្លងទៅមួយឆ្នាំហើយដែលខ្ញុំបានមករស់នៅដីក្រហម ខ្ញុំបានឆ្លងកាត់ជីវិតគ្រោះថ្នាក់ជាច្រើនកន្លែង ។ ខ្ញុំបានដកពិសោធន៍បានច្រើនបែបយ៉ាងណាស់ក្នុងរយៈកាលរស់នៅទីនេះ អំពីមនុស្សដែលរស់នៅជុំវិញខ្ញុំ អំពីចិត្តគំនិត អំពីការលំបាកស្រួលក្នុងជីវិតបដិវត្តន៍នៃខ្ញុំ ។ គ្រោះថ្នាក់ដោយសារការឈឺថ្កាត់នានានៅទីនេះធ្វើឲ្យខ្ញុំស្គាល់ចិត្តមនុស្សក៏បានច្រើនដែរ ។ ការតស៊ូ និងការលំបាកវេទនាសព្វបែបយ៉ាងមិនពិបាកស្មើនឹងការតស៊ូសតិអារម្មណ៍ចំពោះសង្គមបរិយាកាសដែលមានមនុស្សចិត្តចង្អៀតចង្អល់មិនយល់គ្នាទៅវិញទៅមកឡើយ ។ ខ្ញុំធ្លាប់ឆ្លងកាត់ការពិបាកផ្លូវកាយជាច្រើនកន្លែង តែខ្ញុំអាចទ្រាំទ្របានដោយរីករាយនិងចប់ចុងចប់ដើមជាស្ថាពរ ។ ប៉ុន្តែការតស៊ូសតិអារម្មណ៍នៅដីក្រហម ធ្វើឲ្យខ្ញុំមានការជូរចត់ បត់បែនជាច្រើនអន្លើ រហូតដល់កាលមានការខឹងតូចចិត្តនឹងខ្លួនឯង តូចចិត្តនឹងវាសនាអាក្រក់ ដល់ថ្នាក់សម្រក់ទឹកភ្នែកក៏មានគួរឲ្យឈឺចិត្តណាស់ចំពោះមនុស្សប្រភេទខ្លះដែលមិនយល់ចិត្តគ្នាទៅវិញទៅមក ។ មាគ៌ារបស់បក្សត្រឹមត្រូវណាស់ ភ្លឺស្វាងណាស់ តែអ្នកអនុវត្តទេ ដែលមិនត្រឹមត្រូវ ដែលមិនភ្លឺស្វាង ដែលបត់បែកក្រញិកក្រញ៉ុក...។

***(រហូតមកដល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាពុំទាន់រកឃើញគ្រួសាររបស់ម្ចាស់សៀវភៅកំណត់ហេតុនេះនៅឡើយទេ) ។***



ប៉ុល ពត ជាមួយកូននិងក្មួយ









*កំណាព្យខ្មែរក្រហមៈ*

# ប្តេជ្ញារៀនសូត្រមហាជ័យជំនះថ្ងៃ១៧ មេសា

មេឃមីរខ្មៅអាប់អងឹតស្ងប់
គម្រប់ជាជាងពីរពាន់ឆ្នាំ
យើងរស់ដូចស្លាប់ជាប្រចាំ
កប់ត្រាំរណ្តៅទុក្ខខ្លោចផ្សា ។

ភ្នំសក្តិភូមិ ភ្នំនាយទុន
ភ្នំចក្រពត្តិធ្ងន់ឥតឧបមា
សង្កត់ទ្រូងយើងជាន់ប្រហារ
តែយើងប្តេជ្ញាក្រោកប្រយុទ្ធ ។

សាមសិបកញ្ញា ហាសិបមួយ
ដែនដីរញ្ជួយ ខ្លាំងរន្ធត់
បក្សប្រសូត្រភ្លាម ផ្ទុះអាវុធ
បាតដៃពីរគត់ តែតស៊ូ ។

ដឹកនាំប្រយុទ្ធយ៉ាងគគ្រេង
ចលនាធំធេងអង្វែងយូរ
អាវុធនយោបាយផ្សំទាំងគូ
សម្រុកតស៊ូខ្លាំងក្លៀវក្លា ។

១៨ មីនា ឆ្នាំ៧០
មហាលោតផ្លោះព្រឹបយ៉ាងអស្ចារ្យ
សង្គ្រាមបដិវត្តរីកខ្លាំងក្លា
ចក្រពត្តិបរិវារបរាជ័យ ។

មហាព្យុះសង្ឃរាបដិវត្តន៍
បោកបក់កម្ចាត់ខ្លាំងចង្រៃ
គាស់គួចរំលើងភ្នំទាំងបី
ជោគជ័យចិញ្ចែងជាង៥ឆ្នាំ ។

កម្ពុជាក្រហមប្រាលភ្លឺថ្លា
១៧ មេសា ៧៥
កម្មករ កសិករយើងសស្រាំ
សកម្មរំដោះល្បីខ្ទរខ្ទរ ។

ទូទាំងជនបទនិងទីក្រុង
ដាច់ខាតទាំងស្រុងជាស្ថាពរ
មានន័យធំធេងលើសអង្គរ
រីងរីកជីហរប្រែស្រស់បស់ ។

ប្រព័ន្ធភ្លឺស្រែចោលរស្មី
ព្រំដែនទឹកដីមាំឥតខ្ចោះ
កសិកម្ម ឧស្សាហកម្មទាំងអស់
លោតផ្លោះមួយឆ្នាំល្បឿនមហិមា ។

១៧មេសា មហាជោគជ័យ
អត្ថន័យត្រចះនៃមាគ៌ា
ឯករាជ្យម្ចាស់ការទ្រាំវេទនា
ពុះពារប្រយុទ្ធខ្លាំងសន្ធៅ ។

យើងខ្ញុំយុវជន យុវនារី
គ្រវីជ្រោងទង់ប្រយុទ្ធក្តៅ
រៀនសូត្រអត្ថន័យនេះជ្រាលជ្រៅ
សម្រេចទិសដៅបដិវត្តន៍យើង ។

សម្រុកកសាងនិងពុះពារ
មាតុភូមិកម្ពុជាឲ្យថ្កុំថ្កើង
មហាលោតផ្លោះមហាអស្ចារ្យឡើង
រុងរឿងប្រាលផ្សៅគ្រប់វេលា ។

ជយោ! ១៧ ខែមេសា
ជយោ! អង្គការបក្សកម្ពុជា
ជយោ! កងទ័ពឈ្នះគ្រប់គ្រា
ជយោ! ប្រជាមហាអស្ចារ្យ ។

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 16, April 2001.
Funded by the Royal Ministry of Foreign Affairs,Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Canada Funds, Canadian Embassy,Phnom Penh; the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh; the Royal Danish Government and the Royal Netherlands Government, *The Hague*.